សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **យ៉េង តុលា**
កញ្ញា **យ៉ែម រដ្ឋា**

ណែនាំដោយ
លោក **រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **យ៉េង តុលា** និងនាងខ្ញុំ **យ៉េម រដ្ឋា** ជានិស្សិតផ្នែកបរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២៣ ឆ្នាំសិក្សា២០១៩-២០២៣ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅកាន់៖**

- លោកឪពុកឈ្មោះ **មាស យ៉េង** និង អ្នកម្តាយ **សូយ សាក់នី**
- លោកឪពុកឈ្មោះ **មាស យឿង** និងអ្នកម្តាយ **មួង ទូច**

ដែលលោកទាំងបួនបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ប្រកបដោយព្រហ្មវិហារធម៌ទាំងបួនគឺ **មេត្តា ករុណា មុទិតា** និង **ឧបេក្ខា** ចំពោះកូនៗតាំងពីតូចដល់ធំពេញវ័យ ហើយថែមទាំងបានផ្តល់ថវិកា និងពេលវេលាព្រមទាំងឱកាសឱ្យខ្ញុំបានសិក្សាតាំងពីថ្នាក់មត្តេយ្យ បឋមសិក្សា វិទ្យាល័យរហូតមកដល់ថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំអាចឈានមកដល់ពេលសព្វថ្ងៃនេះ ដោយសារមានលោកទាំងបួនបានអប់រំទូន្មានប្រៀនប្រដៅឱ្យយើងខ្ញុំក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គមលោកមិនត្រឹមតែជាអ្នកផ្តល់កំណើតទេ តែលោកទាំងបួនក៏ជាលោកគ្រូអ្នកគ្រូដែលជួយបង្ហាត់បង្រៀនយើងខ្ញុំទាំងពីរឱ្យបានដឹងពីសណ្តាប់ធ្នាប់ក្នុងគ្រួសារ និងការរស់នៅមួយចំនួនក្នុងសង្គម។ លោកទាំងបួនក៏ជាកម្លាំងចិត្តរបស់យើងខ្ញុំផងដែរ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណទៅកាន់លោកឯកឧត្តមបណ្ឌិត **លុយ ចន្ណា** ជាសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកគ្រូ អ្នកគ្រូតែងតែជួយចែករំលែកចំណេះដឹងមកកាន់ យើងខ្ញុំទាំងពីរតាំងពីថ្នាក់មូលដ្ឋានរហូតដល់ឆ្នាំទី៤ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំនឹងចង់ចាំ និងដឹងគុណដ៏មានតម្លៃមួយនេះជានិរន្តរ៍។

យើងខ្ញុំសូមថ្លែងអំណរគុណលោកសាស្ត្រាចារ្យ **រុន ពន្ណារិទ្ធ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការធ្វើឱ្យមានសារណាមួយនេះឡើងប្រកបដោយលទ្ធផលល្អ និងមានប្រសិទ្ធភាព។ លោកគ្រូបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត ពេលវេលាដ៏មានតម្លៃដើម្បីជួយកែសម្រួលសារណារបស់យើងខ្ញុំ។ ប្រសិនបើគ្មានលោកគ្រូទេក៏ពួកយើងមិនអាចធ្វើកិច្ចការមួយនេះបានល្អដែរ លោកគ្រូបានផ្តល់នៅអនុសាសន៍ល្អៗ និងបទពិសោធន៍ល្អៗជាច្រើន ដែលពួកយើងមិនបានដឹងពីមុនមក ហើយជាហេតុនាំឱ្យយើងធ្វើកិច្ចការនេះបាន។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ក៏សូមអរគុណយ៉ាងជ្រាលជ្រៅ និងសូមបួងសួងដល់វត្ថុស័ក្តសិទ្ធទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យជូនទៅកាន់លោកគ្រូ អ្នកគ្រូ លោកឪពុក អ្នកម្តាយ លោកសាស្ត្រាចារ្យ សូមឱ្យជួបពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់ពេលរយៈ៤ឆ្នាំរួចមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងនីតិសាធារណៈ ដោយយើងខ្ញុំបានខិតខំប្រឹងប្រែង តាំងពីឆ្នាំទី១ រហូតមកដល់ឆ្នាំទី៤ យើងខ្ញុំទាំងពីរនាក់ បានទទួលឱកាសក្នុងការសរសេរសារណាក្រោមប្រធានបទ **គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ** ហេតុដែលពួកយើងបានជ្រើសរើសប្រធានបទមួយនេះដោយសាតែពួកយើងមានគោលបំណងឲ្យប្រជាជនកម្ពុជា ក៏ដូចជានិស្សិត បញ្ញាវន្តបានយល់ដឹងឱ្យកាន់តែច្បាស់ និងស៊ីជម្រៅបញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងគោលការណ៍នេះ ថាតើនៅក្នុងរឿងក្តីព្រហ្មទណ្ឌមានកំណត់នូវគោលការណ៍ឯកត្តកម្មចំនួនប៉ុន្មាន? ហើយអ្វីខ្លះ? ប្រើគោលការណ៍នេះដើម្បីអ្វី? នៅពេលមានបទល្មើសមួយកើតឡើងសួរថាតើគេយកគោលការណ៍នេះទៅអនុវត្តគ្រប់ករណី ឬយ៉ាងណា? ប្រើនៅពេលណាខ្លះជាដើម លើសពីនេះទៅទៀត សារណាមួយនេះអាចលេចចេញជារូបរាងទៅបាន ដោយសារមានការជួយណែនាំ ផ្តល់អនុសាសន៍ និងកែតម្រូវផ្សេងៗ ដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ដែលលោកគ្រូបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយកែលំអចំណុចខ្វះខាតសារណាមួយនេះ ។

ជាចុងក្រោយយើងខ្ញុំបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់កិច្ចការមួយនេះ យ៉ាងយកចិត្តទុកដាក់ យ៉ាងណាក៏ដោយ ក៏យើងខ្ញុំជឿថានៅតែមានចំណុចខ្វះខាតមួយចំនួន ត្រង់ចំណុចណាមួយមិនខាននោះទេ។ ហេតុនេះហើយ យើងខ្ញុំទាំងពីរ ក៏សូមខន្តីអភ័យទោសនូវរាល់ចំណុចខុសឆ្គងទាំងឡាយណា ដែលបានសរសេរទៅហើយមានការខ្វះខាត ខុសឆ្គងនៅត្រង់ពាក្យពេចន៍សម្តីណាមួយ ដែលកើតចេញពីកំហុសអចេតនានៅការស្រាវជ្រាវមួយនេះ យើងខ្ញុំសូមទទួលនូវរាល់ការរិះគន់ ដើម្បីស្ថាបនា និងកែលម្អ ដើម្បីកិច្ចការស្រាវជ្រាវមួយនេះមានភាពកាន់តែល្អប្រសើរឡើង និងអាចជាប្រយោជន៍បាន។

ចុងក្រោយយើងខ្ញុំទាំងពីរ ដែលជាអ្នកសរសេរកិច្ចការស្រាវជ្រាវមួយនេះ សង្ឃឹមយ៉ាងមុតមាំថា កិច្ចការស្រាវជ្រាវនេះ អាចជាពុទ្ធិ ឬជាឯកសារមួយសម្រាប់ជំនួយស្មាតីដល់មិត្តអ្នកអាន និងចូលរួមឱ្យប្អូនៗនិស្សិតដែលសរសេរជំនាន់ក្រោយៗ ពាក់ព័ន្ធនឹងប្រធានបទ **គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ** អាចយកធ្វើជាគំរូនៃការសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ទៀតបានដោយសាតែប្រធានបទមួយនេះបានជួយដល់ប្អូនជំនាន់ក្រោយឲ្យយល់ដឹងឲ្យកាន់តែច្បាស់ពីប្រភេទនៃគោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ។

# មាតិកា

**សេចក្តីផ្តើម**......................................................១

## ជំពូកទី១

## គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

**ផ្នែកទី១៖ អត្ថន័យនៃគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**................៤
**ផ្នែកទី២៖ បុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ**......................................................៦
**២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល** ......................................................៨
២.១.១. ការទទួលខុសត្រូវរបស់នីតិជន.......................................................................៩
២.១.១.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ.......................................................៩
២.១.១.១.១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ .......................................................៩
២.១.១.១.២. សមាសភាព ឬឋានៈអ្នកត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ................................ ១០
២.១.១.២ ទណ្ឌកម្មដែលអាចប្រកាសចំពោះនីតិជន ......................................................... ១១
២.១.១.២.១. ប្រភេទនៃទោស ..................................................................................... ១១
២.១.១.២.២. អាជ្ញាយុកាលនៃទោស .............................................................................២០
២.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន.......................................................២០
២.១.២.១. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស ....................................................២១
២.១.២.១.១. វិធានការបង្វែរ........................................................................................២២
២.១.២.១.២. វិធានការផ្សេងៗនៅក្នុងក្រមព្រហ្មទណ្ឌ.......................................................២២
២.១.២.២. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន................................................................ ២៣
២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល....................................................................២៤
២.២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល...............................................២៥
២.២.១.១. អត្ថិភាពនៃច្បាប់ ឬបទដ្ឋានគតិយុត្ត.................................................................២៥
២.២.១.២. បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាង.........................................................២៥
២.២.១.៣. ការប្រព្រឹត្តដើម្បីជាផលប្រយោជន៍នីតិបុគ្គល..........................................................២៦
២.២.២. ទណ្ឌកម្ម ឬទោសអនុវត្តលើនីតិបុគ្គល ..............................................................២៦
២.២.២.១. មូលទោស.....................................................................................................២៦
២.២.២.២. ទោសបន្ថែម ...................................................................................................២៧

# ជំពូកទី២

# គោលការណ៍ឯកត្តកម្មនៃទោស


**ផ្នែកទី១៖ មូលដ្ឋានគតិយុត្តិនៃគោលការណ៍ឯកត្តកម្មនៃទោស** .................................... ៣២

**១. ភាពមិនរើសអើង ឬស្មើភាពគ្នា** ........................................................................ ៣២

**២. ភាពសមាមាត្រនៃទោស** ..................................................................................... ៣៤

**៣. គោលការណ៍ដោយឡែកផ្អែកលើបុគ្គលនីមួយៗ** ....................................................... ៣៥

**៣.១.បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ** ....................................................................... ៣៥

៣.១.១.មុនពេលប្រព្រឹត្តបទល្មើស ........................................................................... ៣៥

៣.១.១.១.ការរស់នៅរបស់ជនល្មើស .................................................................. ៣៦

៣.១.១.២.កត្តានាំឲ្យប្រព្រឹត្តបទល្មើស ................................................................. ៤០

៣.១.២.ក្រោយពេលប្រព្រឹត្តបទល្មើស ........................................................................ ៤១

៣.១.២.១.កិរិយាមាយាទរបស់ជនជាប់ចោទចំពោះជនរងគ្រោះ ..................................... ៤២

៣.១.២.២.កិរិយាមាយាទរបស់ជនជាប់ចោទចំពោះជនដទៃ ............................................ ៤២

**៣.២.កាលៈទេសៈនៃទោសបទល្មើស** .............................................................................. ៤៣

៣.២.១.សកម្មភាពនៃការប្រព្រឹត្តបទល្មើស ................................................................... ៤៣

៣.២.១.១.ការប្រព្រឹត្តកើតចេញពីជនល្មើសផ្ទាល់(សកម្មភាពដោយផ្ទាល់) ........................... ៤៤

៣.២.១.២.បទល្មើសកើតចេញពីការចូលរួមរបស់ជនរងគ្រោះ ........................................... ៤៤

៣.២.២.ភាពធ្ងន់ធ្ងរនៃបទល្មើស ................................................................................ ៤៤

**ផ្នែកទី២៖ ផលវិបាកគតិយុត្តនៃការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស** ............. ៤៤

**២.១. ឯកត្តកម្មនៃទោសនីត្យានុកូល** .......................................................................... ៤៤

២.១.១. ស្ថានភាពទាក់ទងនឹងចារី ............................................................................. ៤៥

២.១.២. ស្ថានភាពទាក់ទងនឹងជនរងគ្រោះ .................................................................... ៤៦

**២.២. ឯកត្តកម្មនៃទោសប្រកាសដោយតុលាការ** ............................................................... ៤៦

២.២.១. ករណីបទល្មើសតែមួយ .................................................................................. ៤៧

២.២.១.១.ស្ថានសម្រាលទោស ........................................................................... ៤៧

២.២.១.១.១.មូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោស ................................................ ៤៧

២.២.១.១.២.ខ្នាតនៃស្ថានសម្រាលទោស ........................................................... ៤៩

២.២.១.២.ស្ថានទម្ងន់ទោស ..................................................... ៥០
២.២.១.២.១.ស្ថានទម្ងន់ទោសទូទៅ ..................................................... ៥១
២.២.១.២.២.ស្ថានទម្ងន់ទោសដោយឡែក ..................................................... ៥៥
២.២.២. ករណីបទល្មើសត្រួតគ្នា(ពហុបទល្មើស) ..................................................... ៥៨
២.២.២.១.វិធានស្រូបទោស ..................................................... ៥៨
២.២.២.១.១.ករណីចោទប្រកាន់តែមួយ ..................................................... ៥៨
២.២.២.១.២.ករណីចោទប្រកាន់ដាច់ពីគ្នា ..................................................... ៦០
២.២.២.២. វិធានត្រួតទោស ..................................................... ៦១
២.២.២.៣. វិធានបូកទោស ..................................................... ៦២
២.២.២.៤. របបនៃការព្យួរទោស ..................................................... ៦២
២.២.២.៤.១.និយមន័យនៃការព្យួរទោស ..................................................... ៦២
២.២.២.៤.២.ប្រភេទនៃការព្យួរទោស ..................................................... ៦៣
២.២.២.៥. របបនៃការផ្អាកការប្រកាសទោស ..................................................... ៦៧
២.២.២.៥.១.និយមន័យនៃការផ្អាកការប្រកាសទោស ..................................................... ៦៧
២.២.២.៥.២.លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស ..................................................... ៦៧
២.២.២.៦. របពាក់កណ្ដាលសេរីភាព ..................................................... ៦៨
២.២.២.៦.១.និយមន័យនៃរបបពាក់កណ្ដាលសេរីភាព ..................................................... ៦៨
២.២.២.៦.២.លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព ..................................................... ៦៨
២.២.២.៦.៣.បែបបទនៃរបបពាក់កណ្ដាលសេរីភាព ..................................................... ៦៩
២.២.២.៧.របបនៃការបែងចែកទោសជាប្រភាគ ..................................................... ៦៩
២.២.២.៧.១.និយមន័យនៃបែងចែកទោសជាប្រភាគ ..................................................... ៦៩
២.២.២.៧.២.លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ ..................................................... ៦៩
២.២.២.៧.៣.បែបបទនៃការបែងចែកទោសប្រភាគ ..................................................... ៧០

## ជំពូកទី៣

## អត្ថប្រយោជន៍នៃការអនុវត្តគោលការណ៍ឯកត្តកម្ម


**ផ្នែកទី១៖ ចំពោះជនជាប់ចោទ** ........................................ ៧១

១.១. ផ្តល់ភាពត្រឹមត្រូវ និង យុត្តិធម៌ដល់ជនជាប់ចោទ ........................................ ៧១

១.២. ការស្តារនីតិសម្បទា និងធ្វើសមាហរណ៍កម្មដើម្បីចូលរួមរស់ក្នុងសង្គមវិញ ........................................ ៧១

១.៣. ទទួលបានភាពកក់ក្តៅពីក្រុមគ្រួសារវិញ ........................................ ៧២

១.៤. មានឱកាសច្រើនក្នុងការស្តារកិត្តិយសរបស់ខ្លួនត្រឡប់មកវិញ ........................................ ៧២

**ផ្នែកទី២៖ អត្ថប្រយោជន៍ចំពោះសង្គមជាតិ** ........................................ ៧៤

២.១. សន្តិសុខ និងសុវត្ថិភាពសាធារណៈ ........................................ ៧៤

២.២. អាចក្លាយជាប្រទេសនីតិរដ្ឋដូចប្រទេសដទៃ ........................................ ៧៤

២.៣. បង្កើនសេដ្ឋកិច្ចជាតិ ........................................ ៧៤

២.៤. រដ្ឋពុំត្រូវចំណាយថវិកាច្រើន ........................................ ៧៤

២.៥. ធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍ និងរីកចម្រើនជឿនលឿន ........................................ ៧៥

២.៦. លើកកម្ពស់មុខមាត់ប្រទេសជាតិ ........................................ ៧៥

២.៧. ជំរុញប្រព័ន្ធយុត្តិធម៌ឲ្យកាន់តែមានភាពត្រឹមត្រូវ និងសុក្រឹត្យ ........................................ ៧៥


## សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍


**១. សេចក្តីសន្និដ្ឋាន** ........................................ ៧១

**២. ការផ្តល់អនុសាសន៍** ........................................ ៧៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌថ្មី នៃព្រះរាជាណាចក្រកម្ពុជាយើង មានចំនួន ០៦ គន្ថី ស្មើនឹង ៦៧២ មាត្រា។ ក្រមនេះត្រូវបានព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាឡាយព្រះហត្ថលេខាប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ កន្លងទៅនេះ។ ក្រមនេះហាក់ដូចជាការកម្រិតនូវដែនកំណត់សិទ្ធិរបស់បុគ្គលគ្រប់រូបនៅក្នុងសង្គម ដែលបានចងភ្ជាប់គ្នាតាមរយៈកិច្ចសន្យាសង្គមនេះឯង មួយវិញទៀតវាអាចជួយអោយបុគ្គលម្នាក់ៗបានដឹងអំពីសិទ្ធិ ឬសកម្មភាពណាខ្លះគួរធ្វើ និងសិទ្ធិ ឬសកម្មភាពណាខ្លះមិនគួរធ្វើកាលណាជនណាម្នាក់បានប្រើប្រាស់សិទ្ធិ ឬធ្វើសកម្មភាពដែលលើសពីដែនកំណត់នឹងត្រូវទទួលទណ្ឌកម្ម។ គ្រប់បុគ្គលដែលរស់នៅក្នុងសង្គមទាំងអស់គ្មាននរណាម្នាក់អាចនិយាយបានថាខ្លួនមិនបានដឹងអំពីច្បាប់នោះទេដូច្នេះហើយបានជា ក្រសួងយុត្តិធម៌បានសហការជាមួយក្រសួងព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ ដល់ប្រជាពលរដ្ឋយើងទូទាំងប្រទេសឱ្យបានយល់ដឹងយើងខ្ញុំសូមអនុញ្ញាតជម្រាបជូនផងដែរថាការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ គឺជាការចូលរួមចំណែកអនុវត្តនយោបាយកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ហើយក៏ជាការអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចទ្រង់បានលើកឡើងក្នុងសន្និសិទជាតិដើម្បីផ្សព្វផ្សាយក្រមព្រហ្មទណ្ឌកាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ កន្លងទៅថ្មីៗនេះ។ ដោយសម្តេចបានណែនាំដល់ក្រសួងយុត្តិធម៌ថា ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបានជ្រួតជ្រាបទៅដល់ប្រជាជនកម្ពុជាទាំងអស់ ដើម្បីនាំគ្នាចូលរួមអនុវត្តច្បាប់ព្រហ្មទណ្ឌនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ ក្រោយពី ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនីព្រះមហាក្សត្រ** ជាអម្ចាស់ជីវិតតម្កល់លើត្បូង នៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើកាលពីចុងឆ្នាំ ២០០៩ រួចមក សួរថាតើក្រមព្រហ្មទណ្ឌចូលជាធរមាន និងមានអានុភាពអនុវត្តចាប់ពីពេលណាមក? ទាក់ទងជាមួយនឹងការចូលជាធរមាន ក៏ដូចជាការអនុវត្តក្រមព្រហ្ម-ទណ្ឌនេះបើយើងគិតអំពីគោលការណ៍ដែលកំណត់នៅក្នុងមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារបស់យើង ក្រមព្រហ្មទណ្ឌនេះបានចូលជាធរមាននៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ បានន័យថា ២០ (ម្ភៃ) ថ្ងៃ ក្រោយពីថ្ងៃប្រកាសឱ្យប្រើគឺត្រូវចូលជាធរមាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែទាក់ទងទៅនឹងការអនុវត្តនូវក្រមព្រហ្មទណ្ឌថ្មីនេះ បើផ្អែកទៅលើបញ្ញត្តិដែលកំណត់នៅក្នុងមាត្រា ៦៧២ បានចែងថា "លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ដែលត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ

បទប្បញ្ញត្តិដទៃទៀត ត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។ ដូច្នេះយើងត្រូវតែធ្វើជាពីរដំណាក់កាលតាមក្រមព្រហ្មទណ្ឌគឺ នៅដំណាក់កាលទី១ គឺអនុវត្តនូវបទប្បញ្ញត្តិទូទៅដែលមានចែងនៅក្នុងគន្ថីទី១ស្តីអំពីបទប្បញ្ញត្តិទូទៅ ដោយមានទាំងអស់ចំនួន ១៨២ មាត្រា គិតចាប់ពីមាត្រា ១ ដល់មាត្រា ១៨២ ដែលត្រូវអនុវត្តភ្លាមក្រោយពីការចូលជាធរមាននៃក្រមនេះ។ ដូច្នេះហើយបទប្បញ្ញត្តិនៃគន្ថីទី១ នេះត្រូវបានអនុវត្តតាំងពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ នៅទូទាំងប្រទេសកម្ពុជាមកម្ល៉េះ និងដំណាក់កាលទី២ ត្រូវអនុវត្ត ១ ឆ្នាំក្រោយចូលជាធរមាននៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ ដូច្នេះក្រមនេះត្រូវអនុវត្តទាំងស្រុងនៅថ្ងៃទី២១ខែធ្នូ ឆ្នាំ២០១០។

ក្រមព្រហ្មទណ្ឌត្រូវបានចាត់ទុកថាជាច្បាប់ទូទៅ ហើយក៏មានច្បាប់ពិសេសផ្សេងៗទៀតដែលត្រូវយកមកអនុវត្តទន្ទឹមគ្នាផងដែរ ដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជនផល ច្បាប់ស្តីពីរបបសារព័ត៌មាន ជាដើម។ ជារួមមក ក្រមព្រហ្មទណ្ឌរមែងចែងពីបទល្មើស ទោស និងការទទួលខុសត្រូវចំពោះបទល្មើស។

គួរយ៉ាង គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ គឺជាគោលការណ៍ដែលមានកំណត់នៅក្នុងបទបញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ ដែលស្ថិតនៅក្នុងគន្ថីទី១ ដូច្នេះគោលការណ៍ឯកត្តកម្មនេះ ត្រូវបានគេយកទៅអនុវត្តភ្លាមក្រោយការប្រកាសចូលជាធរមានដូចបានរៀបរាប់ខាងលើមក។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនបានប្រព្រឹត្តខុស និងជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ហេតុនេះបានជាក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៤ បានបញ្ញត្តិថា បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។

មួយវិញទៀត ជាគោលការណ៍នៅក្នុងការសម្រេចសេចក្តីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមជាបុគ្គលដែលមានអំណាចឆន្ទានុសិទ្ធិ នៅក្នុងការវិនិច្ឆ័យសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះបទល្មើសណាមួយលើបុគ្គលណាម្នាក់ ដើម្បីឱ្យមានភាពត្រឹមត្រូវ និងយុត្តិធម៌ តម្រូវឱ្យចៅក្រមនោះធ្វើការវិនិច្ឆ័យដោយពិចារណាស្របតាមលក្ខខណ្ឌមួយចំនួនដែលកំណត់ដោយច្បាប់។ ដូច្នេះហើយបានជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិនូវគោលការណ៍ពិសេសមួយដើម្បីផ្តល់ជាមូលដ្ឋានដល់ចៅក្រម ក្នុងការយកមកពិចារណា វិនិច្ឆ័យ ដើម្បីកំណត់អំពីទំហំនៃទោសព្រហ្មទណ្ឌ ដែលនឹងត្រូវប្រកាសចំពោះជនជាប់ចោទ ដែលគោលការណ៍នេះហៅថា **គោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ** ដែលមានចែងនៅមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនូវប្រធានបទមួយនេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីសិក្សាស្វែងយល់អំពីភាព មិនច្បាស់លាស់ និងចម្ងល់មួយចំនួន ក៏ដូចជាចង់ស្រាយបំភ្លឺអំពីបញ្ហាគតិយុត្តដូចដែលបានលើកឡើងខាងលើ ក៏ដូចជា ពង្រឹង និងពង្រីកនូវសមត្ថភាពចំណេះដឹងផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារបន្ថែម ដើម្បីសរសេរសារណានេះឡើង។ ក្នុងនោះរួមមានដូចជា ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ និងរួមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀត ដូចដែលបានលើកឡើងនៅក្នុងឯកសារយោង។ នៅក្នុងការសិក្សាស្រាវជ្រាវនេះដែរ យើងខ្ញុំសូមផ្តោតតែទៅលើច្បាប់ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទនេះ មានសារៈប្រយោជន៍ និងអាចក្លាយជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកអានគ្រប់រូប ព្រមទាំងដើម្បីទុកជាឯកសារដល់សិស្សនិស្សិតជំនាន់ក្រោយៗ អាចយល់ដឹងកាន់តែច្បាស់អំពីគោលការណ៍ឯកត្តកម្មសំខាន់ៗដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពណ៌នា និងវិភាគ។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានាដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានស្វះស្វែងរកពត៌មាន និងដកស្រង់ចេញពីប្រភពល្អៗ និងច្បាស់លាស់ ព្រមទាំងច្បាប់សំខាន់ៗរបស់ព្រះរាជា-ណាចក្រកម្ពុជា ក៏ដូចជាឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទសារណាខាងលើនេះ យើងខ្ញុំសូមធ្វើការបែងចែកចេញជា ៣ (បី) ជំពូកធំៗគឺ៖

ជំពូកទី១៖ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ជំពូកទី២៖ គោលការណ៍ឯកត្តកម្មនៃទោស

ជំពូកទី៣៖ អត្ថប្រយោជន៍នៃការអនុវត្តគោលការណ៍ឯកត្តកម្ម។

# ជំពូកទី១៖
# គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ
## ផ្នែកទី១៖ អត្ថន័យគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ សំដៅដល់ការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។

- "**អំពើផ្ទាល់ខ្លួន**" មានន័យថា បើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។

- "**អ្នកណាធ្វើ អ្នកនោះទទួល**" ហេតុនេះមិនអាចឲ្យអ្នកដទៃចូលទៅទទួលទោសជំនួសទេ ទោះបីទោសនោះជាទោសប្រភេទអ្វីក៏ដោយ។

- "**អំពើផ្ទាល់ខ្លួន**" មានន័យថា បើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌក្នុងន័យរួមមានន័យថានៅក្នុងរឿងព្រហ្មទណ្ឌ អ្នកណាជាអ្នកប្រព្រឹត្តបទល្មើស អ្នកនោះគឺជាអ្នកទទួលខុសត្រូវដែលភាសាខ្មែរយើងនិយាយយ៉ាងសាមញ្ញថា "**អ្នកណាធ្វើ អ្នកនោះទទួល**" ហេតុនេះមិនអាចឲ្យអ្នកដទៃចូលទៅទទួលទោសជំនួសទេ ទោះបីទោសនោះជាទោសប្រភេទអ្វីក៏ដោយ។ ដើម្បីងាយយល់យើងសូមលើក ឧទាហរណ៍៖ មូលទោស គឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[1] ប្រសិនបើជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ គឺច្បាប់មិនអនុញ្ញាតឲ្យអ្នកដ៏ទៃចូលទៅទទួលរងទោសជំនួសឲ្យចារីនោះទេ។ សូម្បីតែការបង់ប្រាក់ពិន័យក៏ច្បាប់មិនអនុញ្ញាតឲ្យអ្នកដ៏ទៃទៅបង់ប្រាក់ជំនួសដែរព្រោះគោលបំណងនៃទោសព្រហ្មទណ្ឌដែលមានគោលដៅធ្វើឲ្យជននោះខ្លាចរអារ និងដើម្បីបង្ការដល់សាធារណជន។ ដូច្នេះការដាក់ទណ្ឌកម្ម គឺធ្វើឲ្យទណ្ឌិតមានអារម្មណ៍មួយទទួលដឹងថាអ្វីដែលគាត់ប្រព្រឹត្តគឺខុសហើយនៅពេលខុសតើគាត់បានទទួលរងនូវផលវិបាកអ្វីខ្លះចំពោះខ្លួនឯងផ្ទាល់ជាដើម។

**ឧទាហរណ៍៖** ប្រសិនបើបុគ្គលម្នាក់ដែលមានអាយុចាប់ពី ១៨ឆ្នាំ ហើយគេធ្វើសកម្មភាពលួចយកម៉ូតូមួយគ្រឿងពីផ្ទះរបស់លោក **ក** នោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសលួចនោះត្រូវទទួលខុសត្រូវចំពោះតែអំពើផ្ទាល់ខ្លួនរបស់គេ យោងទៅលើ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បានចែងថា បុគ្គលម្នាក់ៗទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ[2]។ ដូច្នេះមិនអាចឱ្យឪពុក ឬម្ដាយរបស់បុគ្គលនោះមកទទួលខុសត្រូវជំនួសបានទេ ទោះបីជាស្ថិតក្នុងករណីណាក៏ដោយ បើទោះបីជាឪពុក ឬម្ដាយរបស់បុគ្គលនោះស្ម័គ្រចិត្តក្នុង

[1] មាត្រា ៤៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[2] មាត្រា ២៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ការទទួលខុសត្រូវជំនួសក៏ដោយ ក៏ច្បាប់មិនអាចលើកលែងឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើស ហើយទៅដាក់ទោសឪពុក ឬម្ដាយ ទាំងដែលគាត់ទាំងពីរមិនបានប្រព្រឹត្តបទល្មើសទេ។ ក្នុងករណីនេះផ្ទុយពីរឿងរដ្ឋប្បវេណី ដែលអាចឱ្យឪពុកឬម្ដាយទទួលខុសត្រូវសំណងរដ្ឋប្បវេណីជំនួសបានក្នុងរឿងរដ្ឋប្បវេណី(**រឿងស៊ីវិល**)។ **ឧទាហរណ៍៖** ប្រសិនបើកូនរបស់ស្ត្រីម្នាក់បានធ្វើឱ្យឡានរបស់អ្នកដទៃខូចនោះ ស្ត្រីដែលជាម្ដាយអាចធ្វើការទូទាត់សងសំណងនៃការខូចខាតជំនួសកូនរបស់គាត់បាន ប្រសិនបើកូនរបស់គាត់ជាអនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ។

**តើភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌនិងអំពើល្មើសផ្នែករដ្ឋប្បវេណីខុសគ្នាយ៉ាងដូចម្ដេច?**និយមន័យបទល្មើសព្រហ្មទណ្ឌ គឺជាអំពើដែលល្មើសទៅនឹងច្បាប់ព្រហ្មទណ្ឌ។ បទល្មើសអាចត្រូវចាត់ទុកថាជាបាតុភូតអសកម្ម ក្នុងជីវភាពរស់នៅ ផងដែរ ដោយហេតុថាបទល្មើសបានជះឥទ្ធិពលអាក្រក់ដល់សណ្ដាប់ធ្នាប់សង្គម ដល់សេរីភាពរបស់ពលរដ្ឋ។ ជាធម្មតាគេចាត់ទុកអំពើមួយ គឺជាបទល្មើសបាន លុះត្រាតែអំពើនោះបានបង្ហាញនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់ការពារ។ ជាទូទៅបទល្មើស គឺជាអំពើខុសនឹងសីលធម៌សង្គម និងបង្កផលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គម និងបង្កឲ្យមានព្យសនកម្មដល់សង្គម។ តាមការពិតទៅ មិនមែនមានតែបទល្មើសព្រហ្មទណ្ឌដែលបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គមទេ គឺនៅមានអំពើមួយចំនួនទៀត ដែលជាអំពើបង្កឲ្យមានគ្រោះថ្នាក់ដែរ ក៏ប៉ុន្តែមិនត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌទេ តែគេចាត់ទុកថាជាកំហុសរដ្ឋប្បវេណី ហើយចារីត្រូវដាក់ទណ្ឌកម្មឲ្យបង់ជាសំណងការខូចខាត និង សំណងជម្ងឺចិត្តតែប៉ុណ្ណោះ។ អំពើល្មើសផ្នែករដ្ឋប្បវេណី គឺមានប្រភពមកពីបទបញ្ញត្តិនៃមាត្រា១២១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្ដីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ ១៩៨៨ ដែលចែងថា ជនណាធ្វើឲ្យមានការខូចខាតដល់អ្នកដទៃដោយកំហុសរបស់ខ្លួន ជននោះត្រូវជួសជុលការខូចខាត។ រីឯបទល្មើសព្រហ្មទណ្ឌវិញ គឺត្រូវតែជាអំពើដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ថាជាបទល្មើសព្រហ្មទណ្ឌ។ សម្រាប់អំពើរដ្ឋប្បវេណីវិញ ព្យសនកម្ម គឺជាកត្តាចាំបាច់ណាស់ ដើម្បីអាចអោយចៅក្រម ដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តបាន។ ផ្ទុយទៅវិញការបង្កើតជាបទល្មើសព្រហ្មទណ្ឌពុំសុទ្ធតែទាមទារឲ្យមានព្យសនកម្មទេដូចជាៈ បទល្មើសជួញដូរគ្រឿងញៀន ការបើកបរល្បឿនខុសច្បាប់ជាដើម ការបង់សំណងជម្ងឺចិត្ត ជាទណ្ឌកម្មសម្រាប់អំពើល្មើសរដ្ឋប្បវេណី និងជាទណ្ឌកម្មដែលផ្ដល់ផលប្រយោជន៍ដល់ជនរងគ្រោះ។ ប្រាក់ពិន័យ គឺជាចំណូលថវិការបស់រដ្ឋ រីឯប្រាក់សំណងជម្ងឺចិត្ត គឺត្រូវបានទៅជនរងគ្រោះ។ អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះថ្វីត្បិតតែជាអំពើខុសឆ្គង ប៉ុន្តែពុំមែនជាបទ ល្មើសទេ។ **ឧទាហរណ៍៖** ការធ្វើឲ្យខូចខាតទ្រព្យរបស់អ្នកដទៃដោយអចេតនា។ ផ្ទុយទៅវិញអំពើ មួយអាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង អំពើល្មើសផ្នែករដ្ឋប្បវេណីផង គឺ រួមមានដូចជាៈ អំពើឃាតកម្ម ឬអំពើហិង្សាដោយចេតនាដល់តតិយជនជាដើម។ ក្នុងករណីបែបនេះអំពើល្មើសនាំឲ្យមានបណ្ដឹងពីរប្រភេទគឺ៖ បណ្ដឹងអាជ្ញា និង បណ្ដឹងរដ្ឋប្បវេណី។ ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើស

ផ្នែកវិន័យ គឺជាអំពើធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ សមូហភាពនៃក្រុមសង្គមណាមួយដូចជាៈ ពេទ្យ មេធាវីជាដើម ដោយអំពើនោះមិនត្រូវបានកំណត់ឲ្យច្បាស់លាស់ជាទូទៅទេ។

**ឧទាហរណ៍៖** មាត្រា ៥៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥ បានចែងថាៈ ត្រូវទទួលទណ្ឌកម្ម ជាបទវិន័យចំពោះមេធាវីណាដែលប្រព្រឹត្តល្មើស និងវិធានវិជ្ជាជីវៈប្រកបវិជ្ជាជីវៈរបស់ខ្លួន។ ការកំណត់យ៉ាងដូច្នេះបានបង្ហាញឲ្យឃើញថា អំពើល្មើសផ្នែកពិន័យសម្រាប់វិជ្ជាជីវៈមេធាវី ពុំត្រូវបានបញ្ជាក់ឲ្យច្បាស់ជាមុន ដូចជាៈ បទល្មើសព្រហ្មទណ្ឌទេ ព្រោះថាអំពើប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវីជាសញ្ញាមួយទូលំទូលាយណាស់។ ផ្ទុយទៅវិញបទល្មើសព្រហ្មទណ្ឌទោះបីជាមានច្រើនយ៉ាងណាក៏ដោយ ក៏សុទ្ធសឹងជាអំពើ ដែលច្បាប់បានកំណត់យ៉ាងច្បាស់លាស់ជាមុនរួចស្រេចអស់ហើយ។ មានន័យថាអំពើណាដែល ច្បាប់ពុំបានចែងថាជាបទល្មើសព្រហ្មទណ្ឌទេ គឺពុំអាចចាត់ទុកថាអំពើនោះ ជាបទល្មើសព្រហ្មទណ្ឌបានឡើយ ដោយផ្អែកតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស[3] អំពើល្មើសផ្នែកវិន័យធ្វើឲ្យប៉ះពាល់តែផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ។ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តល្មើសស្ថិតនៅ។ ប៉ុន្តែបទល្មើសព្រហ្មទណ្ឌវិញ ជាអំពើដែលប៉ះពាល់ដល់សង្គមជាទូទៅ។ ការដាក់ទណ្ឌកម្មលើអំពើ ល្មើសខាងវិន័យ គឺត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយដូចជាៈ ក្រុមប្រឹក្សាមេធាវីសម្រាប់ការដាក់វិន័យមេធាវី ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់ការដាក់វិន័យចៅក្រម ជាដើម។ ចំណែកឯការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌវិញ គឺជាសមត្ថកិច្ចរបស់សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយទណ្ឌកម្មអាចមានលក្ខណៈធ្ងន់ធ្ងររហូតដល់ការដាក់ពន្ធនាគារអស់មួយជីវិតទៀតផងដូចជាៈ បំណែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណីដែលការជីវិតទៀតផងដូចជាៈ បំណែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណីដែលការ បែងចែករវាងបទល្មើសផ្នែកវិន័យ និងបទល្មើសព្រហ្មទណ្ឌ គឺវាឆ្លុះបញ្ចាំងឲ្យឃើញថា ក្នុងករណីខ្លះ អំពើមួយត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែកវិន័យទេ។ ឧទាហរណ៍៖ អំពើលួចប្រព្រឹត្តដោយជនអនាថាម្នាក់។ ពេលខ្លះអំពើណាមួយត្រូវចាត់ទុកជាអំពើល្មើសផ្នែកវិន័យ ប៉ុន្តែពុំត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌឡើយ។

## ផ្នែកទី២៖ បុគ្គលដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌ

ចំពោះបុគ្គលដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌមាន ២(ពីរ) ប្រភេទ គឺ៖ រូបវន្តបុគ្គល និងនីតិបុគ្គល ហើយរូបវន្តបុគ្គលត្រូវបានបែងចែកជា ០២ (ពីរ) ទៀត គឺអនីតិជន និងនីតិជន រីឯនីតិបុគ្គលក៏មាន២ (ពីរ) ដូចគ្នា គឺនីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន។ ចំពោះអនីតិជនដែលមានអាយុនៅក្រោម ១៤ឆ្នាំ គឺច្បាប់កំណត់មិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ[4] ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងរហូតដល់

[3] មាត្រា ៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[4] មាត្រាក្រ ៣៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ក្រោម ១៨ឆ្នាំ តុលាការអាចប្រកាសទោសបាន ប្រសិនបុគ្គលិកលក្ខណៈអនីតិជននោះតម្រូវ។[5] ការប្រកាសទោសចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំឡើង គឺផ្អែកទៅលើកាលៈទេសៈ ឬស្ថានភាពរបស់បុគ្គលនោះ ដែលការប្រកាសទោសរបស់តុលាការ គឺផ្អែកទៅលើការយល់ដឹងរបស់បុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ គេមិនអាចឱ្យបុគ្គលដែលមិនដឹងខុសត្រូវចំពោះអំពើរបស់ខ្លួន មកទទួលខុសត្រូវព្រហ្មទណ្ឌទេ។ **ឧទាហរណ៍៖** ដូចជា ជនដែលមានបញ្ហាផ្នែកស្មារតី។ ការទទួលខុសត្រូវរបស់អនីតិជន គឺ អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបានបន្ថយពាក់កណ្ដាល ប្រសិនបើអតិបរមានៃទោសនោះ អស់មួយជីវិតមកត្រូវបន្ថយមកនៅត្រឹម ២០ឆ្នាំ។ ចំពោះនីតិជនវិញ ត្រូវទទួលខុសត្រូវពេញលេញតាមច្បាប់កំណត់ ចំពោះអំពើរបស់ខ្លួន ពោលគឺប្រសិនបើប្រព្រឹត្តបទល្មើសលួចត្រូវផ្ដន្ទាទោសពី ៦ខែ ទៅ ៣ឆ្នាំតាមច្បាប់ចែង។[6] ប៉ុន្តែក៏មិនដាច់ខាតដែរចំពោះនីតិជន តុលាការអាចពិនិត្យមើលទៅលើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ ដើម្បីបានទទួលនូវស្ថានសម្រាលទោស[7] ហើយស្ថានសម្រាលទោសអាចផ្តល់ឱ្យជនជាប់ចោទបានដែរ បើទោះបីជាជននោះត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចោលក៏ដោយ។[8] **ឧទាហរណ៍៖** លោក ក បានប្រព្រឹត្តបទល្មើសលួចហើយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំហើយពេលអនុវត្តទោសរួចគាត់ចេញមកវិញ គាត់ប្រព្រឹត្តបទល្មើសឃាតកម្មក្នុងរយៈពេលចេញពីពន្ធនាគារមិនទាន់គ្រប់៥ឆ្នាំ ដូចនេះលោក ក៏ ត្រូវទទួលនូវស្ថានទម្ងន់ទោសដោយអតិបរិមាទ្វេដង បទឃាតកម្មត្រូវផ្តន្ទាទោស ១០ឆ្នាំ ទៅ ១៥ឆ្នាំតែដោយគាត់ទទួលស្ថានទម្ងន់ទោស គឺចន្លោះពី ១០ឆ្នាំ ទៅ ៣០ឆ្នាំ។ ចំណែកឯនីតិបុគ្គល គឺគេមិនអាចឱ្យ ឬចាប់នីតិបុគ្គលមកដាក់ពន្ធនាគារបានទេពោលគឺ គេអាចផ្តន្ទាទោសនីតិបុគ្គលបានត្រឹមតែទោសពិន័យប៉ុណ្ណោះ (មូលទោស[9])និងទោសបន្ថែមមួយចំនួនសម្រាប់នីតិបុគ្គលដូចជា៖ ការរំលាយចោលដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ឬក៏ហាមឃាត់ចំពោះការចេញជាដើម[10]**ឧទាហរណ៍៖** អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបានដែលកំណត់ដោយធនាគារជាដើម។រីឯនីតិបុគ្គលសាធារណៈ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[11]ការទទួលឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះមិនថាបុគ្គលនោះបានប្រព្រឹត្តបទល្មើសដោយចារីឬ សហចារីនោះទេ បុគ្គលនោះមិនអាចគិចវេសអំពីអំពើរបស់ខ្លួនបានឡើយ។

[5] មាត្រា ៣៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[6] មាត្រា ៣៥៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[7] មាត្រា ៩៣ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[8] មាត្រា ៩៣ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[9] មាត្រា ១៦៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[10] មាត្រា ១៦៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[11] មាត្រា ៤២ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

## ២.១.ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល

បរិបទនៃការរស់នៅក្នុងសង្គម គឺតែងតែមានមនុស្សល្អ និងមនុស្សអាក្រក់ ដែលគ្រប់បុគ្គលទាំងអស់មិនអាចមានការគិតដូចគ្នាទាំងអស់នោះទេ។ ប្រាក់ គឺជាវត្ថុដែលមានតម្លៃនៅការរស់នៅ។ ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមានច្រើនករណី ដូចជាករណីប្លន់ លួច ឃាតកម្ម រំលោភជាដើម ហើយបទល្មើសដែលបានរៀបរាប់ខាងលើ គឺបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកមួយចំនួនទៀត។ ជាទូទៅការរស់នៅក្នុងសង្គម គឺជៀសមិនផុតអំពីការប្រព្រឹត្តបទល្មើសទេ។ គ្រប់បុគ្គលទាំងអស់សុទ្ធតែធ្លាប់បានប្រព្រឹត្តបទល្មើស ប៉ុន្តែអ្នកគ្រប់គ្នាប្រាកដជាមិនដឹងទេថាខ្លួនធ្លាប់ប្រព្រឹត្តបទល្មើសដូចជាការបើកបរមិនពាក់មួកសុវត្ថិភាពហើយត្រូវបានប៉ូលីសចរាចរណ៍ចាប់ផាកពិន័យ ការជេរប្រមាថជាសាធារណៈ គឺជាបទជាបទល្មើសមួយដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ គ្រាន់តែពេលខ្លះទោសរបស់វាត្រឹមតែពិន័យជាប្រាក់ ហើយពេលខ្លះគ្មានអ្នកណាប្ដឹងដោយសារវាមិនបានបង្កជាគ្រោះថ្នាក់ដល់សង្គមខ្លាំង។ ដូចចំណុចដែលយើងខ្ញុំបានលើកឡើងអំពីទោសពិន័យជាប្រាក់ គឺស្ថិតនៅក្នុងមូលទោស ហើយវាស្ថិតក្នុងបទល្មើសលហុ[12]។ យ៉ាងណាមិញ នៅពេលដែលមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺត្រូវមានអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ នៅក្នុងចំណុចនេះ យើងខ្ញុំសូមលើកយកតែការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលមកធ្វើការបកស្រាយជាមុនសិន។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលត្រូវបានបែងចែកជា២ (ពីរ) ប្រភេទទៀត គឺការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន។ មុននឹងឈានទៅដល់បកស្រាយឱ្យបានក្បោះក្បាយ យើងខ្ញុំក៏សូមលើកយកនូវពាក្យមួយចំនួនមកពន្យល់ជាមុន ដើម្បីឱ្យងាយស្រួលក្នុងការយល់ពាក់ព័ន្ធទៅនឹងប្រធានបទនៃជំពូកទី១នេះ។ ពាក្យថារូបវន្តបុគ្គល គឺសំដៅទៅលើមនុស្សដែលកើតមកហើយរស់ មានសាច់មានឈាម ទទួលបានបុគ្គលភាពគតិយុត្តិ សិទ្ធិ និងកាតព្វកិច្ច តាំងពីពេលកើតមក។ រីឯ ពាក្យនីតិជន គឺជាជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ហើយមានសមត្ថភាពខាងអំពើ។ ចំណែកឯពាក្យអនីតិជន គឺសំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ។[13]

តើនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ដោយច្បាប់ណា? ហើយការកំណត់អាយុចាប់ពីប៉ុន្មានទៅទើបត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ?

ដូច្នេះដើម្បីយល់កាន់តែច្បាស់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលនៅក្នុង ជំពូកនេះ យើងខ្ញុំសូមធ្វើការបែងចែក ជា២ (ពីរ) ផ្នែក គឺផ្នែកទី១ អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន និងផ្នែកទី២

---

[12] មាត្រា ៤៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[13] មាត្រា ១៧ ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន។

### ២.១.១.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន

នីតិជន គឺជាបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់។ សមត្ថភាព គឺសំដៅដល់សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ បើតាមក្រមព្រហ្មទណ្ឌ នីតិជន គឺជាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ នីតិជន គឺជាជនពេញវ័យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត។

#### ២.១.១.១.លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

##### ២.១.១.១.១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាគោលការណ៍នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។[14] នេះជាលក្ខខណ្ឌមួយដែលច្បាប់បានកំណត់យ៉ាងជាក់ច្បាស់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាគោលការណ៍ ប្រសិនបើបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពេញលេញតាមច្បាប់កំណត់ ដែលនេះវាខុសពីអនីតិជនត្រូវទទួលខុសត្រូវត្រឹមតែពាក់កណ្តាលនៃទោសប៉ុណ្ណោះ។[15] នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនាំឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសទទួលខុសត្រូវនូវអំពើរបស់ខ្លួននៅចំពោះមុខច្បាប់ ព្រោះបើយើងគិតពីអាយុ និងការយល់ដឹងគឺអាចមានការយល់ដឹងពេញលេញចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។ គោលការណ៍នៃច្បាប់បានសន្មតទុកជាមុនថា ប្រជាពលរដ្ឋគ្រប់រូប គឺយល់ដឹងអំពីច្បាប់ ហើយការយល់ដឹងអំពីច្បាប់ សំដៅទៅលើការយល់ដឹងអំពីអំពើរបស់ខ្លួនថាខុសច្បាប់ ឬមិនខុសច្បាប់។ ឧទាហរណ៍៖ អំពើលួច យើងគ្រប់គ្នាប្រាកដជាដឹងហើយថាការលួចទ្រព្យរបស់អ្នកដទៃ គឺជាអំពើខុសច្បាប់ទោះបីប្រជាពលរដ្ឋមិនអាចដឹងថាអំពើដែលប្រព្រឹត្តនោះមានចែងនៅក្នុងមាត្រាណានៃច្បាប់ណា ក៏គាត់អាចយល់យ៉ាងច្បាស់ថា នេះជាអំពីអំពើខុសច្បាប់។[16]

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនាំឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើស ទទួលខុសត្រូវទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្ម-ទណ្ឌ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។[17] មួយវិញទៀត ក៏មានមូលហេតុ

[14] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[15] មាត្រា ១៦០ ព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[16] មាត្រា ៣៥៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[17] មាត្រា ២៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដែរ រួមមាន៖ អនីតិជនអាយុក្រោម ១៤ឆ្នាំ[18] វិបល្លាសស្មារតី[19] ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ[20] ការការពារស្របច្បាប់[21] សច្ចធារណ៍នៃការការពារស្របច្បាប់[22] ស្ថានភាពចាំបាច់[23] និងអានុភាពនៃកម្លាំង ឬការបង្ខំ។[24]

### ២.១.១.១.២ សមាសភាព ឬឋានៈអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើងគឺតែងតែមានបុគ្គលមួយចំនួនទទួលខុសត្រូវព្រហ្មទណ្ឌ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពី ១៨ឆ្នាំឡើងទៅ ដូចដែលយើងបានលើកឡើងនៅក្នុងចំណុចខាងលើ។ នៅក្នុងក្រមព្រហ្មទណ្ឌ បានកំណត់អំពីសមាសភាពបុគ្គលមួយចំនួនក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌមានដូចជា ៖

- **ចារី** ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមក្នុងករណីដែលច្បាប់ចែងទុក។[25]
- **សហចារី** ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរបើ កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់ចែងទុក។[26]
- **អ្នកផ្ដើមគំនិត** សំដៅទៅលើជនទាំងឡាយណាដែលបានជំរុញ ឬបង្កឱ្យមានបទល្មើសបទឧក្រិដ្ឋ បទមជ្ឈិម តាមរយៈការណែនាំ ការបញ្ជា ការផ្តល់អំណោយ ការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។[27]

[18] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[19] មាត្រា ៣១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[20] មាត្រា ៣២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[21] មាត្រា ៣៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[22] មាត្រា ៣៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[23] មាត្រា ៣៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[24] មាត្រា ៣៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[25] មាត្រា ២៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[26] មាត្រា ២៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[27] មាត្រា ២៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- **អ្នកសមគំនិត** ត្រូវចាត់ទុកជាអ្នកផ្សំគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួល ដល់ចេតនានៃការប៉ុនប៉ង ឬសម្រួលបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។[28]

- **អ្នករាជការសាធារណៈ** មានន័យថាបុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះបីជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្នក្តី ទោះបីជាទទួលបាន ឬមិនទទួលបានប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុរបស់បុគ្គលនោះឡើយ។ បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ក៏ដូចជាស្ថាប័នសាធារណៈដទៃទៀតដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[29]

- **ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត** គឺមានន័យថាជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលបានអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។[30]បុគ្គលដែលបានរៀបរាប់ខាងលើ នៅពេលដែលបានប្រព្រឹត្តបទល្មើស គឺសុទ្ធតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួន តែបុគ្គលមួយចំនួនមានអភ័យឯកសិទ្ធិមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌទេ។

### ២.១.១.២.ទណ្ឌកម្មដែលអាចប្រកាសចំពោះនីតិជន

ទណ្ឌកម្មព្រហ្មទណ្ឌ គឺជាការដាក់ទោសទៅលើជនល្មើសដោយស្ថាប័នតុលាការចំពោះអំពើដែលជននោះបានប្រព្រឹត្តខុសទៅនឹងច្បាប់។ ចំពោះការដាក់ទណ្ឌកម្មទៅលើជនល្មើស គឺមានគោលបំណងឱ្យជននោះកែប្រែចិត្តគំនិតកុំឱ្យមានការប្រព្រឹត្តខុសម្តងទៀត ពោលគឺចង់ឱ្យជននោះក្លាយទៅជាពលរដ្ឋល្អ។

### ២.១.១.២.១.ប្រភេទនៃទោស

ដោយយោងទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ទោសព្រហ្មទណ្ឌត្រូវបានបែងចែកជា ៣ (បី) គឺ៖ មូលទោស ទោសបន្ថែម និងទោសជំនួស។

[28] មាត្រា ២៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[29] មាត្រា ៣០ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[30] មាត្រា ៣០ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**គ. មូលទោស**

មូលទោស គឺជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយការពិន័យត្រូវគិតជាប្រាក់រៀល។[31] ចំពោះប្រាក់ពិន័យដែលទទួលបានត្រូវបង់ចូលជាថវិការដ្ឋ ពោលគឺប្រាក់ពិន័យនេះមិនមែនជាប្រាក់សំណងរដ្ឋប្បវេណី ដែលភាគីបង្កបង់សងជម្ងឺចិត្តទៅជនរងគ្រោះទេ។[32]

ទោសដាក់ពន្ធនាគារ គឺជាទោសដែលលុបបំបាត់ទាំងអស់ នូវសិទ្ធិសេរីភាពជាមូលដ្ឋាន ឬយើងហៅជាសាមញ្ញថាជាប់ពន្ធនាគារ ឬជាប់គុក។ ទោសដាក់ពន្ធនាគារនេះ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ យោងតាមមាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។[33]

ចំណែកឯ ទោសពិន័យជាប្រាក់ គឺតម្រូវឱ្យទណ្ឌិតបង់ប្រាក់តាមច្បាប់កំណត់ ហើយប្រាក់ពិន័យត្រូវទុកចូលជាថវិការដ្ឋដែលត្រូវទុកនៅរតនាគារជាតិ ដោយយោងតាមមាត្រា ៥២ នៃក្រមព្រហ្មទណ្ឌ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និង អតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។[34] ឧទាហរណ៍៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០រៀល ទៅ ៦.០០០.០០០រៀល។ ការពិន័យបែបនេះហៅថាមូលទោស។

បទល្មើសត្រូវបានបែងចែកចេញជា ៣(បី) គឺ៖ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។

- បទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាប្រភេទនៃបទល្មើសដែលមានទោសធ្ងន់ធ្ងរជាងគេក្នុងចំណោមប្រភេទនៃបទល្មើសនេះ។ ចំពោះការដាក់ទោសទៅលើបទល្មើសប្រភេទនេះមាន៖[35]

- ទោសដាក់ពន្ធនាគារអស់មួយជីវិត។
- ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ឆ្នាំ។
- ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

- បទមជ្ឈិម

---

[31] មាត្រា ៤៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[32] មាត្រា ៥២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[33] មាត្រា ៤៤ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[34] មាត្រា ៤៤ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[35] មាត្រា ៤៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

បទមជ្ឈិម គឺជាបទល្មើសមួយដែលត្រូវផ្តន្ទាទោសមានអតិបរមានៃទោសពន្ធនាគារដែលត្រូវរងនោះមានរយៈពេលលើសពី ៦ខែ និងក្រោម ឬស្មើ៥ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[36]

- បទលហុ

បទលហុ ក្នុងករណីដែល៖

• អតិបរមានៃទោសដាក់ពន្ធនាគារដែលជនល្មើសត្រូវរងនោះមានរយៈពេលក្រោម ឬស្មើនឹង ៦ ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

• បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។[37]

**ខ. ទោសបន្ថែម**

ទោសបន្ថែម គឺជាទោសបន្ទាប់បន្សំ ដែលចៅក្រមសម្រេចបន្ថែមក្នុងមូលទោស ហើយទាល់តែតុលាការសម្រេចថាបុគ្គលរូបណាមានមូលទោសហើយ ទើបតុលាការអាចសម្រេចដាក់ទោសបន្ថែម ពីលើមូលទោសនោះបាន។ លើសពីនេះទៅទៀត ទោសបន្ថែមបង្កើតឡើងក្នុងគោលបំណង ដើម្បីឱ្យការដាក់ទណ្ឌកម្មមានភាពសមស្របទៅនឹងអំពើល្មើសច្បាប់ដែលបុគ្គលរូបនោះបានប្រព្រឹត្ត ឬធានាដល់ការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស។ ជាគោលការណ៍បទឧក្រិដ្ឋតែងតែមានអនុទោស ប៉ុន្តែអនុទោសនេះមិនមានច្បាប់ចែងទេ វាអាស្រ័យលើចៅក្រម បើគាត់យល់ឃើញថាត្រូវតែផ្តន្ទាទោសអនុទោសមួយទៀត ដើម្បីឱ្យបុគ្គលនោះរាងចាលឈប់ប្រព្រឹត្តដែលភាគច្រើនសំដៅទៅលើមុខរបរអាជីព។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត។ ចំពោះលក្ខខណ្ឌនៃការប្រកាសទោសបន្ថែម គឺទោសបន្ថែមនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន ហើយទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។[38] ប្រភេទទោសបន្ថែមនេះរួមមាន៖[39]

- ការដកសិទ្ធិខ្លះជាពលរដ្ឋ៖[40]

---

[36] មាត្រា ៤៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[37] មាត្រា ៤៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[38] មាត្រា ៥៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[39] មាត្រា ៥៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[40] មាត្រា ៥៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ជាទូទៅ ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបតែងតែមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ហើយមានសិទ្ធិ និង ករណីយកិច្ចដូចៗគ្នាដោយមិនប្រកាន់វណ្ណៈ ពណ៌សម្បុរ ភេទ ភាសា សាសនា ជំនឿឡើយ។ ម្យ៉ាងទៀត ចំពោះ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គល គឺមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដទៃទៀតឡើយ ចំពោះ ការប្រើសិទ្ធិនេះដែរ គឺត្រូវប្រព្រឹត្តតាមលក្ខខណ្ឌដែលកំណត់ក្នុងច្បាប់។[41]

ជាងនេះទៅទៀត ប្រសិនបើមានជនណាមួយបានប្រព្រឹត្តបទល្មើស ដែលផ្ទុយនឹងច្បាប់បានកំណត់ នោះសិទ្ធិពលរដ្ឋនឹងត្រូវបានដកដែលមានដូចជា សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត សិទ្ធិបំពេញ ការងារជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈ សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជា អាណត្តិគាហករបស់តុលាការ សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ សិទ្ធិធ្វើជាសាក្សី ដែលទទួល សម្បថនៅមុខតុលាការ។

- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលប្រកបវិជ្ជាជីវៈ នេះ៖

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិ ដែលជ្រើសតាំងដោយការ បោះឆ្នោតជាសាធារណៈ ឬ ការទទួលខុសត្រូវខាងសហជីពទេ។ ការហាមឃាត់នេះ មិនអាចអនុវត្តចំពោះបទ ល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ។ ទោសនេះអាចជាស្ថាពរ ឬក៏ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។ តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត់។[42] ឧទាហរណ៍៖ លោក ក ជាគ្រូពេទ្យ ហើយ បានប្រព្រឹត្តខុសទៅនឹងវិជ្ជាជីវៈរបស់ខ្លួន ដែលបណ្តាលឱ្យអ្នកជំងឺរងគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរ។ ដូចនេះ តុលាការ អាចប្រកាសទោសបន្ថែមដោយហាមឃាត់ ចំពោះការប្រកបវិជ្ជាជីវៈដែលបានប្រព្រឹត្តក្នុងពេលប្រកបវិជ្ជាជីវៈ ឬ ព្យួរអាជ្ញាប័ណ្ណរបស់គាត់ជាដើម។[43]

- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ៖

ចំពោះបទល្មើសខ្លះមិនថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬក៏បទលហុទេ ទោសបន្ថែមគឺត្រូវហាមឃាត់មិនឱ្យ ធ្វើការបើកបរយានយន្តគ្រប់ប្រភេទ ដែលការហាមឃាត់មិនឱ្យបើកបរយានយន្តមិនត្រូវលើសពី ៥ឆ្នាំទេ។[44]

- ការព្យួរលិខិតបើកបរ៖

---

[41] មាត្រា ៣១ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[42] មាត្រា ៥៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[43] មាត្រា ៥៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[44] មាត្រា ៥៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ករណីដែលអ្នកបើកបរប្រព្រឹត្តបទល្មើស តុលាការអាចសម្រេចសេចក្តីក្នុងការព្យួរលិខិតបើកបររបស់ជនល្មើសបាន នៅពេលតុលាការសម្រេចរឿងក្តីជាស្ថាពររួចហើយ សេចក្តីសម្រេចរបស់តុលាការខាងលើត្រូវជំនួសដោយសេចក្តីសម្រេចរបស់សាលក្រម ឬសាលដីកា។ ទោសព្យួរលិខិតបើកបរនេះមិនត្រូវលើសពី ៥ឆ្នាំទេ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួនទៅក្រឡាបញ្ជីតុលាការ។ លិខិតបើកបរ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[45]

- ការហាមឃាត់ចំពោះការស្នាក់នៅ៖[46]

ទោសហាមឃាត់ការស្នាក់នៅ គឺជាការហាមឃាត់ដល់ទណ្ឌិតចំពោះការមានមុខនៅកន្លែងខ្លះលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ទោសនេះមិនអាចលើសពី ១០ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង៥ឆ្នាំ ចំពោះបទមជ្ឈិម។ តុលាការកំណត់បញ្ជីនៃទីកន្លែងដែលហាមឃាត់ និងកំណត់ចិរវេលានៃការហាមឃាត់។

ការហាមឃាត់ការស្នាក់នៅរួមមានវិធានការតាមដានដែលទណ្ឌិតត្រូវតែ៖ ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង និងចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន។ សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។

- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា៖[47]

ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាមិនត្រូវលើសពី ៥ឆ្នាំ។ ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ។ លិខិតឆ្លងដែននេះត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួលទោសនោះ។

- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស៖[48]

[45] មាត្រា ៥៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩។
[46] មាត្រា ៥៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩។
[47] មាត្រា ៦០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩។
[48] មាត្រា ៦១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩។

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចចូលជាស្ថាពរ ឬជាបណ្ដោះអាសន្ន សម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។ ការហាមឃាត់នេះ នាំឱ្យមានការបណ្ដេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ។

- ការរឹបអូស៖

ការរឹបអូស គឺជាការដកហូតសិទ្ធិកាន់កាប់អចិន្ត្រៃយ៍នូវទ្រព្យរបស់ទៅតាមសេចក្តីសម្រេចរបស់តុលាការ ឬរបស់អាជ្ញាធរមានសមត្ថកិច្ច។[49] ការរឹបអូស អាចសំដៅដល់អំពើនៃការដកហូតរបស់ទ្រព្យពីម្ចាស់ទ្រព្យដោយបង្ខំនៅក្រោមអំណាចជាក់ស្ដែង ឬអំណាចពហិលក្ខណ៍នៃច្បាប់ ឬជាការយកទ្រព្យសម្បត្តិដាក់ចូលក្នុងការឃុំគ្រងរបស់តុលាការដើម្បីជម្រះបំណុលតាមសាលក្រម ឬដោយមកពីផលវិបាកនៃការបំពានច្បាប់។[50]

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចជា៖[51]

- ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។
- វត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។
- ផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

ប៉ុន្តែ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។

ម៉្យាងវិញទៀត ចំពោះការចាត់ចែងទ្រព្យសម្បត្តិរឹបអូស កាលបើបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែ មានបញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ។ រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ។[52]

- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ៖[53]

ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវអាចជាស្ថាពរបាន ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។ ការហាមឃាត់នេះត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

---

[49] អនុសញ្ញា ឆ្នាំ១៩៨៨ របស់អង្គការសហប្រជាជាតិប្រឆាំងនឹងការធ្វើចរាចរគ្រឿងញៀនខុសច្បាប់ និង សារធាតុដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ។

[50] កម្មវិធីវចនានុក្រមអេឡិចត្រូនិចរបស់គម្រាច្បាប់ ឆ្នាំ២០២២។

[51] មាត្រា ៦២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[52] មាត្រា ៦៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[53] មាត្រា ៦៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ៖[54]

លទ្ធកម្មសាធារណៈ គឺការផ្គត់ផ្គង់ទំនិញផ្សេងៗតាមការដេញថ្លៃជាសាធារណៈ ដោយប្រើថវិការដ្ឋ។ ហើយការបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយណាដែលរៀបចំដោយ៖

- រដ្ឋ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រឹះស្ថានសាធារណៈ
- សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោសបណ្តេញចេញនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។[55]

- ការបិទគ្រឹះស្ថាន៖[56]

ការបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថាន ដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង។

ទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន៖[57]

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស៖[58]

ទោសបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ខែ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។ ក្នុងករណីមានការបំបាត់

[54] ដកស្រង់ចេញពី សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០១១។

[55] មាត្រា ៦៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[56] មាត្រា ៦៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[57] មាត្រា ៦៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[58] មាត្រា ៦៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ចោល ការលាក់បំបាំង ឬការហែកចោលសេចក្តីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី។ ការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោល លាក់បំបាំង ឬ អ្នកហែកចោលសេចក្តីប្រកាសនេះ។

- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ៖[59]

ទោសផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរតាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត។ ក្នុងករណីមិនគោរពតាម ទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការផ្សាយនេះបានទេ។

- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍៖[60]

ទោសផ្សាយជាសាធារណៈនូវសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ។ ការផ្សាយនេះមិនអាចលើសពី ៨ថ្ងៃទេ។ ការផ្សាយអាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

**គ.ទោសជំនួស**

ទោសជំនួស គឺអាចត្រូវបានតុលាការយកមកប្រើប្រាស់ជំនួសទោសចំពោះការប្រព្រឹត្តបទល្មើសណាមួយ។ ទោសជំនួស សំដៅលើទោសការងារសហគមន៍ ឬការស្តីបន្ទោសដែលជំនួសឱ្យមូលទោស។ តុលាការដែលប្រកាសទោសការងារសហគមន៍ ឬការស្តីបន្ទោស ពុំអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ។ តុលាការពុំអាចប្រកាសទោសជំនួសទាំងពីរនេះ ត្រួតគ្នាបានឡើយ។ មូលហេតុដែលសម្រេចអំពីទោសជំនួស គឺដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ គេអាចពិនិត្យទៅលើស្ថានភាព កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីអនុវត្តទោសដែលជាមូលដ្ឋាន ដោយយកទោសជំនួសមកអនុវត្តវិញ។ ទោសជំនួស ត្រូវបានបែងចែកជា ២(ពីរ) គឺ ទោសការងារសហគមន៍ និងទោសស្តីបន្ទោស។

**គ.១.ទោសការងារសហគមន៍**

ទោសការងារសហគមន៍ ជាទោសជំនួសមួយប្រភេទដែលតម្រូវឱ្យទណ្ឌិតបំពេញការងារក្នុងចិរវេលាចន្លោះពី ៣០ម៉ោងទៅ ២០០ម៉ោង ដោយគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គល នៃនីតិសាធារណៈផ្សេងៗទៀតដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[61]

[59] មាត្រា ៦៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[60] មាត្រា ៧០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[61] ដកស្រង់ចេញពី សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ រក្សាសិទ្ធិបោះពុម្ពលើកទី១ដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០១១។

ទោសការងារសហគមន៍ តុលាការអាចប្រកាសបានលុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ជនជាប់ចោទយល់ព្រមធ្វើការងារនេះ។ តុលាការនៅមុនពេលប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ ហើយដែលចម្លើយរបស់ជនជាប់ត្រូវតែមានចុះនៅក្នុងសាលក្រម ឬសាលដីកា។[62]

ជាងនេះទៅទៀត តុលាការដែលប្រកាសទោសការងារសហគមន៍ត្រូវកំណត់ពីចិរវេលានៃការងារ និងរយៈពេលដែលត្រូវបំពេញ ដែលរយៈពេលនេះមិនអាចលើសពី ១ឆ្នាំទេ។[63] ចំពោះការអនុវត្តទោសសហគមន៍ត្រូវកំណត់ដោយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញា ជាអ្នកចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះដែលទោសនេះត្រូវអនុវត្តនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។[64] ហើយដើម្បីប្តូរមូលទោសមកជាទោសការងារសហគមន៍ និងទោសស្តីបន្ទោសបានលុះត្រាតែជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលមានអតិបរិមាតិចជាង ឬស្មើនឹង ៣ឆ្នាំ ទើបតុលាការអាចប្រកាសទោសបាន។ ឧទាហរណ៍ៈ បុគ្គល ខ បានប្រព្រឹត្តអំពើលួច។ យោងតាមខ្លឹមសារនៃមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌអំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០រៀល ទៅ ៦.០០០.០០០រៀល។ ក៏ប៉ុន្តែដើម្បីជាការជំនួសនូវមូលទោស គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ខាងលើ តុលាការអាចប្រកាសឱ្យបុគ្គល ខ ធ្វើការងារសហគមន៍ចំនួន ១០០ម៉ោង ដោយមិនទទួលបានប្រាក់កម្រៃមកវិញទេ។ ក្នុងករណីនេះ បុគ្គល ខ នឹងមិនត្រូវទទួលរងទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ទេ គឺបុគ្គល ខ គ្រាន់តែធ្វើការងារសហគមន៍ជំនួសតែប៉ុណ្ណោះ។

### គ.២. ទោសស្តីបន្ទោស

ការស្តីបន្ទោស គឺតុលាការអាចប្រកាសស្តីបន្ទោសកាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ហើយប្រសិនបើមានគ្រប់លក្ខខណ្ឌ ៣ (បី) ដូចតទៅៈ

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ និង
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ។[65]

[62] មាត្រា ១០១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[63] មាត្រា ១០២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[64] មាត្រា ១០៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[65] មាត្រា ៧៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

តុលាការគ្រាន់តែស្ដីបន្ទោសដល់ជនល្មើសដែលបានប្រព្រឹត្ត មិនផ្ដន្ទាទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ឡើយ កាលបើជនល្មើសបានសងការខូចខាតរួចរាល់ហើយ។

**២.១.១.២.២.អាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោស ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ។ ថិរវេលានេះ ចាប់ផ្ដើមគិតពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោសបានចូលជាស្ថាពរ។ រីឯថិរវេលាអាជ្ញាយុកាលនៃទោសមានដូចតទៅ៖

- ទោសដែលប្រកាស ចំពោះបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ឆ្នាំ។
- ទោសដែលប្រកាស ចំពោះបទមជ្ឈិមមានអាជ្ញាយុកាល ៥ឆ្នាំ។
- ទោសដែលប្រកាស ចំពោះបទលហុមានអាជ្ញាយុកាល ១ឆ្នាំ។[66]

ឧទាហរណ៍ លោក ក ត្រូវបានតុលាការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគាររះពេល ១០ឆ្នាំ ដែលសាលក្រមចូលជាស្ថាពរ នៅក្នុងករណីនេះប្រសិនបើលោក ក ចង់រត់គេចខ្លួន ត្រូវរត់ឱ្យបានលើសពី ២០ឆ្នាំ ទើបផុតអាជ្ញាយុកាលនៃទោស ។

**២.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន**

នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើង ជាគោលការណ៍ត្រូវតែមានអ្នកទទួលខុសត្រូវចំពោះអំពើល្មើស តែច្បាប់ក៏បានលើកលែងដែរ ចំពោះបុគ្គលមួយចំនួន ដូចជាអនីតិជនអាយុក្រោម១៤ឆ្នាំ ជនវិបល្លាសស្មារតី ការការពារស្របច្បាប់ជាដើម។ ប៉ុន្តែយើងខ្ញុំនឹងធ្វើការលើកជាសំខាន់ដោយផ្ដោតតែទៅលើអនីតិជនតែប៉ុណ្ណោះ។ ការអនុវត្តទោសលើអនីតិជន គឺមានលក្ខណៈខុសប្លែកពីការអនុវត្តទោសចំពោះនីតិជន ដោយការកំណត់ទោស និងវិធានការអប់រំផ្សេងៗចំពោះអនីតិជន គឺមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ គន្ថីទី១ មាតិកាទី២ ជំពូកទី៣ និងច្បាប់ស្តីពីយុត្តិធម៌របស់អនីតិជន ឆ្នាំ២០១៦ និងគោលការណ៍យុត្តិធម៌អនីតិជន ដែលការអនុវត្តទោសចំពោះអនីតិជននោះ។

ជាគោលការណ៍គេមិនអាចឱ្យជនដែលមិនយល់ដឹងអំពីអំពើរបស់ខ្លួន ទៅទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ច្បាប់បានចែងយ៉ាងជាក់ច្បាស់អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។[67] អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចពិចារណា ប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី

[66] មាត្រា ១៤៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[67] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ [68]ច្បាប់បានចែងមកបែបនេះ គឺដើម្បីការពារអនីតិជនផង និងការពារសណ្ដាប់ធ្នាប់សាធារណៈផង។ ការពារទៅអនីតិជនប្រសិនបើគាត់ប្រព្រឹត្តបទល្មើស អាយុតិចជាង ១៤ឆ្នាំ គាត់មិនទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសារតែការមិនយល់ដឹងអំពីអំពើនៃការប្រព្រឹត្តបទល្មើស ប៉ុន្តែច្បាប់ក៏បានចែងដែរនៅ កថាខណ្ឌទី២ មាត្រា ៣៩ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌចំពោះអនីតិជនអាយុចាប់ពី ១៤ឆ្នាំឡើងទៅ ប្រសិនបើបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ គឺអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំដល់ក្រោម១៨ឆ្នាំ គាត់អាចយល់ដឹងអំពីអំពើរបស់ខ្លួនបានខ្លះហើយ។ ប្រសិនបើតុលាការមិនធ្វើការប្រកាសទោសទេនោះ នឹងនាំឱ្យមានហានិភ័យដល់សង្គម ដោយសារអំពើខ្លះពិតជាមានផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់សង្គម ដូចជាបទឃាតកម្ម អំពើហិង្សា រំលោភហើយសម្លាប់ ដែលឃើញមាននៅក្នុងសង្គមយើងសព្វថ្ងៃ ហើយបទល្មើសដែលបានរៀបរាប់ខាងលើពិតជាមានសភាពធ្ងន់ធ្ងរ។ ប៉ុន្តែតុលាការប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់ តែពាក់កណ្ដាលតែប៉ុណ្ណោះ។ [69]

ដើម្បីយល់ឱ្យកាន់តែច្បាស់ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ខ្ញុំនឹងធ្វើការបែងចែកជា៣ចំណុចគឺ ១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ២. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស និង ៣. ការអនុវត្តទោសចំពោះអនីតិជន។

### ២.១.២.១.វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស

វិធានការអនុវត្តចំពោះអនីតិជនមានដូចជា វិធានការបង្វែរ និងវិធានការផ្សេងៗទៀតដែលកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ប៉ុន្តែវិធានការនេះមិនអាចអនុវត្តគ្រប់អនីតិជនទាំងអស់នោះទេ អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ តុលាការអាចធ្វើការប្រកាសទោសលើអនីតិជនបានដែរ។[70] ឧទាហរណ៍៖ ប្រសិនបើអនីតិជនម្នាក់មានអាយុ ១៦ឆ្នាំ បានប្រព្រឹត្តបទល្មើសឃាតកម្ម ដូច្នេះតុលាការនឹងធ្វើការប្រកាសទោសទៅលើអនីតិជនតាមច្បាប់កំណត់ បទឃាតកម្ម ដាក់ពន្ធនាគារ ១០ឆ្នាំ ទៅ ១៥ឆ្នាំ។ ប៉ុន្តែដោយសារតែអនីតិជន គេត្រូវបន្ធូរបន្ថយទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ពាក់កណ្ដាល។[71]

---

[68] មាត្រា ៣៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[69] មាត្រា ១៦០ កថាខណ្ឌទី៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[70] មាត្រា ៣៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[71] មាត្រា ១៦០ កថាខណ្ឌទី១ ចំណុច១ និង ចំណុច៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**២.១.២.១.១.វិធានការបង្វែរ**

អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានមួយ ឬ ច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃការត្រួត ពិនិត្យតាមផ្លូវតុលាការ ទៅសាលារៀនឲ្យបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ។

- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ។

- តម្រូវឲ្យចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងចិរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ។

- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមាន លក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជន មិនឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី។

- ឲ្យស្នាក់នៅទីកន្លែងណាមួយដោយកំណត់ពេលវេលាជាក់លាក់ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ។

- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ។

រាល់វិធានការបង្វែរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់។[72]

**២.១.២.១.២. វិធានការផ្សេងៗនៅក្រមព្រហ្មទណ្ឌ**

ដោយមានចែងក្នុងមាត្រា ៣៩ និងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ៖

១.ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនិងទំនុកចិត្ត។

២.ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣.ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤.ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។

៥.ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការកាពាររបស់តុលាការ។

---

[72] មាត្រា ៦៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

### ២.១.២.២.ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន

ដូចដែលបានជម្រាបជូនខាងលើរួចមកហើយនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំដល់ ក្រោម១៨ឆ្នាំ ទើបអាចឱ្យតុលាការសម្រេចធ្វើការប្រកាសទោសបាន ផ្អែកទៅលើកាលៈទេសៈ ស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជន។ ប៉ុន្តែចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំមិនត្រូវទទួលខុសត្រូវ ឬអនុវត្តទោសឡើយ ហើយអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ គឺត្រូវទៅអនុវត្តន៍វិធានការអប់រំ វិធានការតាមដាន វិធានការការពារ និងឧបត្ថម្ភ។

ទណ្ឌកម្មដែលអាចអនុវត្តចំពោះអនីតិជនវាពុំមានលក្ខណៈខុសប្លែកគ្នាខ្លាំងពីនីតិជននោះទេ។ ប្រភេទទណ្ឌកម្មដែលអាចអនុវត្តទៅលើអនីតិជនមានដូចជាៈ មូលទោស ទោសបន្ថែម និងទោសជំនួស។

**ក. មូលទោស**

ករណីដែលធ្វើការប្រកាសទោសទៅអនីតិជនជាប្រភេទមូលទោស ត្រូវមានស្ថានសម្រាលទោសជានិច្ច។ កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌលើនីតិជនអាយុចាប់ពី ១៤ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលប្រកាន់ត្រូវបន្ថយលក្ខខណ្ឌដូចតទៅៈ

១- អតិបរមានៃទោសដាក់ពន្ធនាគារ ទៅបន្ថយពាក់កណ្តាល។

២- ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារ គឺទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមានៃទោសត្រូវបន្ថយមកដាក់ពន្ធនាគារត្រូវ ២០ឆ្នាំ។

៣- អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានោះលើសពី ១ថ្ងៃ។

៤- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល [73]។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទបញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់ នៅតែជាបទល្មើសឧក្រិដ្ឋដដែល។ ឧទាហរណ៍ៈ អនីតិជនបានប្រព្រឹត្តបទល្មើស លួចដោយមានស្ថានទម្ងន់ទោស[74] ទោសដាក់ពន្ធនាគារពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ដូច្នេះដោយអនុលោមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ អតិបរមា និងអប្បបរមាត្រូវបន្ថយពាក់កណ្តាល អនីតិជននោះត្រូវទទួលទោសដាក់ពន្ធនាគារពី ១ឆ្នាំកន្លះ ទៅ ៥ឆ្នាំ តែទោសដែលគាត់ប្រព្រឹត្តនៅតែជាបទឧក្រិដ្ឋដដែល មិនមែនជាបទមជ្ឈិមទេ។

[73] មាត្រា ១៦០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[74] មាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**ខ. ទោសបន្ថែមដែលអាចដាក់លើអនីតិជន**

អនីតិជនក៏អាចទទួលខុសត្រូវទោសបន្ថែមដែរ ទោសបន្ថែមមានដូចជា ៖

១- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុមួយដែលបានប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។ ឧទាហរណ៍៖ ការរឹបអូសម៉ូតូ វត្ថុតាងផ្សេងៗ។

២- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។ ឧទាហរណ៍ លួចបានទូរស័ព្ទ និងកាបូបលុយ។

៣- ការរឹបផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅទីកន្លែងបទល្មើសត្រូវបានប្រព្រឹត្ត។

៥- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននៅអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[75]។

**គ. ទោសការងារសហគមន៍**

អនីតិជនដែលមានអាយុយ៉ាងតិច ១៦ឆ្នាំ និងថិរវេលានៃការងារមិនអាចលើសពី ១០០ម៉ោង ទើបអាចអនុវត្តលើអនីតិជនបាន។ ការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងការសម្រួលដល់ការបញ្ជូនខ្លួនទៅរស់នៅក្នុងសង្គមវិញ[76]។ ទោសមិនរាងចាល មិនអនុវតទៅលើអនីតិជនទេ។[77]

**២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

ជាទូទៅ ការទទួលខុសត្រូវព្រហ្មទណ្ឌរមែងអាចកើតមានតែសម្រាប់រូបវន្តបុគ្គលតែប៉ុណ្ណោះ ឬអាចនិយាយបានថា ទាល់តែមនុស្សទើបអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ប៉ុន្តែតាមពិតទៅ ក្រមព្រហ្មទណ្ឌក៏ទទួលស្គាល់ពីការទទួលខុសត្រូវរបស់នីតិបុគ្គលដែរ។ លើកលែងតែរដ្ឋចេញនីតិបុគ្គលអាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌបាន។ វាស្តែងចេញពីគោលការណ៍នៃភាពស្មើគ្នាចំពោះមុខច្បាប់។ គោលការណ៍នេះត្រូវបានសម្តែងឡើងនៅក្នុងមាត្រា ២ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ច្បាប់បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស។

ចំពោះពាក្យថា **នីតិបុគ្គល** គឺក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ចដោយឯករាជ្យ ឬក៏ជាអង្គភាពមួយដែលមិនមែនជាមនុស្ស ឬជាអង្គការមួយដែលច្បាប់ឱ្យនិយមន័យយ៉ាងច្បាស់ ហើយចាត់ទុកជាបុគ្គលសម្រាប់គោលបំណងនៃច្បាប់នោះតែប៉ុណ្ណោះ។ ក្នុងនោះដែរ នីតិបុគ្គលដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌចែកចេញជា២ (ពីរ) គឺ៖ នីតិបុគ្គលនៃនីតិឯកជន និងនីតិបុគ្គលនៃនីតិសាធារណៈ។

[75] មាត្រា ១៦១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[76] មាត្រា ១៦២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[77] មាត្រា ១៦៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**២.២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**

ទោះជាយ៉ាងណា ការទទួលខុសត្រូវរបស់រូបវន្តបុគ្គលមិនចោទជាចម្ងល់ទៀតឡើយ នាពេលបច្ចុប្បន្ននេះ។ លើសពីនេះ ការវិវត្តនៃច្បាប់ព្រហ្មទណ្ឌបានឈានដល់ដំណាក់កាលឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។ ស្របជាមួយគ្នានេះ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីលក្ខខណ្ឌទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងការអនុវត្តទោសទៅលើនីតិបុគ្គលផងដែរ។ នីតិបុគ្គលគ្រប់ប្រភេទសុទ្ធតែអាចទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែរដ្ឋដែលជានីតិបុគ្គលសាធារណៈ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ នីតិបុគ្គលអាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាណាមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតចែងទុកជាមុន។ នីតិបុគ្គលទទួលខុសត្រូវតែក្នុងករណីដែលបទល្មើសត្រូវបានប្រព្រឹត្តឡើង ដើម្បីជាប្រយោជន៍របស់នីតិបុគ្គល និងប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គលនោះ។

**២.២.១.១. អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត**

នីតិបុគ្គលមិនទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈទូទៅទេ នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌកាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងជាក់លាក់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសណាមួយជាកំណត់។

អាស្រ័យហេតុនេះចំពោះបទល្មើសអំពីបទឃាតកម្ម[78] ក្រមព្រហ្មទណ្ឌពុំមានចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលទេ មានន័យថានីតិបុគ្គលមិនអាចប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌពីបទឃាតកម្មបានឡើយ។

**២.២.១.២. បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល**

នីតិបុគ្គល គឺជាបុគ្គលដែលកើតឡើងដោយពីការសន្មតរបស់ច្បាប់។ នីតិបុគ្គលតែងតែមានអង្គការតំណាងដោយមានរូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងជារូបវន្តបុគ្គលដែលធ្វើសកម្មភាពតំណាងឱ្យនីតិបុគ្គលជានិច្ច។

អង្គភាពតំណាង ឬអ្នកតំណាងនៃនីតិបុគ្គល ឬអង្គការដែលច្បាប់ ឬលក្ខន្តិកៈផ្តល់នូវមុខងារជាអ្នកដឹកនាំគ្រប់គ្រង ហើយមាននីតិសម្បទាគ្រប់គ្រាន់ក្នុងការសម្រេចសេចក្តីដែលអាចធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវបាន ឬអាចនិយាយបានម្យ៉ាងទៀតថា ជាអង្គភាព ឬជាអ្នកតំណាងដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រព្រឹត្តអំពើណាមួយក្នុងនាមនីតិបុគ្គល។

អង្គភាពដែលតំណាងឱ្យនីតិបុគ្គលមានដូចជា ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាឃុំ សង្កាត់ជាដើម។

អ្នកតំណាងឱ្យនីតិបុគ្គលមានដូចជា ប្រធានសមាគម អភិបាល មេឃុំ ចៅសង្កាត់ជាដើម។

[78] មាត្រា ១៩៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**២.២.១.៣. ការប្រព្រឹត្តដើម្បីជាផលប្រយោជន៍ដល់នីតិបុគ្គល**

មានតែការប្រព្រឹត្តបទល្មើសដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលតែប៉ុណ្ណោះ ដែលជាកត្តាធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ប្រយោជន៍ សំដៅទៅលើប្រយោជន៍ខាងសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់លាស់ ឬគ្រាន់តែមានលក្ខណៈជាយថាហេតុក៏បានដែរ។

ឧទាហរណ៍៖ អភិបាលរបស់រោងចក្រមួយមិនបានចាត់វិធានការសន្តិសុខបានគ្រប់គ្រាន់ទៅតាមច្បាប់កំណត់ ដើម្បីធានានូវសុវត្ថិភាពដល់កម្មករនិយោជិតរបស់ក្រុមហ៊ុនទេ ដោយសារតែក្រុមហ៊ុនមិនចង់មានការចំណាយច្រើន។ អំពើនេះធ្វើឡើងដើម្បីផលប្រយោជន៍របស់នីតិបុគ្គល ហេតុដូច្នេះហើយ ប្រសិនបើការមិនបានចាត់វិធានការនោះ បានធ្វើឱ្យកម្មករនិយោជិតស្លាប់ដូច្នេះក្រុមហ៊ុននឹងត្រូវប្រកាសថា ទទួលខុសត្រូវព្រហ្មទណ្ឌពីបទមនុស្សឃាតដោយអចេតនា។

ដោយឡែក បទល្មើសដែលប្រព្រឹត្តដោយអ្នកតំណាងនីតិបុគ្គល ធ្វើឡើងក្នុងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អ្នកតំណាង មិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។

**២.២.២. ទណ្ឌកម្ម ឬទោសអនុវត្តចំពោះនីតិបុគ្គល**

ទោសមួយចំនួនអាចអនុវត្តបានចំពោះនីតិបុគ្គលដូចជា ទោសពិន័យជាប្រាក់ក្នុងនាមជាមូលទោស ឬការដកហូតសិទ្ធិសេរីភាពក្នុងនាមជាទោសបន្ថែម។[79] ទោសមួយចំនួនទៀត មិនអាចអនុវត្តចំពោះនីតិបុគ្គលបាននោះទេ ដូចជាទោសដាក់ពន្ធនាគារ ឬទោសការងារសហគមន៍។ នីតិបុគ្គលក៏អាចបានត្រូវរំលាយដោយតុលាការបានដែរ ដោយការប្រកាសសាលក្រម ឬសាលដីការបស់តុលាការ។ ដូចនេះយើងឃើញថា ទោសអនុវត្តចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលខុសគ្នាដោយយោងទៅតាមលក្ខណៈពិសេសរបស់នីតិបុគ្គល។[80] ប៉ុន្តែនីតិបុគ្គលសាធារណៈមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។

**២.២.២.១. មូលទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលទទួលរងនូវទោសពិន័យក្នុងឋានៈជាមូលទោស។ ទោសពិន័យក្នុងឋានៈជាមូលទោសនេះមិនមែនមានន័យថា រាល់បទល្មើសដែលចោទប្រកាន់លើនីតិបុគ្គលជាបទលហុនោះទេ។ បទល្មើសប្រព្រឹត្តដើម្បីជាប្រយោជន៍របស់នីតិបុគ្គលត្រូវចាត់ទុកជា បទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ វាអាស្រ័យទៅតាមទម្ងន់នៃបទល្មើសនីមួយៗដែលច្បាប់តម្រូវឱ្យនីតិបុគ្គលទទួលខុសត្រូវ បើទោះបីជាទោសដែលនីតិបុគ្គលត្រូវទទួលរងខុស

---

79 មាត្រា ១៦៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

80 មាត្រា ១៨២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

គ្នាអំពីទោសដែលរូបវន្តបុគ្គលត្រូវទទួលរងក៏ដោយ នេះក៏ដោយសារតែគោលការណ៍ឯកត្តកម្មនៃទោស។ ទោសបន្ថែមមួយ ឬច្រើនអាចត្រូវបានប្រកាសបន្ថែមលើមូលទោសដោយតុលាការ[81]។

មាត្រា ១៦៧ ដល់១៨២ ក្នុងជំពូកទី៧ មាតិកាទី៣ គន្ថីទី១ ក្រមព្រហ្មទណ្ឌ កំណត់អំពីរបបទូទៅនៃទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល។ ដូចនេះ មូលទោសដែលនីតិបុគ្គលត្រូវរងក្នុងគ្រប់បទល្មើស គឺទោសពិន័យជាប្រាក់ដូចគ្នា ដូចមានចែងក្នុងមាត្រា១៦៧ ចំណុចទី១។

**២.២.២.២. ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គល**

ទោសបន្ថែមដែលនីតិបុគ្គលត្រូវរងអាចខុសពីបទល្មើសមួយទៅបទល្មើសមួយទៀត អាស្រ័យទៅតាមភាពចាំបាច់ និងកាលៈទេសៈនៃបទល្មើសនីមួយៗ។ ទោសបន្ថែមជារួមដែលនីតិបុគ្គលត្រូវរងនោះ។ តែបញ្ញត្តិនេះបានអនុញ្ញាតឱ្យមានការបង្កើតទោសបន្ថែមដទៃទៀតបាន ដោយបញ្ញត្តិដោយឡែក។

ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមានដូចតទៅ៖[82]

- ការរំលាយចោល៖[83]

សេចក្តីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី។

- ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ៖[84]

ការដាក់ឱ្យនៅស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ឆ្នាំទេ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការ នាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម។ ជារៀងរាល់ ៦ខែយ៉ាងតិចអាណត្តិគាហកតុលាការធ្វើរបាយការណ៍ ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន។ ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការព្រះរាជ-អាជ្ញា អាចប្តឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុមេធាវីរបស់នីតិបុគ្គលនោះ។

- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន៖[85]

---

[81] មាត្រា ១៦៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[82] មាត្រា ១៦៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[83] មាត្រា ១៧០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[84] មាត្រា ១៧១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[85] មាត្រា ១៧២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់ចិរវេលា ៥ឆ្នាំយ៉ាងច្រើន។ តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់។

- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ៖[86]

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលនៅគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ៖

- រដ្ឋ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រឹះស្ថានសាធារណៈ
- សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទោសនេះ អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥ឆ្នាំ។

- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ៖[87]

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការដាក់ប្រាក់សន្សំ អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។ ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមូលបត្រ។ ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ចំពោះការផ្សាយជាសាធារណៈដែរ។

- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ៖[88]

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

- ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់៖

ចំពោះការហាមឃាត់ប្រើប្រាស់បណ្ណទូទាត់ក៏ដូចគ្នាដែរ។[89]

- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស៖[90]

---

[86] មាត្រា ១៧៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[87] មាត្រា ១៧៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[88] មាត្រា ១៧៥ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[89] មាត្រា ១៧៥ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[90] មាត្រា ១៧៦ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើង នៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។ ទោសនេះអាចជាស្ថានពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន។

- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជនៈ[91]

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬបណ្ដោះអាសន្នក្នុងរយៈពេល ៥ឆ្នាំយ៉ាងច្រើន។

- ការរឹបអូសៈ

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមៈ[92]

- ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។
- វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។ម្យ៉ាងទៀត កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទបញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត។ រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែង សម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ។ កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឱ្យបានទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃវត្ថុរឹបអូសនេះ។ តម្លៃនេះត្រូវបានកំណត់ដោយតុលាការ។ វិធានការដើម្បីផលប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ។[93]

- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសៈ[94]

---

[91] មាត្រា ១៧៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[92] មាត្រា ១៧៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[93] មាត្រា ១៧៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[94] មាត្រា ១៨០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ខែ។ ការបិទផ្សាយអាចទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេសធម្មតា។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស។ ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត។ សោហ៊ុយនៃការបិទផ្សាយនេះ ត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល។

- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍៖[95]
    - ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ។ ការផ្សាយនេះ មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេស។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស។
    - ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរតាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ។
    - បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន។[96]

[95] មាត្រា ១៨១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[96] មាត្រា ១៦៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

# ជំពូកទី២៖
# គោលការណ៍ឯកត្តកម្មនៃទោស

**"គោលការណ៍ឯកត្តកម្មនៃទោស"** គឺជាគោលការណ៍ថ្មីដែលទើបតែមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ហើយគោលការណ៍នេះជាគោលកាណ៍ដែលត្រូវគ្របដណ្តប់លើការប្រកាសទោសរបស់ ចៅក្រមជំនុំជម្រះ ដូច្នេះទាមទារឲ្យចៅក្រមត្រូវប្រកាន់ពីការអនុវត្តគោលការណ៍នេះឲ្យបានត្រឹមត្រូវ។ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ ចំពោះជនរងគ្រោះ ហៅថា គោលការណ៍ឯកត្តកម្មនៃទោស[97]។

ជាក់ស្តែង ច្បាប់ព្រហ្មទណ្ឌសម័យមុនៗ មិនបានចែងអំពីគោលការណ៍ឯកត្តកម្មនៃទោសឡើយ។ ប្រសិនបើគោលការណ៍នេះអវត្តមានក្នុងច្បាប់ព្រហ្មទណ្ឌសម័យមុនៗ សួរថាតើការសម្រេចប្រកាសទោសរបស់តុលាការនាសម័យនោះធ្វើឡើងយ៉ាងដូចម្តេច? ថ្វីបើច្បាប់ព្រហ្មទណ្ឌសម័យមុនរបស់ប្រទេសកម្ពុជា ពុំបានបញ្ញត្តគោលការណ៍ឯកត្តកម្មនៃទោសក៏ពិតមែន ក៏ប៉ុន្តែ គោលការណ៍នេះតែងតែបង្កប់ក្នុងផ្នត់គំនិតរបស់ចៅក្រមក្នុងការសម្រេចអំពីការប្រកាសទោស។ ទោះបីជា ច្បាប់ព្រហ្មទណ្ឌសម័យមុនមិនបានបញ្ញត្តិច្បាស់លាស់អំពីគោលការណ៍ឯកត្តកម្មនៃទោសក៏ពិតមែន ក៏ប៉ុន្តែ តាមរយៈការសិក្សាស្រាវជ្រាវរបស់ **សៀវភៅមាតកយុត្តិធម៌ខ្មែរ** បានបង្ហាញពី**គោលការណ៍សមទណ្ឌោ** តាមរយៈរឿងព្រេងបុរាណខ្មែរ ដែលបានរៀបរាប់អំពីគោល ការណ៍កាត់ក្តីរបស់ព្រះមហាក្សត្រ ឬចៅក្រមដែល **គោលការណ៍សមទណ្ឌោ** នេះត្រូវបានប្រសូតឡើងតាំងពីយូរយារណាស់មកហើយ។ **ពាក្យ "សមទណ្ឌោ"** នេះមានន័យថាជាការកាត់ទោស ឬការដាក់ទណ្ឌកម្មឲ្យសមតាមកំហុសដែលបានប្រព្រឹត្ត ឬដោយស្មើនឹងអំពើល្មើសដែលបានប្រព្រឹត្ត ដោយមិនមានភាពលំអៀងព្រោះអគតិដោយប្រការណាមួយឡើយ។ ឬនិយាយម្យ៉ាងទៀតបានថា ពាក្យ **"សមទណ្ឌោ"** គឺជាការកាត់ក្តីដាក់ទោសឲ្យវាសមស្របជាមួយនឹងទោសកំហុសដែលបានកសាង[98] ។ ចៅក្រមត្រូវប្រកាន់យក គោលការណ៍នេះក្នុងការដាក់ទណ្ឌកម្មដល់ពិរុទ្ធជន ដោយទណ្ឌកម្មនោះមិនធ្ងន់ពេកមិនស្រាលពេក ពោលគឺធ្វើយ៉ាងណាឲ្យទណ្ឌកម្មត្រូវសមស្របទៅតាមកំហុសដែលបានប្រព្រឹត្ត។ ក្រោយពីការលើកឡើងអំពី គោលការណ៍សមទណ្ឌោ ក្នុងសៀវភៅមាតកយុត្តិធម៌ខាងលើនេះ បានបង្ហាញឲ្យឃើញថាគោលការណ៍នេះគឺជាផ្នែកមួយនៃគោលការណ៍ឯកត្តកម្មនៃទោស ដែលមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន។

---

[97] មាត្រា ៩៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[98] ប្រសាសន៍របស់ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៅក្នុងកម្មវិធីប្រកាសដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ព្រះសីហនុ កាលពីថ្ងៃអង្គារ ទី១០ ខែវិច្ឆិកា ឆ្នាំ២០២០។

ហេតុដូច្នេះគោលការណ៍ឯកត្តកម្មនៃទោស ក៏មានសញ្ញាណតាំងពីបុរាណកាលមក ហើយក្រមព្រហ្មទណ្ឌបច្ចុប្បន្ននេះ បានបញ្ញត្តិអំពី គោលការណ៍ឯកត្តកម្មនៃទោស គឺស្របតាមអត្ថន័យនៃគោលការណ៍សមទណ្ឌោនេះដែរ។ គោលការណ៍ឯកត្តកម្មនៃទោស គ្របដណ្តប់លើការប្រកាសទោសរបស់ចៅក្រមដែលតម្រូវឲ្យចៅក្រមត្រូវពិចារណាឲ្យបានម៉ត់ចត់ទៅលើស្ថានភាពដែលជាកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងបុគ្គលិកលក្ខណៈរបស់ជនល្មើស ជាមុនសិន មុននឹងធ្វើការសម្រេចប្រកាសទោសរបស់ជនជាប់ចោទនោះ។ ពោលគឺតម្រូវឲ្យចៅក្រមសម្រេចផ្តន្ទាទោសឲ្យសមាមាត្រនឹងអំពើល្មើសនោះ។

ហេតុដូច្នេះហើយ ការសិក្សាអំពីគោលការណ៍ឯកត្តកម្មនៃទោសនេះមានសារៈប្រយោជន៍ដល់ចៅក្រមដែលជាអ្នកសម្រេចអំពីជោគវាសនារបស់ប្រជាជន។ ជាពិសេសគឺ ទាមទារឲ្យចៅក្រមនីមួយៗត្រូវស្វែងយល់ឲ្យបានច្បាស់លាស់អំពីមូលដ្ឋាននៃគោលការណ៍នេះដើម្បីជៀសវាងការកំណត់ទណ្ឌកម្ម ឬប្រកាសទោសមិនសមហេតុផល។ ចំណោទបញ្ហាគតិយុត្តិដែលតែងតែកើតមានចំពោះចំណុចនេះ គឺគេច្បាស់ជាលើកឡើងហើយថាតើអ្វីខ្លះគឺជាមូលដ្ឋាននៃគោលការណ៍ឯកត្តកម្មនៃទោស? និងតើផលវិបាកនៃការអនុវត្តគោលការណ៍នេះមានអ្វីខ្លះ?

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហានៃប្រធានបទខាងលើនេះ យើងខ្ញុំនឹងធ្វើការបកស្រាយដោយផ្អែកលើទ្រឹស្តី ផ្សាភ្ជាប់ជាមួយនឹងការអនុវត្តជាក់ស្តែងដែលមានក្នុងសាលក្រមព្រហ្មទណ្ឌរបស់តុលាការដែលជាការសម្រេចសេចក្តីអំពីការប្រកាសទោស។ ដូច្នេះ ជាបឋមគប្បីស្វែងយល់ពី មូលដ្ឋាននៃគោលការណ៍ឯកត្តកម្មនៃទោស ( ផ្នែកទី១) និងផលវិបាកនៃការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស (ផ្នែកទី ២)។

## ផ្នែកទី១៖ មូលដ្ឋានគតិយុត្តនៃគោលការណ៍ឯកត្តកម្មនៃទោស

អនុលោមតាមមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ មុននឹងធ្វើការសម្រេចអំពីការផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការចាំបាច់សិក្សាពីមូលហេតុ និងកត្តាជំរុញដែលនាំឱ្យមានបទល្មើស និងកិរិយាមាយាទក្រោយពេលប្រព្រឹត្តបទល្មើស ដោយគោរពភាពមិនរើសអើង និងស្មើភាពគ្នា ភាពសមាមាត្រនៃទោស និងគោលការណ៍ដោយឡែកដោយផ្អែកលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។ ផ្ទុយទៅវិញ បើការប្រកាសទោសពុំបានឆ្លងកាត់ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការជំនុំជម្រះលើទោសនឹងនាំឱ្យមានភាពលម្អៀង និងអយុត្តិធម៌។

### ១. ភាពមិនរើសអើង និងស្មើភាពគ្នា

រាល់ការសម្រេចប្រកាសទោសរបស់តុលាការចំពោះជនល្មើស ត្រូវធ្វើឡើងដោយគោរពនូវគោលការណ៍ឯកត្តកម្មនៃទោស ដែលតម្រូវឲ្យតុលាការពិចារណាទៅលើបុគ្គលិកលក្ខណៈ របស់ជនជាប់ចោទ និងកាលៈទេសៈ

នៃការប្រព្រឹត្តបទល្មើស[99] ។ ហេតុដូច្នេះ តុលាការត្រូវធ្វើការប្រកាសទោសដោយផ្អែកទៅលើស្ថានភាព និងបុគ្គលដែលប្រព្រឹត្តល្មើស ហើយការប្រកាសទោសមិនត្រូវធ្វើឡើងដោយមានភាពរើសអើងចំពោះបុគ្គលដែលជាជនជាប់ចោទម្នាក់ណាឡើយ ស្របទៅនឹងគោលការណ៍សន្មតជាមុនថាគ្មានទោស ហើយគោលការណ៍នេះក៏មានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញផងដែរថាៈ ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ[100] ។ ពោលគឺចៅក្រមត្រូវសម្រេចអំពីអត្រានៃទោសលើជនជាប់ចោទដោយឈរលើមូលដ្ឋាននៃភាពស្មើគ្នា ដោយមិនត្រូវប្រកាន់លើពូជសាសន៍ ជំនឿ ភាសា ភេទ ពណ៌សម្បុល ឋានៈធនធាន ឬ ធនធានរបស់ជនជាប់ចោទឡើយ[101] ។ មានន័យថា ជនជាប់ចោទនីមួយៗមានសិទ្ធិស្មើគ្នាក្នុងការទទួលយកយុត្តិធម៌ ដោយមិនត្រូវបានទទួលរងនូវការរើសអើងពីតុលាការឡើយ ដូច្នេះតុលាការ ត្រូវធ្វើការសម្រេចសេចក្តីដោយពិចារណាទៅលើ កាលៈទេសៈនៃអំពើល្មើស និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទព្រមទាំងការប្រកាសទោសត្រូវតែមានសមភាពនៃទោសរវាងជនជាប់ចោទនីមួយៗដោយយុត្តិធម៌។ ចៅក្រមត្រូវបំពេញភារកិច្ចជម្រះក្តី ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ ហេតុដូច្នេះ មុននឹងធ្វើការសម្រេចប្រកាសអំពីទោស ចាំបាច់ចៅក្រមត្រូវពិនិត្យឲ្យបានសព្វគ្រប់ និងប្រើប្រាស់សម្បជញ្ញៈរបស់ខ្លួនមកវិភាគដោយគោរពនូវ **គោលការណ៍ឯកត្តកម្មនៃទោស**។

ឧទាហរណ៍ទី១ ៖ ជនជាតិចិនឈ្មោះ ក ជាសង្សារជាមួយនារីឈ្មោះ ខ ដែលមានអាយុ ១៤ឆ្នាំ។ អ្នកទាំងពីរបានរស់នៅជាមួយគ្នាដូចប្តីប្រពន្ធទៅហើយ ប៉ុន្តែឪពុកម្តាយ ខាងនារីឈ្មោះ ខ មិនពេញចិត្តជាមួយបុរសជនជាតិចិន នោះទេ។ បន្ទាប់មក ក៏បានឲ្យកូនស្រីខ្លួនដាក់ពាក្យបណ្តឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ឲ្យចាប់ខ្លួនបុរសជនជាតិចិនម្នាក់នោះ ហើយបញ្ជូនមកដល់ដំណាក់កាលជំនុំជម្រះ នារី ខ ក៏បានឆ្លើយសុំដកពាក្យបណ្តឹងវិញ នៅចំពោះមុខចៅក្រមជំនុំជម្រះ ដោយសំអាងថាខ្លួនព្រមព្រៀងគ្នានោះទេ ហើយការដាក់ពាក្យបណ្តឹងនេះកើតឡើងដោយសារការបង្ខិតបង្ខំពីឪពុកម្តាយខ្លួនប៉ុណ្ណោះ។ ករណីនេះ បើអនុលោមតាមមាត្រា ២៣៩ បុរសជនជាតិចិនត្រូវបានចោទប្រកាន់ពីបទល្មើស រំលោភសេពសន្ថវៈ ពីព្រោះទោះបី ជាការរួមសមគ្គសង្វាសជាមួយគ្នាដោយការព្រមព្រៀងក៏ដោយ ប៉ុន្តែនារីរងគ្រោះមានអាយុទើបតែ ១៤ឆ្នាំ ពុំទាន់ដល់នីតិភាព

[99] មាត្រា ៩៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[100] មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[101] មាត្រា ២ នៃមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត និងប្រកាសសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ និងមាត្រា ៣១ កថាខណ្ឌទី២ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ក្នុងការរួមភេទនោះទេ[102] ។ ដូច្នេះ បុរសជនជាតិចិននោះ នៅតែត្រូវបានតុលាការផ្តន្ទាទោសពីបទ រំលោភសេពសន្ថវៈ ចន្លោះពី ៥ឆ្នាំ ទៅ ១០ឆ្នាំ[103] ។

ឧទាហរណ៍ទី២ ៖ សម្មតិកម្មដដែល ជនជាតខ្មែរឈ្មោះ ក ជាសង្សារជាមួយនារីឈ្មោះ ខ ដែលមានអាយុ ១៤ឆ្នាំ។ អ្នកទាំងពីរបានរស់នៅជាមួយគ្នាដូចប្តីប្រពន្ធទៅហើយ ប៉ុន្តែឪពុកម្តាយខាងនារីឈ្មោះ ខ មិនពេញចិត្តជាមួយលោក ក នោះទេ។ បន្ទាប់មក ក៏បានឲ្យកូនស្រីខ្លួនដាក់ពាក្យបណ្តឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ឲ្យចាប់ខ្លួនលោក ក ។ បន្ទាប់ពីដាក់ពាក្យបណ្តឹងរួចមន្ត្រីនគរបាលយុត្តិធម៌ ក៏បានចាប់ខ្លួនលោក ក បានបញ្ជូនមកដល់ដំណាក់កាលជំនុំជម្រះ នារី ខ ក៏បានឆ្លើយសុំដកពាក្យបណ្តឹងវិញ នៅចំពោះមុខចៅក្រមជំនុំជម្រះ ដោយសំអាងថាខ្លួនព្រមព្រៀងគ្នានោះទេ ហើយការដាក់ពាក្យបណ្តឹងនេះកើតឡើងដោយសារការបង្ខិតបង្ខំពីឪពុកម្តាយខ្លួនប៉ុណ្ណោះ ពេលនោះតុលាការ បានដោះលែងលោក ក វិញបាត់ទៅ។ ករណីនេះបើអនុលោមតាមមាត្រា ២៣៩ លោក ក ត្រូវផ្តន្ទាទោសដូចបុរសជនជាតិចិនខាងលើដែរ ប៉ុន្តែដោយសារការយោគយល់គ្នា។ យើងដឹងហើយថាជនជាតិខ្មែរយើងពាក់ព័ន្ធនឹងរឿងមនោសញ្ចេតនាគឺខ្លាំងក្លាមែនទែន ដោយឃើញបែបនេះតុលាការក៏បានដោះលែងលោក ក វិញបាត់ទៅ។ ករណីនេះគឺមិនអាចប្រកាសបែបនេះបាននោះទេ វាផ្ទុយទៅនឹងគោលការណ៍ឯកត្តកម្មនៃទោស ដែលមានកំណត់ក្នុងក្រមព្រហ្មទណ្ឌ។

## ២. ភាពសមាមាត្រនៃទោស

ភាពសមាមាត្រនៃទោស គឺសំដៅលើការប្រកាសទោសត្រូវធ្វើឡើងដោយកំណត់អំពីកម្រិតនៃទោសឲ្យសមាមាត្រនឹងអំពើល្មើស ក៏ប៉ុន្តែក៏ត្រូវពិចារណាអំពីស្ថានភាព និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទនោះផងដែរ។ តុលាការត្រូវធ្វើការប្រកាសទោសនោះឲ្យសមាមាត្រនឹងអំពើដែលជនជាប់ចោទបានប្រព្រឹត្តព្រមជាមួយគ្នានេះដែរ តុលាការនឹងជ្រើសរើសរបបនៃការប្រកាសទោសណាមួយដែលមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ដើម្បីយកមកអនុវត្តចំពោះជនជាប់ចោទ។ ហេតុដូច្នេះ តុលាការនឹងជ្រើសរើសរបបអនុវត្តទោសណាមួយដែលសាកសមនឹងស្ថានភាព និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ នៅពេលដែលតុលាការធ្វើការប្រកាសទោសនោះ។

ឧទាហរណ៍៖ យោងតាមឧទាហរណ៍ខាងលើអម្បាលមិញនេះ យើងឃើញថា លោក ក និងនារី ខ បានរួមរស់ជាមួយគ្នាសុខសាន្តទេ ប៉ុន្តែដោយសារកត្តាខាងក្រៅទើបធ្វើឲ្យនារីម្នាក់ប្តឹងលោក ក ចំពោះករណីនេះនៅក្នុងដំណាក់កាលជំនុំជម្រះកាលណា នារី ខ បានឆ្លើយសុំដកពាក្យបណ្តឹងវិញ នៅចំពោះមុខចៅក្រមជំនុំជម្រះដោយសំអាងថាខ្លួនព្រមព្រៀងគ្នានោះទេ ហើយការដាក់ពាក្យបណ្តឹងនេះកើតឡើងដោយសារការបង្ខិតបង្ខំពីឪពុកម្តាយខ្លួនប៉ុណ្ណោះ បូករួមនឹងការសុំអង្វរពីនារី ខ ទៀតនោះ តុលាការត្រូវពិចារណាថាគួរប្រកាសទោស

[102] មាត្រា ២៣៩ កថាខណ្ឌទី៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[103] មាត្រា ២៣៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ឬអត់? ចុះបើប្រកាសហើយ នារី ខ នឹងមានឈ្មោះថាជាស្ត្រីមេម៉ាយចាយមាត់ញាតិ មួយទៀតអាចប៉ះពាល់ដល់មនោសញ្ចេតនា រវាងលោក ក និងនារី ខ ទៀត ដូច្នេះឃើញថាព្យសនៈកម្មធំគ្រាន់បើដែរ ដូចនេះតុលាការមានយន្តការផ្សេងក្រៅពីឲ្យជាប់គុគ គឺអាចប្រកាសព្យួរទោសលើលោក ក បាន។

**៣. គោលការណ៍ដោយឡែកដោយផ្អែកលើបុគ្គលនីមួយៗ**

គោលការណ៍ដោយឡែកដោយផ្អែកលើបុគ្គលនីមួយៗ គឺជាគោលការណ៍ដែលតុលាការ ចាំបាច់ត្រូវធ្វើការពិនិត្យ និងពិចារណាឲ្យបានល្អិតល្អន់ ដែលគោលការណ៍នេះសិក្សាស៊ីជម្រៅទៅលើបុគ្គលដែលប្រព្រឹត្តល្មើសនោះថា តើមានមូលហេតុអ្វីខ្លះបានជាជននោះប្រព្រឹត្តបទល្មើស។ ហេតុដូច្នេះ តុលាការត្រូវធ្វើការសិក្សាបុគ្គលិកលក្ខណៈរបស់ជននោះទាំង**មុនពេលដែលប្រព្រឹត្តបទល្មើស** និង **ក្រោយពេលដែលប្រព្រឹត្តបទល្មើស**។

ជាពិសេស តុលាការត្រូវពិនិត្យលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសដែលជាចំណុចចម្បងក្នុងការសម្រេចសេចក្តីអំពីទោស ដោយហេតុថាកាលៈទេសៈនៃបទល្មើសនេះអាចបង្កើតជាស្ថានទម្ងន់ ឬស្ថានសម្រាលនៃបទល្មើស[104] ។

**៣.១ បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ**

បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ គឺជាការស្វែងយល់ពីលក្ខណៈផ្ទាល់ខ្លួនដែលជាអត្តចរិក និងឥរិយាបថពិសេសរបស់ជនជាប់ចោទនោះ ហើយបុគ្គលិកលក្ខណៈនេះអាចមានការប្រែប្រួលទៅតាមពេលវេលាមានន័យថាមុនពេលដែលប្រព្រឹត្តបទល្មើស និងក្រោយពេលដែលប្រព្រឹត្តបទល្មើស មានលក្ខណៈមិនដូចគ្នាឡើយ។ ម្យ៉ាងទៀត កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស គឺសំដៅពីសកម្មភាពដែលជននោះប្រព្រឹត្តបទល្មើសថាតើសកម្មភាពប្រព្រឹត្តបទល្មើសនោះមានលក្ខណៈធ្ងន់ធ្ងរយ៉ាងដូចម្តេច។

**៣.១.១ មុនពេលប្រព្រឹត្តបទល្មើស**

តុលាការគឺជាអ្នកសម្រេចសេចក្តីលើការផ្តន្ទាទោសចំពោះជនជាប់ចោទ ដូច្នេះសេចក្តីសម្រេចអំពីការផ្តន្ទាទោសនោះមានសារៈសំខាន់ដែលទាមទារឲ្យតុលាការត្រូវធ្វើការពិចារណា និងសិក្សាអំពីចរិតលក្ខណៈរបស់ជនជាប់ចោទ មុននឹងធ្វើការសម្រេចផ្តន្ទាទោស។ ដើម្បីសិក្សាពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទមុនពេលប្រព្រឹត្តបទល្មើស គប្បីដឹងអំពីការរស់នៅរបស់ជនល្មើសនៅក្នុងសង្គម ព្រមទាំងទំនាក់ទំនងរបស់ពួកគេជាមួយមជ្ឈដ្ឋានខាងក្រៅ ដែលវាអាចនាំឲ្យតុលាការដឹងអំពីកត្តាដែលបណ្តាលឲ្យជននោះឈានមកដល់ដំណាក់កាលប្រព្រឹត្តបទល្មើស ថាតើមានមូលហេតុ ឬកត្តាអ្វីខ្លះដែលជំរុញឲ្យជននោះប្រព្រឹត្តបទល្មើស។

ការកំណត់អត្តចរិតរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើស ក៏ជាផ្នែកមួយដែលទាមទារឲ្យតុលាការពិចារណាមុននឹងធ្វើការសម្រេចសេចក្តីលើការផ្តន្ទាទោសផងដែរ។

---

[104] មាត្រា ៤៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

### ៣.១.១.១ ការរស់នៅរបស់ជនល្មើស

ជាទូទៅជនល្មើសកើតមានឡើងគ្រប់ស្រទាប់វណ្ណៈ មិនថាបុគ្គលដែលស្ថិតក្នុងគ្រួសារអ្នកមាន ឬបុគ្គលដែលស្ថិតក្នុងគ្រួសារក្រីក្រ ឬបុគ្គលដែលមានចំណេះដឹងខ្ពង់ខ្ពស់ ឬបុគ្គលដែលជាអនក្ខរជននោះទេ គឺសុទ្ធតែអាចក្លាយជាជនល្មើសបានគ្រប់ពេលវេលា។ ដើម្បីអាចក្លាយជាជនល្មើសក៏អាស្រ័យទៅលើការរស់នៅរបស់ជននោះពោលគឺបែបបទក្នុងការរស់នៅ ព្រមទាំង បញ្ហាជីវភាព និងគ្រួសាររបស់ជនល្មើសនោះផងដែរ។ កត្តារស់នៅរបស់ជនល្មើស គឺជាផ្នែកមួយដ៏សំខាន់ដែលវាអាចជាចំណុចដែលផ្ដើមឲ្យជននោះសម្រេចចិត្តធ្វើជាជនល្មើស មូលហេតុ ដែលជំរុញឲ្យជននោះប្រព្រឹត្តល្មើស។ ក៏ប៉ុន្តែតាមទស្សនៈមតិភាគច្រើនតែងតែយល់ថា បុគ្គលដែលមានជីវភាពក្រីក្រ និងមិនសូវមានចំណេះដឹង ងាយនឹងក្លាយជាជនល្មើស ដោយហេតុថា ពួកគេមិនសូវជាគិតគូរបានច្រើនចំពោះផលវិបាកនៃអំពើល្មើសរបស់ពួកគេ និងពិចារណាអំពីលទ្ធផលដែលពួកគេបានប្រព្រឹត្តនោះឡើយ។ ជនល្មើសរស់នៅដោយស្ថិតក្នុងមជ្ឈដ្ឋានសង្គមមាន ០២(ពីរ) គឺ៖ មជ្ឈដ្ឋានសង្គមទូទៅ(ខាងក្រៅ) និងមជ្ឈដ្ឋានផ្ទាល់ខ្លួន(គ្រួសារ)[105]

#### ក. មជ្ឈដ្ឋានសង្គមទូទៅ

មជ្ឈដ្ឋាន គឺជាបរិស្ថានជុំវិញដែលបុគ្គលស្ថិតនៅ។ មជ្ឈដ្ឋានអាចមានការប្រែប្រួលទៅតាមពេលវេលា និងទីកន្លែង។ មជ្ឈដ្ឋានសង្គម គឺសំដៅដល់បរិស្ថានដែលស្ថិតនៅជុំវិញ ដែលជាការទំនាក់ទំនងរបស់មនុស្សជាមួយនឹងសង្គម មានដូចជានយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ជាដើម។ ការចូលរួមសកម្មភាពក្នុងសង្គមក៏ត្រូវរាប់បញ្ចូលជាការទំនាក់ទំនងសង្គមខាងក្រៅរបស់ជនល្មើសផងដែរ។ ដើម្បីកំណត់អំពីបុគ្គលិកលក្ខណៈក្នុងការរស់នៅរបស់ជនល្មើស ត្រូវធ្វើការកត់សម្គាល់អំពីទំនាក់ទំនងរបស់ជនល្មើសជាមួយមជ្ឈដ្ឋានខាងក្រៅ ដែលអាចឲ្យដឹងថាអត្តចរិតរបស់ជនល្មើសប្រែប្រួលបែបណាខ្លះក្នុងអំឡុងពេលមានទំនាក់ទំនងជាមួយអ្នកដទៃ។

#### ខ. មជ្ឈដ្ឋានផ្ទាល់ខ្លួន

មជ្ឈដ្ឋានផ្ទាល់ខ្លួន មិនមែនសំដៅលើកត្តាក្នុងខ្លួនរបស់ជនល្មើសតែម្យ៉ាងនោះទេ ពោលគឺសំដៅដល់កត្តាគ្រួសាររបស់ជនល្មើសផងដែរ។ គ្រួសារគឺជាចំណែកមួយដ៏សំខាន់ក្នុងជីវិតរស់នៅ មានន័យថាប្រសិនបើក្មេងម្នាក់រស់នៅក្នុងក្រុមគ្រួសារមួយដែលពេញលេញ និងមានភាពកក់ក្ដៅ នោះភាគរយនៃពួកគេអាចក្លាយជាបុគ្គលម្នាក់ដែលអាចសម្របសម្រួលជាមួយសង្គមបានដោយងាយស្រួល។ ផ្ទុយទៅវិញ ប្រសិនបើក្មេងម្នាក់នោះរស់នៅក្នុងស្ថានភាពដែលលំបាក ហើយខ្វះភាពកក់ក្ដៅពីឪពុកម្ដាយ ឬក្រុមគ្រួសាររបស់ពួកគេ នោះភាគរយនៃពួកគេនឹងពិបាកសម្របខ្លួន ក្នុងការរស់នៅជាមួយសង្គមខាងក ព្រមទាំងអាចឈានដល់ការប្រព្រឹត្តបទល្មើសដើម្បីបំពេញនូវតម្រូវការរបស់ខ្លួន។

---

[105] មេរៀនឧក្រិដ្ឋវិទ្យា របស់លោកសាស្ត្រាចារ្យ សាន់ វ៉ាដា។

- **កត្តាក្នុងខ្លួន៖** មូលហេតុដែលបណ្ដាលឲ្យបុគ្គលម្នាក់ក្លាយជាជនល្មើស គឺ អាចកើតចេញពីកត្តាក្នុងខ្លួនរបស់ជននោះផ្ទាល់តែម្ដង។ កត្តាក្នុងខ្លួននេះ គឺសំដៅដល់ភាពស្រួយស្រាវនៃសរីរាង្គខាងក្នុងរបស់បុគ្គល ពោលគឺអាចបណ្ដាលមកពីប្រវត្តិរបស់គេពីកំណើត ឬ ក្រោយពេលកើត ដែលចូលរួមក្នុងការបង្កើតនូវបុគ្គលភាពរបស់ជនល្មើស។

ប្រសិនបើការលូតលាស់មុនកំណើតមិនមានភាពប្រក្រតី ដែលវាអាចបណ្ដាលឲ្យមានបញ្ហាខាងបញ្ញា ឬអាកប្បកិរិយា និងបង្កើតក្រូមូសូមខុសប្លែកពីគេ ឬប្រសិនបើមានភាពអាក់អួលនៅពេលសម្រាលបុត្រ ដែលជាហេតុផលមួយអាចនាំឲ្យមានបញ្ហាខាងប្រព័ន្ធសសៃប្រសាទ ឬប្រសិនបើមានការឆ្លងជម្ងឺដែលបណ្ដាលឲ្យរំខានដល់ប្រព័ន្ធខួរក្បាលការប្រែប្រួលបណ្ដាលមកពីការសេពសុរា ឬសិក្សាក្នុងស្ថានភាពគ្រោះថ្នាក់ច្រើនពេក ជាពិសេសនៅពេលពេញវ័យ។ មានន័យថា ជម្ងឺដែលកើតឡើង អាចបង្កឲ្យមានភាពពិការ ឬកាត់បន្ថយសមត្ថភាពធ្វើការនាំឲ្យក្លាយជាជនឥតមានការងារធ្វើ។ កត្តាខាងលើនេះ មិនមែនជាកត្តាដែលជំរុញឲ្យមានអំពើ ល្មើសដោយផ្ទាល់នោះទេ តែវាជាកត្តាដែលចូលរួមក្នុងការកាត់បន្ថយនូវតុល្យភាពផ្នែកចិត្តសាស្ត្រ និងធ្វើឲ្យមានភាពស្រួយស្រាវនៃសរីរាង្គខាងក្នុងរបស់បុគ្គលធ្វើឲ្យជននោះងាយទទួលរងឥទ្ធិពលពីខាងក្រៅ និងជំរុញឲ្យប្រព្រឹត្តអំពើល្មើស។

ឧទាហរណ៍៖ បុរសម្នាក់ឈ្មោះ បុត្រ គាត់មានជម្ងឺប្រចាំកាយរបស់គាត់ដែលជាទូទៅយើងហៅវាថាជាជម្ងឺឆ្កួតជ្រូក(ម្ដងអាចយល់ដឹង/មិនយល់ដឹងពីសកម្មភាពរបស់ខ្លួន) បានទៅរំលោភ នារីម្នាក់ឈ្មោះ ថារី ក្នុងពេលដែលខ្លួនបាត់បង់ស្មារតីពុំអាចយល់ដឹងពីសកម្មភាព ឬអំពើរបស់ខ្លួនបាន។ ចំណុចនេះ ជាសំណួរសួរថា ដាក់ទោសទៅលើបុរសឈ្មោះ បុត្រ នោះបានដែរឬទេ? ជាការឆ្លើយតប គឺអាចដាក់ទោសបាន ប៉ុន្តែតុលាការត្រូវគិតគូរពិចារណាផ្ដល់ស្ថានសម្រាលទោសជូនគាត់ដោយសារការប្រព្រឹត្តបទល្មើសនេះឡើងគឺនៅពេលដែលគាត់បាត់បង់ស្មារតីទៅហើយ ដែលជាគោលការណ៍ពុំមានបទល្មើសនោះទេ ប្រសិនបើមគ្មានចេតនាប្រព្រឹត្ត[106] ។

- **កត្តាគ្រួសារ៖** គ្រួសារមាននាទីសំខាន់ណាស់ ក្នុងការបង្កើតបុគ្គលភាពរបស់មនុស្ស ហើយការជះឥទ្ធិពលនៃគ្រួសារទៅលើការបង្កើតបុគ្គលភាពរបស់ជនល្មើស អាចស្ដែងឡើងដោយផ្ទាល់ ឬមិនផ្ទាល់។

  + ឥទ្ធិពលដោយផ្ទាល់ គឺវាស្ដែងឡើងតាមការធ្វើត្រាប់តាមឪពុកម្ដាយរបស់ខ្លួន ដែលប្រកាន់របៀបរស់នៅជាជនល្មើស និងតាមរយៈការសិក្សារៀនសូត្រពីអំពើហិង្សាក្នុងគ្រួសារ ដែលអាចធ្វើឲ្យគេក្លាយទៅជាជនកាចសាហាវ។

[106] មាត្រា ៤ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ឧទាហរណ៍៖ ក្មេងប្រុសម្នាក់ឈ្មោះ ណាដេត មានអាយុ១៧ឆ្នាំ រស់នៅក្នុងក្រុមគ្រួសារដែលខ្វះខាត ឪពុកគិតតែពីស្រីញីអូនបង មិនរកស៊ី ម្តាយវិញ គិតតែពីលេងល្បែងពាលា មិនគិតគូរពីជីវិតកូន នៅពេលកូនទៅរៀនតែងតែវាយដំ មិនកូនទៅរៀននោះទេ។ ជារៀងរាល់ថ្ងៃ ឪពុកម្តាយ ណាដេត នៅពេលដែលឃើញមុខគ្នាគឺតែងតែជេរប្រមាថ និងវាយដំគ្នា ផ្អើលភូមិ២ ទៅ៣ភូមិ។ ថ្ងៃមួយ ពេល ណាដេត បានលួចម្តាយទៅរៀននៅសាលា ស្រាប់តែមានក្មេងប្រុសម្នាក់ទៀតបានមកនិយាយឌឺដង ណាដេត ពីឪពុកម្តាយគាត់។ ភ្លាមៗនោះ ណាដេត ខឹងពេកក៏បានទាញដំបងយកសំពងក្បាលក្មេងប្រុសម្នាក់នោះបែបឈាម។ ក្នុងករណីនេះ ណាដេត បានប្រព្រឹត្តបទល្មើសដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ គឺបទ ហិង្សាដោយចេតនាដោយស្ថានទម្ងន់ទោស ត្រូវផ្តន្ទាទោសពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លានរៀល ទៅ ១០លានរៀល[107]។ ប៉ុន្តែដោយសារ ណាដេត ជាអនីតិជននៅឡើយដូច្នេះត្រូវអនុលោមតាមបទបញ្ញត្តិស្តីពីមូលទោសដែលត្រូវអនុវត្តចំពោះអនីតិជន បន្ថយពាក់កណ្តាលនីសល់ ១ឆ្នាំ ទៅ ២ឆ្នាំ៦ខែ និងពិន័យប្រាក់ពី ២លានរៀល ទៅ ៥លានរៀល[108] ។

+ ឥទ្ធិពលមិនផ្ទាល់ សំដៅដល់ជនល្មើសដែលបានទទួលរងនូវការអប់រំប្រឆាំងទៅនឹងសង្គមពីសំណាក់គ្រួសាររបស់ពួកគេ។ ដូច្នេះ ឪពុកម្តាយមានតួនាទីសំខាន់ណាស់ ក្នុងការបង្កើតនូវសតិសម្បជញ្ញៈរបស់កូន និងក្នុងការបង្កើនភាពកក់ក្តៅដល់កូន។ បើពុំនោះទេកូននឹងអាចធ្លាក់ចូលក្នុងអំពើល្មើស។ ស្ថានភាពអវិជ្ជមានក្នុងគ្រួសារដូចជា៖ ការបោះបង់កូនចេញចោល ឬខ្វះការមើលថែ, ការយកកូនចេញពីម្តាយ,អវត្តមានរបស់ឪពុក,ភាពមិនចុះសម្រុងគ្នារបស់ឪពុកម្តាយ,ភាពធូររលុងរបស់ឪពុកម្តាយ, ការលែងលះគ្នា ជាដើម។ល។ ម្យ៉ាងវិញទៀត មជ្ឈដ្ឋានស្នាក់នៅ និងអ្នកជិតខាង ក៏ជាផ្នែកមួយនៃឥទ្ធិពលមិនផ្ទាល់ មានន័យថា ក្មេងរស់នៅក្នុងអាគាររួមប្រព្រឹត្តអំពើល្មើសច្រើនជាងក្មេងដែលរស់នៅក្នុងផ្ទះដាច់ដោយឡែកពីគេ។ បញ្ហានេះបណ្តាលមកពីការប្រកាន់យករបៀបរស់នៅក្នុងអាគាររួមរបស់ពួកក្មេងៗ។ ស្ថានភាពខាងលើនេះហើយ ដែលជាកត្តាជំរុញឲ្យកូនៗទាំងនោះងាយនឹងអាចចូលរួមប្រព្រឹត្តបទល្មើស។

ឧទាហរណ៍៖ បូរ៉ា មានអាយុ១០ឆ្នាំ ជាអ្នករស់នៅខេត្តស្វាយរៀង ត្រូវបានម្តាយរបស់ខ្លួនយកទៅទុកនៅកន្លែងកុមារកំព្រាមួយកន្លែងនៅទីក្រុងភ្នំពេញ។ ប៉ុន្តែជាក់ស្តែង កន្លែងនោះពុំមែនជាទីតាំងកុមារកំព្រានោះទេ ជាកន្លែងដែលគេយកក្មេងៗមកហើយដើម្បីយកទៅប្រើដើម្បីជាប្រយោជន៍ឯកជននោះទេ ដោយស៊ូនឹងភាពលំបាកមិនបាន បូរ៉ា ក៏បានរត់ចេញពីទីនោះ ក្លាយជាក្មេងតែលតោលគ្មានផ្ទះសម្បែង គេងតាមផ្លូវជាដើម ថ្ងៃមួយដោយសារតែភាពឃ្លានខ្លាំងពេក បូរ៉ា បានលួចចូលទៅក្នុងផ្ទះរបស់គេក្នុងបំណងលួចរបស់របរដែល

[107] មាត្រា ២១៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[108] មាត្រា ១៦០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

អាចយកមកលក់ហើយយកលុយទិញបាយហូប។ អំពើរបស់ បូរ៉ា ជាបទល្មើសព្រហ្មទណ្ឌ ស្ថិតនៅគន្លឹទី៣ បទលួច[109] ។

### គ. ការទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ

ការទំនាក់ទំនងជាមួយនឹងមជ្ឈដ្ឋានខាងក្រៅ ក៏ជាកត្តាមួយដែលរួមចំណែកនាំឲ្យបុគ្គលម្នាក់សម្រេចចិត្តប្រព្រឹត្តបទល្មើសផងដែរ។ ទំនាក់ទំនងជាមួយនឹងមជ្ឈដ្ឋានខាងក្រៅ សំដៅដល់ការរាប់អានមនុស្សក្នុងសង្គមដូចជា ការសេពគប់មិត្តភក្តិ ការរាប់រកអ្នកជិតខាង និងរាល់ទំនាក់ ទំនងជាមួយអ្នកដទៃ។ ហេតុនេះហើយ ការសេពគប់មិត្តភក្តិ គឺជាមូលហេតុចម្បងដែលនាំឲ្យកើតមានបទល្មើសផងដែរ ជាពិសេសគឺក្មេងជំទង់។ មានន័យថា បុគ្គលដែលនៅសភាពវ័យក្មេង ងាយនឹងជឿ និងចង់សាកល្បងនូវអ្វីដែលពួកគេមិនធ្លាប់បានជួប មិនដែលបានដឹកពីមុនមកដូចជា ការប្រើប្រាស់គ្រឿងញៀន អំពើលួច និងហិង្សាជាដើម។ បទល្មើសដែលប្រព្រឹត្តដោយក្មេងជំទង់ ភាគច្រើន ដោយសារតែការរាប់អានមិត្តភក្តិដែលជាជនខិលខូចដូចជា អ្នកប្រើប្រាស់គ្រឿងញៀន ឬ អ្នកប្រព្រឹត្តអំពើលួចជាដើម។ ផ្ទុយទៅវិញ ប្រសិនបើក្មេងនោះរាប់អានមនុស្សដែលប្រព្រឹត្តអំពើល្អ នោះក្មេងនោះនឹងមិនប្រព្រឹត្តអំពើដែលមិនត្រឹមត្រូវឡើយ។

ទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ គឺដូចជាការចម្លងទង្វើពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ ហេតុដូច្នេះ ការទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅពិតជាសំខាន់ណាស់ ដែលវាមានឥទ្ធិពលអាចឲ្យបុគ្គលម្នាក់ដែលជាបុគ្គលដែលត្រឹមត្រូវក្លាយទៅជាជនល្មើស។ តុលាការត្រូវគិតពិចារណាលើចំណុចនេះផងដែរ ដើម្បីអនុវត្តគោលការណ៍ឯកត្តកម្មនៃទោសឲ្យបានត្រឹមត្រូវ។

ឧទាហរណ៍៖ វិសាល មានអាយុ១២ឆ្នាំ ជាក្មេងល្អស្តាប់បង្គាប់ឪពុកម្តាយណាស់ ព្រមទាំងជាសិស្សឆ្នើមប្រចាំថ្នាក់ទៀតផង។ នៅថ្ងៃមួយ ឪពុកម្តាយ របស់ វិសាល បានលែងលះគ្នា ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា ពេលនោះម្តាយវិសាល ក៏ព្រមឲ្យកូនប្រុសរបស់ខ្លួនទៅរស់នៅជាមួយឪពុករបស់គាត់ ដោយសារ ឪពុកមានលទ្ធភាពធូរធារជាងខ្លួន និងកន្លែងដែលខ្លួនរស់នៅសព្វថ្ងៃពោរពេញទៅដោយក្មេងៗពាលាអាវ៉ាសែរច្រើន បន្ទាប់មកកន្លងទៅបាន១ឆ្នាំក្រោមមក ឪពុក របស់ វិសាល ក៏បានមានភរិយាថ្មី ម្តាយថ្មីនោះបានវាយធ្វើបាប វិសាល និងមិនព្រមឲ្យ វិសាល ទៅរៀនសូត្រទៀតនោះទេ ដោយការទ្រាំនឹងទង្វើម្តាយថ្មីមិនបាន វិសាល ក៏ប្តូរទៅរស់នៅជាមួយម្តាយវិញ ដែលមជ្ឈដ្ឋានសុទ្ធសឹងតែអ្នកពាលា នៅពេលរស់នៅជាមួយម្តាយបានបន្តិចក្រោយមក វិសាល ក៏មានមិត្តភ័ក្ត្រច្រើន គិតតែពីដើរលេង មិនគិតពីការរៀនសូត្រទៀតនោះទេ ដើរដាច់យប់ សេពគ្រឿងញៀន ជាដើម លុះថ្ងៃមួយដោយសារតែ ខ្វះប្រាក់ក្នុងការទិញគ្រឿងអាភៀន វិសាល និងមិត្តភ័ក្ត្រ បានរៀបចំគម្រោងចាំឆក់កាបូប ទូរស័ព្ទ អ្នកដំណើរតាមផ្លូវ ភ្លាមៗនោះក៏មាន

[109] មាត្រា ៣៥៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

និស្សិតស្រីម្នាក់ទើបតែចេញពីរៀនប្រហែលម៉ោង ០៨ កន្លះយប់ ពេលនោះ វិសាល និងមិត្តភ័ក្ត្រ ក៏បានចាប់ផ្តើមធ្វើសកម្មភាពឆក់កាបូបនារីរងគ្រោះ ប៉ុន្តែពុំបានសម្រេចនោះទេ ត្រូវបានប៉ូលីសចាប់បាន។ ករណីនេះ វិសាល ត្រូវជាប់ពីបទ លួចមានស្ថានទម្ងន់ដោយសារការប្រើហិង្សា[110] ។

### ៣.១.១.២ កត្តានាំឲ្យប្រព្រឹត្តបទល្មើស

ជាទូទៅបទល្មើសកើតឡើង គឺដោយសារតែមានកត្តាជំរុញ ឬមូលហេតុអ្វីមួយដែលនាំឲ្យជននោះប្រព្រឹត្តអំពើល្មើស។ ស្ថានភាពមុនអំពើល្មើស គឺជាបណ្តុំនៃកាលៈទេសៈមុនពេលដែលមានអំពើល្មើស។

#### ក. ព្រឹត្តិហេតុនាំឲ្យមានបទល្មើស

បទល្មើសខ្លះត្រូវបានកើតឡើងដោយសារមានព្រឹត្តិហេតុដើមដែលព្រឹត្តិហេតុដើមនេះកើតមានមុនពេលដែលជនល្មើសសម្រេចចិត្តប្រព្រឹត្តអំពើល្មើស ហើយវាគឺជាកត្តាដែលជំរុញឲ្យមានអំពើល្មើសកើតឡើង។ ព្រឹត្តិហេតុដើម គឺជាព្រឹត្តការណ៍ដែលជំរុញឲ្យមានការបង្កើតនូវគម្រោងប្រព្រឹត្តអំពើល្មើស ក្នុងអារម្មណ៍ជនល្មើស និងកាលៈទេសៈទាំងឡាយដែលនៅជុំវិញការរៀបចំ និងការអនុវត្តគម្រោងល្មើសនោះបន្ទាប់មកលេចឡើងនូវព្រឹត្តិការណ៍ណាមួយផ្សេងទៀត ឬព្រឹត្តិការណ៍បន្តបន្ទាប់គ្នា។

#### ខ. កត្តាជីវភាព និងសម្ភារៈនិយម

មានជនល្មើសមួយចំនួនប្រព្រឹត្តបទល្មើសដោយសារតែកាលៈទេសៈបង្ខំ។ មានន័យថា ជននោះប្រព្រឹត្តបទល្មើស ដោយសារតែតម្រូវការចាំបាច់របស់ខ្លួន។ កត្តាជីវភាព គឺជាចំណុចសំខាន់ដែលអាចនាំឲ្យកើតមានបទល្មើស ពោលគឺប្រព្រឹត្តបទល្មើសដើម្បីបំពេញនូវតម្រូវការ ជីវភាព ឬចិញ្ចឹមជីវិតគ្រួសារ។ ពេលខ្លះជនល្មើសគ្មានចេតនានឹងប្រព្រឹត្តបទល្មើសនោះឡើយ ក៏ប៉ុន្តែ ជននោះប្រព្រឹត្តបទល្មើសក៏ព្រោះតែភាពអត់ឃ្លានក្នុងគ្រួសារដែលជំរុញឲ្យជននោះត្រូវតែប្រព្រឹត្តបទល្មើស។ ដោយសារតែ សង្គមបច្ចុប្បន្នគឺជាសង្គមដែលនិយមទៅដោយសម្ភារៈទំនើប(សម្ភារៈនិយម) និងឲ្យតម្លៃដល់គ្រឿងសម្ភារៈនិយម ដែលវាជាមូលហេតុដែលធ្វើឲ្យបុគ្គលមួយចំនួនស្ម័គ្រចិត្តនឹងប្រព្រឹត្តបទល្មើសដោយសារតែពួកគេចង់បំពេញនូវចំណង់នៃការចង់បានរបស់ខ្លះ។ ភាគច្រើនបទល្មើស ដែលកើតចេញពីកត្តាជីវភាព មានដូចជា អំពើលួច ឬលួចមានស្ថានទម្ងន់ជាដើម។

កត្តាខាងលើនេះ ក៏ជាមូលហេតុមួយដែលធ្វើឲ្យតុលាការអាចពិចារណាឲ្យមានស្ថានសម្រាលទោសដល់ជនជាប់ចោទ នាពេលប្រកាសទោសផងដែរ។

ឧទាហរណ៍៖ ដូចជាករណីដែលយើងខ្ញុំបានលើកឡើងពីខាងលើករណីដូចជា បូរ៉ា ជាដើម។

[110] មាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

### គ. បញ្ហាស្មារតីរបស់ជនជាប់ចោទ

កត្តាបញ្ហាស្មារតីរបស់ជនជាប់ចោទ ក៏ជាមូលហេតុមួយនៃការជំរុញឲ្យមានបទល្មើស។ មូលហេតុនោះមានដូចជា បញ្ហាក្នុងជីវិតស្នេហា, សេពសុរា(ស្រវឹង), ការជំរុញលើកទឹកចិត្តដោយភាពស្រឡាញ់, ការយកគំរូប្រព្រឹត្តអំពើល្មើសតាមក្នុងកាសែត ឬតាមរយៈខ្សែភាពយន្តជាដើម។ ទាំងនេះគឺជាចំណុចដែលចៅក្រមត្រូវពិនិត្យពិចារណាអំពីមូលហេតុ ដែលនាំឲ្យជននោះប្រព្រឹត្តបទល្មើសដោយសារតែជននោះមានបញ្ហាស្មារតី ឬយ៉ាងណាហើយ ចំណុចនេះក៏ជាចំណុចដែលអាចពិចារណាដល់ស្ថានទម្ងន់ ឬស្ថានសម្រាលដល់ជនជាប់ចោទ នោះផងដែរ។

ឧទាហរណ៍៖ លោក ដារ៉ា និងកញ្ញា រ៉ូស គឺជាសង្សារនឹងគ្នា។ កញ្ញា រ៉ូស ស្អប់ បុរសម្នាក់ឈ្មោះ ដា រីន ជាសង្សារចាស់របស់ខ្លួន ខ្លាំងមែនទែន។ ថ្ងៃមួយ កញ្ញា រ៉ូស បានប្រទះឃើញ លោក ដារីន បណ្តើរស្រីថ្មីម្នាក់ ដែលជាមិត្តភ័ក្រខ្លួន ក៏កើតចិត្តខឹងសម្បារនឹងលោក ដារីន រិតតែខ្លាំងទៀត។ ភ្លាមៗនោះ កញ្ញា រ៉ូស ក៏បានទៅជួបសង្សារខ្លួនឈ្មោះ ដារ៉ា ព្រមទាំងនិយាយលួងលោមឲ្យលោក ដារ៉ា ប្រដៅលោក ដារីន ជាសង្សារចាស់ខ្លួនដោយប្រាប់លោក ដារ៉ា ថាលោក ដារីន ពេលនៅទាក់ទងគ្នាតែងតែវាយដំធ្វើបានខ្លួនយ៉ាងព្រៃផ្សៃ។ លឺដូច្នេះ ដោយសារចិត្តស្រលាញ់កញ្ញា រ៉ូស ខ្លាំងពេក លោក ដារ៉ា មិនបង្អង់យូរឡើយ ក៏បានទៅជួបជាមួយលោក ដារីន ហើយវាយលោក ដារីន បែកក្បាល។

### ៣.១.២ ក្រោយពេលប្រព្រឹត្តបទល្មើស

ជនល្មើសខ្លះ ក្រោយពេលខ្លួនប្រព្រឹត្តអំពើល្មើសហើយបានធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬប្រគល់ខ្លួនឲ្យប៉ូលីស។ ជនប្រភេទនេះច្រើនជាជនប្រព្រឹត្តអំពើល្មើសដែលកើតចេញពី ការស្រឡាញ់ ឬប្រច័ណ្ឌ ជាដើម។ ចំពោះជនល្មើសអាជីពវិញ ក្រោយពេលប្រព្រឹត្ត ពួកគេស្វែងរកវិធីបំបាត់ភស្តុតាង ឬគេចខ្លួន ហើយមិនខ្លាចការប្រយុទ្ធជាមួយនឹងប៉ូលីសដើម្បីការពារខ្លួននោះទេ។ ហើយមានជនល្មើសខ្លះទៀត ក្រោយពេលប្រព្រឹត្ត ពួកគេនៅស្ងៀមស្ងាត់ប្រកបទៅដោយភាពប្រុងប្រយ័ត្ន។

ហេតុដូច្នេះ តុលាការត្រូវធ្វើការពិចារណាទៅលើកិរិយាមាយាទរបស់ជនជាប់ចោទ ក្រោយពីការប្រព្រឹត្តបទល្មើស ទាំងលើកិរិយាមាយាទចំពោះជនរងគ្រោះ និងជនដទៃ ដើម្បីសម្រេចកំណត់អំពីអត្រានៃទណ្ឌកម្មដែលជននោះត្រូវទទួលរង។

ឧទាហរណ៍៖ លោក ក និងនារី ខ ជាគូរស្វាមីភរិយានឹងគ្នាជាយូរឆ្នាំមកហើយ ដោយនៅក្នុងចំណងអាពាហ៍ពិពាហ៍ ពួកគាត់មានកូនចំនួន ៣ នាក់។ ថ្ងៃមួយនោះ នារី ខ បានលួចមានទំនាក់ទំនងស្នេហាថ្មីជាមួយបុរសម្នាក់ទៀតឈ្មោះ គ បន្ទាប់មកលោក ក ក៏បានស៊ើបដឹងអំពីរឿងនេះ ហើយប្រាប់ប្រពន្ធឲ្យឈប់ទាក់ទងជាមួយលោក គ ទៀតទៅកុំឲ្យរឿងបែកធ្លាយទៅធ្វើឲ្យកូនខ្មាសគេ ប៉ុន្តែនារី ខ មិនព្រមនោះទេ។ ជារៀងរាល់ពេលចូលផ្ទះ នារី ខ តែងតែព្យាយាមរករឿងដោយគ្មានមូលហេតុដើម្បីទាមទារលែងលះគ្នា ប៉ុន្តែលោក ក មិនព្រម

រហូតដល់ថ្ងៃមួយ នារី ខ បានបណ្តើរលោក គ នៅទីសាធារណៈហើយលោក ក ក៏បានប្រទះឃើញ ដោយសារតែភាពប្រច័ណ្ឌមួយឆាវ នៅពេលនារី ខ បានទៅដល់ផ្ទះវិញភ្លាមលោក ក ក៏បានអូស និងខ្ទប់មាត់នារី ខ មិនឲ្យស្រែកនោះទេ ដោយគំរាមថាបើនាងឯងហ៊ានស្រែក អាញនឹងចាប់នាងឯងអារកចោល។ ដោយការភ័យខ្លាចនារី ខ បានត្រឹមតែយំ និងសុំអង្វរឲ្យលោក ក លើកលែងទោស និងដោះលែងខ្លួន ប៉ុន្តែលោក ក មិនព្រមដោះលែងនោះទេក៏បានយកខ្សែគោមករិតជាមួយ ករ នារី ខ រហូតដាច់ខ្យល់ស្លាប់ បន្ទាប់មកលោក ក បានសរសេរសាររៀបរាប់រឿងរ៉ាវដាក់ក្រដាសមួយសន្លឹកទុកជូនគ្រួសារ និងកូនរបស់ខ្លួន ហើយក៏បានយកខ្សែមកចងករខ្លួនឯងផងដែរ ប៉ុន្តែមានគេមកជួយទាន់ពេលវេលា។ ចំពោះឧទាហរណ៍នេះ យើងអាចសន្និតបានថា អំពើរបស់លោក ក ជាអំពើដែលបំពេញធាតុផ្សំនៃបទល្មើស ឃាតកម្ម ដែលត្រូវផ្តន្ទាទោស ពី១០ឆ្នាំ ទៅ ១៥ឆ្នាំ[111] ។ ប៉ុន្តែតុលាការអាចប្រកាសទោសក្រោមនឹងឲ្យលោក ក បានពីព្រោះបើពិនិត្យទៅឃើញថាគាត់ប្រព្រឹត្តបទល្មើសដោយសារការប្រច័ណ្ឌមួយឆាវ មួយទៀតវាក៏ជាកំហុសនារីរងគ្រោះ ផងដែរ ចំណុចសំខាន់មួយទៀតនោះគឺ កូនតើកូនគាត់អ្នកណាចិញ្ចឹម? បើម្តាយស្លាប់ឪពុកជាប់គុក? អនាគតក្មេងៗទៅថ្ងៃមុខទៅជាយ៉ាងណា? សុទ្ធតែជាចំណុចដែលតុលាការត្រូវពិចារណា។

### ៣.១.២.១ កិរិយាមារយាទរបស់ជនជាប់ចោទចំពោះជនរងគ្រោះ

តាមការជាក់ស្តែងមួយចំនួន មានជនជាប់ចោទខ្លះសោកស្តាយនឹងអំពើល្មើសដែលពួកគេបានប្រព្រឹត្ត ហើយជនជាប់ចោទទាំងនោះទទួលស្គាល់នូវអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត ចំពោះជនរងគ្រោះ ជាពិសេសពួកគេមានចិត្តចង់កែខ្លួន និងសុំការអត់អោនទោសពីជនរងគ្រោះ។ អំពើល្មើសដែលកើតឡើង ភាគច្រើនជាអំពើកើតចេញពីការឆេវឆាវមួយពេលរបស់ជនល្មើស ដែលមិនមែនជាការតាំងចិត្តទុកយូរមកហើយទេ ឬកើតចេញពីការខ្វះការពិចារណាវែងឆ្ងាយ ដោយពួកគេមិនបានគិតពីផលវិបាកក្រោយពីប្រព្រឹត្តបទល្មើសរួច។ ប្រសិនបើជនជាប់ចោទស្ថិតនៅករណីខាងលើនេះ តុលាការនឹងអាចពិចារណាអំពីស្ថានសម្រាលសម្រាប់ជនជាប់ចោទនោះដើម្បីអាចឲ្យជនជាប់ចោទនោះអាចឆាប់សមាហរណ៍កម្មជាមួយសង្គមវិញ។

ឧទាហរណ៍៖ ឱសថការីម្នាក់បានប្រគល់ថ្នាំដែលមានសារធាតុពុលដោយច្រឡំទៅឲ្យអ្នកទិញ បន្ទាប់មកអ្នកទិញក៏បានលេបហើយពុលស្លាប់បាត់បង់ជីវិត[112] ។

### ៣.១.២.២ កិរិយាមារយាទរបស់ជនជាប់ចោទចំពោះជនដទៃ

ជនជាប់ចោទខ្លះ មិនមានការសោកស្តាយនឹងអំពើរបស់ខ្លួនឡើយ ហើយប្រែជាបង្កើតគំនិតគុំគួនជាមួយជនដទៃថែមទៀត។ ពួកគេបែរជាមិនទទួលស្គាល់នូវអំពើល្មើសរបស់ខ្លួន ហើយទៅជាស្អប់កាន់តែខ្លាំងទៅលើជន

[111] មាត្រា ១៩៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[112] មាត្រា ២០៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

រងគ្រោះ ឬជនដទៃទៀតដែលមកឈឺឆ្អៀលនឹងអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត។ មានករណីជនល្មើសខ្លះ ក្រោយពីប្រព្រឹត្តបទល្មើសរួចត្រូវបានជនរងគ្រោះប្តឹង ឲ្យប៉ូលីសចាប់ខ្លួន និងឲ្យតុលាការធ្វើការវិនិច្ឆ័យនូវអំពើល្មើសដែលបានកើតឡើងរួច។ ក្រោយពី តុលាការសម្រេចផ្តន្ទាទោស ជនល្មើសទាំងនោះបែរជាបង្កើតជាគំនុំជាមួយជនរងគ្រោះ និងស្អប់សមត្ថកិច្ចប៉ូលីសនិងតុលាការ។ ករណីនេះ ភាគច្រើនក្រោយពីផុតរយៈពេលផ្តន្ទាទោស ហើយ ពួកគេមានសេរីភាព ពួកគេនឹងអាចទៅប្រព្រឹត្តបទល្មើសថ្មីទៀតដែលបង្កើតជាករណីមិនរាងចាល។ ដូច្នេះ តុលាការក៏ត្រូវពិចារណាទៅលើចំណុចករណីមិនរាងចាលរបស់ជននោះផងដែរ នៅពេលដែលជននោះត្រូវបានផ្តន្ទាទោសចំពោះបទល្មើសថ្មីទៀត។

ឧទាហរណ៍៖ ចាន់ធឿន ជាក្មេងពាលាមិនស្តាប់បង្គប់ឪពុកម្តាយ ថ្ងៃមួយពេលដែលអ្នកជិតខាងមិននៅគាត់បានប្រុងនឹងចូលទៅលួចរបស់របរផ្ទះអ្នកជិតខាងមួយទៀត ប៉ុន្តែត្រូវបានគេតាមទាន់ ហើយចាប់បញ្ជូនទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ចាន់ធឿន ត្រូវបានតុលាការសម្រេចផ្តន្ទាទោសពីបទ លួច ដោយផ្តន្ទាទោសចំនួន ១ ឆ្នាំ[113]។ ដោយសារការខឹងសម្បារនឹងអ្នកជិតខាងម្នាក់នោះ នៅពេលដែលដល់ថ្ងៃចេញពីពន្ធនាគារ ចាន់ធឿន បានបបួលមិត្តភ័ក្រ្តគាត់ផ្សេងទៀតទៅស្ទាក់វាយអ្នកជិតខាងដែលចាប់បញ្ជូនគាត់ដាក់គុកនោះ។ ករណីនេះ ចាន់ធឿន បានប្រព្រឹត្តបទល្មើស ហិង្សាដោយមានស្ថានទម្ងន់ទោស ត្រូវផ្តន្ទាទោសពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យពី ៤លានរៀល ទៅ ១០ លានរៀល[114] ។ ប៉ុន្តែ តុលាការអាចសម្រេចផ្តន្ទាទោសលើសពីនេះបាន។

### ៣.២ កាលៈទេសៈនៃបទល្មើស

កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស គឺសំដៅដល់សកម្មភាពនៃការប្រព្រឹត្តអំពើល្មើសនោះ ថាតើអំពើនោះកើតចេញពីសកម្មភាពផ្ទាល់របស់ជនជាប់ចោទ មានការចូលរួមពីសកម្មភាពខាងក្រៅមកជំរុញ ឬ សកម្មភាពរបស់ជនរងគ្រោះជាកត្តាអំណោយផលក្នុងការប្រព្រឹត្តបទល្មើសដែលអាចជាការគិតទុកជាមុនឬមិនបានគិតទុកជាមុន។ ទន្ទឹមនឹងនេះដែរ កាលៈទេសៈនៃបទល្មើស ក៏សំដៅទៅលើភាពធ្ងន់ធ្ងរនៃល្មើស និងផលវិបាកនៃបទល្មើសផងដែរ។

### ៣.២.១ សកម្មភាពនៃការប្រព្រឹត្តបទល្មើស

បទល្មើសខ្លះកើតចេញពីសកម្មភាពដោយផ្ទាល់ពីជនជាប់ចោទ ដោយពុំមានចូលរួមពីជនរងគ្រោះ។ ផ្ទុយទៅវិញ បទល្មើសខ្លះទៀតកើតចេញពីការចូលរួមសកម្មភាពរបស់ជនរងគ្រោះផងដែរ។

---

113 មាត្រា ៣៥៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

114 មាត្រា ២១៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

### ៣.២.១.១ ការប្រព្រឹត្តកើតចេញពីជនល្មើសផ្ទាល់(សកម្មភាពដោយផ្ទាល់)

ការប្រព្រឹត្តបទល្មើសដោយប្រើសកម្មភាពផ្ទាល់របស់ជនជាប់ចោទ អាចកើតឡើងតាមរយៈ ០២ (ពីរ) ករណីគឺៈ អំពើចេតនា ឬអចេតនារបស់ជនជាប់ចោទនោះ។ សកម្មភាពដោយផ្ទាល់របស់ជនជាប់ចោទនេះ អាចចាត់ទុកថាជាធាតុផ្សំសត្យានុម័តនៃបទល្មើស ចំណែកឯអំពើចេតនា ឬអចេតនា គឺជាធាតុផ្សំអត្តនោម័តនៃបទល្មើស។ ជាពិសេសអំពើល្មើសដែលជននោះបានប្រព្រឹត្ត គឺមានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ដែលជាធាតុផ្សំនីត្យានុកូល។ ដូច្នេះ តុលាការត្រូវពិនិត្យ អំពីអំពើនោះថាមានគ្រប់ធាតុផ្សំនៃបទល្មើសដែរឬទេដើម្បីអាចធ្វើការប្រកាសទោសចំពោះជន នោះបាន។

### ៣.២.១.២ បទល្មើសកើតចេញពីការចូលរួមរបស់ជនរងគ្រោះ

បទល្មើសដែលកើតចេញពីការចូលរួមសកម្មភាពរបស់ជនរងគ្រោះ មានន័យថា ជនជាប់ចោទគ្មានចេតនា ឬគ្មានគម្រោងទុកជាមុនក្នុងការប្រព្រឹត្តបទល្មើស ដែលបទល្មើសប្រភេទនេះភាគច្រើនកើតចេញពីភាពអចេតនារវាងជនជាប់ចោទ និងជនរងគ្រោះ។ ចំណែកឯ បទល្មើសខ្លះទៀត ជនជាប់ចោទមិនបានប្រើសកម្មភាពផ្ទាល់របស់ខ្លួនទៅប្រព្រឹត្តបទល្មើសនោះទេ ពោលគឺពួកគេរៀបចំគម្រោងប្រព្រឹត្តបទល្មើសដោយប្រយោល មានន័យថាប្រើសកម្មភាពជនរងគ្រោះឲ្យបង្កើតជាបទល្មើស។

### ៣.២.២ ភាពធ្ងន់ធ្ងរនៃបទល្មើស

ជនល្មើសមួយចំនួន មានចរិតឃោរឃៅ ហើយបទល្មើសដែលពួកគេបានប្រព្រឹត្តនោះភាគច្រើនជាបទមនុស្សឃាត បទរំលោភសេពសន្ថវៈជាដើម ដែលចរិតលក្ខណៈនៃការប្រព្រឹត្តបទល្មើស មានលក្ខណៈសាហាវឃោឃៅ និងធ្វើឲ្យជនរងគ្រោះទទួលរងនូវសភាពធ្ងន់ធ្ងរ ដែលភាពធ្ងន់ធ្ងរនៃបទល្មើសនេះធ្វើឲ្យសង្គមមានភាពស្អប់ខ្ពើម និងមិនអាចទទួលយកបានពីមនុស្សក្នុងសង្គម។

## ផ្នែកទី២៖ ផលវិបាកគត្តិយុត្តនៃការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស

### ២.១. ឯកត្តកម្មនៃទោសនីត្យានុកូល

បន្ទាប់ពីបានរកឃើញពិរុទ្ធភាពរបស់ចារីនៃបទល្មើសរួចហើយ ចៅក្រម ត្រូវកំណត់ពីការផ្តន្ទាទោសដែលចារីនឹងត្រូវទទួលរង។ ហេតុដូច្នេះ ទោស ទាំងឡាយដែលបានកំណត់ឡើងក្នុងលក្ខណៈជាទ្រឹស្តីដោយច្បាប់សម្រាប់បទល្មើសនីមួយៗនឹងត្រូវយកមកប្រកាសជាក់ស្តែងដោយចៅក្រម។ បទល្មើសបញ្ញត្តឡើងដោយច្បាប់មានលក្ខណៈអរូបី។ ក្នុងការពិតជាក់ស្តែង ចៅក្រមត្រូវតែគិតគូរពិចារណាពីតថភាពផ្ទាល់ខ្លួន ឬពីតថភាពនៃស្ថានភាពណា មួយដែលមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសឲ្យបានល្អិតល្អន់ជាមុនសិន មុននឹងធ្វើការប្រកាសទោសចំពោះជនជាប់ចោទ។

**ឯកត្តកម្មនៃទោស** មានពីរ (០២) យ៉ាងគឺ : ឯកត្តកម្មនៃទោសនីត្យានុកូល (ចំណុចទី១) និងឯកត្តកម្មនៃទោសប្រកាសដោយតុលាការ (ចំណុចទី២)។

**ឯកត្តកម្មនៃទោសនីត្យានុកូល៖** គឺជាការកំណត់ទោសដោយអ្នកនីតិបញ្ញត្តិទៅតាមបុគ្គលិកលក្ខណៈ ឬស្ថានភាពផ្ទាល់របស់ចារីនៅក្នុងអត្ថបទច្បាប់តែម្តង[115]។ បានន័យថា នីតិករបានកំណត់ទោសជាមុនរួចទៅហើយ ចំពោះអំពើល្មើស ដោយផ្អែកតាមភាពធ្ងន់ធ្ងរនៃអំពើ ឬសកម្មភាពល្មើសនោះ។

### ២.១.១. ស្ថានភាពទាក់ទងនឹងចារី

ឧទាហរណ៍៖ ក្នុងករណី **បទឧបឃាត** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ អនុលោមតាមមាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ[116] ក៏ប៉ុន្តែ ក្នុងករណីដែលអំពើប្រព្រឹត្តនេះត្រូវបានប្រព្រឹត្តដោយ **អ្នករាជការសាធារណៈ បទឧបឃាត** ត្រូវផ្តន្ទាទោសអស់មួយជីវិត យោងតាមមាត្រា ៤៥២ នៃក្រមព្រហ្មទណ្ឌ[117]។

ឧទាហរណ៍៖ **បទឃាតកម្ម** ត្រូវបានផ្តន្ទាទោសពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ អនុលោមតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ[118] ប៉ុន្តែបើ **បទឃាតកម្ម** នេះប្រព្រឹត្តដោយអ្នករាជការសាធារណៈ ច្បាប់បានធ្វើការលើកទឹកចិត្តភ្លាមៗ ចំពោះចារីពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ទៅជា ១៥ឆ្នាំ ទៅ ៣០ឆ្នាំ ផ្អែកតាមមាត្រា ២០៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ [119]។

ឧទាហរណ៍៖ លោក ក ជាអ្នកជិតខាងម្នាក់របស់ លោក ខ ។ អ្នកទាំងពីរ ពុំសូវត្រូវគ្នានោះទេ ដោយលោក ក តែងតែជេរប្រមាថ និងតិះដៀលក្រុមគ្រួសាររបស់លោក ខ ដោយប្រយោលជារឿយៗ។ ថ្ងៃមួយ ដោយទប់ចិត្តខឹងពុំបានលោក ខ បានចាប់យកកូនស្រីរបស់លោក ក បានចងនៅផ្ទះខ្លួនដោយបង្អត់អាហារ និងចងដៃចងជើង ខ្ទប់មាត់កូនស្រីលោក ក ជាប់ហើយលោក ខ តែងតែយកទៀនដុតហើយទម្លាក់ជ័រភ្លើងទៀនមកលើរូបរាងកាយកូនស្រីលោក ក ជារៀងរាល់ថ្ងៃ។ ចំពោះករណីនេះ លោក ខ បានប្រព្រឹត្តបទទារុណកម្ម និងអំពើឃោរឃៅ ដោយអនុលោមតាមមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ[120] ផ្ទុយមកវិញ ក្នុងករណី បទទារុណកម្ម និងអំពើឃោរឃៅ ដូចគ្នា ប៉ុន្តែប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ការផ្តន្ទាទោសត្រូវដាក់ចន្លោះពី ១០ឆ្នាំ ទៅ ២០ឆ្នាំ[121] ។

---

[115] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងកែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៣៨២។

[116] មាត្រា ៤៥១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[117] មាត្រា ៤៥២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[118] មាត្រា ១៩៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[119] មាត្រា ២០៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[120] មាត្រា ២១០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[121] មាត្រា ២១៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

### ២.១.២. ស្ថានភាពទាក់ទងនឹងជនរងគ្រោះ

ឧទាហរណ៍៖ **បទឃាតកម្ម** ត្រូវបានផ្តន្ទាទោសពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ អនុលោមតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ[122] ប៉ុន្តែបើ **បទឃាតកម្ម** នេះប្រព្រឹត្តទៅលើបុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុអាយុ ជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង និងនារីមានគភ៌ កាលបើគភ៌នោះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ការផ្តន្ទាទោសត្រូវបានប្រែប្រួលភ្លាមៗពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ទៅជា ១៥ឆ្នាំ ទៅ ៣០ឆ្នាំ យោងតាមមាត្រា ២០២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩[123]។

ឧទាហរណ៍៖ ក្នុងករណីនៃបទល្មើសរំលោភសេពសន្ថវៈ ជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ បើតាមខ្លឹមសារនៃមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ[124] ។ ប្រសិនបើការរំលោភសេពសន្ថវៈប្រព្រឹត្តទៅលើនារីមានគភ៌ចាប់ពី ៦ខែ ឡើងទៅ (ជាធម្មតានារីមាន គភ៌ ៦ខែ ត្រូវបានមើលឃើញជាក់ស្តែងតាមរយៈផ្ទៃពោះរបស់ស្ត្រីដែលមានផ្ទៃពោះ) ការផ្តន្ទាទោសដាក់ពន្ធនាគារគឺចាប់ពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ តាមបទប្បញ្ញត្តិនៃមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ[125] ។

### ២.២. ឯកត្តកម្មនៃទោសប្រកាសដោយតុលាការ

ដូចបានជម្រាបពីខាងលើហើយថា **ឯកត្តកម្មនៃទោស** មានពីរ (០២) យ៉ាងគឺ : ឯកត្តកម្មនៃទោសនីត្យានុកូល និងឯកត្តកម្មនៃទោសប្រកាស។

ចំពោះឯកត្តកម្មនៃទោសនីត្យានុកូល បានធ្វើការបកស្រាយពីខាងដើមរួចហើយ ដូច្នេះយើងខ្ញុំនឹងធ្វើការបកស្រាយបន្តទៅទៀត។

**ឯកត្តកម្មនៃទោសប្រកាស៖** គឺជាការសម្រេចទោសដោយតុលាការ និងដោយយោងទៅលើបុគ្គលិកលក្ខណៈ ឬស្ថានភាពផ្ទាល់របស់ចារី។ ក្នុងករណីនេះ ចៅក្រមមិនអាចធ្វើអ្វីឱ្យហួសពីការកំណត់របស់ច្បាប់បានឡើយ គឺមានន័យថា ចៅក្រមត្រូវតែគោរពតាមអតិបរមា និងអប្បបរមានៃទោសដែលច្បាប់បានចងទុកជាស្រេចចំពោះបទល្មើសនីមួយៗ លើកលែងតែមានស្ថានទម្ងន់ សម្រាលទោស ដែលច្បាប់អនុញ្ញាតឲ្យតុលាការធ្វើការផ្តន្ទាទោសលើសពីអតិបរមានៃទោស ឬអប្បបរមានៃទោសដែលកំណត់ដោយច្បាប់សម្រាប់បទល្មើសណាមួយ[126]

---

[122] មាត្រា ១៩៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[123] មាត្រា ២០២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[124] មាត្រា ២៣៩ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[125] មាត្រា ២៤១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[126] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ និងកែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៣៤២។

ឯកត្តកម្មនៃទោសប្រកាសដោយតុលាការអាចមានករណីខុសប្លែកគ្នា គឺអាស្រ័យទៅតាមចំនួនអំពើដែលចារីបានប្រព្រឹត្ត។ ជានិច្ចកាល មានពីរ(០២)ករណី គឺៈ ករណីដែលមានបទល្មើសតែមួយ (២.២.១) និងករណីដែលមានបទល្មើសត្រួតគ្នា(ពហុបទល្មើស) (២.២.២)។

**២.២.១ ករណីដែលមានបទល្មើសតែមួយ**

ចៅក្រមមានតួនាទីជាអ្នកអនុវត្តច្បាប់ ហើយមិនត្រូវដាក់ទោសឲ្យតិចជាងអប្បបរមានៃទោស ឬច្រើនជាងអតិបរមានៃទោសដែលបានកំណត់ដោយច្បាប់នោះឡើយ។ ក៏ប៉ុន្តែនៅមានមូលហេតុមួយចំនួនដែលអនុញ្ញាតឲ្យចៅក្រមអាចធ្វើ ផ្ទុយពីអ្វីដែលបានរិយាយខាងលើនេះបាន។ ក្នុងករណីបែបនេះ ក្រមព្រហ្មទណ្ឌចង់គូសបញ្ជាក់ពីស្ថានភាពដោយសំដៅទៅលើ **ស្ថានសម្រាលទោស** និង**ស្ថានទម្ងន់ទោស**។

**២.២.១.១ ស្ថានសម្រាលទោស**

ចុះសួរថា តើផ្អែកទៅលើស្ថានភាពអ្វីខ្លះដើម្បីធ្វើការកាត់បន្ថយទម្ងន់ទោសអាចទៅបាន ? ជាចម្លើយចំៗតែម្តង ចំពោះបញ្ហាស្ថានសម្រាលទោសនេះវិញ គឺយើងនឹងសាកល្បងពន្យល់ដោយបែងចែកជាមូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោស និងខ្នាតនៃស្ថានសម្រាលទោស។

**២.២.១.១.១ មូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោស**

យោងតាមមាត្រា ៩៣ ដល់ មាត្រា ៩៥ ដែលចែងអំពីស្ថានសម្រាលទោស ដើម្បីទុកឲ្យយើងធ្វើការពិចារណានោះ ឃើញថាក្រមព្រហ្មទណ្ឌបានកំណត់ ពីមូលដ្ឋានគ្រឹះនៃស្ថានសម្រាលទោស ត្រឹមតែបញ្ហាចំនួន ៣ (បី) សំខាន់ៗ ប៉ុណ្ណោះគឺរួមមាន ទី១ និយមន័យនៃស្ថានសម្រាលទោស ទី២ ទោសដាក់ពន្ធនាគារអស់មួយជីវិតដែលនេះក៏ជាមូលដ្ឋានគ្រឹះសំខាន់ដែរនៃ ស្ថានសម្រាលទោស។

**ក. និយមន័យនៃស្ថានសម្រាលទោស**

យោងតាមមាត្រា ៩៦ បានចែងថា កាលណាកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទ បានទទួលនូវស្ថានសម្រាលទោស។ ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទបានដែរ ទោះបីជា ជននោះត្រូវបានប្រកាសថាស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ[127]។ ដូច្នេះ ស្ថានសម្រាលទោស គឺជាកាលៈទេសៈនៃបទល្មើសឬបុគ្គលិកលក្ខណៈ នៃជនជាប់ចោទដែលញ៉ាំងឲ្យតុលាការសម្រេចឲ្យជនជាប់ចោទបានទទួល នូវស្ថានសម្រាលទោស។ យោងតាមអត្ថន័យខាងលើនេះ យើងអាចដឹងបានថា ស្ថានសម្រាលទោស គឺជាការគិតគូរបស់តុលាការដោយផ្អែកទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសដែលតម្រូវឲ្យ ហើយអាចមានដូចជា សាវតា ចំណេះដឹង អាកប្បកិរិយា ស្ថានភាពគ្រួសារ ឬមួយក៏ការសារភាព ទទួលស្គាល់នូវទោសកំហុសដោយខ្លួនឯង និងគ្មានការបង្ខិតបង្ខំណាមួយនោះទេ។ ឬក៏ តុលាការត្រូវ

[127] មាត្រា ៧៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ពឹងផ្អែកទៅលើកាលៈទេសៈនៃបទល្មើស ដូចជាក្នុងពេលវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ ឬហាក់ដូចជា ការការពារស្របច្បាប់តែអាចខុសពីការការពារស្របច្បាប់បន្តិច និងការគិតគូ អំពីចរិកគ្រោះថ្នាក់នៃអំពើផងដែរ ដែលតុលាការគិតគូថា តើគួរឲ្យជននេះទទួលបាននូវស្ថានធូរស្រាលដល់កម្រិតណា។ ឬមួយនិយាយម្យ៉ាងទៀតថា ដូចជាករណីដែលតុលាការ គាត់បានពិនិត្យឃើញអំពីការប្រព្រឹត្តបទល្មើស របស់ជនម្នាក់នៅក្នុងកាលៈទេសៈមួយពិសេស ថាបានចូលជាស្ថានភាពដែលគាត់ធ្វើដោយមិនមែនចង់ធ្វើទេ ក៏ប៉ុន្តែ ដោយសារមានការជម្រុញណាមួយឬក៏ការបង្កើតឲ្យគាត់មានការរំជួលចិត្តណាមួយដែលទប់នូវអំពើនេះមិនបានក្រមព្រហ្មទណ្ឌ តុលាការមើលឃើញថា អំពើរបស់ជននេះ មានលក្ខណៈដែលមិនគួរឲ្យគាត់ទទួលនូវទោសធ្ងន់ធ្ងរពេកទេ។ គាត់ត្រូវគិតគូរទៅលើកាលៈទេសៈច្រើនណាស់ មិនមែនតែប៉ុណ្ណឹងទេ គឺតុលាការត្រូវគិតមើលអំពីបញ្ហាទាំងអស់ មានតាំងពី ស្ថានភាពនៃការរស់នៅរបស់ជននោះ ប្រវត្តិរបស់ជននោះ តើជាជនដែលប្រកបដោយគ្រោះថ្នាក់ទៅដល់សង្គមទេ? មូលដ្ឋានទាំងអស់នេះហើយដែលជាការស្រាវជ្រាវរកឲ្យឃើញថា ជនម្នាក់ណាដែលតុលាការផ្តល់ការប្រកាសទោសឲ្យគាត់ចូលទៅក្នុងស្ថានទម្ងន់ ឬស្ថានសម្រាលនេះគាត់ត្រូវតែគិតគូរ ទាំងអស់ដូចដែលយើងតែងឃើញហើយ នៅពេលដែលតុលាការចាប់ផ្តើម នូវសវនាការ គាត់តែងតែសួរប្រវត្តិរបស់ជននោះ គឺចង់ដឹងថាតើជនហ្នឹងគឺជាជនបែបម៉េច? តើជាជនមួយដែលមានបង្កគ្រោះថ្នាក់ដល់សង្គមដែរឬអត់? ហើយបានគេពិនិត្យមើលអំពីការប្រព្រឹត្តបទល្មើសរបស់គាត់ ថាគាត់ប្រព្រឹត្តនៅក្នុងកាលៈទេសៈបែបណា ? ហើយធ្វើឲ្យសង្គមទូទៅនោះខ្លាចរអារ ឬក៏ភ័យព្រួយចំពោះអំពើហ្នឹងខ្លាំងដែរអត់ ? ដូច្នេះ ការដែលគិតគូរទាំងអស់នេះទើប បានតុលាការថាគួរឲ្យគាត់ប្រកាសទោសនៅក្នុងកម្រិតស្រាល ឬក៏កម្រិតធ្ងន់។

### ខ. ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

ចំពោះបញ្ហានៃទោសដាក់ពន្ធនាគារ ដែលត្រូវកំណត់ដោយច្បាប់អស់មួយជីវិតនេះ ក្រមព្រហ្មទណ្ឌថ្មីយើងបានកំណត់នៅក្នុងមាត្រា ៩៥ ឲ្យតុលាការ គាត់អាចប្រកាសនូវចន្លោះទោសរវាងពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ មានន័យថា ប្រសិនបើជាបទល្មើសណាមួយត្រូវផ្តន្ទាទោសដាក់គុកអស់មួយជីវិត ហើយ តុលាការបានពិនិត្យឃើញច្បាស់ថា អ្នកនោះត្រូវទទួលបាននូវស្ថានសម្រាល ណាមួយដែលគួរឲ្យគាត់ទទួលទោសធូរស្រាលនោះ គឺចៅក្រមអាចប្រកាស ទោសចន្លោះពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ[128] ។ ជាទូទៅទោសដាក់គុក ឬមួយទោស ដាក់ពន្ធនាគារអស់មួយជីវិត ដែលជាប្រភេទនៃទោសដាក់ពន្ធនាគារគ្មាន កាលកំណត់នេះគឺមានតិចតួចទេនៅក្នុងក្រមព្រហ្មទណ្ឌថ្មីរបស់កម្ពុជាយើង។ បើតាមការស្រាវជ្រាវឃើញទោសជាប់គុកអស់មួយជីវិតមានដូចជា៖ បទ

[128] មាត្រា ៩៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ឧក្រិដ្ឋប្រល័យពូជសាសន៍[129], បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ [130] ,បទឧក្រិដ្ឋសង្គ្រាម [131], បទឃាតកម្មគិតទុកជាមុន [132] ,បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ [133], បទរាជឃាតកម្ម [134] បទប្រគល់ឱ្យរដ្ឋបរទេសនូវដែនដីជាតិ ទាំងស្រុងឬមួយផ្នែក [135]។

**២.២.១.១.២ ខ្នាតនៃស្ថានសម្រាលទោស**

ស្ថានធូរស្រាលនេះ ជាធម្មតាតុលាការតែងតែគិតគូរនៅក្នុងកម្រិតអប្បបរមានៃទោសដែលច្បាប់បានកំណត់ចំពោះបទល្មើស។ នៅក្នុងក្រមព្រហ្មទណ្ឌបានចែងឲ្យតុលាការអាចគិតគូរបន្ថយក្រោមអប្បបរមានៃទោសដែលត្រូវកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធនឹងបទល្មើសនោះផងដែរ។ ករណីបែបនេះ គឺត្រូវគិតគូរនៅក្នុងស្ថានភាពមួយថាតើជននេះប្រព្រឹត្តបទល្មើសនៅក្នុងកាលៈទេសៈបែបម៉េច ? ការដែលទទួលបាននូវស្ថានសម្រាល គឺត្រូវកំណត់នៅក្នុងខ្នាតមួយដែលច្បាប់បានចែងយ៉ាងជាក់លាក់ អាចប្រកាសទោសស្រាលហ្នឹង ក្រោមខ្នាតដែលច្បាប់កំណត់ទេ។ នៅក្នុង បញ្ញត្តិនៃមាត្រា ៩៤ គឺបានកំណត់យ៉ាងជាក់លាក់នូវខ្នាតដូចខាងក្រោម៖

- ទី១ ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ (ដប់) ឆ្នាំ អប្បបរមា នៃទោសនេះ ត្រូវបន្ថយមកនៅត្រឹម ២ (ពីរ) ឆ្នាំ ។

ឧទាហរណ៍ ៖ ជនម្នាក់បានប្រព្រឹត្តបទល្មើសផ្ទុយទៅនឹងការហាមឃាត់ក្នុង មាត្រា ៤៣៤ គឺបទធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ ច្បាប់បានកំណត់ថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំ ។ យើងឃើញថា អប្បបរមានៃទោសដាក់ពន្ធនាគារដែលច្បាប់បានកំណត់ក្នុង បទល្មើសនេះស្មើនឹង ១០ ឆ្នាំ ។ ដូចនេះ ប្រសិនបើតុលាការរកទៅឃើញថា មានស្ថានសម្រាល ដែលគួរឲ្យគាត់ធូរស្រាលក្រោមអប្បបរមានៃទោសដែល ច្បាប់កំណត់ជាធម្មតាគឺ ១០ ឆ្នាំនោះ ចៅក្រមគាត់អាចបន្ធូររហូតមកដល់ ទាបជាងគេ ២ ឆ្នាំ អញ្ចឹងគាត់អាចដាក់ ៩ ៨ ៧ ៦ ៥ ៤ ៣ ២ ដែលទាបជាងគ នោះគឺ ២ ឆ្នាំ បានន័យថា មិនអាចនៅក្រោម ២ ឆ្នាំទេ បើទៅដាក់គុក ១ ឆ្នាំ គឺខុសពីស្មារតីនៃក្រមនេះហើយ ។

- ទី២ ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ (ប្រាំ) ឆ្នាំ ហើយតិចជាង ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ)ឆ្នាំ។

---

[129] មាត្រា ១៨៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[130] មាត្រា ១៨៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[131] មាត្រា ១៩៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[132] មាត្រា ២០០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[133] មាត្រា ២០៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[134] មាត្រា ៤៣៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[135] មាត្រា ៤៤០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ឧទាហរណ៍ ៖ ច្បាប់កំណត់ថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ ចំពោះអំពីជាបទល្មើសតាមមាត្រា ២១០ គឺបទទារុណកម្មនិងអំពើឃោរឃៅ។ ដូច្នេះបើសិនជាចៅក្រមរកទៅឃើញថា ត្រូវមានស្ថានសម្រាល គឺគាត់អាច បន្ថយរហូតមកដល់ ១ ឆ្នាំ មិនមែនមានន័យថាត្រូវតែយកមកដាក់ ១ ឆ្នាំទេ គឺគាត់អាចដាក់ចុះចាប់ពី ៦ ៥ ៤ ៣ ២ ១ ដែលទាបជាងគេគឺ ១ ឆ្នាំ ។

- ទី៣ ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ (ពីរ) ឆ្នាំ ហើយតិចជាង ៥ (ប្រាំ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ។

ឧទាហរណ៍ ៖ ច្បាប់កំណត់ថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ ចំពោះអំពីជាបទល្មើសតាមមាត្រា ២៨៤ គឺបទសញ្ចាកម្ម។ ដូច្នេះបើសិនជា ចៅក្រមរកទៅឃើញថា ត្រូវមានស្ថានសម្រាល គឺគាត់អាចបន្ថយរហូតមក ដល់ ៦ ខែ មិនមែនមានន័យថាត្រូវតែយកមកដាក់គុក ៦ ខែ ទេ គឺគាត់អាច ដាក់ចុះចាប់ពី ១ ឆ្នាំ និង ៦ ខែ ឬ ១ ឆ្នាំគត់ ឬ ៦ ខែ ដែលទាបជាងគេគឺ ៦ ខែ។

- ទី៤ ប្រសិនបើអប្បបរមានៃទោសស្មើ ឬ លើសពី ៦ (ប្រាំមួយ) ថ្ងៃ ហើយ តិចជាង ២ (ពីរ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ ។

ឧទាហរណ៍ ៖ ជនម្នាក់ប្រព្រឹត្តបទល្មើសតាមមាត្រា ៥៤១ គឺបទបដិសេធមិន ស្តាប់បង្គាប់បញ្ជា ហើយច្បាប់បានកំណត់ថាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ។ យើងពិនិត្យទៅឃើញថាអប្បបរមានៃទោស ដាក់ពន្ធនាគារដែលច្បាប់កំណត់ក្នុងបទល្មើសនេះស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ។ ហេតុដូច្នេះ ប្រសិនបើតុលាការរកទៅឃើញថាមានស្ថានសម្រាលដែលគួរឲ្យ គាត់ទទួលបានធូរស្រាលនូវក្រោមអប្បបរមានៃទោសដែលច្បាប់បានកំណត់ ១ ថ្ងៃ ជាធម្មតាគឺ ៦ ថ្ងៃនោះ ចៅក្រមអាចបន្ធូររហូតមកដល់ទាបជាងគេគឺ ១ ថ្ងៃ។

- ទី៥ អប្បបរមានៃទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្តាល ។ (ចំណុចទី ៤ នៃមាត្រា ៩៤)

ឧទាហរណ៍ ៖ ជនម្នាក់ប្រព្រឹត្តបទល្មើសយោងទៅតាមបញ្ញត្តិនៃមាត្រា ២៩៨ គឺបទហៅអ្នកដទៃនៅទីសាធារណៈ ។ ច្បាប់បានកំណត់ថា ត្រូវផ្តន្ទាទោស ពិន័យពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ៥០.០០០ (ប្រាំម៉ឺន) រៀល ។ អញ្ចឹងអប្បបរមានៃទោសពិន័យនេះត្រឹមតែ ៥.០០០ (ប្រាំពាន់) រៀល ប៉ុណ្ណោះ។ ដូច្នេះ បើសិនជាចៅក្រមរកឃើញថាត្រូវមានស្ថានសម្រាល គាត់អាចបន្ថយ មកនៅត្រឹមពាក់កណ្តាលអប្បបរមានៃ ៥.០០០ (ប្រាំពាន់) រៀល បើយើងយក ទៅចែកនឹងពីរគឺស្មើនឹង ២.៥០០ (ពីរពាន់ប្រាំរយ) រៀល ប៉ុណ្ណោះ[136]។

### ២.២.១.២ ស្ថានទម្ងន់ទោស

ស្ថានទម្ងន់ទោស គឺជាស្ថានភាពមួយចំនួនដែលច្បាប់បានចងយ៉ាងជាក់នឹងធ្វើឲ្យទោសដែលតុលាការត្រូវផ្តន្ទាកាន់តែមានសភាពធ្ងន់ធ្ងរឡើង។ ស្ថានទម្ងន់ទោស មិនមែនចង់សំដៅទៅលើស្ថានទម្ងន់ ដែលតុលាការ

[136] មាត្រា ៩៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ត្រូវយកមកពិចារណា ដើម្បីដាក់ទោសទៅលើជនជាប់ចោទដោយកម្រិតមិនឲ្យលើសពីអតិបរមានៃទោស ដែលបានកំណត់ដោយច្បាប់នោះទេ។

**២.២.១.២.១ ស្ថានទម្ងន់ទោសទូទៅ**

ស្ថានទម្ងន់ទោសទូទៅ គឺជាស្ថានទម្ងន់ទោសដែលតុលាការត្រូវយកមកអនុវត្តលើគ្រប់បទល្មើសទាំងអស់ ទោះបីជាពុំមានបទបញ្ញត្តិពិសេសណាមួយដែលបានចែងឲ្យបន្ថែមទម្ងន់ទោសទៅលើបទល្មើសណាមួយឲ្យជាក់លាក់ក៏ដោយ។ ការមិនរាងចាលមានអានុភាព នាំឲ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែង [137]។ យោងតាមបទបញ្ញត្តិខាងលើ យើងឃើញថា ក្រមព្រហ្មទណ្ឌពុំបានកម្រិតការអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាលទៅលើបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយឡើយ ដែលជាហេតុនាំឲ្យមានការគិតសន្និដ្ឋានថា ស្ថានទម្ងន់ទោសនេះត្រូវយកទៅអនុវត្ត សម្រាប់រាល់បទឧក្រិដ្ឋ បទមជ្ឈិមទាំងអស់ កាលបើលក្ខខណ្ឌនៃការមិនរាងចាលត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។ ការមិនរាងចាល បានសម្តែងឲ្យឃើញពីភាពបរាជ័យនៃការផ្តន្ទាទោសជាស្ថាពរកាលពីលើកមុន ដោយសារតែការដែលជនល្មើសបានប្រព្រឹត្តបទល្មើសថ្មីទៀត តាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

**ក. និយមន័យនៃការមិនរាងចាល**

ការមិនរាងចាល គឺទាក់ទងទៅនឹងករណីដែលជនម្នាក់បានប្រព្រឹត្តបទល្មើស ដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលត្រូវបានផ្តន្ទាទោសចំពោះអំពើនោះជាស្ថាពររួចរាល់ហើយ បន្ទាប់មកមិនទាន់ផុតរយៈពេលហាមឃាត់កុំឲ្យប្រព្រឹត្តបទល្មើសថ្មីផង ស្រាប់តែជននោះបានប្រព្រឹត្តបទល្មើសថ្មីទៀត។ គួរបញ្ជាក់ផងដែរថា ចំពោះរបបគតិយុត្តនៃការមិនរាងចាលនេះអនុវត្តបានតែចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម តែប៉ុណ្ណោះ។

**ខ. លក្ខខណ្ឌនៃការមិនរាងចាល**

ការកំណត់ថាមានការមិនរាងចាលឬក៏អត់ គឺត្រូវតែពិនិត្យទៅលើប្រភេទនៃបទល្មើសទីមួយដែលត្រូវបានតុលាការផ្តន្ទាទោសជាស្ថាពររួចហើយ និងប្រភេទនៃបទល្មើសថ្មីដែលចារីទើបតែបានប្រព្រឹត្ត ព្រមទាំងរយៈពេលគម្លាតរវាងការផ្តន្ទាទោសជាស្ថាពរកាលពីលើកមុន និងការប្រព្រឹត្តបទល្មើសថ្មីចុងក្រោយ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរកាល ពីលើកមុន [138]។ ករណីនៃការមិនរាងចាលរួមមានដូចខាងក្រោមនេះ៖

- **កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋបុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតក្នុងរយៈពេល ១០ឆ្នាំ**[139]

[137] មាត្រា ៨៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[138] មាត្រា ៨៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[139] មាត្រា ៨៤ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ជាដំបូងត្រូវធ្វើការកត់សម្គាល់ថា រយៈពេលនេះចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចរបស់តុលាការផ្តន្ទាទោសចំពោះបទល្មើសលើកទីមួយបាន ជាស្ថាពររួចហើយ។ ក្នុងករណីដូចនេះ ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះឧក្រិដ្ឋថ្មីមិនលើសពី ២០ឆ្នាំ ទេ អតិបរមានេះត្រូវឡើងទ្វេដង[140] ។

ឧទាហរណ៍៖ **លោក ក** ត្រូវបានឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅ ១០ ខែឧសភា ឆ្នាំ២០០០។ ឧបមាថាតុលាការបានសម្រេចផ្តន្ទាទោស **លោក ក** ពី បទរំលោភសេពសន្ថវៈ តម្រូវឲ្យជាប់ពន្ធនាគារចំនួន ៦ ឆ្នាំ។ បន្ទាប់មកសេចក្តីសម្រេចផ្តន្ទាទោសក៏បានចូលជាស្ថាពរនៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០០១ ចុងបញ្ចប់ ពោលគឺនៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៦។ **លោក ក** ដោះលែងឲ្យមានសេរីភាពឡើងវិញ បន្ទាប់ពីបានទទួលរងនូវការអនុវត្តទោសជាពន្ធនាគាររួចរាល់ហើយ ស្រាប់តែប៉ុន្មានឆ្នាំក្រោយមកទៀត គឺនៅថ្ងៃ ខែកញ្ញា ឆ្នាំ២០១០ **លោក ក** បានធ្វើឃាតលើគូសត្រូវរបស់ខ្លួនម្នាក់ទៀត ដោយសារទំនាស់ពាក្យសំដី ហើយត្រូវបានឃាត់ខ្លួនជាថ្មីម្តងទៀត។ ក្នុងករណីនេះ គឺ **លោក ក** ស្ថិតក្នុងស្ថានភាពមិនរាងចាល ពីព្រោះថាបើគិតពីថ្ងៃទី ឆ្នាំ២០០១ រហូតដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១០ លោក ក បទឃាតកម្មក្នុងរយៈពេល ១០ឆ្នាំ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចទោសរបស់តុលាការ ចំពោះបទល្មើសទី ១ បានចូលជាស្ថាពររួចមក។ ជាលទ្ធផល អតិបរមានៃទោសដាក់ពន្ធនាគារចំពោះ បទឃាតកម្ម ដែលជាបទល្មើសថ្មី ត្រូវអនុវត្តទ្វេឡើង ពោលគឺតុលាការត្រូវគិតថា ទោសដាក់ពន្ធនាគារដែលត្រូវ អនុវត្តលើ **លោក ក** សម្រាប់បទឃាតកម្ម គឺចាប់ពីទោសដាក់ពន្ធនាគារចំនួន ១០ឆ្នាំ (អប្បបរមានៃទោស ) ទៅ ៣០ឆ្នាំ (អតិបរមានៃទោស)។ ផ្ទុយទៅវិញ ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋ ថ្មីមានរយៈពេលរហូតដល់ ៣០ឆ្នាំ នោះអតិបរមានៃទោសគឺត្រូវដាក់ពន្ធនាគារ រហូតអស់មួយជីវិត។

- **កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមនៅក្នុងរយៈពេល ៥ឆ្នាំ**[141]

ក្នុងករណីបែបនេះ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមដែរបានប្រព្រឹត្តថ្មីត្រូវឡើងទ្វេដង[142]។ ទោះបីជាអតិបរមានៃទោសដាក់ពន្ធនាគារដែលឡើងត្រូវលើសពី ៥ឆ្នាំ ក៏ដោយ ក៏បទល្មើសថ្មីនេះនៅតែជាបទមជ្ឈិមដដែល [143]។

ឧទាហរណ៍៖ **លោក ខ** ត្រូវបានឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៩ តុលាការក៏បានសម្រេចផ្តន្ទាទោស លោក ខ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ដែលជា

[140] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ ៣៥៤។

[141] មាត្រា ៨៤ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[142] មាត្រា ៨៦ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[143] មាត្រា ៨៦ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

បទល្មើស ដោយតម្រូវឲ្យជាប់ពន្ធនាគារចំនួន ៤ ឆ្នាំ សេចក្តីសម្រេចផ្តន្ទាទោស បានចូលស្ថាពរនៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៧។ នៅថ្ងៃទី ២១ ខែកញ្ញា ២០០៩ **លោក ខ** ត្រូវបានដោះលែងឲ្យមានសេរីភាព បន្ទាប់ពីបានទទួលបាន ការអនុវត្តទោសដាក់ពន្ធនាគាររួចរាល់ហើយ។ ស្រាប់តែក្រោយមកទៀតនៅ ទី ២០ ខែកុម្ភៈ ឆ្នាំ ២០១០ **លោក ខ** បានខ្ចីម៉ូតូពីមិត្តភក្តិរបស់ខ្លួន ហើយបានយកទៅលក់យកប្រាក់ចាយអស់។ ដូច្នេះ បទល្មើសដែល **លោក ខ** បានប្រព្រឹត្តជាថ្មីនេះគឺជា **បទរំលោភលើទំនុកចិត្ត** យោងតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន រៀល ទៅ ៦លានរៀល។ ក៏ប៉ុន្តែដោយសារ លោក ខ ស្ថិតនៅក្នុងស្ថានភាពមិនរាងចោល ដូច្នេះ ទោសដែលត្រូវផ្តន្ទាលើ **លោក ខ** សម្រាប់បទល្មើសថ្មីនេះ ទោសដាក់ពន្ធនាគារ ៦ (អប្បបរមានៃទោស) ទៅ ៦ឆ្នាំ (អតិបរមានៃទោស ) និងទោសពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។

- **កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមហើយបុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលជាថ្មីទៀតក្នុងរយៈពេល៥ឆ្នាំ**[144]

គួរកត់សម្គាល់ថា ចំពោះករណីនេះ ត្រូវចាត់ទុកថាមានការមិនរាងចាលលុះត្រាតែជនល្មើសបានប្រព្រឹត្តបទមជ្ឈិមដដែល នៅក្នុងរយៈពេល ៥ឆ្នាំ ដែលខុសពីករណីផ្សេងទៀតនៃការមិនរាងចាលដូចបានរៀបរាប់ខាងលើ ដោយក្រមព្រហ្មទណ្ឌពុំបានតម្រូវឲ្យមានការប្រព្រឹត្តបទល្មើសដដែល នោះឡើយ។ បញ្ហាដែលតែងតែចោទឡើងសម្រាប់ការអនុវត្ត គឺការវាយតម្លៃថាបទមជ្ឈិមថ្មីបែបណាដែលជា **បទមជ្ឈិមដដែល នោះ ?** ប្រសិនបើបទមជ្ឈិមទីមួយ ដែលជនល្មើសបានប្រព្រឹត្ត**គឺជាបទលួច** ហើយបទមជ្ឈិម**ទីពីរក៏ជាបទលួចដែរនោះ** បានសេចក្តីថា **បទមជ្ឈិមថ្មីនេះគឺពិតជាបទមជ្ឈិមដដែល** ហើយ។ ដោយឡែក សម្រាប់បទល្មើសខ្លះ ទោះបីជាអំពើដែលជាធាតុផ្សំសត្យានុម័តនៃបទល្មើសមាន ភាពខុសប្លែកគ្នា ក៏ច្បាប់បានចាត់ទុកថាជាបទល្មើសតែមួយ ដូចជាករណីនៃអំពើ ប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិពុលនាំឲ្យខូចសុខភាពទៅ ក្នុងទឹកសម្រាប់ហូបជាសាធារណៈ សកម្មភាពនេះត្រូវបានចាត់ទុកថាជាអំពើហិង្សាដោយចេតនា ហេតុដូច្នេះ អំពើខាងលើនេះត្រូវចាត់ទុកថាជាបទមជ្ឈិមដដែល តាមបទបញ្ញត្តិ ថាជាបទល្មើសប្រហាក់ប្រហែលគ្នា ហើយត្រូវបានបញ្ញត្តិនៅក្នុងផ្នែកមួយដូចគ្នាហិង្សាដោយចេតនា តាមខ្លឹមសារនៃមាត្រា ២២៧ នៃក្រមព្រហ្មទណ្ឌ ស្តីពីការមិនរាងចាលបាន។ យ៉ាងណាមិញ បទល្មើសខ្លះទៀតត្រូវបានចាត់បញ្ចូលដាក់ស្តែងដូចជាករណី បទប្រទូស្តកេរខ្មាស បទបង្ខាញកេរភេទ បទរុកគួនខាងផ្លូវភេទ ដែលក្រមព្រហ្មទណ្ឌបានចាត់ទុកថាជាបទល្មើសបំពានខាងផ្លូវភេទ ដទៃទៀត ។ បើយ៉ាងដូច្នេះ បើយោងតាមគោលការណ៍ខាងលើ តើបទល្មើសទាំងនេះត្រូវរាប់បញ្ចូលថាជាបទមជ្ឈិមដដែល

[144] មាត្រា ៨៤ កថាខណ្ឌទី៤ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ដើម្បីអាចឲ្យអនុវត្ត បទបញ្ញត្តិស្តីពីការមិនរាងចាលបានដែរឬទេ ? ការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង មិនគួរគប្បីចាត់ទុកថាបទល្មើសទាំងនោះ គឺជាបទមជ្ឈិមដដែល ដើម្បីអាចឲ្យយកបទបញ្ញត្តិនៃការមិនរាងចាលមកអនុវត្ត ក្នុងនោះឡើយ ពីព្រោះថាមាត្រា ៨៤ និងមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ **ពាក្យថា បទមជ្ឈិមដដែល គឺមិនមែន បទមជ្ឈិមប្រហាក់ប្រហែល** ទោះបីជាយ៉ាងណា យុត្តិសាស្ត្ររបស់តុលាការកម្ពុជាអាចកំណត់ផ្សេងពីនេះបាន កាលបើមានហេតុផលគតិយុត្តដ៏ត្រឹមត្រូវ។ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តបទបញ្ញត្តិនៃមាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ មាត្រា ៨៩ នៃក្រមព្រហ្មទណ្ឌតម្រូវឲ្យចាត់ទុក **បទលួច បទរំលោភលើទំនុកចិត្ត បទឆបោក ថាជា បទល្មើសដូចគ្នាដដែល** ចំណែកឯ **បទទទួលផលចោរកម្ម** ត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួល ប្រាក់នេះបានសម្រេច។ ហេតុដូច្នេះ ប្រសិនបើបុគ្គលម្នាក់ត្រូវបានផ្តន្ទាទោសជា ស្ថាពរពី បទលួច រួចហើយ ក្រោយមកក៏បានប្រព្រឹត្ត បទរំលោភលើទំនុកចិត្ត ទៀត គឺមានន័យថា បុគ្គលនេះបានប្រព្រឹត្ត បទល្មើសដដែល តាមអត្ថន័យ មាត្រា ៨៨ នៃក្រមព្រហ្មទណ្ឌ ដែលជាមូលហេតុនាំឲ្យតុលាការកំណត់ថាបទល្មើសថ្មីក្នុងស្ថានភាពមិនរាងចាល។

ឧទាហរណ៍ ៖ ដារ៉ា ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ចំនួន ១ឆ្នាំ បទលួច ទន្ទឹមនឹងនេះសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយជាស្ថាពរនៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១០។ ស្រាប់តែនៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១០ ដារ៉ា បានឆបោកមិត្តរួមថ្នាក់របស់គាត់យកបានទូរស័ព្ទមួយគ្រឿង។ ក្នុងករណីនេះ ត្រូវបានចាត់ទុកថាស្ថិតក្នុងស្ថានភាពមិនរាងចាល ពីព្រោះ ថា អំពើលួច ត្រូវបានចាត់ទុកថាជា បទមជ្ឈិមដដែល ជាមួយនឹង បទឆបោក។ ហេតុដូច្នេះ ទោសដែលត្រូវផ្តន្ទាលើឈ្មោះ ដារ៉ា ចំពោះ បទឆបោក គឺដាក់ពន្ធនាគារពី ៦ខែ (អប្បបរមានៃទោស) ទៅ ៦ ឆ្នាំ (អតិបរមានៃទោស) និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៦លានរៀល។

ក្រៅពីនេះ ក្រមព្រហ្មទណ្ឌបានអនុញ្ញាតឲ្យតុលាការយកការមិនរាងចាល មកធ្វើជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបានលុះត្រាតែមានចងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់។ តុលាការអាចអនុវត្តបទបញ្ញត្តិស្តីពីការមិនរាងចាលបានកាលបើជននេះបានទទួលរងនូវការផ្តន្ទាទោសជាស្ថាពរតែប៉ុណ្ណោះ ពោលគឺជាសេចក្តីសម្រេចដែលមិនអាចមានផ្លូវតវ៉ាបានទៀតទេ ។ លើសពីនេះទៅទៀត ទោះបីជា ទោសដែលកើតចេញពីការផ្តន្ទាទោសនោះ**ត្រូវផុតអាជ្ញាយុកាលក៏ដោយ** ក៏តុលាការ ត្រូវយកមកគិតសម្រាប់កំណត់ពីភាពមិនរាងចាលបានដែរ លើកលែងតែករណីដែល ទោសនោះ **ត្រូវបានលើកលែងទាំងស្រុងតាមការលើកលែងទោសជាទូទៅ** ដោយអនុលោមតាមបទបញ្ញត្តិ[145]។

[145] មាត្រា ៩០ ថ្មី កថាខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា។

រួមសេចក្តីមក ដើម្បីបង្ហាញឲ្យឃើញច្បាស់ពីអត្ថិភាពនៃការមិនរាងចាល ការកំណត់ពីអត្តសញ្ញាណកម្ម លើចារីគឺជារឿងចាំបាច់បំផុត ជាពិសេសគឺនៅពេល ដែលចារីបានខិតខំលាក់បាំងពីអត្តសញ្ញាណពិតប្រាកដរបស់ខ្លួន។ គួរកត់សម្គាល់ថា អត្តសញ្ញាណកម្មចារី អាចធ្វើបានតាមវិធីសាស្ត្រច្រើនយ៉ាង រួមមានដូចជា ការយកស្នាមម្រាមដៃរបស់ជនជាប់ចោទ មកធ្វើការប្រៀបធៀបជាមួយនឹងស្នាមម្រាមដៃ និងព័ត៌មានផ្សេងៗទៀត ដែលត្រូវបានកត់ត្រាទុកក្នុងសំណុំរឿងដោយអាជ្ញាធរមានរបស់ជនណាម្នាក់ អាជ្ញាធរតុលាការអាចស្នើសុំបញ្ជីថ្កោលទោសរបស់ជនដែល ពាក់ព័ន្ធពីក្រសួងយុត្តិធម៌មកពិនិត្យផ្ទៀងផ្ទាត់បាន[146]។

### គ. អានុភាពនៃការមិនរាងចាល

ដូចដែលបានបកស្រាយបង្ហាញនៅចំណុចខាងលើរួចហើយថា ការមិនរាងចាលនឹងនាំឲ្យមានការបន្ថែមទម្ងន់ទោស ទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ ដែលកំណត់ដោយច្បាប់ ទោះជាយ៉ាងនេះ អានុភាពនៃការមិនរាងចាលពីមុន មិនធ្វើឲ្យមានការកែប្រែប្រភេទនៃបទល្មើសពី បទមជ្ឈិម ទៅជាបទក្រិដ្ឋ ឡើយ។ សរុបមក ក្រៅពីការបន្ថែមទម្ងន់ទោសលើបទល្មើសថ្មី ការមិនរាងចាលធ្វើឲ្យជនល្មើសត្រូវបាត់បង់ឱកាសនឹងទទួលបាននូវវិធានការអនុគ្រោះទោសខ្លះៗពីតុលាការសម្រាប់រូបខ្លួន ដូចជាការដែលអាចព្យួរទោសបានជាដើម។

### ២.២.១.២.២ ស្ថានទម្ងន់ទោសដោយឡែក

ស្ថានទម្ងន់ទោសដោយឡែក គឺជាស្ថានទម្ងន់ទោសដែលត្រូវយកមកអនុវត្ត កាលបើច្បាប់បានចងដំជាក់លាក់ថាយ៉ាងដូច្នេះស្ថានទម្ងន់ទោសដោយឡែករួម មានច្រើនប្រភេទទៅតាមការកំណត់របស់អត្ថបទច្បាប់នីមួយៗ។ ជារួម ស្ថានទម្ងន់ទោសដោយឡែកត្រូវបានកំណត់ ដោយយោងទៅតាមស្ថានភាពរបស់ជនរងគ្រោះ ស្ថានភាពរបស់ចារី ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើជាសត្យានុម័តនៃបទល្មើស និងពហុភាពនៃបទល្មើស។

### ក. ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

ស្ថានភាពរបស់ជនរងគ្រោះ ដែលច្បាប់ព្រហ្មទណ្ឌច្រើន យកមកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើស មានដូចជា៖ ស្ថានភាពទន់ខ្សោយពិសេស ដោយមូលហេតុអាយុ (វ័យក្មេងពេក ឬចាស់ជរាពេក) មានជម្ងឺ មានពិការភាព ភាពមានគភ៌ (កាលបើស្ថានភាពនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង) គុណភាពរបស់ជនរងគ្រោះ (ជាសហព័ទ្ធ ឬក៏ជាអ្នករាជការសាធារណៈ) ដើម[147] ។

[146] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៣៦៣។

[147] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៣៦៥។

ឧទាហរណ៍៖ ក្នុងករណីនៃបទរំលោភសេពសន្ថវៈ ជនល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ឆ្នាំ បើតាមខ្លឹមសារនៃមាត្រា ២៣៩ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌ ប្រសិនបើការរំលោភសេពសន្ថវៈប្រព្រឹត្តទៅលើនារីមានគភ៌ ចាប់ពី ៦ ឡើងទៅ (ជាធម្មតានារីមានគភ៌ ៦ ខែ ត្រូវបានគេមើលឃើញជាក់ស្តែងតាមរយៈផ្ទៃពោះរបស់ស្ត្រីដែលពពោះ ការផ្តន្ទាទោសដាក់ពន្ធនាគារ គឺចាប់ពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ តាមអត្ថន័យនៃមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

### ខ. ស្ថានទម្ងន់ទោសទាក់ទងនឹងចារី

ស្ថានភាពរបស់ចារី ដែលច្បាប់ព្រហ្មទណ្ឌច្រើនយកមកធ្វើជាស្ថានទម្ងន់ទោសនៃបទល្មើសមានដូចជា៖ គុណភាពរបស់ចារីជាអ្នករាជការសាធារណៈ ជាសហព័ទ្ធ ជាអនីតិសង្វាសជន ជាជនដែលមានអំណាចលើជនរងគ្រោះ បុព្វញាតិ បច្ឆាញាតិ របស់ជនរងគ្រោះ ។ ជាងនេះទៅទៀត ចំនួននៃអ្នកប្រព្រឹត្តបទល្មើស (មានគ្នាច្រើនក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត) ក៏ជាមូលហេតុដែលជម្រុញឱ្យមានស្ថានទម្ងន់ទោសដែរ។ ឧទាហរណ៍៖ បទឧបឃាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ អនុលោមតាមមាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ ក៏ប៉ុន្តែបើក្នុង ករណីដែលអំពើនេះត្រូវបានប្រព្រឹត្តដោយ អ្នករាជការសាធារណៈ ឧបឃាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមមាត្រា ៤៥២ ថ្ងៃ នៃក្រមព្រហ្មទណ្ឌ[148]។

### គ.ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើជាសត្យានុម័តនៃបទល្មើស

ស្ថានទម្ងន់ទោសទាក់ទងនឹងអំពើជាសត្យានុម័តនៃបទល្មើសរួមមាន ០៦ (ប្រាំមួយ) ទម្រង់ដូចខាងក្រោម៖

- ក្រុមមានអ្នកចាត់តាំង៖ គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជា ( សន្និដ្ឋិភាព ដែលបានធ្វើឡើងដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន ។ មួយវិញទៀត ក្រុមមានការចាត់តាំង គឺជាក្រុមមនុស្សដែលត្រូវ បានបង្កើតឡើង ដោយមានការចាត់តាំងច្បាស់លាស់ និងមានគោលដៅ ប្រព្រឹត្តបទល្មើស[149]។
- ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើង មុនសកម្មភាព ប្រព្រឹត្តបទល្មើស។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀន ទៅលើរូបបុគ្គលនៃជនរងគ្រោះ[150]។
- ការកាប់គាស់ទម្លុះទម្លាយ ឬ ត្រូវចាត់ទុកដូចជា ការកាប់គាស់ទម្លុះទម្លាយ ការកាប់គាស់ទម្លុះទម្លាយ គឺជាអំពើបង្ខំធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញ គ្រឿងបិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ។ ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ៖

[148] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៣៦៦។

[149] មាត្រា ៧៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[150] មាត្រា ៧៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- ការប្រើប្រាស់កូនសោក្លែង
- ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត
- ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬបំផ្លិចបំផ្លាញបានទេ[151]។

- ការផ្លោះរបងចូល៖ ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយចូលតាមទ្វារ ឬបង្អួចដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ[152]។
- អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ៖ អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឱ្យមានរបួស។ ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ៖
    - វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង
    - វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង។

  ការប្រើប្រាស់សត្វដើម្បីសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធផងដែរ [153]។
- ការពួនស្ទាក់៖ ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តបទល្មើស [154]។

### ឃ. ស្ថានទម្ងន់ទោសដោយសារពហុបទល្មើស

ពហុបទល្មើស មានន័យថាបទល្មើសជាច្រើន[155]។ ថ្វីត្បិតតែក្រមព្រហ្មទណ្ឌបានចងពីការផ្តន្ទាទោសក្នុងករណីមានបទល្មើស ២ ត្រួតគ្នាក៏ដោយ ក៏ពេលខ្លះច្បាប់ព្រហ្មទណ្ឌបានកំណត់យកស្ថានភាពនៃការបបគត្តិយុត្តចំពោះបទល្មើសច្រើនមកធ្វើជាមូលហេតុនៃស្ថានទម្ងន់ទោសទៅវិញ។ ក្នុងករណីបែបនេះ តុលាការមិនយកវិធាននៃបទល្មើសត្រួតគ្នាមកអនុវត្ត ដោយត្រូវអនុលោមទៅ តាមបទបញ្ញត្តិច្បាប់ ដែលចាត់ទុកស្ថានភាពនៃការប្រព្រឹត្តបទល្មើសច្រើនដងយក មកធ្វើជាមូលហេតុនៃការកំណត់ស្ថានទម្ងន់ទោសវិញ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌ បានយកស្ថានភាពនៃការប្រព្រិត្តបទល្មើស ដែលបណ្តាលឲ្យជនរងគ្រោះស្លាប់បាត់បង់ ជីវិត ឬក៏

[151] មាត្រា ៧៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[152] មាត្រា ៨០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[153] មាត្រា ៨១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[154] មាត្រា ៨២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[155] យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៣៧២។

បណ្តាលឲ្យមានការកាត់អវយវៈ ឬបង្កឲ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬក៏ករណីដែលបទល្មើសប្រព្រឹត្តឡើងមុនពេល ក្នុងពេលពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ មកធ្វើជាស្ថានទម្ងន់ទោសសម្រាប់ផ្តន្ទាទោស។

**២.២.២ ករណីមានបទល្មើសត្រួតគ្នា(ពហុបទល្មើស)**

ការប្រព្រឹត្តបទល្មើសច្រើនអាចកើតមានឡើង ក្រោមករណីជារូបភាពច្រើនយ៉ាង។ ពេលខ្លះចារីបានប្រព្រឹត្តបទល្មើសរួចហើយ ថែមទាំងត្រូវបានទទួលទោសជាស្ថាពរទៀតផង ប៉ុន្តែក្រោយមកចារីនៅតែបន្តប្រព្រឹត្តបទល្មើសជាថ្មីថ្ងៃម្តងទផតក្នុងករណីនេះគេហៅថាជា ការមិនរាងចាល ដែលត្រូវបានយើងខ្ញុំលើកយកមករៀបរាប់ពីខាងលើរួចហើយ ជួនកាលទៀត ចារីបានប្រព្រឹត្តបទល្មើស ច្រើនដងក្នុងពេលតែមួយ ក្នុងពេលខុសៗគ្នាដោយចារីបានប្រព្រឹត្តបទល្មើសពីមុនម្តងហើយមិនទាន់បានទទួលទោសផង ស្រាប់តែទីប្រព្រឹត្តបទល្មើសមួយផ្សេងទៀត នៅមុនពេលដែលតុលាការបានផ្តន្ទាទោសចំពោះបទល្មើសមុនជាស្ថាពរ។ ករណីបែបនេះ គឺចូលទៅក្នុងរបបគត្តិយុត្ត នៃការត្រួតគ្នានៃបទល្មើស ឬបទល្មើសត្រួតគ្នា។ មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ នៅមុនពេលដែលបុគ្គលនេះ ត្រូវបានផ្តន្ទាទោសជាស្ថាពរចំពោះបទល្មើសមួយផ្សេងទៀត[156]។

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបាន ប្រកាសឲ្យប្រើដោយព្រះមហាក្សត្រកាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ចំពោះករណីមានបទល្មើសច្រើន(ពហុបទល្មើស) គេពិនិត្យឃើញមាននូវវិធានចំនួន ០៣ (បី) ដែលអាចយកមកអនុវត្តក្នុងករណី ៖ បទល្មើសត្រួតគ្នា គឺ វិធានស្រូបទោស, វិធានត្រួតទោស និង វិធានបូកទោស ការជ្រើសរើសយកវិធានណាមួយមកអនុវត្ត **ពេលខ្លះអាស្រ័យទៅលើនីតិវិធីនៃការចោទប្រកាន់ចំពោះបទល្មើសដែលត្រួតគ្នា** និងពេលខ្លះអាស្រ័យទៅលើប្រភេទនៃបទល្មើសដែលត្រួតគ្នា។

**២.២.២.១ វិធានស្រូបទោស**

វិធាននេះ គេយកទៅអនុវត្តបានសម្រាប់បទល្មើសត្រួតគ្នា ទាំងក្នុងនីតិវិធីនៃការចោទប្រកាន់តែមួយ និងក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ដោយឡែកពីគ្នា។

**២.២.២.១.១ ករណីចោទប្រកាន់តែមួយ**

វិធានស្រូបទោសតាមបទប្បញ្ញត្តិ មាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌថ្មី ត្រូវយកទៅអនុវត្តនៅក្នុងនីតិវិធីនៃការចោទប្រកាន់តែមួយចំពោះបទល្មើសត្រួតគ្នាទាំងអស់។ ការចោទប្រកាន់តែ ាមួយនេះ សំដៅដល់ស្ថានភាពនៃនីតិវិធី ដែលក្នុងនោះបទល្មើសត្រួតគ្នា ទាំងអស់ ត្រូវបានចោទប្រកាន់នៅក្នុង**លិខិតចោទប្រកាន់តែមួយ**ដូចជាការចោទបទល្មើសត្រួតគ្នានៅក្នុង**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតែមួយ**នៅក្នុងកំណត់ហេតុស្តីពីកា

[156] មាត្រា ១៣៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**បង្ហាញខ្លួនភ្លាមតែមួយ ឬក៏នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់តែមួយ។** ទន្ទឹមនឹងនេះដែរត្រូវបានចាត់ទុក ថាជាការចោទប្រកាន់តែមួយផងដែរ ក្នុងករណីដូចជា៖ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ចៅក្រមស៊ើបសួរបានទទួល **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីអយ្យការ** សម្រាប់អង្គហេតុនៃបទល្មើសថ្មីផ្សេង[157] ដែលចៅក្រមស៊ើបសួរបានរកឃើញថាមានការពាក់ព័ន្ធទៅនឹងជនត្រូវចោទ ហើយចៅក្រមស៊ើបសួរបានសម្រេចបិទការស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ សម្រាប់អង្គហេតុដែលបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។ ដូចគ្នាផងដែរនៅក្នុងករណីដែលសភាស៊ើបសួរ ពន្លាតការស៊ើបសួររបស់ខ្លួនទៅដល់បទល្មើសពាក់ព័ន្ធផ្សេងទៀត ស្របតាម បទប្បញ្ញត្តិមាត្រា ២៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ហើយបានបិទបញ្ចប់ការស៊ើបសួររបស់ខ្លួន តាមសាលដីកាបញ្ជូនទៅជំនុំជម្រះ សម្រាប់អង្គហេតុបង្កើតបានជាបទល្មើសត្រួតគ្នាទាំងនោះ។ នៅក្នុងករណី ដែលតុលាការសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌ ច្រើនជាមួយគ្នា ហើយនៅក្នុងសំណុំរឿងទាំងនេះ មានអង្គហេតុបង្កើតបានជាស្ថានភាពនៃបទល្មើសត្រួតគ្នា ( មាត្រា ២៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧)។ ករណីនេះ តុលាការត្រូវអនុវត្តវិធាននៃការស្រូបទោស ដោយស្វ័យប្រវត្តិស្របតាមបទប្បញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា បើទោះបីជាពុំមានបណ្តឹងសុំពីអយ្យការ ឬភាគីពាក់ព័ន្ធក៏ដោយ។

កាលបើនៅក្នុងពេល ចោទប្រកាន់តែមួយ ហើយជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវបានប្រកាសឡើង។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើន ហើយ **មានប្រភេទដូចគ្នា** តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ **នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ**[158] ។ ទោសនីមួយៗដែលប្រកាស ត្រូវចាត់ទុកថាជាទោសរួមចំពោះបទល្មើសដែលត្រួតគ្នា នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ។ វិធាននេះ ត្រូវយកទៅអនុវត្ត នៅក្នុងករណីទោសដែលត្រូវប្រកាស សម្រាប់បទល្មើសត្រួតគ្នាមានប្រភេទដូចគ្នា ដូចជាទោសដាក់ពន្ធនាគារដូចគ្នា ឬទោសពិន័យជាប្រាក់ដូចគ្នា ។ នៅក្នុងករណីនេះ ចំពោះទោសដែលមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយរួមគ្នា សម្រាប់បទល្មើសត្រួតគ្នាទាំងអស់ ហើយទោសដែលប្រកាសនេះ ត្រូវចាត់ទុកថាជាទោសរួម សម្រាប់ប្រភេទនៃទោសនីមួយៗ នៅក្នុងព្រំដែនអតិបរមាស្របច្បាប់អនុវត្ត ទៅលើបទល្មើសនីមួយៗ។

ឧទាហរណ៍ ៖ ឈ្មោះ "ក" បានប្រព្រឹត្តបទល្មើសក្នុងស្ថានភាពជាបទល្មើសត្រួតគ្នា រួមមាន ៖

- បទរំលោភសេពសន្ថវៈ ៖ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោស ដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

[157] មាត្រា ១២៥ នៃក្រមនីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[158] មាត្រា ១៣៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- បទកំហែងយក ៖ មាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌចែងផ្តន្ទាទោសដាក់ ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លានរៀល ទៅ ១០ លានរៀល។
- បទឆបោក ៖ មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ចែងផ្តន្ទាទោសដាក់ ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៦ លានរៀល។

នៅក្នុងឧទាហរណ៍នេះ ប្រសិនបើតុលាការយល់ឃើញថាត្រូវសម្រេចផ្តន្ទាទោស ៖

- ចំពោះបទរំលោភសេពសន្ថវៈ ៖ ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ។
- ចំពោះបទកំហែងយក ៖ ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ និងពិន័យជាប្រាក់ ៨ លានរៀល។
- ចំពោះបទឆបោក ៖ ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ និងពិន័យជាប្រាក់ ៤ លានរៀល។

យោងតាមមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ តុលាការត្រូវប្រកាសទោសតែមួយ ចំពោះប្រភេទនៃទោសដាក់ពន្ធនាគារ និងប្រកាសទោសតែមួយ ចំពោះប្រភេទនៃទោសពិន័យជាប្រាក់ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ មានន័យថា តុលាការអាចប្រកាសទោសដាក់ពន្ធនាគារ អតិបរមាច្រើនបំផុត ត្រឹមតែ ១០ ឆ្នាំ និងពិន័យជាប្រាក់អតិបរមាច្រើនបំផុត ១០ លានរៀល សម្រាប់បទល្មើសទាំង ៣ (បី) ខាងលើ ។

### ២.២.២.១.២ ករណីចោទប្រកាន់ដាច់ពីគ្នា

វិធានស្រូបទោស ក៏អាចយកទៅអនុវត្តបានផងដែរនៅក្នុង **នីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នា** ចំពោះបទល្មើសត្រួតគ្នា[159] យោងតាមបញ្ញត្តិនៃមាត្រានេះ និងយោងតាមបញ្ញត្តិនៃមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៧ តុលាការដែលអាចសម្រេចអំពីការស្រូបទោសបញ្ចូលគ្នាបាន គឺ**តុលាការដែលត្រូវសម្រេចចុងក្រោយគេ ឬតុលាការដែលបានសម្រេចចុងក្រោយគេ** ។ ប្រសិនបើសំណុំរឿងកំពុងស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួននៅឡើយតុលាការអាចសម្រេចដោយឯកឯងបាន អំពីការស្រូបទោសបញ្ចូលគ្នា។ ក្រៅពីនេះទៀត តុលាការអាចសម្រេចបានលុះត្រាតែបានទទួលបណ្តឹងសុំពីអយ្យការ ឬពីភាគីពាក់ព័ន្ធ (មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៧ ) ។ នៅក្នុងករណីចុងក្រោយនេះ តុលាការត្រូវសម្រេចក្នុងពេលសវនាការជាសាធារណៈ ក្រោយពីបានស្តាប់ អយ្យការ ភាគីពាក់ព័ន្ធ និងមេធាវីរបស់ភាគីនេះ។ ក្នុងគ្រប់ករណីទាំងអស់ ការស្រូបទោសបញ្ចូលគ្នាត្រូវធ្វើតាមសាលក្រមឬសាលដីកា របស់តុលាការ។ខ្លឹមសារនៃការអនុវត្តវិធាននេះ ក្នុងករណីដែលតុលាការសម្រេចអនុវត្តវិធានស្រូបទោស តុលាការអាចសម្រេចឲ្យអនុវត្តទោសស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នាបាន ស្របតាមរបៀបនៃការស្រូបទោសដែលមានចែងនៅក្នុងមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ។ ក៏ ប៉ុន្តែនៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះបទល្មើសត្រួតគ្នាណាមួយ ហើយប្រសិនបើជនជាប់ចោទមិនទាន់ត្រូវ

[159] មាត្រា ១៣៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

ទោសព្រហ្មទណ្ឌ បានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនៅឡើយទេ អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ នៅក្នុងការអនុវត្តវិធានស្រូបទោសនេះ ត្រូវបានកំណត់ដាក់ពន្ធនាគារ**មិនឲ្យលើសពី ៣០ (សាមសិប) ឆ្នាំ**។

### ២.២.២.២ វិធានត្រួតទោស

***វិធានត្រួតទោសនេះ*** មានចែងកំណត់នៅក្នុងមាត្រា ១៣៨ នៃក្រម ព្រហ្មទណ្ឌ ។ ជាគោលការណ៍ វិធានត្រួតទោសត្រូវយកមកអនុវត្តនៅក្នុងករណីដែលមាន **ការចោទប្រកាន់ដាច់ពីគ្នាចំពោះបទល្មើសត្រួតគ្នា**។ មាត្រា ១៣៨ វាក្យខណ្ឌ ទី ១ នៃក្រមព្រហ្មទណ្ឌថ្មី បានចែងថា នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើនទោសដែលត្រូវប្រកាស ***ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ ដែលខ្ពស់ជាងគេ*** នៅក្នុងករណីដែលច្បាប់ចែងផ្តន្ទាទោសដាក់ពន្ធនាគារ អស់មួយជីវិតចំពោះបទ ល្មើសត្រួតគ្នាណាមួយ ហើយប្រសិនបើជនជាប់ចោទ **មិនទាន់ត្រូវបាន** តុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ឆ្នាំ ។ ឧទាហរណ៍ ៖ ឈ្មោះ "ក" បានប្រព្រឹត្តបទល្មើសនៅក្នុងស្ថានភាពជា បទល្មើសត្រួតគ្នា រួមមាន ៖

- បទរំលោភសេពសន្ថវៈ ៖ មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។
- បទកំហែងយក ៖ មានចែងផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០ លានរៀល តាមមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។
- បទឆបោក ៖ មានចែងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១ លានរៀល ទៅ ៦ លានរៀល មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

នៅក្នុងឧទាហរណ៍នេះ ឈ្មោះ "ក" ត្រូវបានចោទប្រកាន់នៅក្នុង សំណុំរឿងចំនួន ៣ ដាច់ពីគ្នា ហើយតុលាការបានសម្រេចផ្តន្ទាទោសតាមសាលក្រម ឬសាលដីកាស្ថាពរចំនួន ៣ ដាច់ពីគ្នា ដោយសម្រេចផ្តន្ទាទោស៖

- ចំពោះបទរំលោភសេពសន្ថវៈ ៖ ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ។
- ចំពោះបទកំហែងយក ៖ ដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ និង ពិន័យជាប្រាក់ ៦ លានរៀល។
- ចំពោះបទឆបោក ៖ ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ និងពិន័យជាប្រាក់ ៤ លានរៀល ។

យោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ទោសដែលតុលាការ ប្រកាសផ្តន្ទាទោស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ ដែលខ្ពស់ជាងគេ មានន័យថា ទណ្ឌិតត្រូវទទួលរងនូវការអនុវត្តទោសដាក់ពន្ធនាគារជាអតិបរមាត្រឹម **១០ (ដប់) ឆ្នាំ** និងពិន័យជាប្រាក់ជាអតិបរមាត្រឹម ១០ លានរៀល សម្រាប់បទល្មើសទាំង ៣ ខាងលើ។

### ២.២.២.៣ វិធានបូកទោស

**វិធានបូកទោស** នេះយើងឃើញមានចែងកំណត់នៅក្នុងមាត្រា ១៤០ នៃក្រមព្រហ្មទណ្ឌ។ វិធានបូកទោសនេះត្រូវយកមកអនុវត្តចំពោះបទល្មើសត្រួតគ្នា **ទោះនៅក្នុងនីតិវិធីនៃការចោទប្រកាន់តែមួយក្តី ទោះនៅក្នុងនីតិវិធីនៃការចោទប្រកាន់ដាច់ពីគ្នាក្តី**។ មាត្រា ១៤០ នៃក្រមព្រហ្មទណ្ឌចែងកំណត់ អំពីវិធាននៃការបូកទោសនេះយ៉ាងច្បាស់ណាស់ថា ជាបដិប្បញ្ញត្តិទៅលើ បទប្បញ្ញត្តិ មុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យដែលប្រកាសឡើង **ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម**។ ការបូកបញ្ចូលគ្នានៃទោសនេះ ក៏ត្រូវបានយកទៅអនុវត្តផងដែរចំពោះ **ទោសដាក់ពន្ធនាគារ**។ បើយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា **១៤១** នៃ ក្រមព្រហ្មទណ្ឌ ទោសដែលតុលាការប្រកាសផ្តន្ទាពីបទរត់ចេញពីពន្ធនាគារត្រូវបូកបញ្ចូលគ្នាជាមួយនឹងទោសដែលប្រកាសឡើង ចំពោះបទល្មើសដែល នាំឲ្យមានការឃុំខ្លួនជននោះដោយមិនអាចមានការស្រូបចូលគ្នា ឬត្រួតគ្នា តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១៣៧ និង មាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌឡើយ។ គួរកត់សម្គាល់ផងដែរថា ការបូកបញ្ចូលគ្នានៃទោស ក៏ត្រូវយកទៅអនុវត្ត ផងដែរ នៅក្នុងករណីក្រៅពីស្ថានភាពនៃបទល្មើសត្រួតគ្នាជាអាទិ៍ **នៅក្នុងករណីដែលមានការដកហូតការព្យួរទោស** ( ទោះបីជាព្យួរទោសធម្មតាក្តី ព្យួរទោសសាកល្បងក្តី ) ដោយសារមានការផ្តន្ទាទោសថ្មីតាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១០៩ មាត្រា ១១៤ និងមាត្រា ១២២ នៃ ក្រមព្រហ្មទណ្ឌ។ នៅក្នុងករណីទាំងអស់នេះ ទោសទី ១ ត្រូវអនុវត្តដោយ បូកបញ្ចូលគ្នាជាមួយទោសទី២ ដោយគ្មានការស្រូបចូលគ្នា ឬត្រួតគ្នា តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១៣៧ និងមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌឡើយ។

ក្រៅពីវិធានទាំងបីខាងលើនេះ ចៅក្រមក៏អាចចាត់វិធានការមួយចំនួនផ្សេងទៀត ដើម្បីកំណត់ទោសដែលត្រូវផ្តន្ទាទោសលើចារីក្នុងលក្ខខណ្ឌច្បាស់លាស់កំណត់ដោយច្បាប់។ វិធានការទាំងនោះ រួមមាន៖ ការព្យួរទោស, ការផ្អាកការប្រកាសទោស, របបពាក់កណ្តាលសេរីភាព, ការបែងចែកទោសជាប្រភាគ។

### ២.២.២.៤ របបនៃការព្យួរទោស

#### ២.២.២.៤.១ និយមន័យនៃការព្យួរទោស

**ការព្យួរទោស** មានន័យថា ការប្រកាសនូវការព្យួរការអនុវត្តទោសគឺ ព្យួរនូវមូលទោសទាំងស្រុងឬក៏មួយផ្នែក។ ដូច្នេះ ការព្យួរទោស គឺគេព្យួរតែទៅលើមូលទោសទ គេមិនប្រកាសព្យួរទៅលើទោសបន្ថែម ឬក៏ទោសជំនួសនោះទេ។ ការព្យួរទោស គឺជាការលើកចោលដោយមានលក្ខខណ្ឌនូវការអនុវត្តមូលទោសដែលបានប្រកាសដោយតុលាការ។

### ២.២.២.៤.២ ប្រភេទនៃការព្យួរទោស

តាមរយៈក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា គេបានធ្វើការបែងចែក ការព្យួរទោស ជាពីរ (០២) ប្រភេទ គឺ៖ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង[160]។

**ក. ការព្យួរទោសធម្មតា**

ការព្យួរទោសធម្មតា គឺជាការព្យួរទោស ដែលមិនមានដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងមិនត្រូវគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើននោះទេ។

បើផ្អែកតាមមាត្រា ១០៦ ដល់ មាត្រា ១១៦ ការព្យួរទោសធម្មតា យើងខ្ញុំនឹងធ្វើការបកស្រាយលម្អិតទៅលើ ៖

**ក.១. ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម**

ការព្យួរទោសធម្មតា នេះចៅក្រមអាចធ្វើទៅបានគឺទាល់តែបំពេញនូវ លក្ខខណ្ឌចំនួន ២ (ពីរ) ៖ លក្ខខណ្ឌទី១ គឺទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន និងលក្ខខណ្ឌទី២ គឺទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរទោស។ ការព្យួរទោសធម្មតា មាន ពីរ ប្រភេទ៖ ការព្យួរទោសទាំងស្រុង និងការព្យួរទោសមួយផ្នែក។

**+ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**

ចំណុចនេះ គឺទាក់ទងនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ តុលាការអាចប្រកាសការព្យួរទោសបាន **លុះត្រាតែជនជាប់ចោទនេះមិនដែលមានការផ្តន្ទាទោសជាស្ថាពរពីមុនក្នុងរយៈពេល ៥ ឆ្នាំ** មានន័យថា **រហូតមកទល់នឹងថ្ងៃដែលគាត់ប្រព្រឹត្តបទល្មើសនោះ** គឺគាត់អត់មានត្រូវបានតុលាការ ផ្តន្ទាទោសណាមួយពីមុនជាស្ថាពរទេក្នុងរយៈពេល ៥ ឆ្នាំ[161]។

**+ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ**

ទោសដែលដាក់ពន្ធនាគារ ដែលមាន**រយៈពេលតិចជាង ឬស្មើ នឹង ៥ ឆ្នាំ** មានន័យថា ត្រឹម ៥ ឆ្នាំ តុលាការប្រកាសថាគាត់មានទោសត្រូវ **ដាក់ពន្ធនាគារត្រឹម ៥ ឆ្នាំ ចុះក្រោមហ្នឹង** គឺគាត់អាចជ្រើសរើសយកការព្យួរទោសនេះបាន។ ហើយករណីទោសពិន័យជាប្រាក់ ដែលជួនកាលតុលាការ ប្រកាសទោសពិន័យជាប្រាក់ ប្រសិនបើជាគាត់មិនចង់ឲ្យមានការអនុវត្តទេ ក៏គាត់អាចប្រកាសការព្យួរទោសបានដែរ[162]។

---

160 យោងតាមសៀវភៅ នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រទី ៤០៥។

161 មាត្រា ១០៦ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

162 មាត្រា ១០៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

**ក.២. ការចោទប្រកាន់ចំពោះបទលហុ**

ចំពោះការព្យួរទោសក្នុងបទលហុវិញ គឺមានលក្ខណៈខុសប្លែកគ្នាខ្លះ អំពីចិរវេលាដែលទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន។ វាគឺជាលក្ខខណ្ឌ ចាំបាច់ដែលផ្តល់ឲ្យតុលាការអាចសម្រេចពីការព្យួរទោសធម្មតា។ លក្ខខណ្ឌ នៅក្នុងការចោទប្រកាន់អំពីបទលហុនេះគឺមាន ០២ដែរ ហើយក៏មានចំណុច សំខាន់ផ្សេងៗទៀតដូចគ្នានឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែរគឺខុសត្រង់តែចិរវេលាប៉ុណ្ណោះ។

**+ លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**

ក្នុងករណីជននោះ មិនដែលទទួលការផ្តន្ទាទោសពីមុនក្នុងរយៈពេល ១ ឆ្នាំ មានន័យថា គាត់មិនត្រូវបានចៅក្រមផ្តន្ទាទោសណាមួយពីបទល្មើសណាមួយក្នុងរយៈពេល **០១ ឆ្នាំទេ។** ប្រសិនបើមានការផ្តន្ទាទោសពីមុននៅក្នុង រយៈពេល ១ ឆ្នាំ មិនអាចយកការព្យួរទោសចំពោះបទលហុនេះមកប្រើបានទេ[163]។

**+ លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរទោស**

ទោសអាចព្យួរបានចំពោះបទលហុនេះមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ពីព្រោះក្រមថ្មីយើងបានចែងថា ក្នុងករណីចោទប្រកាន់ពីបទលហុ ការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ៖ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[164]។

ដូចបានបញ្ជាក់ពីខាងលើ ចំពោះការព្យួរទោសធម្មតា មាន ពីរ ប្រភេទ៖ ការព្យួរទោសទាំងស្រុង និងការព្យួរទោសមួយផ្នែក។ **ការព្យួរទោសទាំងស្រុង** គឺព្យួរទាំងអស់ពុំឲ្យទណ្ឌិតអនុវត្តទោសនោះទេ។

រីឯ ការព្យួរទោសមួយផ្នែកវិញ តុលាការអាចប្រកាសព្យួរទាំងស្រុងក៏បាន ឬព្យួរមួយផ្នែកក៏បាន ពីព្រោះតុលាការអាចសម្រេចថា ការព្យួរទោសធម្មតា នេះអាចនឹងអនុវត្តទៅលើមួយផ្នែក នៃទោសពន្ធនាគារ ដែលតុលាការគឺជា អ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ ចំនួនទឹកប្រាក់ មានន័យថា បើសិនជាគាត់ចង់ប្រកាសឲ្យព្យួរទោសមួយផ្នែក នោះគឺត្រូវតែកំណត់ឲ្យបានច្បាស់លាស់នូវផ្នែកនៃទោសដែលត្រូវព្យួរ ដូចជា ប្រកាសព្យួរទោសទៅលើទោសដាក់ពន្ធនាគារ បើគាត់ចង់ព្យួរមួយផ្នែកនោះ គឺគាត់ត្រូវកំណត់ថារយៈពេលប៉ុន្មានដែលគាត់ឲ្យអនុវត្តហើយនិងរយៈពេលប៉ុន្មានថ្ងៃខែឆ្នាំដែលគាត់ត្រូវព្យួរមិនឲ្យជាប់គុកនោះ? ឧទាហរណ៍៖ តុលាការប្រកាសទោសចំពោះទណ្ឌិតណាមួយ ឧបមាថាឥឡូវត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ០២ ឆ្នាំទៅចុះ អញ្ចឹងគាត់សម្រេចថាមិនចង់ឲ្យ មានការព្យួរទាំងស្រុងទេ គាត់ថា ០១ ឆ្នាំ គឺត្រូវព្យួរ ០១ ឆ្នាំ ទៀតគឺត្រូវ

[163] មាត្រា ១១២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[164] មាត្រា ១១៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

អនុវត្ត។ គាត់ត្រូវតែប្រកាសកំណត់យ៉ាងច្បាស់លាស់នៅក្នុងសាលក្រមថាផ្តន្ទាទោស ដាក់ពន្ធនាគារ ០២ ឆ្នាំ ប៉ុន្តែ ០១ ឆ្នាំត្រូវព្យួរ នេះគឺត្រូវកំណត់ឲ្យជាក់លាក់[165]។

**ខ. ការព្យួរទោសសាកល្បង**

ការព្យួរទោសសាកល្បង គឺខុសគ្នាពីការព្យួរទោសធម្មតាដែលចែងនៅក្នុងក្រមព្រហ្មទណ្ឌ ខុសប្លែកពីការព្យួរទោសធម្មតា គឺត្រង់ការព្យួរទោសសាកល្បងមានអានុភាព ឲ្យជនជាប់ចោទស្ថិតក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកណាមួយ ឬច្រើនក្នុងរយៈពេលដែលត្រូវបានកំណត់ពីរយៈពេល ១ឆ្នាំ រហូតដល់ ៣ឆ្នាំ។ ចំពោះរយៈពេលនេះ ជនជាប់ចោទត្រូវទទួលរងនូវវិធានការត្រួតពិនិត្យមួយចំនួន និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនដែលច្បាប់បានកំណត់។

**ខ.១. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង**

យោងតាមមាត្រា ១១៧ កថាខណ្ឌទី១ ដើម្បីទទួលបានការព្យួរទោសសាកល្បងបាន ទាល់តែទណ្ឌិតនេះត្រូវបានតុលាការគាត់ប្រកាសទោសនៅចន្លោះពី ៦ (ប្រាំមួយ) ខែ ទៅ ៥(ប្រាំ) ឆ្នាំ។ តាមរយៈបញ្ញត្តិនេះ យើងអាចយល់បានថា ការព្យួរទោសសាកល្បងនេះអនុវត្តតែទោសដាក់ពន្ធនាគារប៉ុណ្ណោះ គឺមិនធ្វើការព្យួរសាកល្បងទៅលើទោសពិន័យជាប្រាក់នោះទេ[166]។

**ខ.២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែករបស់ទណ្ឌិត**

វិធានការត្រួតពិនិត្យ និងការព្វកិច្ចដោយឡែករបស់ទណ្ឌិត ចំពោះរយៈពេលសាកល្បងគឺមិនអាចតិចជាងរយៈពេល ១ឆ្នាំ ហើយក៏មិនត្រូវលើសពីរយៈពេល ៣ឆ្នាំឡើយ។ ដូចនេះ តុលាការត្រូវកំណត់រយៈពេលសាកល្បងឱ្យបានច្បាស់លាស់ នៅក្នុងសេចក្តីសម្រេចរបស់តុលា ការ។ ចំពោះវិធានការត្រួតពិនិត្យ គឺទណ្ឌិតត្រូវអនុវត្តតាមករណីដូចខាងក្រោមនេះ៖

យោងតាមមាត្រា ១១៩ នៃក្រមព្រហ្មទណ្ឌ វិធានការត្រួតពិនិត្យដែលតម្រូវលើទណ្ឌិតមានដូចតទៅ៖

- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ទណ្ឌិតត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។
- ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬ ដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារ សម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ។
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាស័យដ្ឋានរបស់ខ្លួន។

[165] មាត្រា ១០៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។
[166] មាត្រា ១១៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។

ក្រៅពីវិធានការត្រួតពិនិត្យហើយ តុលាការក៏អាចតម្រូវឱ្យទណ្ឌិតគោរពនូវការព្វកិច្ចដោយឡែក ឬអាចមានច្រើន នៅក្នុងសេចក្តីសម្រេចរបស់តុលាការ។ជាមួយគ្នានេះ តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែកដែលដាក់លើទណ្ឌិតបាន គឺនៅគ្រប់ពេលវេលាតុលាការអាចកែប្រែកាព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបាន។ យោងតាមមាត្រា១២០ នៃក្រមព្រហ្មទណ្ឌ វិធានការត្រួតពិនិត្យដែលតម្រូវលើទណ្ឌិតមានដូចតទៅៈ

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ។
- ទទួលការបង្ហាត់បង្រៀន ឬ ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។
- ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬ ការព្យាបាល។
- បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសតាមលទ្ធភាពនៃធនធានរបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬ សង្គមដែលអនុញ្ញាត ឬ សម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។
- មិនត្រូវសេពគប់បនល្បែង។
- មិនត្រូវសេពគប់តៀមភេសជ្ជៈស្រវឹង។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។
- មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ[167]

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិត។ ចំណុចនេះមានន័យថា សេចក្តីសម្រេចរបស់តុលាការត្រូវចង្អុលបង្ហាញពីកាតព្វកិច្ចដោយឡែកមួយ ឬច្រើនដែលត្រូវសម្រេចលើទណ្ឌិត ក៏ប៉ុន្តែតុលាការមិនអាចបង្ខំដល់ទណ្ឌិតឱ្យអនុវត្តកាព្វកិច្ចដែលពុំបានកំណត់នៅក្នុងកាតព្វកិច្ចដោយឡែកដូចបានរៀបរាប់ខាងលើទេ។

[167] មាត្រា ១១៩ និងមាត្រា ១២០ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

### ២.២.២.៥ របបនៃការផ្អាកការប្រកាសទោស

#### ២.២.២.៥.១ និយមន័យនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ គឺជាយន្តកាមួយដ៏ថ្មីស្រឡាងមាននៅក្នុងប្រព័ន្ធនៃនីតិវិធីព្រហ្មទណ្ឌក៏ដូចជាក្រមព្រហ្មទណ្ឌថ្មីរបស់កម្ពុជាយើងដែរ។

ការផ្អាកការប្រកាសទោស គឺជាការផ្អាកការប្រកាសទោសដោយតុលាការនូវទោសណាមួយ ដើម្បីអាចយកទោសនោះមកអនុវត្តបាននៅពេលក្រោយ[168]។

#### ២.២.២.៥.២ លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

តើការផ្អាកការប្រកាសទោសត្រូវប្រកាសដោយរបៀបណាខ្លះ? របបនៃការផ្អាកការប្រកាសទោសគឺធ្វើឡើងនៅក្នុងលក្ខខណ្ឌចំនួន ៤ គឺ ៖

**ក. បទល្មើសដែលត្រូវចោទប្រកាន់**

បទល្មើសដែលត្រូវចោទប្រកាន់ គឺអនុវត្តបានចំពោះតែបទល្មើសមជ្ឈិមប៉ុណ្ណោះ នេះមានអត្ថន័យថាជាស្ថានភាពមួយ នៅពេលដែលតុលាការធ្វើការចោទប្រកាន់អំពីបទមជ្ឈិម ហើយឈានទៅដល់ការសម្រេចប្រកាសទទួលស្គាល់ថា ជនជាប់ចោទមាន ពិរុទ្ធភាព ក៏ប៉ុន្តែចៅក្រមមិនប្រកាសទោសនៅពេលនោះតែម្តងទេ គឺគាត់ អាចផ្អាកការប្រកាសទោសនោះសិន។

**ខ. ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់**

មានន័យថា បើយើងគិតអំពីសារជាតិនៃបទល្មើសនេះ គឺសំដៅ តែទៅលើបទល្មើសស្រាលៗមួយចំនួនប៉ុណ្ណោះ ជាពិសេសគឺបទល្មើសដែល ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលផលប៉ះពាល់ ឬភាពរឹករវដែល បង្កឡើងដោយបទល្មើសវាទាក់ទងជាមួយនឹងការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ អ្នកដទៃនេះ វាមិនមានអានុភាពជាចិត្តសាស្ត្រ ឬក៏ធ្វើឲ្យរន្ធត់ទៅដល់សង្គម ទៅដល់ភូមិ ឃុំ ដែលបទល្មើសនោះបានកើតឡើងទេ ហេតុនេះវាអាចត្រូវ បានបញ្ឈប់ភ្លាមៗ។

**គ. ជនជាប់ចោទបានបង្ហាញនូវការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ**

បានន័យថា ពាក់ព័ន្ធអំពីឥរិយាបទរបស់គាត់ អំពីការសន្យារបស់ គាត់ថានឹងកែប្រែខ្លួនដើម្បីធ្វើជាពលរដ្ឋល្អនៅក្នុងសង្គមរបស់គាត់វិញ។

**ឃ. ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត**

បានសេចក្តីថា បើប្រកាសផ្តន្ទាទោសគាត់នៅពេលហ្នឹង គឺគាត់ អត់ទាន់មានលុយសងទេ ដូច្នេះគាត់សុំឲ្យទុករយៈពេលដល់គាត់ផង ដើម្បី ឲ្យគាត់មានពេលអាចទៅរកស៊ីប្រកបរបរ ឬក៏ ធ្វើការក្នុងគោលបំណងយក

[168] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី១១។

ចរិកាទៅជួសជុលការខូចខាត។ អញ្ចឹងយើងឃើញថា សារជាតិនបទល្មើស នេះគឺជាបទមជ្ឈិមហើយជាបទល្មើសដែលពាក់ព័ន្ធនឹងការធ្វើឲ្យខូចខាតនូវ ទ្រព្យសម្បត្តិរបស់អ្នកដ៏ទៃ ។ តែក៏អាចមានបទល្មើសផ្សេងៗទៀត ដូចជា បទល្មើសដែលច្បាប់ឲ្យឈ្មោះថា "អំពើហិង្សាស្រាល " ដែលនេះគឺអាចជា កម្មវត្ថុក្នុងការផ្អាកការប្រកាសទោសដែរ។

**ង. ជនជាប់ចោទត្រូវតែមានវត្តមាននៅពេលសវនាការ**

យោងតាមមាត្រា ១២៥ នៃក្រមបានកំណត់ថា ការផ្អាកការប្រកាសទោស អាចត្រូវបង្គាប់បានលុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ។ តុលាការកំណត់នៅក្នុងសាលក្រម ឬសាលដីកានូវកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស។

សេចក្តីសម្រេចអំពីទោស ត្រូវតែធ្វើឡើងយ៉ាងយូរបំផុត ១ (មួយ) ឆ្នាំ ក្រោយសេចក្តីសម្រេចផ្អាក។

ដូច្នេះ ទាល់តែបានបំពេញនូវលក្ខខណ្ឌនេះផងដែរ ទើបតុលាការអាច បង្គាប់ឲ្យផ្អាកការប្រកាសទោសទៅបាន ។ ហើយពិសេសនៅក្នុងសាលកម ឬសាលដីកា ដែលសម្រេចអំពីការផ្អាកការប្រកាសទោសនោះគឺតុលាការ កំណត់ពីរយៈពេលថាតើថ្ងៃណា ពេលណា ម៉ោងប៉ុន្មាន? ទើបយើងត្រូវបើក សវនាការសាជាថ្មីដើម្បីសម្រេចអំពីទោសចំពោះករណីនេះ ។ បើយោងតាម ក្រមព្រហ្មទណ្ឌ ក៏បានកំណត់ថាសវនាការដែលលើកឡើងដើម្បីសម្រេចអំពី ទោសទាក់ទងនឹងករណីនេះគឺមានរយៈពេលយ៉ាងយូរបំផុតត្រឹម ១ ឆ្នាំ[169]។

**២.២.២.៦ របបពាក់កណ្តាលសេរីភាព**

**២.២.២.៦.១ និយមន័យនៃរបបពាក់កណ្តាលសេរីភាព**

**របបពាក់កណ្តាលសេរីភាព** គឺជារបបនៃការអនុវត្តទោសដែលអនុញ្ញាតឲ្យទណ្ឌិតអាចចេញពីពន្ធនាគារទៅបំពេញសកម្មភាពវិជ្ជាជីវៈ ក្នុងរយៈពេលមានកំណត់[170] របបពាក់កណ្តាលសេរីភាពនេះ គឺជារបបមួយ ឬក៏ជាយន្តការថ្មីស្រឡាងមួយ ដែលទាក់ទងជាមួយ នឹងរបបទូទៅនៃការប្រកាសទោសនោះ គឺសុទ្ធតែក្នុងគោលដៅយើងហៅថា កែសម្រួលទណ្ឌិត និង ធានាថា អាចធ្វើសមាហរណកម្មទណ្ឌិតឲ្យចូលទៅ រួមរស់នៅក្នុងសង្គមវិញបានន័យថា នៅពេលដែលគាត់អនុវត្តទោសក្តី គាត់ ជាទណ្ឌិតក្តី តែសង្គមមិនចង់កាត់ផ្តាច់ទំនាក់ទំនងគ្រួសារ ទំនាក់ទំនងវិជ្ជាជីវៈ ទំនាក់ទំនងការងារ និងទំនាក់ទំនងក្នុងការសិក្សានៅក្នុងសង្គមនោះឡើយ។

**២.២.២.៦.២ លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព**

លក្ខខណ្ឌនានានៃរបបពាក់កណ្តាលសេរីភាពមានដូចខាងក្រោមនេះ ៖

- ទោសដាក់ពន្ធនាគារដែល**តុលាការប្រកាស**មានចំនួនតិចជាង ឬស្មើនឹង ៦ខែ។

[169] មាត្រា ១២៤ និងមាត្រា ១២៥ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[170] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀង ១៩៨។

- ដើម្បីអនុញ្ញាតឲ្យទណ្ឌិតបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជម្ងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ។

ចំណុចមួយនេះ គឺមានបទល្មើស ភាគច្រើនជាបទល្មើសមជ្ឈិមដែលតុលាការប្រកាសទោសមិនលើសពី ៦ ខែ ហើយក្រៅពីនោះ ក៏អាចមាននូវបទល្មើសឧក្រិដ្ឋមួយចំនួនដែលស្ថិតនៅក្នុងស្ថានភាពជាស្ថានសម្រាលទោសផងដែរ ដែលតុលាការឬចៅក្រមអាចប្រើ របបពាក់កណ្ដាលសេរីភាពបាន ពិសេសសម្រាប់អនីតិជន[171]

**២.២.២.៦.៣ បែបបទនៃរបបពាក់កណ្ដាលសេរីភាព**

ទណ្ឌិតដែលស្ថិតនៅក្រោម របបពាក់កណ្ដាលសេរីភាព ត្រូវបាន អនុញ្ញាតឱ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់ ។ ហើយតុលាការ កំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបាន អនុញ្ញាតឱ្យមានអវត្តមាននៅក្នុងពន្ធនាគារ[172]។

ឧទាហរណ៍ ៖ ថាដោយសារតែនិស្សិតម្នាក់ គាត់ធ្វេសប្រហែសធ្វើឲ្យជ្រុលដៃ ជ្រុលជើងបានបណ្ដាលឲ្យខ្លួនប្រព្រឹត្តបទល្មើស។ អញ្ចឹង តុលាការនៅពេល ដែលពិនិត្យទៅលើស្ថានភាពនោះរួចហើយ ដូច្នេះ ដើម្បីកុំឲ្យគាត់ផ្ដាច់អំពី ការសិក្សារបស់គាត់ ព្រោះនៅសល់ពេល ១ ខែទៀតទេ និស្សិតនោះត្រូវ ប្រឡងបញ្ចប់ ដើម្បីយកសញ្ញាបត្របរិញ្ញាបត្ររបស់គាត់ហើយ ។ ហេតុនេះ ប្រើរបបពាក់កណ្ដាលសេរីភាព បានន័យថា ពេលថ្ងៃឲ្យគាត់ទៅសាលារៀន ដល់ពេលយប់ ឬនៅម៉ោង ១៨ ល្ងាច ត្រូវចូលមកក្នុងគុកវិញ ហើយអ្នកត្រូវ យកសៀវភៅទៅអាននៅក្នុងគុកទៅ, ក៏ប៉ុន្តែពេលថ្ងៃអាចទៅរៀន ឬអាចទៅ ធ្វើអ្វីផ្សេងបាន។

**២.២.២.៧ របបនៃការបែងចែកទោសជាប្រភាគ**

**២.២.២.៧.១ និយមន័យនៃការបែងចែកទោសជាប្រភាគ**

ការបែងចែកទោសជាប្រភាគ គឺជាប្រភេទនៃស្ថានសម្រាលទោសមួយដែលតុលាការយល់ថាទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុ ធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[173]។

**២.២.២.៧.២ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ**

នៅក្នុងមាត្រា ១៣២ បានចែងអំពីលក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ៖

- កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថាទោសនោះត្រូវអនុវត្តបែងចែកជាប្រភាគ។

[171] មាត្រា ១២៧ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[172] មាត្រា ១២៨ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[173] សទ្ទានុក្រមពាក្យច្បាប់ ផ្នែកក្រមព្រហ្មទណ្ឌ ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀង ១០។

- ដោយសារតែមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម[174]

វាមានបទល្មើសមួយចំនួន គឺអាស្រ័យទៅមើលលើ សាលក្រមរបស់តុលាការ បើថាតុលាការសម្រេចដាក់ពន្ធនាគារមិនលើសពី ១ ឆ្នាំ ទេ ទោសនោះអាចអនុវត្តនៅក្រោមការបែងចែកទោសជាប្រភាគបាន។ ចំណុចនេះវាមានបទល្មើសភាគច្រើន គឺជាបទល្មើសមជ្ឈិម ដែលតុលាការ ប្រកាសទោសមិនលើសពី ១ ឆ្នាំឡើយ ក្រៅពីនោះ ក៏វាមាននូវបទល្មើស ឧក្រិដ្ឋមួយចំនួន ដែលស្ថិតនៅក្នុងស្ថានភាពជាស្ថានសម្រាលទោសផងដែរ ដែលតុលាការអាចប្រើរបបពាក់កណ្តាលសេរីភាពបាន ជាពិសេសគឺសម្រាប់ អនីតិជន។

**២.២.២.៧.៣ បែបបទនៃការបែងចែកទោសជាប្រភាគ**

ប្រភាគនៃទោសនីមួយៗមិនត្រូវតិចជាង **១ (មួយ) ខែទេ**។ ចិរវេលា សរុបនៃការអនុវត្តទោសមិនអាច**លើសពី ២ (ពីរ) ឆ្នាំ**ឡើយ ដោយរាប់បញ្ចូល ទាំងការផ្អាកការអនុវត្តទោស។ តុលាការកំណត់ក្នុងសេចក្តីសម្រេចរបស់ខ្លួន អំពីបែបបទនៃការបែងចែកទោសជាប្រភាគ [175]។ ដូច្នេះក្នុងឃ្លានេះ មានន័យថា ចំណុចនៃរូបមន្តក្នុងការបែងចែកទោសជាប្រភាគហ្នឹង គឺទោសគុកនីមួយៗ ត្រូវបែងចែកមិនឲ្យតិចជាង ១ខែឡើយ ហើយចិរវេលាដែលត្រូវអនុវត្តគឺ មិនត្រូវឲ្យលើសពី ២ ឆ្នាំទេ ដោយត្រូវបូកបញ្ចូលទាំងរយៈពេលនៃការផ្អាក ការអនុវត្តទោសផងដែរ។

ឧទាហរណ៍ ៖ តុលាការសម្រេចផ្តន្ទាទោសគាត់ដាក់គុក ១ ឆ្នាំ ដូច្នេះចូលទៅក្នុងលក្ខខណ្ឌនៃមាត្រា ១៣២ ហើយ។ ហេតុនេះ គាត់ត្រូវអនុវត្តឆ្លាស់គ្នា បើឆ្លាស់គ្នាទៅវាចូលទៅដល់ ២៤ ខែ ឬ ២ ឆ្នាំ ទើបអាចរួចអំពីការអនុវត្តទោសទាំងស្រុង ។ ដូចជាសម្រេចមួយឆ្នាំ ហើយថាខែនេះ គឺត្រូវនៅក្នុងគុក ដល់ខែក្រោយប្រពន្ធគាត់អត់នៅដោយសារជាប់បេសកកម្ម ឬជាប់ធុរអ្វីផ្សេងៗ ក៏នៅក្រៅគុក ។ ដល់ខែណាប្រពន្ធខ្លួនត្រឡប់មកវិញហើយ ទណ្ឌិតនោះត្រូវ មកចូលដេកក្នុងគុកវិញ ដូច្នេះគឺត្រូវឆ្លាស់គ្នាបែបហ្នឹងឯង ។ ហើយត្រូវចាំថា សម្រាប់ពេលនៅក្រៅគុកនោះក៏ត្រូវរាប់បញ្ចូលថាបានជាប់គុកហើយដែរ ។

174 មាត្រា ១៣២ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

175 មាត្រា ១៣៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

# ជំពូកទី៣៖
# អត្ថប្រយោជន៍នៃការអនុវត្តគោលការណ៍ឯកត្តកម្ម

## ផ្នែកទី១៖ ចំពោះជនជាប់ចោទ

### ១.១. ផ្តល់នាពត្រឹមត្រូវ និងយុត្តិធម៌ដល់ជនជាប់ចោទ៖

ឧទាហរណ៍៖ លោក ក មានអាយុ២០ឆ្នាំ បានធ្វើសកម្មភាពរួមបវេណីជាមួយ នារីឈ្មោះ ខ មានអាយុ ១៤ឆ្នាំ ម្នាក់ដោយបានព្រមព្រៀងគ្នា(ស្ម័គ្រចិត្ត) លុះក្រោយមក ឪពុកម្តាយ របស់នារី ខ ក៏បានដឹងហើយបានបង្ខំឲ្យនារី ខ ដាក់ពាក្យបណ្តឹងចំពោះលោក ក ពី **បទរំលោភសេពសន្ថវៈ** ដោយអនុលោមទៅតាមខ្លឹមសារនៃមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ[176] បើយើងសង្កេតមើលឲ្យច្បាស់នោះ យើងនឹងដឹងថាអវត្តមាននៃធាតុផ្សំអត្តនោម័ត ដូច្នេះ យោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ កំណត់ថា ពុំមានបទល្មើសទេ បើគ្មានចេតនប្រព្រឹត្ត[177] ។ ប៉ុន្តែ ថ្វីត្បិតតែការរួមបវេណីនេះ កើតចេញពីការព្រមព្រៀងក៏ដោយ អវត្តមាននៃធាតុផ្សំអត្តនោម័តក៏ដោយ ក៏លោក ក នៅតែទទួលទណ្ឌកម្មពី **បទរំលោភសេពសន្ថវៈដដែល** ពីព្រោះនីតិភាពនៃការរួមភេទច្បាប់បានកំណត់ជាក់លាក់ហើយថា គឺចាប់ពីអាយុ ១៥ឆ្នាំ ឡើងទៅ[178] ។ ដូច្នេះ លោក ក អាចត្រូវបានគេផ្តន្ទាទោសពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ប៉ុន្តែដោយសារអំពើដែលប្រព្រឹត្តគឺកើតចេញមកភាគីគឺសុទ្ធតែបានព្រមព្រៀងគ្នា មួយវិញទៀតលោក ក ក៏មានទំនួសខុសត្រូវខ្ពស់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ដូច្នេះ តុលាការគឺគួរតែសម្រេចដោយផ្អែកលើគោលការណ៍ឯកត្តកម្មដែលមានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌដើម្បីជាពុទ្ធិពិចារណាមុននឹងឈានទៅដល់កាសម្រេចសេចក្តីផ្តន្ទាទោសចំពោះលោក ក។

### ១.២. ការស្តារនីតិសម្បទា និងធ្វើសមាហរណ៍កម្មដើម្បីចូលរួមរស់ក្នុងសង្គមវិញ

គោលបំណងដែលនីតិករបង្កើតនូវគោលការណ៍នេះឡើងមក គឺវាគ្មានលក្ខណៈខុសគ្នាពីគោលបំណងនៃការបង្កើតទោសព្រហ្មទណ្ឌនោះទេ គឺធ្វើយ៉ាងណាឲ្យបុគ្គលដែលល្មើសច្បាប់បានទទួលរងទណ្ឌកម្មនូវអំពើដែលខ្លួនបានប្រព្រឹត្ត និងកែប្រែអប់រំជននោះឲ្យក្លាយជាបុគ្គលដែលអាចចូលមករួមរស់ក្នុងសង្គមវិញបាន។ ជនដែលប្រព្រឹត្តខុសគ្មានថ្ងៃដឹងកំហុសរបស់ខ្លួននោះទេ បើពុំបានទទួលរងទណ្ឌកម្ម ឬទោស ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

ឧទាហរណ៍៖ លោក ក បានប្រព្រឹត្តបទល្មើស រំលោភសេពសន្ថវៈ ទៅលើនារីម្នាក់ ផ្អែកតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ លោក ក ត្រូវទទួលទោស ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ [179] ត្រូវទៅដេកក្នុងគុគ បាត់បង់សិទ្ធិសេរីសព្វ

[176] មាត្រា ១៩៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[177] មាត្រា ៤ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[178] មាត្រា ១៩៩ កថាខណ្ឌទី៣ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

[179] មាត្រា ១៩៩ ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩។

គ្រប់បែបយ៉ាង ដូច្នេះ លោក ក ពិតជារាងចាលមិនហ៊ានប្រព្រឹត្តអំពើនោះទៀតទេ។ ផ្ទុយមកវិញ នៅក្នុងករណីដែលច្បាប់ពុំបានចែងកំណត់ពីគោលការណ៍ឯកត្តកម្មនេះមកទេ វានឹងធ្វើអោយមានភាពអសន្តិសុខខ្លាំងណាស់ដោយសារជនដែលប្រព្រឹត្តបទល្មើសពុំត្រូវបានផ្តន្ទាទោសឲ្យដឹងអំពីកំហុសរបស់ខ្លួននោះ មួយវិញទៀតបើកំណត់ឲ្យជនល្មើសសងត្រឹមសំណងការខូចខាតខាងផ្នែករដ្ឋប្បវេណី នោះនឹងបង្កឲ្យមានការដើររំលោភគេសុទ្ធតែអំពើរបស់ខ្លួនទៅហើយ ឧបមាថា រំលោភ ម្នាក់នេះ បង់ប្រាក់អស់តែ ១០លាន ចឹងរំលោភ ១០០ នាក់ទៀតក៏មិនទាន់ក្រដែរ។

**១.៣. ទទួលបានភាពកក់ក្តៅពីក្រុមគ្រួសារវិញ**

ដូចយើងបានដឹងហើយថា ការអនុវត្តទោស គឺគេអនុវត្តនៅក្នុងពន្ធនាគារ(គុគ) ជាទីកន្លែងមួយដែលត្រូវយកដាក់ដោយឡែកពីគេ ដូច្នេះទណ្ឌិតគឺត្រូវឃ្លាតឆ្ងាយពីក្រុមគ្រួសារ ញាតិមិត្ត បងប្អូនទាំងអស់ ធ្វើឲ្យបាត់បង់នូវការផ្តល់ភាពកក់ក្តៅ ភាពស្និតស្នាលចំពោះប្រពន្ធ កូន និងធ្វើឲ្យគ្រួសារមិនមានសុភមង្គលជាដើម។ ផ្ទុយមកវិញ នៅពេលដែលអនុវត្តគោលការណ៍នេះ វាអាចធ្វើឲ្យបុគ្គលដែលគិតចង់ប្រព្រឹត្តបទល្មើស លែងហ៊ានប្រព្រឹត្តវិញ និងមួយទៀតចំពោះទណ្ឌិតវិញគឺបានសិក្សាស្វែងយល់ពីកំហុសខុសឆ្គងរបស់ខ្លួន ដូច្នេះនៅពេលដែលចេញពីគុគវិញប្រាកដជាកែប្រែខ្លួន និងចេះផ្តល់ភាពកក់ក្តៅឲ្យគ្រួសារជាងពេលមុន។

**១.៤. មានឱកាសច្រើនក្នុងការស្តារកិត្តិយសរបស់ខ្លួនត្រឡប់មកវិញ**

ឧទាហរណ៍៖ នៅពេលដែលគេសួរថានរណាជា Iron Man? ហើយនរណាគេជាអ្នកដើរតួជា Tony Stark ក្នុងខ្សែស្រឡាយរឿងរបស់ MCU (Marvel Cinematic Universe) ដែលមានដូចជា Iron Man និង Avengers ជាដើមនោះ។ បុរសដែលដើរតួជាតួអង្គ Superhero មានអ្នកគាំទ្រ ស្រលាញ់និងចូលចិត្តច្រើន ហើយយើងតែងហៅថា **Tony Stark** នោះ គឺមានឈ្មោះពិតថា **Robert Downey Jr.**។ គាត់ទទួលបានកេរ្តិ៍ឈ្មោះល្បីខ្លាំងដំបូង បន្ទាប់ពីគាត់ដើរតួជា Tony Stark (ឈ្មោះក្នុងរឿង) នៅក្នុងខ្សែភាពយន្ត ដ៏ល្បីមួយមានឈ្មោះថា Iron Man កាលពីឆ្នាំ ២០០៨ ហើយបន្តទទួលបានការគាំទ្រ កាន់តែខ្លាំងបន្ថែមទៀត មកដល់ពេលបច្ចុប្បន្ននេះ។ លោក **Robert Downey Jr.** កើតនៅថ្ងៃទី ៤ ខែមេសា ឆ្នាំ ១៩៦៥ នៅទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិច។ លោកមានឪពុកឈ្មោះ Robert Downey Sr. និងម្តាយឈ្មោះ Elsie Downey បានទទួលមរណៈភាពកាលពីឆ្នាំ ២០១៤។ គាត់មានបងប្អូនពីរនាក់ ដោយមានបងប្អូនស្រីម្នាក់ ឈ្មោះថា Allyson Downey ជាតារាសម្តែងដូចគ្នា។ បើនិយាយពីប្រវត្តិស្នេហា របស់គាត់វិញ គាត់ធ្លាប់មានទំនាក់ទនងស្នេហា ជាមួយនារីច្រើននាក់ដែរ។ ដោយដំបូងគេ គាត់ចាប់ផ្តើមមានស្នេហា ជាមួយតារាសម្តែង Sarah Jessica Parker ចាប់ពីឆ្នាំ ១៩៨៤–១៩៩១ ហើយបានបែកគ្នា **ដោយសារតែការញៀនថ្នាំ** របស់លោក Robert Downey Jr.។ បន្ទាប់មកនៅឆ្នាំ ១៩៩២ លោកបានរៀបអាពាហ៍ពិពាហ៍ ជាមួយតារាចម្រៀង និងអតីតតារាសម្តែង Deborah Falconer

ហើយទទួលបាន កូនប្រុសម្នាក់ មានឈ្មោះថា Indio Falconer Downey។ ជាអកុសល គូស្វាមីភរិយាមួយគូនេះ បានជួបរឿងរកាំរកុះច្រើន ហើយបានសម្រេចលែងលះគ្នា នៅឆ្នាំ ២០០៤ ដោយសារតែលោក **នៅតែមានបញ្ហាជាមួយគ្រឿងញៀន** មិនដាច់ស្រេចសោះ។ បន្ទាប់ពីនោះនៅក្នុង អំឡុងឆ្នាំ ២០០៥ គាត់បានរៀបអាពាហ៍ពិពាហ៍ម្តងទៀត ជាមួយអ្នកផលិតភាពយន្ត មួយរូបឈ្មោះថា Susan Levin បន្ទាប់ពីបានមាន ទំនាក់ទំនងស្នេហាជាមួយគ្នា ប្រមាណជាពីរឆ្នាំមកនោះ។ Susan Downey នេះហើយ ជាភរិយារបស់គាត់រហូតមកដល់ បច្ចុប្បន្ននេះ ហើយពួកគាត់ក៏បង្កើតបានកូនប្រុសម្នាក់ នៅក្នុងឆ្នាំ ២០១២ មានឈ្មោះថា Exton Elias Downey និងបានកូនស្រីមួយទៀត នៅក្នុងឆ្នាំ ២០១៤ មានឈ្មោះថា Avri Roel Downey។ អញ្ចឹងសរុបមកវិញ មកដល់ពេលបច្ចុប្បន្ននេះ លោក Robert Downey Jr. មានកូនទាំងអស់ ៣ នាក់ ប្រុស ២ នាក់ និងកូនស្រីម្នាក់។ គាត់ចាប់ផ្តើមសម្តែងលើកដំបូងបង្អស់នៅអាយុ ៥ ឆ្នាំ គឺនៅក្នុងរឿងរបស់ឪពុក របស់គាត់តែម្តង ដែលមានចំណងជើងថា Pound (1970)។ ហើយបន្ទាប់ក្រោយៗមកទៀត គាត់ក៏បានចូលរួមសម្តែង ជាហូរហែក្នុងភាពយន្តជាច្រើន។ គាត់មានដំណែង ជាតួឯងប្រុសដំបូង គឺនៅក្នុងរឿង The Pick-up Artist នៅក្នុងឆ្នាំ 1987។ នៅក្នុងឆ្នាំ 1992 គាត់បានសម្តែងជាតួ Charlie Chaplin នៅក្នុងរឿង Chaplin ជារឿងមួយ ដែលគាត់ប្រឹងប្រែងខ្លាំងមែនទែន ដែលតម្រូវអោយគាត់រៀន លេងវីយូឡុង ក៏ដូចជារៀន វាយ Tennis ដោយប្រើដៃឆ្វេងផងដែរ ដោយធ្វើយ៉ាងម៉េច អោយដូចតួអង្គពិត Charlie Chaplin នោះ។ រឿងនេះហើយ ដែលធ្វើអោយគាត់បានក្លាយជា បេក្ខភាពមួយរូប ក្នុងការដណ្តើមជា Best Actor នៅក្នុងកម្មវិធី Academy Awards លើកទី 65 ដែលយើងស្គាល់ថា ជាពានអូស្កានោះឯង។ តែគួរអោយស្តាយ គាត់មិនបានជាប់ ជាម្ចាស់ជ័យលាភីនោះទេ។

**នៅឆ្នាំ 1996-2001 គាត់ត្រូវបានប៉ូលីសចាប់ខ្លួន ជាច្រើនលើកច្រើនសារ ពាក់ព័ន្ធនឹងករណី គ្រឿងញៀន ហើយក៏ធ្លាប់ជាប់ ពន្ធនាគារផងដែរ ដោសារគ្រឿងនេះឯង។** ដូចយើងដឹងអញ្ចឹង គ្រឿងញៀននេះហើយ ដែលបានធ្វើអោយគាត់ បែកបាក់ស្នេហា និងគ្រួសារពីរលើកមកហើយ។ គាត់ក៏បានសារភាពផងដែរថា ការញៀននេះ ចាប់តាំងពីគាត់មានអាយុ ប្រាំបីឆ្នាំមកម្លេះ ដោយដូចយើងដឹងស្រាប់ចឹងថា ឪពុករបស់គាត់ក៏ជាអ្នកញៀនថ្នាំផងដែរ ហើយឪពុកគាត់នេះហើយ ជាអ្នកអោយគាត់ ប្រើប្រាស់ថ្នាំញៀន។ បន្ទាប់ពីមានរឿងរ៉ាវនិងបញ្ហាច្រើនទាក់ទងនឹងជីវិតរបស់របស់គាត់ ជាពិសេសរឿងគ្រឿងញៀន អស់រយៈ ៥ ឆ្នាំ ដែលសឹងតែធ្វើអោយគាត់បាត់បង់ អាជីពសម្តែងនោះ គាត់ក៏បានចាប់ផ្តើមផ្តាច់ខ្លួន ពីការញៀននិងចាប់ផ្តើមការ សម្តែងរបស់គាត់ឡើងវិញ។ អាជីពសម្តែងរបស់គាត់ កាន់តែប្រសើរឡើងៗ បន្ទាប់ពីមានការជួយជ្រោមជ្រែង ពីសំណាក់មិត្តភក្តិជិតស្និទ្ធ របស់គាត់គឺលោក Mel Gibson ដោយទទួលបានតំណែងជាតួឯង ក៏ដូចជាតួរង នៅក្នុងរឿងផ្សេងៗទៀត នេះអាចសបញ្ជាក់បានហើយថានៅពេលដែលបានទទួលទណ្ឌកម្មវាមានភាគច្រើនក្នុងការកែប្រែបុគ្គលនោះឲ្យល្អឡើងវិញ។

ឧទាហរណ៍៖ ដើម្បីឲ្យកាន់តែច្បាស់យើងខ្ញុំ នឹងលើកយកតួរអង្គសម្ដែងរឿងដ៏ល្បីម្នាក់ទៀតនៅក្នុងខ្សែភាពយន្តហុងកុងគឺលោក Iam Ching Ying ដែលភាគច្រើនប្រជាពលរដ្ឋខ្មែរយើងស្គាល់គាត់តាមរយៈខ្សែភាពយន្តរឿងខ្មោចឆៅ ដែលគាត់អាចនិយាយបានថា ជាបុគ្គលដែលជោគជ័យខ្លាំងលើវិស័យខ្សែភាពយន្ត ប៉ុន្តែនៅពីក្រោយភាពជោគជ័យនេះ លោក Iam Ching Ying បានធ្វើការឆ្លើយតាមរយៈកិច្ចសម្ភាសថា មុននឹងទទួលបានភាពល្បីល្បាញ ក៏ដូចជាភាពជោគជ័យដូចសព្វថ្ងៃនេះ លោក បានដើរខុសផ្លូវជាច្រើលើកជាច្រើនសារ តាមរយៈការសេពគប់មិត្តភ័ក្រ្ត នៅក្នុងលោក ក៏បានលើកឡើងទៀតថា លោក មានប្រវត្តិធ្លាប់ជាប់ពន្ធនាគារ ពីបទ ហិង្សា (ការវាយតប) គ្នា ផងដែរ។

## ផ្នែកទី២៖ ចំពោះសង្គមជាតិ

### ២.១. សន្តិសុខ និងសុវត្ថិភាពសាធារណៈ

កាលណាសង្គមជាតិ ពោលពេញទៅដោយទណ្ឌិតច្រើននោះ នឹងធ្វើឲ្យប្រទេសជាតិ ពុំមានសន្តិសុខឡើយ ពីព្រោះកើតមាននូវបទល្មើសជារៀងរាល់ថ្ងៃ ការរំលោភបំពានផ្សេងៗនឹងកើតមានឥឈប់ឈរឡើយ។ ផ្ទុយមកវិញ បើកាលណាសង្គមជាតិមានច្បាប់ដោយកំណត់អំពីគោលការណ៍នៃការអនុវត្តច្បាប់បានច្បាស់លាស់ វានឹងជួយបង្ការដល់ការកើនឡើងនូវបទល្មើស នៅពេលដែលបទល្មើសអន់ថយនោះ សង្គមជាតិនឹងទទួលបានភាពសុខសាន្ត គ្មានភាពចលាចលដែលអាចបង្កឲ្យកើតមានភាពអសន្តិសុខនោះទេ។

### ២.២. អាចក្លាយជាប្រទេសនីតិរដ្ឋដូចប្រទេសដទៃទៀត

នៅពេលដែលប្រជាពលរដ្ឋទាំងអស់គោរពច្បាប់ដែលមានកំណត់នូវគោលការណ៍ដូចយើងខ្ញុំបានជម្រាបពីខាងដើមនោះ គេនឹងអាចវាយតម្លៃបានថាសង្គមនោះជាប្រទេសមួយដែលមានការគោរពច្បាប់បានល្អ នេះហើយជាកម្មវត្ថុមួយដែលអាចបណ្ដាលឲ្យប្រទេសនោះក្លាយទៅជាប្រទេសនីតិរដ្ឋ។

### ២.៣. បង្កើនសេដ្ឋកិច្ចជាតិ

សម្រប់វិនិយោគិនបរទេស ឬអ្នកវិនិយោគបរទេស ឬអ្នកជំនាញធំៗរបស់បរទេសវិញ ប្រសិនបើបានឃើញថាប្រទេសមួយនោះ មានទណ្ឌិតតិចតួច មានការអនុវត្តច្បាប់បានល្អ ពុំមានភាពអណាធិបតេយ្យ គឺច្បាស់ណាស់ ពួកគេនឹងហ៊ានមករកស៊ី ឬបណ្ដាក់ទន់នូវស្រុកខ្មែរ យើងច្រើន ពីព្រោះច្បាប់តឹងរឹងអាចការពារសុខសុវត្ថិភាពគេបានហើយ និងមួយទៀតពន្ធនាំចេញពីស្រុកយើងមានតម្លៃថោក។

### ២.៤. រដ្ឋពុំត្រូវចំណាយថវិកាច្រើន

ចំពោះចំណុចនេះ នៅពេលដែលមានទណ្ឌិតច្រើន រដ្ឋត្រូវតែចំណាយជាចាំបាច់ទៅលើ ថ្លៃសម្រាប់អាហារទណ្ឌិត និងប្រាក់ខែអ្នកយាមគុក សង់ពន្ធនាគារច្រើន ខាតទីតាំងដី បើយកទៅធ្វើដីសម្បទានគឺវាចំណេញជាងយកមកធ្វើគុក។

### ២.៥. ធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍ និងរីកចម្រើនលឿនលឿន

នេះអាចនិយាយបានថា ជារឿងធម្មតាទៅហើយ ក្នុងករណីដែលសេដ្ឋកិច្ចកើនឡើងនោះប្រទេស ក៏ដូច ជាសង្គមនោះច្បាស់ជាមានភាពជឿនលឿនជាងមុនជាក់ជាមិនខាន ដោយសារចំណុលជាតិគឺបានមកតាមរយៈ ផ្នែកសេដ្ឋកិច្ច ផ្នែកទេសចរណ៍ អីជាដើម ដើម្បីយកចំណុលទាំងនោះទៅផ្គត់ផ្គង់រដ្ឋផង និងសាងសាង់ហេដ្ឋា រចនាសម្ព័ន្ធដើម្បីលំអប្រទេសផង។

### ២.៦. លើកកម្ពស់មុខមាត់ប្រទេសជាតិ

នៅពេលដែលប្រទេសយើងអាចអនុវត្តតាមគោលការណ៍ដែលកំណត់ដោយច្បាប់ នោះវាច្បាស់ជាមិន អាចមានការរិះគន់នៅលើឆាកអន្តរជាតិ ក៏ដូចជាពីសំណាក់ជនបរទេស ដែលចាំតែឃ្លាំមើលនូវសកម្មភាព ទាំងឡាយរបស់រដ្ឋមុននឹងចាត់ទុកថាជាប្រទេសនីតិរដ្ឋពិតប្រាកដនោះ លើសពីនេះទៀតគឺយើងនឹងទទួលបាន តែពាក្យកោតសរសើរមកលើប្រទេសយើង។

### ២.៧. ជំរុញប្រព័ន្ធយុត្តិធម៌ឲ្យកាន់តែមានភាពត្រឹមត្រូវ និងសុក្រឹត្យ

ចំណុចនេះ បានន័យថា ជនណាប្រព្រឹត្តខុស ជននោះត្រូវទទួលខុសត្រូវចំពោះអំពើរបស់ដោយផ្ទាល់ ពុំអាចអនុញ្ញាតឲ្យបុគ្គលដទៃមកទទួលជំនួសនោះទេ ឬនិយាយម៉្យាងទៀតបានថា គ្រាន់តែសងសំណងខាង រដ្ឋប្បវេណីចប់រឿងនោះទេ ហើយរាល់ការសម្រេចអំពីទោសកំហុសតុលាការត្រូវតែថ្លឹងថ្លែងអំពីអំពើ និងទំហំ ព្យសនកម្មដែលបានកើតឡើងព្រមទាំងវៀរចាកនូវអគតិទាំង៤ ក្នុងពេលបំពេញមុខងារ និងប្រកាន់ខ្ជាប់នៅសុគតិ ទាំង ០៥គឺ ៖ វិរិយសម្បយុត្ត(សេចក្តីអត់ធ្មត់ សេចក្តីព្យាយាម) សុចរិតយុត្តិធម៌(ទៀងត្រង់) បញ្ញត្តិគារវោ(គោរព ច្បាប់ជាគោល) សមទណ្ឌោ ( កាត់ក្តីដោយយុត្តិធម៌ មិនលម្អៀង) និងបញ្ញាវុធវិនិច្ឆ័យ((ប្រើប្រាស់ប្រាជ្ញារបស់ខ្លួន ដែលមានធ្វើជាអាវុធសម្រាប់ការវិច្ឆ័យ)[180] អំពីអំពើ និងទំហំព្យសនកម្មដែលបានកើតឡើង។

[180] យោងតាមប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ យើងអាចសន្និតបានថា គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ គឺជាគោលការណ៍ដ៏សំខាន់មួយនៅក្នុងក្រមព្រហ្មទណ្ឌ សម្រាប់ជាមូលដ្ឋាននៅក្នុងការសម្រេចសេចក្តីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ចៅក្រមជាបុគ្គលដែលមានអំណាចឆន្ទានុសិទ្ធិ នៅក្នុងការវិនិច្ឆ័យសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌចំពោះបទល្មើសណាមួយលើបុគ្គលណាម្នាក់ ដើម្បីឱ្យមានភាពត្រឹមត្រូវ និងយុត្តិធម៌ តម្រូវឱ្យចៅក្រមនោះធ្វើការវិនិច្ឆ័យដោយពិចារណាស្របតាមលក្ខខណ្ឌមួយចំនួនដែលកំណត់ដោយច្បាប់។

ជាគោលការណ៍ធំៗរបបនៃការប្រកាសទោសព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងនូវគោលការណ៍សំខាន់ៗចំនួន ០២ គឺគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ។ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺសំដៅដល់ការទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ មានន័យថាបុគ្គលណាជាអ្នកប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវទោសព្រហ្មទណ្ឌ មិនអាចឱ្យអ្នកដទៃ ឬសាច់ញាតិរបស់ខ្លួនទទួលទោសជំនួសឡើយ ទោះបីទោសនោះជាប្រភេទទោសអ្វីក៏ដោយ ដែលស្របទៅនឹងគោលបំណងនៃការបង្កើតក្រមព្រហ្មទណ្ឌផងដែរ ដែលមានគោលបំណង ០៣(បី) គឺ គោលដៅអប់រំ កែប្រែ និងបង្ក្រាប ។ ដូច្នេះគ្រប់បុគ្គលទាំងអស់មិនថារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តីឲ្យតែប្រព្រឹត្តអំពើល្មើសនឹងច្បាប់ដែលជាធរមាន ហើយច្បាប់បានចែងកំណត់ទុកថាអំពើដែលប្រព្រឹត្តនោះជាបទល្មើស បុគ្គលទាំងនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល លើកលែងតែ រដ្ឋ ប៉ុណ្ណោះ។ ប៉ុន្តែលើកលែងចំពោះអនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ចំណែកគោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ គឺជាគោលការណ៍ដែលត្រូវបានបង្កើតឡើងទុកជាមូលដ្ឋានគ្រឹះដល់ចៅក្រមជំនុំជម្រះពិចារណាទៅតាមស្ថានភាពរបស់បុគ្គលម្នាក់ៗដែលបានប្រព្រឹត្តបទល្មើស ដើម្បីឈានទៅដល់ការប្រកាសទោសព្រហ្មទណ្ឌ។ លើសពីនេះទៅទៀត គោលការណ៍នេះក៏ជាមូលដ្ឋានសំខាន់ពាក់ព័ន្ធនឹងរបបទូទៅនៃការប្រកាសទោសរបស់តុលាការ ពោលគឺត្រូវប្រកាសទោសដោយគោរពគោលការណ៍ឯកត្តកម្មនៃទោសដែលអាចឱ្យចៅក្រមធ្វើការពិចារណាក្នុងការសម្រេចលើការប្រកាសមូលទោស ការប្រកាសទោសជំនួស ការប្រកាសទោសបន្ថែមលើមូលទោស ការប្រកាសទោសការងារសហគមន៍ ការព្យួរទោសធម្មតា ការព្យួរទោសសាកល្បង របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ ជាអាទិ៍។

ដូចនេះ យើងអាចសន្និដ្ឋានបាន គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ យើងមិនអាចឱ្យបុគ្គលផ្សេងក្រៅពីអ្នកប្រព្រឹត្តអំពើផ្ទាល់មកទទួលខុសត្រូវជំនួសអ្នកប្រព្រឹត្តអំពើល្មើសឡើយ ដោយហេតុថា ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺដាក់ទោសចំពោះតែជនណាបានប្រព្រឹត្តអំពើដែលផ្ទុយច្បាប់ ឬច្បាប់ហាមឃាត់ហើយដើម្បីដាក់ទោសទៅដល់ជនល្មើសឱ្យមានការរាងចាលថានឹងមិនប្រព្រឹត្តបទល្មើសតទៅទៀត។ ទាក់ទងទៅនឹង

ការដាក់ទោសទណ្ឌនេះ វាបានធ្វើឱ្យជនមួយចំនួនមានការខ្លាចរអាចំពោះការប្រព្រឹត្តខុសច្បាប់ ជាហេតុនាំឱ្យសង្គម ក៏ដូចជាប្រទេសជាតិមានសុខសន្តិភាព សុវត្ថិភាព មានសណ្ដាប់ធ្នាប់ល្អ និងធ្វើឱ្យប្រទេសជាតិឆ្ពោះទៅរកការរីកចម្រើនជឿនលឿន។ រីឯ គោលការណ៍ឯកត្តកម្មនៃទោសព្រហ្មទណ្ឌ គឺជាគោលការណ៍ពិសេសមួយដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតឡើងដើម្បីកំណត់ជាមូលដ្ឋានគ្រឹះមួយសម្រាប់ចៅក្រមជំនុំជម្រះធ្វើការថ្លឹងថ្លែង ពិចារណា និងប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយគោរពតាមគោលការណ៍នេះ ក្នុងការប្រកាសទោសព្រហ្មទណ្ឌ ទៅតាមកម្រិតនៃអំពើដែលជនជាប់ចោទបានប្រព្រឹត្ត និងទំហំព្យសនកម្មដែលបានបង្កដល់ជនរងគ្រោះ និងសង្គមជាតិ ដើម្បីផ្ដល់ភាពត្រឹមត្រូវ និងយុត្តិធម៌។

# អនុសាសន៍

# ការផ្តល់អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសយកប្រធានបទស្តីពី **គោលការណ៍ឯកត្តកម្មនៅក្នុងរឿងព្រហ្មទណ្ឌ** ដើម្បីជាការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររួចមក។ យើងខ្ញុំមានអនុសាសន៍ និងសំណូមពរនូវបញ្ហាខ្លះៗទាក់ទងនឹងប្រធានបទនេះផងដែរ។

## អនុសាសន៍មួយចំនួនទាក់ទងនឹងប្រធានបទ

## ១.ប្រជាពលរដ្ឋ

- ត្រូវគោរព និងអនុវត្តច្បាប់នៅក្នុចប្រទេសឲ្យបានខ្ជាប់ខ្ជួន
- ជៀសវាងការប្រព្រឹត្តបទល្មើស ដោយអារម្មណ៍មួយពេលដោយមិនដឹងខ្លួន
- បង្កើនចំណេះដឹងពាក់ព័ន្ធទៅនឹងប្រព័ន្ធយុត្តាធិការ។

## ២.ចៅក្រមជំនុំជម្រះ

- ត្រូវកាត់ក្តីប្រកបដោយយុត្តិធម៌ទាំងជនល្មើស និង ជនរងគ្រោះ
- ការជំនុំជម្រះត្រូវតែយុត្តិធម៌ និង ឆាប់រហ័ស
- ត្រូវកំណត់កាលបរិច្ឆេទជំនុំជម្រះឲ្យបានច្បាស់លាស់ ជៀសវាងមានការភ័ន្តច្រឡំ
- ត្រូវពិចារណា និងថ្លឹងថ្លែងអំពីអំពើ និងទំហំព្យសនកម្មដែលបានកើតឡើង ជាពិសេសមូលដ្ឋានច្បាប់ព្រហ្មទណ្ឌដែលបានកំណត់ជាធរមាន
- វៀរចាកនូវអគតិទាំង៤ ក្នុងពេលបំពេញមុខងារ និងប្រកាន់ខ្ជាប់នៅសុគតិទាំង ០៥គឺ ៖ វិរិយសម្បយុត្ត(សេចក្តីអត់ធ្មត់ សេចក្តីព្យាយាម) សុចរិតយុត្តិធម៌(ទៀងត្រង់) បញ្ញត្តិគារវោ (គោរពច្បាប់ជាគោល) សមទណ្ឌោ( កាត់ក្តីដោយយុត្តិធម៌ មិនលម្អៀង) និងបញ្ញាវុធវិនិច្ឆ័យ ((ប្រើប្រាស់ប្រាជ្ញារបស់ខ្លួនដែលមានធ្វើជាអាវុធសម្រាប់ការវិច្ឆ័យ)។
- ក្នុងនាមជាអ្នកផ្តល់នូវភាពយុត្តិធម៌ ការសម្រេចសេចក្តីត្រូវឈរលើឧត្តមគតិរបស់ខ្លួន។

## ក្រៅពីអនុសាសន៍មួយចំនួនខាងលើយើងខ្ញុំសូមសំណូមពរដូចខាងក្រោម៖

- សូមឲ្យអ្នកអនុវត្តច្បាប់ទាំងអស់អនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់
- មានឆន្ទៈរួម គឺយុត្តិធម៌ជូនបុគ្គលស្លូតត្រង់
- ការពារ និងផ្តល់យុត្តិធម៌ជូនបុគ្គលស្លូតត្រង់
- ដាក់ទណ្ឌកម្មចំពោះបុគ្គលដែលល្មើសច្បាប់ឲ្យសមនឹងទង្វើដែលគេបានប្រព្រឹត្ត
- លុបបំបាត់ឲ្យបាននូវអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គម

- គោរពច្បាប់ឲ្យបានតឹងរ៉ឹង ផ្តល់ទំនុបចិត្តដល់ប្រជាពលរដ្ឋដើម្បីឲ្យពួកគាត់មានភាពជំនឿលើប្រព័ន្ធយុត្តិធម៌
- បង្កើតនូវបទដ្ឋានគតិយុត្តិថ្មី ឬវិសោធនកម្មច្បាប់ចាស់ដែលខ្វះចន្លោះ ដើម្បីផលប្រយោជន៍សាធារណៈ
- មន្ត្រីអនុវត្តគួរតែគោរព និងអនុវត្តនូវអភិក្រមរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួន ដូចកាលដែលខ្លួនធ្វើសម្បថ។ល។

# ឯកសារយោង

## I. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

២. ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

៣. ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៤. ច្បាប់ព្រហ្មទណ្ឌអន្តរកាល (UNTAC) ឆ្នាំ១៩៩២។

៥. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៦. ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦។

៧. សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បងនៃក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។

៨. សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍ ឆ្នាំ២០១៤។

## II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. អនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងនឹងការធ្វើចរាចរគ្រឿងញៀនខុសច្បាប់ និង សារធាតុដែលប៉ះពាល់ប្រព័ន្ធសសៃប្រសាទ ឆ្នាំ១៩៨៨។

២. កតិកាសញ្ញាអន្តរជាតិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ២០០៩។

៣. ប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨។

## III. វចនានុក្រម និងសទ្ទានុក្រម

១. កម្មវិធីវចនានុក្រមអេឡិចត្រូនិចរបស់តម្រាច្បាប់ ឆ្នាំ២០២២។

២. សទ្ទានុក្រមច្បាប់ភូមិបាល ឆ្នាំ២០០១។

៣. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីដែលត្រូវរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់  និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០០៧។

៤. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌ ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ២០១១។

## IV. សៀវភៅ និងស្នាដៃនិពន្ធ

១. នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងកែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

២.នីតិព្រហ្មទណ្ឌ និងគ្រួសារ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៧។

៣. នីតិព្រហ្មទណ្ឌទូទៅ របស់សាស្ត្រាចារ្យ ជូន ប៊ុនធី ឆ្នាំ២០២០។

៤. សៀវភៅមរតកយុត្តិធម៌ខ្មែរ រៀបរៀងដោយបណ្ឌិត ហ៊ែល ចំរើន ឆ្នាំ២០០៩-២០១០។

៥. សៀវភៅទោសព្រហ្មទណ្ឌ រៀបរៀងដោយលោកមេធាវី កៅ សីហា ឆ្នាំ២០១៣។

V. **ប្រភពផ្សេងៗ**

១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បកស្រាយដោយ ឯកឧត្តម សាស្ត្រាចារ្យ ហ៊ី សោភា។ https://youtu.be/IRdjldeoy5s ។

២. ការទទួលខុសត្រូវព្រហ្មទណ្ឌ https://youtu.be/z34N9WQw7BE ។

៣. ទោសព្រហ្មទណ្ឌ វគ្គ១ https://youtu.be/gqJnaysbUkM ។

៤. ទោសព្រហ្មទណ្ឌ វគ្គ២ https://youtu.be/heFkCuuIUpY ។

៥. របបនៃការប្រកាសទោស វគ្គ១ https://youtu.be/6sAordnnbI8 ។

៦. របបនៃការប្រកាសទោស វគ្គ២ https://youtu.be/Qvl5cXrUUdE ។

៧.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន វគ្គ១ បកស្រាយដោយលោកមេធាវី តែ ចំណាន សមាជិកគណៈកម្មការព្រហ្មទណ្ឌ នៃគណៈមេធាវី https://youtu.be/YvvA9tzrTBc ។

៨.ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន វគ្គ២ បកស្រាយដោយលោកមេធាវី តែ ចំណាន សមាជិកគណៈកម្មការព្រហ្មទណ្ឌ នៃគណៈមេធាវី https://youtu.be/kCFQOtZ6m8o ។

៩. អនុសញ្ញាស្តីពីសិទ្ធិកុមារ https://www.unicef.org/cambodia/km ។

# ឧបសម្ព័ន្ធ៖

- ឧបសម្ព័ន្ធទី១៖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ចាប់ពីមាត្រា២៤ ដល់មាត្រា១៨២។
- ឧបសម្ព័ន្ធទី២៖ សាលក្រមព្រហ្មទណ្ឌ។
- ឧបសម្ព័ន្ធទី៣៖ សាលដីកាព្រហ្មទណ្ឌ។
- ឧបសម្ព័ន្ធទី៤៖ សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បងនៃក្រសួងយុត្តិធម៌ ឆ្នាំ២០១៤។
- ឧបសម្ព័ន្ធទី៥៖ សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍ ឆ្នាំ២០១៤។

# ឧបសម្ព័ន្ធទី១៖ ក្រមព្រហ្មទណ្ឌ ពីមាត្រា២៤ ដល់មាត្រា ១៨២

# ឧបសម្ព័ន្ធទី២៖ សាលក្រម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**

**-សំណុំរឿងព្រហ្មទណ្ឌលេខ** [redacted]

**ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២០**

**ជំនុំជម្រះលេខ** [redacted]

**ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨**

**សាលក្រមលេខ:** [redacted] **(ច)**

**ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១**

## <u>តាងនាមប្រជារាស្ត្រខ្មែរ</u>

## <u>សាលាដំបូងខេត្តកំពង់ស្ពឺ</u>

បានបើកសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ១២កើត ខែស្រាពណ៌ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដែលមានសមាសភាពដូចតទៅ ៖

**សមាសភាពជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី

ដោយមានលោក [redacted] និងកញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]

លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

**១-** ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ មុខរបរបុគ្គលិកក្រុមហ៊ុន [redacted] ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិចេក ឃុំស្គុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០២នាក់ ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី១២ ទោសពីមុនគ្មាន ។ *(ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ [redacted] ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៨)*

ពីបទ: *លួច* ប្រព្រឹត្តនៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

**២-** ឈ្មោះ [redacted] (ז[redacted]) ភេទស្រី អាយុ ៥២ឆ្នាំ មុខរបរកសិករ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូនចំនួន ០៤នាក់ ជានីតិជន កម្រិតវប្បធម៌បញ្ចប់ថ្នាក់បរិញ្ញាបត្រ ទោសពីមុនគ្មាន ។ *(ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ [redacted] ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៨)*

ពីបទ: ***ទទួលផលចោរកម្ម*** ប្រព្រឹត្តនៅភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា**៣៩៩** និងមាត្រា**៤០០** នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ កេទស្រី អាយុ ៦០ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្ននៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ អ.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-**បានឃើញ** ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ ។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ដចជ.រប/២០ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ។

-**បានឃើញ** ដីកាសម្រេចដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលើឈ្មោះ **ហាក់** លេខ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ ។

-**បានឃើញ** ដីកាសម្រេចដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលើឈ្មោះ លេខ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ ។

## ១-<u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីអំឡុងឆ្នាំ២០១៨ មានឈ្មោះ បានយកប្លង់ដីរបស់ឈ្មោះ នៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ យកទៅដាក់បញ្ចាំឲ្យគេ រួចក៏ទៅខ្ចីប្រាក់បន្ថែមពីឈ្មោះ ( ) នៅភូមិដក់ពរ សង្កាត់កណ្ដាលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ តាមរយៈឈ្មោះ ដោយឈ្មោះ បានឃើញឈ្មោះ ជំពាក់ប្រាក់ឈ្មោះ ( ) ច្រើន ទើបឈ្មោះ ទៅលស់ប្លង់នោះយកមកឲ្យឈ្មោះ ( ) រក្សាទុក ។ លុះដល់ឆ្នាំ២០២០ ទើបឈ្មោះ ដឹងថាបាត់ប្លង់ដីរបស់ខ្លួនក៏ទៅប្ដឹងអាជ្ញាធរភូមិឃុំ លុះក្រោយមកទៀត ទើបឈ្មោះ ទទួលដំណឹងថា ប្លង់ដីរបស់ខ្លួននៅនឹងដៃរបស់ឈ្មោះ ( ) ទើបឈ្មោះ ទៅទំនាក់ទំនងសុំដីរបស់ខ្លួនពិឈ្មោះ ( ) វិញ តែឈ្មោះ ( ) មិនព្រមឲ្យ ទើបឈ្មោះ ដាក់ពាក្យបណ្ដឹងមកតុលាការតែម្ដង ។

## ២-<u>នាពេលសវនាការ</u>

**២.១.** ក្រឡាបញ្ជីអានកំណត់ហេតុស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ បានឆ្លើយថាៈ ខ្លួនបានរៀបការជាមួយឈ្មោះ ដែលត្រូវជាកូនស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ តាំងពីឆ្នាំ២០១៥ ក្រោយរៀបការរួចខ្លួន និងប្រពន្ធឈ្មោះ បានមករស់នៅភូមិស្តុកអក ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឯម្ដាយក្មេករបស់ខ្លួនឈ្មោះ រស់នៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ប៉ុន្តែសព្វថ្ងៃខ្លួន និងប្រពន្ធរបស់ខ្លួនបានលែងលះគ្នាហើយ គឺខ្លួនបានលែងលះគ្នាក្នុងឆ្នាំ២០១៩ ។ ក្នុងឆ្នាំ២០១៨ អំឡុងពេលរស់នៅជាមួយគ្នានោះ ខ្លួនមិនបានខ្ចីប្លង់ដី ឬលួចយកប្លង់ដីម្ដាយក្មេករបស់ខ្លួននោះទេ ។ ចំពោះចម្លើយដែលឈ្មោះ បានឆ្លើយថា គាត់បានឮកូនរបស់គាត់ប្រាប់ថា "អ្នកដែលកាន់ប្លង់នោះបាននិយាយថា គាត់បានប្លង់ពីឈ្មោះ ដែលជារូបខ្លួននោះ គឺមិនពិតនោះទេ ។ អំឡុងពេលរស់នៅជាមួយគ្នានោះ ខ្លួនមិនធ្លាប់បានដឹងថាអតីតប្រពន្ធរបស់ខ្លួនសុំខ្ចីប្លង់ម្ដាយរបស់គាត់ ដើម្បីខ្ចីលុយធនាគារនោះទេ ។ ខ្លួនបានស្គាល់ឈ្មោះ ហៅ ហៅ ពេទ្យ ភេទប្រុស អាយុប្រហែល ២៨ឆ្នាំ មិនស្គាល់ទីលំនៅរបស់គាត់នោះទេ ។ ខ្លួនបានស្គាល់គាត់ ព្រោះក្នុងឆ្នាំ២០១៩ ពេលដែលខ្លួនលែងលះជាមួយប្រពន្ធរបស់ខ្លួនរួច ខ្លួនបានទៅធ្វើការនៅថ្នល់ទទឹង ដោយបានជួលផ្ទះគេស្នាក់នៅទីនោះ ហើយឈ្មោះ ក៏បានស្នាក់នៅជាប់ផ្ទះជួលរបស់ខ្លួនដែរ (ខ្លួនមិនដឹងថាឈ្មោះ រកស៊ីអ្វីនោះទេ ក៏មិនស្គាល់

ក្រុមគ្រួសាររបស់គាត់ដែរ) ខ្លួនស្គាល់គាត់គ្រាន់តែធ្លាប់បាននិយាយជាមួយគ្នាតែប៉ុណ្ណោះ ។ ខ្លួនមិនធ្លាប់បានខ្ចីលុយឈ្មោះ [redacted] នោះទេ ។ ចំពោះចម្លើយដែលឈ្មោះ [redacted] បានឆ្លើយថា បានឃើញខ្លួន និងអតីតប្រពន្ធឈ្មោះ [redacted] ទៅផ្ទះរបស់គាត់នោះ ខ្លួនមិនធ្លាប់បានទៅផ្ទះរបស់គាត់នោះទេ ។ ក្រោយលែងលះគ្នា អតីតប្រពន្ធរបស់ខ្លួនធ្លាប់បានតេទូរស័ព្ទមកឪពុកម្តាយបង្កើតរបស់ខ្លួន ហើយឪពុកម្តាយរបស់ខ្លួនក៏បានសួរមកខ្លួនថាមានបានយកប្លង់ម្តាយក្មេកដែរឬទេ? ខ្លួនក៏បានឆ្លើយប្រាប់ឪពុកម្តាយរបស់ខ្លួនថា ខ្លួនមិនបានយកទេ ខ្លួនឆ្ងល់ថាហេតុអ្វីបានជាគាត់ចោទខ្លួនថាយកប្លង់ដីម្តាយគាត់ តែខ្លួនធ្វើមិនដឹងមិនឮ ។ ខ្លួនមិនធ្លាប់បានស្គាល់ឈ្មោះ [redacted] និងឈ្មោះ [redacted] នោះទេ ។ នៅក្នុងរឿងហេតុនេះ ខ្លួនសូមសំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ឱ្យរូបខ្លួនផង ។

**២.២.** ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ ឈ្មោះ [redacted] យកប្លង់មកបញ្ចាំឈ្មោះ [redacted] ក្រោយមកឈ្មោះ [redacted] យកទៅបញ្ចាំងតទៀត ។ ក្រោយមកដោយអត់លទ្ធភាព ឈ្មោះ [redacted] ក៏យកប្លង់មកបញ្ចាំខ្លួន ហើយយកលុយទៅសងគេ ប្លង់នោះរក្សាទុកនៅខ្លួន ។ ឈ្មោះ [redacted] ជំពាក់លុយខ្លួនដែរ ទើបមកប្រាប់ខ្លួនថាឲ្យលោះប្លង់ឲ្យ ។ ឈ្មោះ [redacted] បានប្រាប់ថា បើចង់លក់ដី ម្ចាស់ប្លង់គេផ្តិតមេដៃឲ្យ ពីព្រោះគេក៏អត់លទ្ធភាពដែរ ។ ប្លង់នោះខ្លួនលស់ចំនួន ១១០០០ដុល្លារអាមេរិក ។ ក្រោយមកគេមកសុំប្លង់ពីខ្លួនវិញ ខ្លួនថាឲ្យលុយខ្លួនខ្លះមក តែគាត់ថាមិនមានទេ តែខ្លួនមិនឲ្យ ទើបមានរឿងដល់តុលាការតែម្តង ។ ពេលយកប្លង់មិនមានឯកសារអ្វីទេ ខ្លួនមិនមែនអ្នករកស៊ីចងការទេ ខ្លួនរៀនចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ។ គេជំពាក់ខ្លួនចំនួន ៦៥០០ដុល្លារអាមេរិក ។ ខ្លួនបានហៅម្ចាស់គេឲ្យមកយកប្លង់ពីខ្លួនដែរ តែគាត់មិនទាន់យក ។ ខ្លួនសុខចិត្តប្រគល់ប្លង់ឲ្យម្ចាស់គេវិញ ។

**២.៣.** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថាៈ កាលពីថ្ងៃខែ មិនចាំ អំឡុងឆ្នាំ២០១៨ វេលាម៉ោងប្រហែល១២ថ្ងៃត្រង់ ស្ថិតនៅភូមិប៉ាលហាល ឃុំចាន់សែន ឃុំឧដុង្គ ខេត្តកំពង់ស្ពឺ នៅផ្ទះរបស់ខ្លួន ថ្ងៃនោះបន្ទាប់ពីហូបបាយថ្ងៃរួចកូនស្រីរបស់ខ្លួនឈ្មោះ [redacted] បាននិយាយជាមួយខ្លួនថា "ម៉ែខ្លួនខ្ចីប្លង់ម៉ែសិនព្រោះខ្លួនចង់ខ្ចីលុយធនាគារ"ខ្លួនក៏បានដើររកប្លង់ដីនៅក្នុងផ្ទះ ទើបខ្លួនបានដឹងថាបាត់ប្លង់ដីមួយប្លង់ ដែលដីនោះមានទីតាំងស្ថិតនៅភូមិស្តុក ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ក្រោយខ្លួនមិនបានរកប្លង់ដែលបាត់នោះទៀតទេខ្លួនបានឱ្យប្លង់ដីផ្សេងទៀតឱ្យកូនស្រីរបស់ខ្លួនដើម្បីទៅខ្ចីលុយធនាគារ ។ ចុងឆ្នាំ២០១៩ខ្លួនក៏បានទៅរាយការណ៍នៅឃុំចាន់សែនថាខ្លួនបានបាត់ប្លង់ដី មិនដឹងថាបាត់ទៅណាទេ ក្រោយមកក្នុងឆ្នាំ២០២០ មេប៉ុស្តិ៍ឃុំចាន់សែន បានមកដល់ផ្ទះរបស់ខ្លួន ដោយបានយករូបថតមកឱ្យខ្លួនមើលដែលរូបថតនោះគេបានផុសក្នុង FACEBOOK ស្វែងរកម្ចាស់ប្លង់ ទើបខ្លួនដឹងថាប្លង់ដែលខ្លួនបាត់នោះ នៅគេ (មិនស្គាល់គេទេ) ។ ក្រោយមកខ្លួនក៏បានឱ្យកូនស្រីរបស់ខ្លួនឈ្មោះ [redacted] មកសុំអ្នកដែលបង្ហោះរូបប្លង់ដីរបស់ខ្លួនដើម្បីមើល (កូនស្រីរបស់ខ្លួន មកជាមួយប៉ូលីស) គេក៏បានថតចម្លងប្លង់ដីនោះឱ្យកូនស្រីរបស់ខ្លួនមើលទើបកូនរបស់ខ្លួនថាពិតជាប្លង់របស់ខ្លួនមែនក៏បាននិយាយជាមួយកូនរបស់ខ្លួនថា បើកូនរបស់ខ្លួនចង់បានប្លង់ដីនោះឱ្យកូនរបស់ខ្លួនយកលុយសងគេចំនួន១១.០០០ (មួយម៉ឺនមួយពាន់)ដុល្លារអាម៉េរិក ទើបគេព្រមឱ្យប្លង់ដីវិញរួចកូនរបស់ខ្លួនក៏បានត្រឡប់មកផ្ទះវិញ ។ ខ្លួនក៏បានទៅឃុំដើម្បីសួរនាំឃុំថា ខ្លួនអាចសុំប្លង់នោះបានមកវិញឬអត់ ទើបខាងឃុំប្រាប់ថា អត់បានទេទើបខ្លួនឱ្យកូនស្រីរបស់ខ្លួនដាក់ពាក្យបណ្តឹងឈ្មោះ [redacted] និងឈ្មោះ [redacted] មកតុលាការ ។ ខ្លួនប្តឹងឈ្មោះ [redacted] ព្រោះខ្លួនបានឮកូនរបស់ខ្លួនប្រាប់ថា គាត់បានសួរអ្នកដែលកាន់ប្លង់ខ្លួនថា បានប្លង់មកពីណា គេបានប្រាប់ថា បានមកពីឈ្មោះ [redacted] ប៉ុន្តែក្រោយមកពេលតុលាការកោះហៅមកតុលាការនៅដំណាក់កាលតំណាងអយ្យការ ឈ្មោះ [redacted] បានឆ្លើយថា បានមកពីឈ្មោះ [redacted] ដែលជាកូនប្រសាររបស់គេ។ អ្នកដែលកាន់ប្លង់នោះឈ្មោះ [redacted] ដោយសារស្គាល់គេដែលនៅជិតនោះ ។ ឈ្មោះ [redacted] ពីមុនត្រូវជាកូនប្រសាររបស់ខ្លួន ត្រូវជាអតីតប្តីរបស់កូនស្រីរបស់ខ្លួនឈ្មោះ [redacted] ពួកគេបានបែកគ្នា កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៩ ។ ពេលដែលបាត់ប្លង់នោះកូនប្រសាររបស់

ខ្លួនឈ្មោះ [redacted] មិនទាន់បែកជាមួយកូនស្រីរបស់ខ្លួននោះទេ គឺនៅរស់នៅជាមួយខ្លួន និងកូនស្រីរបស់ខ្លួន ក្រោយមកនៅពេលមេឃុំបានមកកេខ្លួននៅផ្ទះ និងបានប្រាប់ខ្លួនពីព័ត៌មានប្លង់ខ្លួន កូនស្រីរបស់ខ្លួនបានបែកគ្នាជាមួយឈ្មោះ [redacted] ហើយ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] នោះទេ ខ្លួនក៏មិនធ្លាប់ស្គាល់ឈ្មោះ [redacted] ដែរ ។ កាលនៅដំណាក់កាលតំណាងអយ្យការ តំណាងអយ្យការបានកោះហៅខ្លួន , ឈ្មោះ [redacted] និងឈ្មោះ [redacted] មកតទល់ ។ ដោយឈ្មោះ [redacted] បានឆ្លើយថា បានទទួលប្លង់ដីពីឈ្មោះ [redacted] ហើយឈ្មោះ [redacted] បដិសេធថាគាត់មិនបានយកប្លង់ខ្លួនទៅបញ្ចាំទេ បើថាគាត់យកឯណាស្នាមម្រាមដៃគាត់ ។

## ២.៤- សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី និងក្រោយពីបានពិនិត្យភស្ដុតាងនានាក្នុងសំណុំរឿងរួចមក តំណាងអយ្យការយល់ឃើញថា កាលពីអំឡុងឆ្នាំ២០១៨ មានឈ្មោះ [redacted] បានយកប្លង់ដីរបស់ឈ្មោះ [redacted] យកទៅដាក់បញ្ចាំឲ្យគេ រួចក៏ទៅខ្ចីប្រាក់បន្ថែមពីឈ្មោះ [redacted] តាមរយៈឈ្មោះ [redacted] ដោយឈ្មោះ [redacted] ។ លុះដល់ឆ្នាំ២០២០ ទើបឈ្មោះ [redacted] ដឹងថាបាត់ប្លង់ដីរបស់ខ្លួនក៏ទៅប្ដឹងអាជ្ញាធរភូមិឃុំ [redacted] លុះក្រោយមកទៀតទើបឈ្មោះ [redacted] ទទួលដំណឹងថា ប្លង់ដីរបស់ខ្លួននៅនឹងដៃរបស់ឈ្មោះ [redacted] ទើបឈ្មោះ [redacted] ទៅទំនាក់ទំនងសុំដីរបស់ខ្លួនពីឈ្មោះ [redacted] វិញ តែឈ្មោះ [redacted] មិនព្រមឲ្យ ទើបឈ្មោះ [redacted] ដាក់ពាក្យបណ្ដឹងមកតុលាការប្រាកដមែន ។ ដូច្នេះតំណាងអយ្យការស្នើសុំលោកចៅក្រមជំនុំជម្រះផ្ដន្ទាទោសលើឈ្មោះ [redacted] ដាក់ពន្ធនាគារពីបទ លួច តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល និងស្នើសុំដាក់ពន្ធនាគារក្នុងម្នាក់ៗរយៈពេល ០២ ឆ្នាំ ។

## ២.៥- សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ប្រាក់ ស៊ីលន ធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ ៖ ក្រោយពីបានពិនិត្យសំណុំរឿង និងស្ដាប់ការពិភាក្សាដេញដោលក្នុងសវនាការបានចប់សព្វគ្រប់ ឃើញថា គ្មានភស្ដុតាងស៊ីសង្វាក់ណាមួយ ដែលបញ្ជាក់អំពីអត្ថិភាពនៃបទល្មើសលួចនោះទេ ហេតុនេះធាតុផ្សំទី១ នៃបទទទួលផលចោរកម្មមិនត្រូវបានបំពេញ ។ កូនក្ដីខ្លួនទទួលប្លង់នោះមកក្សាទុក គឺមិនមែនដោយសាថាដីនោះបានមកពីបទលួច ហើយខ្លួននៅតែទទួលទុកនោះទេ ។ ផ្អែកតាមទិដ្ឋភាពអង្គហេតុ និងការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថាគ្មានធាតុផ្សំបទល្មើស និងគ្មានភស្ដុតាងដាក់បន្ទុកមកលើកូនក្ដីខ្លួនពីបទទទួលផលចោរកម្មតាមមាត្រា៣៩៩ នៃក្រមព្រហ្មទណ្ឌទេ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សូមស្នើសុំឲ្យលោកចៅក្រមមេត្តាសម្រេចឲ្យកូនក្ដីខ្លួន រួចខ្លួនពីបទចោទ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ២.៦- សម្ដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] បានសំណូមពរមកកាន់តុលាការ សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាលើកស្តុតាងនានាក្នុងសំណុំរឿងចប់សព្វគ្រប់ហើយ

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## ៣-**<u>សំអាងហេតុ</u>**

**៣.១.** កាលពីអំឡុងឆ្នាំ២០១៨ ឈ្មោះ [redacted] រស់នៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បាននិយាយថាប្លង់ដីរបស់ខ្លួនត្រូវបានអតីតកូនប្រសារឈ្មោះ [redacted] លួចយកទៅបញ្ចាំ ។ ក្រោយមកក៏ទទួលដំណឹងថា ប្លង់ដីរបស់ឈ្មោះ [redacted] នៅនឹងដៃរបស់ឈ្មោះ [redacted] ទើបឈ្មោះ [redacted] ទៅទំនាក់ទំនងសុំប្លង់ដីពីឈ្មោះ [redacted] វិញ ប៉ុន្តែឈ្មោះ [redacted] មិនព្រម ទើបឈ្មោះ [redacted] ដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។ ក្រោយពីទទួលបានបណ្តឹង អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ សម្រេចចោទប្រកាន់ឈ្មោះ [redacted] ពីបទលួច និងឈ្មោះ [redacted] ពីបទទទួលផលចោរកម្ម ។

**៣.២.** ផ្អែកតាមដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ [redacted] ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពរលេខ [redacted] **អ.ក** ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានសម្រេចចោទប្រកាន់ជាស្ថាពរលើជនជាប់ឈ្មោះ [redacted] ពីបទលួច តាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ និងចោទប្រកាន់លើឈ្មោះ [redacted] ពីបទទទួលផលចោរកម្ម តាមបញ្ញត្តិមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

**៣.៣.** ផ្អែកតាមអំណានចម្លើយរបស់ឈ្មោះ **វ៉ន សុខហាក់** បានឆ្លើយថា ខ្លួនមិនបានលួចយកប្លង់របស់អតីតម្តាយក្មេកនោះទេ ហើយក៏មិនដឹងថាអតីតប្រពន្ធរបស់ខ្លួនបានខ្ចីប្លង់របស់ម្តាយក្មេក ដើម្បីទៅខ្ចីប្រាក់ពីធនាគារដែរ ។

**៣.៤.** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ **ប្រាក់ ស៊ីលន** បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនពុំបានដឹងថាប្លង់ដីដែលឈ្មោះ មុយ បារាំង យកមកបញ្ចាំខ្លួននោះគេបានមកពីណានោះទេ ខ្លួនមិនមែនជាអ្នករកស៊ីចងការនោះទេ ដោយសារតែឈ្មោះ មុយ បារាំង ជំពាក់ខ្លួនផង ទើបខ្លួនយល់ព្រមលស់ប្លង់នោះឲ្យទៅ ។

**៣.៥.** ផ្អែកលើចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនានា តុលាការយល់ឃើញថា ការបដិសេធរបស់ជនជាប់ចោទនាពេលសវនាការទុកជាត្រឹមត្រូវ អាចឲ្យតុលាការយកជាមូលដ្ឋានសម្រេចបាន ។

**៣.៦.** ផ្អែកតាមចម្លើយរបស់ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនាពេលសវនាការ បញ្ជាក់ឲ្យឃើញថាជនជាប់ចោទមិនបានប្រព្រឹត្តអំពើលួច និងទទួលផលចោរកម្ម កាលពីអំឡុងឆ្នាំ២០១៨ នៅចំណុចភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ ហេតុដូច្នេះតុលាការយល់ឃើញថាចម្លើយបដិសេធរបស់ជនជាប់ចោទនាពេលសវនាការអាចជឿបាន ពុំមានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកទៅលើឈ្មោះ **វ៉ន សុខហាក់** និងឈ្មោះ **ប្រាក់ ស៊ីលន** នៅក្នុងការប្រព្រឹត្តនេះទេ នោះគ្រាន់តែជាវិមតិសង្ស័យ ហេតុនេះតុលាការគប្បីលើកយកចំណុចវិមតិសង្ស័យនេះ ដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ ដែលរដ្ឋធម្មនុញ្ញបានចែងនៅក្នុងមាត្រា ៣៨ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះតុលាការយល់ឃើញថាពុំមានពិរុទ្ធភាពទៅលើជនជាប់ចោទទេ ។

**៣.៧.** តំណាងអយ្យការបានសន្និដ្ឋានសុំឲ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទក្នុងម្នាក់ៗកំណត់រយៈពេល ០២ឆ្នាំនោះ តុលាការបានពិចារណារួចហើយ ។

**៣.៨.** តាមសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ដែលការពារសិទ្ធិឲ្យជនជាប់ចោទ បានស្នើសុំឲ្យតុលាការសម្រេចឲ្យរួចខ្លួនរួចផុតពីបទចោទ នោះតុលាការបានពិចារណារួចហើយ ។

**៣.៩.** ពុំមានធាតុផ្សំ និងពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ ពីបទ: **លួច** ប្រព្រឹត្តនៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**៣៥៣** មាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ និងជនជាប់ចោទឈ្មោះ ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៨ មាត្រា**៣៩៩** និងមាត្រា**៤០០** នៃក្រមព្រហ្មទណ្ឌ ។

**៣.១០.**តាមសម្តីចុងក្រោយរបស់ជនជាប់ចោទបានសំណូមពរមកតុលាការ នោះតុលាការបានពិចារណារួចហើយ ។

## ៤-<u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>

**៤.១. ឲ្យរួចខ្លួនពីបទចោទលើឈ្មោះ ៖**

**ក.** ឈ្មោះ ភេទប្រុស អាយុ ២៥ឆ្នាំ (មានសាវតាជាតិគ្រប់គ្រាន់)

ពីបទ: *លួច* ប្រព្រឹត្តនៅភូមិប៉ាលហាល ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា**៣៥៦** នៃក្រមព្រហ្មទណ្ឌ ។

**ខ.** ឈ្មោះ ( ) ភេទស្រី អាយុ ៥២ឆ្នាំ (មានសាវតាជាតិគ្រប់គ្រាន់)

ពីបទ: ***ទទួលផលចោរកម្ម*** ប្រព្រឹត្តនៅភូមិដក់ពរ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា**៣៩៩** និងមាត្រា **៤០០** នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះត្រូវបានជំនុំជម្រះជាសាធារណៈនៅថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងកំបាំងមុខជនជាប់ចោទឈ្មោះ ។

បើកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

---

"ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស២៥៦៥

ខេត្តកំពង់ស្ពឺ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រមជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
-សំណុំរឿងព្រហ្មទណ្ឌ
លេខ [redacted]
ចុះថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០១៧
ជំនុំជម្រះលេខ [redacted]
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
សាលក្រមលេខៈ [redacted] (ប)
ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ០៨កើត ខែផល្គុន ឆ្នាំជូត ទោស័ក ពស២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ដែលមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

ដោយមានលោក [redacted] លោក [redacted] និងលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ។

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងទាស់ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទៅលើសាលក្រមព្រហ្មទណ្ឌលេខៈ [redacted] **(ជ)** ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ដែលមានសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

**១**-ឈ្មោះ [redacted] ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ប្តីឈ្មោះ [redacted] ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មានព័ត៌មាន ។

**២**-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ប្រពន្ធឈ្មោះ [redacted] ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មានព័ត៌មាន ។

ពីបទៈ **ឆបោក** ប្រព្រឹត្តនៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៣៧៧** និងមាត្រា**៣៧៨** នៃក្រមព្រហ្មទណ្ឌ ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ [redacted] ដ.ស.៧/២០ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

**-បានឃើញ** ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ [redacted] ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ ។

**-បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ [redacted] ដចជ.រប/២០ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ [redacted] (ជ) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ។

**-បានឃើញ** ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

**-បានឃើញ** ការផ្តល់ និងជូនដំណឹងអំពីកាលបរិច្ឆេទ នៃសវនាការដែលធ្វើឡើងដោយអនុលោមតាមប្បញ្ញត្តិមាត្រា២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ១-<u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ថិតនៅភូមិ៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានករណី ឆបោកប្រាក់ មួយបានកើតឡើងដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុ ២៨ឆ្នាំ និងប្តីឈ្មោះ [redacted] ភេទប្រុស បានធ្វើសកម្មភាពឆបោកប្រាក់របស់ជនរងគ្រោះឈ្មោះ [redacted] អស់ចំនួន **២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** ។

## ២-<u>នាពេលសវនាការ</u>

**២.១-** ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្លួនសូមប្តឹងទាស់នឹងសាលក្រម ដោយសារតែខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនមិនបានឆបោកប្រាក់របស់ឈ្មោះ [redacted] នោះទេ ។ ខ្លួនពិតជាបានខ្ចីប្រាក់ពីឈ្មោះ [redacted] ប្រាកដមែន ប៉ុន្តែការខ្ចីនោះមិនមានធ្វើកិច្ចសន្យាអ្វីទេ ។ ឈ្មោះ [redacted] មិនដែលដាស់តឿនឲ្យខ្លួនសងប្រាក់ម្តងណាឡើយ ហើយខ្លួនក៏មិនដែលនិយាយថាមិនសងប្រាក់នោះដែរ។

**២.២-** ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ៖ ខ្លួនមិនពេញចិត្តនឹងសាលក្រមនេះទេ ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនពុំដែលទទួលលុយពីឈ្មោះ [redacted] ឬនិយាយកិច្ចការអ្វីជាមួយគាត់នោះទេ ។

### ២.៣- សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានឆ្លងការការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ថិតនៅភូមិ៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានករណី ឆបោកប្រាក់មួយបានកើតឡើងដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុ ២៨ឆ្នាំ និងប្តីឈ្មោះ [redacted] ភេទប្រុស បានធ្វើសកម្មភាពឆបោកប្រាក់របស់ជនរងគ្រោះឈ្មោះ [redacted] អស់ចំនួន២៥ ០០០ (ពីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ប្រាកដមែន ។ ដូច្នេះតំណាងអយ្យការ ស្នើសុំឲ្យតុលាការសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ [redacted] (ច) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ទុកជាបានការដដែល ។

### ២.៤- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖ ផ្អែកតាមទិដ្ឋភាពអង្គហេតុ ការបកស្រាយលើអង្គច្បាប់ និងការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា គ្មានធាតុផ្សំបទល្មើស និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់មកលើកូនក្តីខ្លួនពីបទ ឆបោក តាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌទេ ។ ដូច្នេះ ក្នុងនាមជាមេធាវីការពារក្តីឲ្យជនជាប់ចោទ សូមស្នើសុំមកតុលាការឲ្យកូនក្តីខ្លួនរួចផុតពីបទចោទតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ២.៥- សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] បានសំណូមពរមកកាន់តុលាការ ឲ្យខ្លួនរួចផុតពីការចោទប្រកាន់ផង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

ជនជាប់ចោទឈ្មោះ [redacted] បានសំណូមពរមកកាន់តុលាការ ឲ្យខ្លួនរួចផុតពីការចោទប្រកាន់ផង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាលើភស្តុតាងនានាក្នុងសំណុំរឿងចប់សព្វគ្រប់ហើយ

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## ៣-សំអាងហេតុ

**៣.១-** កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ មានឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បាននិយាយថាខ្លួនត្រូវបានឈ្មោះ [redacted] ភេទស្រី អាយុ ៣៥ឆ្នាំ និងប្តីឈ្មោះ [redacted] ធ្វើការខ្ចីប្រាក់ពីខ្លួនសរុបចំនួន ២៥ ០០០(ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក បន្ទាប់ពីខ្ចីហើយជនជាប់ចោទបានគេចវេសមិនព្រមសងប្រាក់មកខ្លួន ទើបខ្លួនដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។ ក្រោយមកអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺចាត់ការតាមនីតិវិធីច្បាប់ ហើយសម្រេចចោទប្រកាន់ពីបទ ឆបោក ។

**៣.២.** ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនមិនពេញចិត្តនឹងសាលក្រមនេះទេ ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ពីឈ្មោះ [redacted] ពិតមែន តែមិនដឹងថាមានចំនួនប៉ុន្មាននោះទេ ហើយការខ្ចីនោះទៀតសោតក៏មិនមានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរអ្វីដែរ ខ្លួនមិនដែលគេចវេសពីការសងប្រាក់ទៅឈ្មោះ [redacted] ឡើយ ។

**៣.៣.** ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ខ្លួនមិនពេញចិត្តនឹងសាលក្រមនេះទេ ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ខ្លួនពុំដែលទទួលលុយពីឈ្មោះ [redacted] ឬនិយាយកិច្ចការអ្វីជាមួយគាត់នោះទេ ។

**៣.៤.** តាមការលើកឡើងរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់ឲ្យឃើញថា វិវាទដែលកើតឡើងនេះ គឺជាវិវាទផ្នែករដ្ឋប្បវេណី ដែលកើតឡើងដោយសារកូនបំណុលមិនអនុវត្តកាតព្វកិច្ចសងប្រាក់ទៅម្ចាស់បំណុល ដែលវិវាទនេះ មិនដែលជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ គប្បីតុលាការឲ្យជនជាប់ចោទបានរួចខ្លួនពីបទចោទប្រកាន់ខាងលើ ។

**៣.៥.** តុលាការទទួលស្គាល់កំណត់ហេតុបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ លើសាលក្រមព្រហ្មទណ្ឌលេខ [redacted] (ច) ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

**៣.៦.** តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានស្នើសុំមកតុលាការនោះ តុលាការបានពិចារណារួចហើយ ។

**៣.៧.** ពុំមានពិរុទ្ធភាព និងជាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] និងប្តីឈ្មោះ [redacted] ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

៣.៨. តាមពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] បានបញ្ជាក់ថា ខ្លួនបានយល់ព្រមបញ្ចប់វិវាទជាមួយឈ្មោះ [redacted] និងប្តីឈ្មោះ [redacted] តាមកិច្ចព្រមព្រៀងបញ្ចប់វិវាទរួចរាល់ហើយ ។

៣.៩. តាមសម្តីចុងក្រោយរបស់ជនជាប់ចោទ បានសំណូមពរមកតុលាការនោះ តុលាការបានពិចារណារួចហើយ ។

## ៤-ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

៤.១- **ទទួលស្គាល់**បណ្តឹងទាស់ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

៤.២- **កែប្រែ** សាលក្រមព្រហ្មទណ្ឌលេខ [redacted] **(ច)** ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

៤.៣- **ឲ្យរួចខ្លួនពីបទចោទលើឈ្មោះ ៖**

**ក.** ឈ្មោះ [redacted] ភេទស្រី អាយុ ៣៥ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិគ្រប់គ្រាន់)

**ខ.** ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិគ្រប់គ្រាន់)

**ពីបទ ឆបោក** ប្រព្រឹត្តនៅចំណុចភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា**៣៧៧** និងមាត្រា**៣៧៨** នៃក្រមព្រហ្មទណ្ឌ ។

៤.៤- បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] លេខ [redacted] **ដ.ប.ច/០២១** ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ និងជនជាប់ចោទឈ្មោះ [redacted] លេខ [redacted] **ដ.ប.ច/២១** ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ចាប់ពីពេលនេះតទៅ ។

សាលក្រមនេះត្រូវបានជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ពស២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted], ឈ្មោះ [redacted] និងកំបាំងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។

បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| --- | --- |
| ហត្ថលេខា និងត្រា ៖ [redacted] | ហត្ថលេខា និងត្រា ៖ [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ខេត្តកំពង់ស្ពឺ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១

| បានឃើញ<br>**ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| --- | --- |
| [redacted] | [redacted] |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

- សាលក្រមព្រហ្មទណ្ឌ លេខ៖ "៣"
  ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២
- សំណុំរឿងព្រហ្មទណ្ឌ លេខ៖
  ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨
- សំណុំរឿងជំនុំជម្រះ លេខ៖
  ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកំពង់ធំ**

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ធំ
នាថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក ជាចៅក្រមនៃសាលាដំបូងខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ដែលមាន៖

**<u>ជនជាប់ចោទ៖</u>**

-ឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ៣ម ឃុំកោកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល និងមានទីលំនៅបច្ចុប្បន្នរស់នៅភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ មានកូន ០១ នាក់ ជានីតិជន ទោសពីមុនគ្មាន ។ **(ក្រៅឃុំ)**

- ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៖ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ។

ត្រូវបានបញ្ជូនមកសាលាដំបូងខេត្តកំពង់ធំ តាមដីកាដំណោះស្រាយលេខ៖ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ធំ ដើម្បីជំនុំជម្រះពីបទ៖ **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ ... ចន្លោះគីឡូម៉ែត្រ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**<u>មេធាវី៖</u>**

-លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ។

## ១. អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ

យោងតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បានបង្ហាញនូវអង្គហេតុ ដូចតទៅ៖ កាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង១៤ និង៣៤នាទី នៅលើកំណាត់ផ្លូវជាតិលេខ៦ ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ស្ថិតត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានករណី គ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង រវាងរថយន្តដឹកអ្នកដំណើរធុនធំ ម៉ាក ហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ផ្លាកលេខ ភ្នំពេញ របស់ក្រុមហ៊ុន និងរថយន្តម៉ាក BONGO III ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ ។ មុនពេលកើតហេតុមានរថយន្តដឹកអ្នកដំណើរធុនធំ ម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ផ្លាកលេខ ភ្នំពេញ របស់ក្រុមហ៊ុន ពិភសរស្មី បើកបរដោយឈ្មោះ ភេទប្រុស អាយុ ៣៥ឆ្នាំ រស់នៅភូមិអំពិលលើ ឃុំអំពិលក្រោម ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានដឹកអ្នកដំណើរជនជាតិចិនច្រើននាក់ ធ្វើដំណើរពីភ្នំពេញ ទៅសៀមរាប លុះមកដល់ចំណតឈប់សម្រាកព្រៃប្រស់ ហើយរថយន្តបានស៊ីញ៉ូភ្លើង ដោយបត់ឆ្លងកាត់ទ្រូងផ្លូវពីស្ដាំទៅឆ្វេង ដើម្បីចូលហាងអាហារស្រាប់តែមានរថយន្តមួយគ្រឿង ម៉ាក Bongo III ពណ៌ស ពាក់ផ្លាកលេខ ភ្នំពេញ បើកបរដោយឈ្មោះ រស់នៅភូមិថ្មគោល ឃុំព្រៃគី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង និងមានអ្នករួមដំណើរជាមួយឈ្មោះ បានបើកបរក្នុងល្បឿនលឿន (ទិសដៅពីខេត្តសៀមរាបទៅភ្នំពេញ) មកបុករថយន្តដឹកអ្នកដំណើរធុនធំ ម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ចំចំហៀងខាងស្ដាំពេញទំហឹង បណ្ដាលឱ្យរថយន្តខ្ទាតចេញពីគ្នា នៅក្នុងរថយន្តដឹកអ្នកដំណើរមានជនជាតិចិន របួសស្រាល ០៦នាក់ ឈ្មោះ និងព្រូឡានឈ្មោះ ក៏មានរបួសទាំងពីរអ្នកផងដែរ ។ ពេលនោះរថយន្តសង្គ្រោះពេទ្យដឹកអ្នករបួសទៅគ្លីនិច ហើយសមត្ថកិច្ចបានធ្វើការឃាត់ដកហូតវត្ថុតាងលើមករក្សាទុកនៅស្នាក់ការអធិការដ្ឋាននគរបាលស្រុកកំពង់ស្វាយជាបណ្ដោះអាសន្ន ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរ លេខ៖ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

**-បានឃើញ** ដីកាដំណោះស្រាយ លេខ៖ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ។

**-បានឃើញ** ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះ លេខ៖ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ ។

**-បានឃើញ** ដីកាសម្រេចប្រគល់វត្ថុតាប់យក លេខ៖ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ។

## ២. ពេលសវនាការ

**- តាមអំណានចម្លើយជនជាប់ចោទឈ្មោះ ក្នុងដំណាក់កាលអយ្យការ នៅពេលសវនាការថា៖** កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ ខ្លួនបានបើករថយន្តជាមួយព្រូ ចេញពីខេត្តសៀមរាបទៅភ្នំពេញ ដើម្បីទៅដឹកឥវ៉ាន់ក្នុងល្បឿនពី ៧០-៨០ គីឡូម៉ែត្រក្នុង០១ម៉ោង មកដល់ចំណុចគីឡូម៉ែត្រ១៨៣-១៨៤ ភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ម៉ោង ១៤៖៣៤នាទី ក៏ឃើញមានរថយន្តក្រុងម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ស្លាកលេខភ្នំពេញ បានឈប់ត្រឹងនៅកណ្ដាលថ្នល់ផ្នែកខាងស្ដាំដៃរបស់គាត់មាន បើកភ្លើងសញ្ញាបត់ឆ្វេង ពេលនោះខ្លួនរក្សាល្បឿនពី៧០-៨០ គីឡូម៉ែត្រដដែល រំពេចនោះរថយន្តនោះក៏បានបត់ឆ្វេង ទើបធ្វើឱ្យខ្លួនមិនអាចគេចផុតក៏បុកត្រូវពាក់កណ្ដាលរថយន្តក្រុងតែម្ដង ហើយខ្លួន និងព្រូឡាន ត្រូវ

របួសធ្ងន់ ។ មូលហេតុដែលខ្លួនឃើញឡានក្រុងបើកភ្លើងសញ្ញាហើយ ខ្លួនមិនបានបន្ថយល្បឿន ដោយសារតែខ្លួនមើលមិនឃើញឡានរបស់គាត់អែបក្បាលឡានមកខាងឆ្វេងនោះទេ ហើយគាត់បត់ឡានមុខឡានរបស់ខ្លួនគឺមានចំងាយប្រហែល២០ទៅ៣០ ម៉ែត្រតែប៉ុណ្ណោះ ទើបខ្លួនស្មានថាគាត់មិនបត់ឡានទេ ដូច្នេះហើយទើបខ្លួនជាន់ឡានបន្ថែមល្បឿនទៅ សូមបញ្ជាក់ថាខ្លួនមានប័ណ្ណបើកបរត្រឹមត្រូវ គឺប័ណ្ណប្រភេទខ ហើយឡានរបស់ខ្លួនគឺស្តង់ដារ ១.៥តោន ហើយកន្លងមកខ្លួនធ្លាប់តែបើកឡានតូច តែក្រោយមកចូលធ្វើការនៅក្រុមហ៊ុនដឹងជញ្ជូនអស់រយៈពេលប្រហែលកន្លះឆ្នាំ គឺខ្លួនបើកឡានធំប្រភេទដឹកទំនិញនេះរហូត ។

- **តាមអំណានចម្លើយជនរងគ្រោះឈ្មោះ                    ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅពេលសវនាការថា៖** ខ្លួនជាតំណាងក្រុមហ៊ុនរថយន្តមួយគ្រឿងម៉ាក BONGO III បានប្តឹងសមត្ថកិច្ចអំពីរឿងគ្រោះថ្នាក់ចរាចរណ៍នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ លើផ្លូវជាតិលេខ៦ ចន្លោះគីឡូម៉ែត្រ១៨៣-១៨៤ ស្ថិតត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានរថយន្តដឹងអ្នកដំណើរធុនធំម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ស្លាកលេខភ្នំពេញ                    របស់ក្រុមហ៊ុនពិភពស្មី បើកបររថយន្តដោយឈ្មោះ

បានបត់រថយន្តពីស្តាំទៅឆ្វេងឆ្លងកាត់ថ្នល់ខ្វះការប្រុងប្រយ័ត្នបណ្តាលឱ្យរថយន្តមួយគ្រឿងម៉ាក BONGO III គាត់បើកលើផ្លូវគេចមិនរួចបណ្តាលឱ្យបុកតែម្តង ។ ធ្វើឱ្យអ្នកបើកបរ និងព្រូឡាន រងរបួសធ្ងន់ធ្ងរទាំងពីរអ្នក និងរថយន្តខូចខាតទាំងស្រុង ខ្លួនសូមទាមទារសំណងជម្ងឺចិត្ត ១០.០០០ មួយម៉ឺនដុល្លារអាមេរិក ។

- **តាមអំណានចម្លើយជនរងគ្រោះឈ្មោះ                    ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅពេលសវនាការថា៖** ខ្លួនជាតំណាងក្រុមហ៊ុនពិភពស្មី ។ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ លើផ្លូវជាតិលេខ៦ ចន្លោះគីឡូម៉ែត្រ១៨៣-១៨៤ ស្ថិតត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ រថយន្តមួយគ្រឿងម៉ាក BINGO III បើកបរដោយឈ្មោះ                    បានបុករថយន្តដឹកអ្នកដំណើរធុនធំម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ របស់ក្រុមហ៊ុនពិភពស្មី បើកបរដោយឈ្មោះ                    បណ្តាលឱ្យខូចខាតរថយន្តផ្នែកខាងស្តាំមួយចំហៀង និងអ្នកធ្វើដំណើររងរបួស ខ្លួនសូមទាមទារសំណងជម្ងឺចិត្តចំនួន ៣.៥០០ ដុល្លារអាមេរិក ។

- **តាមអំណានចម្លើយសាក្សីឈ្មោះ                    ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ នៅពេលសវនាការថា៖** កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ នៅភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ខ្លួនកំពុងច្រកស្រូវដើម្បីយកទៅលក់ឡានក្រុងហាងចំណតស្ទឹងព្រៃប្រស់ក៏ឃើញមានរថយន្តក្រុងម៉ាកហ៊ីយ៉ាន់ដាយ ពណ៌សលាយខៀវ ពាក់ស្លាកលេខ ភ្នំពេញ                    ធ្វើដំណើរពីភ្នំពេញទៅខេត្តសៀមរាប បានស៊ីញ៉ូភ្លើង ឡានដើម្បីបត់ចូលហូបអាហារចំណតព្រៃប្រស់ ស្រាប់តែមានរថយន្តមួយគ្រឿងម៉ាក BONGO III ពណ៌ស ពាក់ស្លាកលេខភ្នំពេញ                    បើកបរក្នុងល្បឿនលឿនជ្រុលទៅបុករថយន្តក្នុងនោះតែម្តង ។

- **មេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋាន ៖** ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ និងអំណាចម្លើយរបស់កូនក្តីរបស់ខ្លួន គឺនៅមានចំណុចសង្ស័យច្រើន ដោយភាគីទាំងសងខាងបានបើកខ្ចីខ្ចារ នឹងល្មើសបញ្ញត្តិច្បាប់ដូចគ្នា មួយវិញទៀតនៅក្នុងគ្រប់ដំណាក់កាល គឺអ្នកបើកបរពុំបានចូលឆ្លើយបំភ្លឺនោះទេ គឺមានតែចម្លើយតំណាងដោយក្រុមហ៊ុន ។ ចំពោះអង្គហេតុកើតឡើងនេះ គឺមានការបើកបរធ្វេសប្រហែសទាំងសងខាង ហើយកូនក្តីរបស់ខ្លួន បច្ចុប្បន្ននេះក៏ទទួលរងនៅពិការភាព ដោយសារតែគ្រោះថ្នាក់ចរាចរណ៍នេះផងដែរ ។ ដូច្នេះ ខ្លួនស្នើសុំតុលាការមេត្តា ពិចារណាពាក់ព័ន្ធនឹងសំណុំរឿងគ្រប់ដំណាក់កាល និងស្នើសុំតុលាការមេត្តា ឱ្យកូនក្តីរបស់ខ្លួនរួចផុតបទចោទ ។

- **តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ឆ្លងកាត់ការពិភាក្សាដេញដោលនៅក្នុងសវនាការ ក្រោយពីបានស្តាប់ចម្លើយអំណានចម្លើយរបស់ជនជាប់ចោទ ,អំណានចម្លើយរបស់ជនរងគ្រោះ និងអំណាន

ចម្លើយរបស់សាក្សី ព្រមទាំងពិនិត្យ ភស្តុតាងនានា ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ដូចនេះតំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរ លេខ៖ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដដែល និងស្នើសុំឱ្យកំណត់ការផ្តន្ទាទោសត្រឹមកម្រិតល្បូរទោស ។

- **សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ** ៖ មិនបានបង្ហាញខ្លួនក្នុងអង្គសវនាការទេ ដោយគ្មានមូលហេតុ ទោះបីជាតុលាការបានធ្វើការកោះហៅតាមនីតិវិធី។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងអយ្យការ
- ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

## ៣.សំអាងហេតុ

ក. យល់ឃើញថា៖ ផ្អែកតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បានបង្ហាញឲ្យឃើញថា កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង១៤ និង៣៤នាទី ពិតជាមានករណី **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ ពិតប្រាកដមែន ។

ខ. យល់ឃើញថា៖ តាមចម្លើយរបស់**ជនជាប់ចោទ** ,អំណានចម្លើយរបស់ជនរងគ្រោះ និងអំណានចម្លើយរបស់សាក្ស យល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងអង្គហេតុ ដែលបង្ហាញថាជនជាប់ចោទ ឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ពិតជាបានធ្វើសកម្មភាព **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

គ. យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ដែលធ្វើសកម្មភាពខាងលើ បានស្តែងចេញមកខាងក្រៅនូវធាតុអចេតនា និងជាសកម្មភាពដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយត្រូវបានច្បាប់កំណត់ថា ជាបទល្មើស៖ **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ឃ. យល់ឃើញថា៖ **ជនជាប់ចោទ** មិនបានបង្ហាញខ្លួនក្នុងអង្គសវនាការទេ ដោយគ្មានមូលហេតុ ទោះបីជាតុលាការបានធ្វើការកោះហៅតាមនីតិវិធី តុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

ង. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ គឺជានីតិជន ហើយពុំមានភស្តុតាង ណាមួយបញ្ជាក់ថា ជនជាប់ចោទនេះ មានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងខុសត្រូវ អំពីផលវិបាក តាមផ្លូវច្បាប់ ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន។

ច. យល់ឃើញថា៖ មានភស្តុតាងនានាគ្រប់គ្រាន់ ដើម្បីប្រកាសថា **មានពិរុទ្ធភាព** លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៤៣ឆ្នាំ ដែលបានប្រព្រឹត្តអំពើដែលជាបទមជ្ឈិម ហើយជនជាប់ចោទនេះ ពិតបានប្រព្រឹត្តអំពើ ដូចដែលបានចោទប្រកាន់ ពីបទ៖ **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

ឆ. យល់ឃើញថា៖ **មេធាវី ការពារសិទ្ធិឱ្យជនជាប់ចោទ** បានធ្វើសេចក្តីសន្និដ្ឋាន ដោយស្នើសុំតុលាការមេត្តាជួយឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទផង ។ ចំពោះសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវី គប្បី តុលាការយកមកពិចារណា លើការស្នើសុំនេះ ។

ជ. យល់ឃើញថា៖ **តំណាងអយ្យការ** បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ ដោយស្នើសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ ដោយកម្រិតត្រឹមព្យួរទោស ។ ចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានភាពជឿជាក់បានថា អំពើរបស់ជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ និងតុលាការ យល់ស្របតាមការប្តឹងសុំនេះ។

ឈ. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ មិនដែលមានប្រវត្តប្រព្រឹត្តបទល្មើសពីមុននោះទេ ហើយជននេះក៏ពុំមានចេតនាក្នុងការប្រព្រឹត្តបទល្មើសផងដែរ ព្រមទាំងស្ថានភាពគ្រួសារមានជីវភាពក្រីក្រ និងពុំមាននៅកាយសម្បទាគ្រប់គ្រាន់ទៀតនោះ ដោយស្របតាមបញ្ញត្តិមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិចារណាលើការព្យួរទោស តាមបញ្ញត្តិ មាត្រា១០៤ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

## <u>៤.សេចក្តីសម្រេច</u>

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពង់ធំ សម្រេច ៖

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ (ដែលមានសវតាជាតិខាងលើ) **ដាក់ពន្ធនាគារកំណត់រយៈពេល <u>០១ (មួយ) ឆ្នាំ</u>** ជាប់ចោទពីបទ៖ **បើកបរធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្នបណ្តាលឱ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៦A ចន្លោះគីឡូម៉ែត្រ ១៨៣-១៨៤ ត្រង់ចំណុចភូមិព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។ **ប៉ុន្តែការអនុវត្តទោសនេះ គឺត្រូវព្យួរធម្មតា ។**

២- បញ្ឈប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ២៤ឆ្នាំ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

សាលក្រមនេះ បានធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ និងបានប្រកាសជាសាធារណៈ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ ។

ភាគីដែលច្បាប់ផ្តល់សិទ្ធិឲ្យ អាចប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

បានឃើញ
**ចៅក្រមជំនុំជម្រះ**

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
កំពង់ធំ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៤
ជំនុំជម្រះលេខ
ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥
សាលក្រមលេខ ២ ត.ព.ព្រ.ឧ
ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៥ វេលាម៉ោង ២ និង ០០ នាទីរសៀល ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក ៖ ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៥ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៤ ដែលមានជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើត ភូមិអំពិល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវលេខ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ នង ណេង (រ) ប្រពន្ធឈ្មោះ (រ) មានកូន ០១ នាក់ ទោសពីមុនគ្មាន ។

ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

លោក ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ភូមិដីថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

លោក ជាតំណាងដោយអាណត្តិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ណ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ជ.ជ.រ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ ជនជាប់ចោទឈ្មោះ ភេទ ប្រុស អាយុ ៣៩ឆ្នាំ បានចេញមូលប្បទានប័ត្រមួយសន្លឹកលេខ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ មានទឹកប្រាក់ចំនួន ១១,៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក របស់ធនាគារភ្នំពេញ ពាណិជ្ជ ទៅឲ្យដើមបណ្ដឹងឈ្មោះ ភេទប្រុស អាយុ ៣៨ ឆ្នាំ ។ លុះដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ឈ្មោះ បានយកមូលប្បទានប័ត្រ ទៅបើកប្រាក់នៅធនាគារខាងលើក ស្រាប់តែ ធនាគារបញ្ជាក់ថា មូលប្បទានប័ត្រខាងលើពុំមានទឹកប្រាក់ទេ ។

## នាពេលសវនាការ

ក្រឡាបញ្ជីអានកំណត់ហេតុស្ដីពីការសួរចម្លើយជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ នៅដំណាក់កាលអយ្យការថា៖ កាលពីអំឡុងខែមីនា ឆ្នាំ ២០១៣ ខ្លួននិងឈ្មោះ ជានាយកក្រុមហ៊ុនដឹកជញ្ជូន បានទំនាក់ទំនងគ្នា ដើម្បីដឹកជញ្ជូនរថយន្តពីប្រទេសអាឡឺម៉ង់មកកាន់ប្រទេសកម្ពុជា ដោយខ្លួនឲ្យគាត់ដឹកឡានពីប្រទេសអាឡឺម៉ង់ចំនួន ០៧ គ្រឿង សរុបទឹកប្រាក់ចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ពេលនោះខ្លួនបានប្រាប់ទៅឈ្មោះ ថា ខ្លួនគ្មានប្រាក់ទេ តែឈ្មោះ ប្រាប់ថា ឲ្យខ្លួនចេញមូលប្បទានប័ត្រដើម្បីតម្កល់ និងទូទាត់សាច់ប្រាក់ជាដំណាក់កាលតាមក្រោយ ។ នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៣ ខ្លួនបានទូទាត់ប្រាក់ឲ្យឈ្មោះ ចំនួន ៤.០០០ (បួនពាន់) ដុល្លាអាមេរិក សំរាប់ថ្លៃជញ្ជូននោះ និងត្រូវដកចេញពីចំនួន ជាក់ស្ដែង នៅក្នុងមូលប្បទានប័ត្រដូចសរសេរក្នុងប័ណ្ណចំណាយ ។ នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៣ ខ្លួនបានទូទាត់ប្រាក់ឲ្យឈ្មោះ ចំនួន ២.០០០ (ពីរពាន់) ដុល្លាអាមេរិក សំរាប់ថ្លៃដឹកជញ្ជូននោះ និងត្រូវដកចេញពីចំនួនជាក់ស្ដែងនៅក្នុងមូលប្បទានប័ត្រដូចមាននៅក្នុងប័ណ្ណចំណាយ។ នៅមុនថ្ងៃចូលឆ្នាំចិន ឆ្នាំ ២០១៤ ប្រពន្ធខ្លួនបានយកប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លាអាមេរិក យកទៅសងឈ្មោះ តែគាត់មិនព្រមទទួលទេ ដោយប្រាប់ថា ប្រាក់តិចពេក យ៉ាងហោចណាស់ក៏មាន ពីរទៅបីពាន់ ដុល្លាអាមេរិកដែរទើបព្រមទទួល ហើយប្រពន្ធខ្លួនក៏ យកប្រាក់ត្រឡប់មកវិញ ។ ខ្លួននៅខ្វះប្រាក់ចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ដើម្បីទូទាត់ថ្លៃ ដឹកជញ្ជូន ពេលដែលខ្លួនទូទាត់ប្រាក់គ្រប់ចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ឈ្មោះ និងប្រគល់មូលប្បទានប័ត្រជូនខ្លួនវិញ ដូចមានសរសេរក្នុងប័ណ្ណចំណាយស្រាប់ ។ មូលហេតុដែលខ្លួន ទូទាត់ប្រាក់យឺតដោយសារឈ្មោះ ពុំបានបំពេញកាតព្វកិច្ចដឹកជញ្ជូនតាមការព្រមព្រៀងគ្នារយៈពេល កន្លះខែ ដោយជាក់ស្ដែងឈ្មោះ ដឹកជញ្ជូនប្រើរយៈពេលដល់ទៅបីខែកន្លះ បណ្ដាលឲ្យភ្ញៀវដែលកុម្ម៉ង់រថយន្តឈប់ទិញ ហើយរថយន្តត្រូវលក់ក្នុងតម្លៃថោក ឲ្យអ្នកផ្សេង។ មូលប្បទានប័ត្រដែលខ្លួនចេញឲ្យឈ្មោះ គឺចេញដើម្បីតម្កល់ ថ្លៃដឹកជញ្ជូនរថយន្តប៉ុណ្ណោះ ។ ប្រាក់ដែលនៅខ្វះចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប)ដុល្លាអាមេរិក នោះខ្លួននឹងសងទៅឲ្យឈ្មោះ គ្រប់ចំនួនឲ្យបានមុន ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៤ ។

ក្រឡាបញ្ជីអានកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ នៅដំណាក់កាលអយ្យការនិងចៅក្រមស៊ើបសួរ បានឆ្លើយថាៈ កាលពីអំឡុងខែមីនា ឆ្នាំ២០១៣ ឈ្មោះ បានមកទំនាក់ទំនងជាមួយខ្លួន ដើម្បីទិញសេវាកម្មដឹកជញ្ជូនពីក្រុមហ៊ុនរបស់ខ្លួន ក្នុងគោលបំណងឲ្យក្រុមហ៊ុនខ្លួនផ្ដល់សេវាកម្មដឹកជញ្ជូនរថយន្តជូនគាត់ពីទីក្រុងប៊ែកឡាំងប្រទេសអាឡឺម៉ង់ មកកាន់កំពង់ផែខេត្តព្រះសីហនុប្រទេសកម្ពុជា ។ សរុបជាទឹកប្រាក់ចំនួន ១២.០១៥ (មួយម៉ឺនពីរពាន់ដប់ប្រាំ) ដុល្លាអាមេរិកដកថ្លៃចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ដកថ្លៃចំនួន ៣៨៥ (បីរយប៉ែតសិបប្រាំ) ដុល្លាអាមេរិក ។ ខ្លួនសុំបញ្ជាក់ថាឈ្មោះ ត្រូវទូទាត់ថ្លៃសេវាកម្មឲ្យមកខ្លួន ខណៈពេលដែលទំនិញ (រថយន្ត) ត្រូវបានដឹកមកដាក់នៅលើកំពង់ផែ ប្រទេសអាឡឺម៉ង់ ។ ប៉ុន្តែឈ្មោះនេះយកលេសថារង់ចាំទំនិញមកដល់កំពង់ផែខេត្តព្រះសីហនុហើយ ខ្លួនបានសម្របសម្រួលឲ្យគាត់យកទំនិញចេញពីកំពង់ផែ ។ ក្រោយពីបានទទួលទំនិញហើយឈ្មោះ នៅតែមិនព្រមទូទាត់ ប្រាក់មកឲ្យខ្លួនដដែល ។ នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៣ ឈ្មោះ បានប្រគល់មូលប្បទានប័ត្រលេខ ០៦៦៨៥៨ មានគណនីលេខ ១១៤០១០១៩៥៨៥៥ មានទឹកប្រាក់ចំនួន ១១,៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ។ ក្រោយពីបានទទួលមូលប្បទានប័ត្រ ពីឈ្មោះ ខ្លួនបានទៅដកប្រាក់នៅធនាគារភ្នំពេញពាណិជ្ជចំនួន ០២ ដង លើកទីមួយ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ និងលើកទី២ នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៣ ប៉ុន្តែត្រូវបានមន្ត្រីធនាគារឆ្លើយតប តាមលិខិតមូលប្បទានប័ត្របញ្ជូនត្រឡប់បញ្ជាក់ថា មិនមានសាច់ប្រាក់នៅក្នុងគណនីលេខ ១១៤០១០១៩៥៨៥៥ របស់ឈ្មោះ ឡើយ ។ ដំបូងឈ្មោះ សងបាន ៤.០០០ (បួនពាន់) ដុល្លាអាមេរិក ក្រោយមក

សង ២.០០០ (ពីរពាន់) ដុល្លាអាមេរិក និងចំនួន ១០០០ (មួយពាន់) ដុល្លាអាមេរិក ទៀត ។ ទង្វើរបស់ឈ្មោះ ជាចេតនាបោកប្រាស់ ដែលជាហេតុធ្វើឲ្យខាតពេលវេលា និងផលប្រយោជន៍ជាច្រើន ។ សំណូមពរៈ ផ្តន្ទាទោសឈ្មោះ តាមច្បាប់ ។ ទាមទារសំណងចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក និងទាមទារជម្ងឺចិត្តព្រមទាំងខាតបង់ពេលវេលាចំនួន១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ។

**លោក ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖** នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០១៣ ឈ្មោះ បានប្រគល់មូលប្បទានប័ត្រលេខ ០៦៦៨៥៨ មានគណនីលេខ ១១៨០១០១៩៥៨៥៥ មានទឹកប្រាក់ចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក តែនៅពេលដែលកូនក្តីខ្លួនទៅបើកប្រាក់នៅធនាគារភ្នំពេញពាណិជ្ជ ក៏ត្រូវបានមន្ត្រីធនាគារឆ្លើយតបតាមលិខិតមូលប្បទានប័ត្របញ្ជូនត្រឡប់បញ្ជាក់ថា មិនមានសាច់ប្រាក់នៅក្នុងគណនីខាងលើនេះទេ ទង្វើរបស់ឈ្មោះ ជាចេតនាបោកប្រាស់ ដែលជាហេតុធ្វើឲ្យខាតពេលវេលា និងផលប្រយោជន៍ជាច្រើន ។ សំណូមពរៈ ផ្តន្ទាទោសឈ្មោះ តាមច្បាប់ ។ ទាមទារសំណងចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក និងទាមទារជម្ងឺចិត្តព្រមទាំងខាតបង់ពេលវេលាចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងពិនិត្យភស្តុតាងជាឯកសារទាក់ទិននៅក្នុងសំណុំរឿងរួចមក ឃើញថានៅក្នុងរឿងនេះ ជនជាប់ចោទឈ្មោះ ពិតជាប្រព្រឹត្តអំពើ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ប្រាកដមែន ។ ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ណ ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ២០១៥ នៅដដែល ទុកជូនតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានពិនិត្យភស្តុតាង
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ឈ្មោះ ភេទប្រុស អាយុ ៣៩ ឆ្នាំ ពិតជាបានចេញមូលប្បទានប័ត្រលេខ ០៦៦៨៥៨ មានគណនីលេខ ១១៨០១០១ របស់ធនាគារភ្នំពេញពាណិជ្ជ មកឲ្យឈ្មោះ ដើម្បីទូទាត់ប្រាក់ថ្លៃ សេវាកម្មដឹកជញ្ជូនរថយន្តចំនួន ១១.៦៣០ (មួយម៉ឺនមួយពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក ។ លុះដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៣ ទៅបើកប្រាក់ខាងធនាគារបញ្ជាក់ថា មូលប្បទានប័ត្រនេះ គ្មានទឹកប្រាក់ក្នុងគណនី ប្រាកដមែន។

២. តាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានចេញមូលប្បទានប័ត្រដើម្បីតម្កល់ និងទូទាត់សាច់ប្រាក់ទៅឲ្យឈ្មោះ ដែលចម្លើយនេះស្របទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងស្របទៅនឹងឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿងអាចបញ្ជាក់បានថាឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រាកដមែន ។ ភស្តុតាងទាំងអស់ខាងលើនេះ អាចឱ្យតុលាការពិចារណាបាន តាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. ជនជាប់ចោទជានីតិជនដែលមានសមត្ថភាពទទួលខុសត្រូវខាងព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយ បញ្ជាក់ថាមានបញ្ហាខាងស្មារតីឡើយ ដូច្នេះ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

៤. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់ដ៏ល្អរបស់សង្គម ដែលមាត្រា២ និងមាត្រា៣ នៃក្រមព្រហ្មទណ្ឌ បានហាមឃាត់ជាដាច់ខាត និងត្រូវតែផ្តន្ទាទោស ។

៥. ហេតុពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឈាង សុផល ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៦. ដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារប្រាក់ចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លាអាមេរិក និងជម្ងឺចិត្តចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក។ គប្បីតុលាការពិនិត្យពិចារណា តាមព្យសនកម្មរបស់ជនរងគ្រោះ និងលទ្ធភាពរបស់ជនជាប់ចោទ ដើម្បីឲ្យស្របតាមមាត្រា ១៤ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសឈ្មោះ ភេទប្រុសអាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

២. បង្គាប់ឲ្យចាប់ និងឃុំខ្លួនឈ្មោះ នៅមណ្ឌលអប់រំកែប្រែ ម១ នៃក្រសួងមហាផ្ទៃ ។

៣. បង្គាប់ឲ្យឈ្មោះ សងប្រាក់ចំនួន ៥.៦៣០ (ប្រាំពាន់ប្រាំមួយរយសាមសិប) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ឲ្យឈ្មោះ ។ ច្រានចោលការទាមទារលើសពីនេះ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ កំបាំងមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥ ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| **ចៅក្រមជំនុំជម្រះ** | រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥ |
| | **ក្រឡាបញ្ជីសវនាការ** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
-លេខ
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ
ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០
-សំណុំរឿងជំនុំជំរះលេខ
ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង៨ និង០០ នាទី ព្រឹក នៅសាលសវនាការទី៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

## ចៅក្រមជំនុំជម្រះ

-លោក ជាចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ លើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខលេខ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

ឈ្មោះ ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ លេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ ៖ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ៥១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

មេធាវីលោក អត្តលេខ និងមេធាវី អត្តលេខ ជាមេធាវីការពារក្តីឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ខ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ )(ង)ដ.ដ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ 'យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលវិនិច្ឆ័យសេចក្តីដូចតទៅ ៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ៧១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២ឆ្នាំ (ពីរឆ្នាំ) តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន៤.000.000(បួនលាន)រៀល បង់ចូលថវិការរដ្ឋ ពីបទ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា១០៧ និងមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ សងសំណងការខូចខាត និងជម្ងឺចិត្តសរុបចំនួន៨.000.000 (ប្រាំបីលាន) រៀល ទៅអោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ និងឈ្មោះ ។ ការទាមទារលើសពីនេះបដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

-បានឃើញ សេចក្តីចម្លងបណ្តឹងទាស់លេខ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ដោយសុំប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ នៅចំណុចផ្ទះដែលមានក្បាលដីលេ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណីគប់ និងវាយបំផ្លាញកាំម៉ារ៉ាសុវត្ថិភាពរបស់ជនរងគ្រោះឈ្មោះ និងឈ្មោះ ដែលបំពាក់ជាប់នឹងផ្ទះ ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ បណ្តាលឱ្យខូចខាតទាំងស្រុង ដែលករណីនេះផ្តើមចេញពីទំនាស់ នៃការសាងសង់ផ្ទះ ដែលមានព្រំជាប់គ្នា។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្ញុំបាទប្តឹងទាស់នឹងសាលក្រមកំបាំងមុខ ដោយហេតុថា ខ្ញុំបាទពុំបានដឹងពីការកោះហៅរបស់តុលាការនោះទេ ទើបខ្ញុំបាទប្តឹងទាស់ ហើយរឿងហេតុនេះកើតឡើងដោយសារឈ្លោះគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីរឿងធ្វើផ្ទះ ហើយខ្ញុំបាទមិនឱ្យដើមបណ្តឹងដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះរបស់ខ្ញុំបាទ ដោយខ្ញុំបាទបានធ្វើកិច្ចសន្យាជាមួយដើមបណ្តឹងទៀត ប៉ុន្តែដើមបណ្តឹងនៅតែដាក់កាំម៉ារ៉ាសុវត្ថិភាពបែមកផ្ទះខ្ញុំដដែល ធ្វើឱ្យមានជម្លោះនឹងគ្នា ហើយខ្ញុំក៏ទៅកាច់កាំម៉ារ៉ាសុវត្ថិភាពនោះចោលតែម្តង។

## សេចក្តីសន្និដ្ឋានបួងសួងរបស់តំណាងអយ្យការ

តំណាងអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ យ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការសម្រេចតាមច្បាប់។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ខ្ញុំបាទសូមឱ្យតុលាការបន្ធូបន្ថយទោស ខ្ញុំបាទដឹងកំហុសហើយ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-ពាក្យបណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ ប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

២.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនប្តឹងទាស់នឹងសាលក្រមកំបាំងមុខនេះ ដោយហេតុថា ខ្លួនពុំបានដឹងពីការកោះហៅរបស់តុលាការនោះទេ ទើបខ្លួនប្តឹងទាស់ ហើយរឿងហេតុនេះកើតឡើងដោយសាការឈ្លោះគ្នាជាមួយដើមបណ្តឹងរដ្ឋប្បវេណីពីរឿងធ្វើផ្ទះ ហើយខ្លួនមិនឱ្យដើមបណ្តឹងដាក់កាំម៉ារ៉ាសុវត្ថិភាពបែរមកផ្ទះរបស់ខ្លួន ដោយខ្លួនបានធ្វើកិច្ចសន្យាជាមួយដើមបណ្តឹងទៀត ប៉ុន្តែដើមបណ្តឹងនៅតែដាក់កាំម៉ារ៉ាសុវត្ថិភាពបែរមកផ្ទះរបស់ខ្លួនដដែល ធ្វើឱ្យមានជម្លោះនឹងគ្នា ហើយខ្លួនក៏ទៅកាច់កាំម៉ារ៉ាសុវត្ថិភាពនោះចោលតែម្តង។ ហេតុដូច្នេះតាមចម្លើយរបស់ជនជាប់ចោទ និងតាមភស្តុតាងនៅក្នុងសំណុំរឿង អាចឱ្យតុលាការជឿបានថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៣.អំពើរបស់ជនជាប់ចោទឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ **ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ទៅលើជនរងគ្រោះឈ្មោះ និងឈ្មោះ ប្រាកដមែន ដោយជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពចូលក្នុងរបងផ្ទះជនរងគ្រោះ យកដុំថ្ម និងឈើជ្រុងទៅវែកម្ទេចកាំម៉ារ៉ាសុវត្ថិភាពបណ្តាលឱ្យខូចខាត។ ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ បានរំលោភទៅលើមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ តំណាងអយ្យការសុំតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ទុកដដែល និងសុំឱ្យតុលាការសម្រេចតាមច្បាប់ គប្បីតុលាការពិចារណាតាមច្បាប់។

៥-សំដីចុងក្រោយរបស់ជនជាប់ចោទ សុំឱ្យតុលាការបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៦-ជនជាប់ចោទមានស្មារតី និងសមត្ថភាពទទួលខុសត្រូវអំពីទង្វើរបស់ខ្លួន ដែលខ្លួនបានប្រព្រឹត្ត រួមទាំងផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ។

៧-តាមភស្តុតាងជាសក្ខានុម័ត បញ្ជាក់ថា: ជនជាប់ចោទពិតជា មានចេតនាពិតប្រាកដ ក្នុងការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃមែន ។

៨-អំពើល្មើសពិតជាធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូ ទ្រព្យសម្បត្តិរបស់អ្នកដទៃ និងរបៀបរៀបរយសង្គម ហើយអំពើនេះវាផ្ទុយនឹងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ពីបទ: ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះមានក្បាលដីលេខ ផ្លូវលំ ភូមិ សង្កាត់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤១១ នៃក្រមព្រហ្មទណ្ឌ ដែលគប្បីតុលាការសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

**ហេតុដូច្នេះសម្រេច**

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ "ឃ" ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**
---|---
ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

សំណុំរឿងព្រហ្មទណ្ឌលេខ១២១ បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ ដោយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ មានសមាសភាពដូចតទៅ:

សាលក្រម
លេខ ០៦ "យ"
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក[redacted]ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក[redacted]ចៅក្រមប្រឹក្សា

លោក[redacted]ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក[redacted]:រាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី[redacted]ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ:១២១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ដែលរួមមាន ជនជាប់ចោទ៖

១/ឈ្មោះ[redacted]ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted]) ជាអនីតិជន ទោសពីមុន គ្មាន។ (ក្នុងឃុំ០៧.០៦.២០១៧)

ជាប់ចោទពីបទ:ឃាតកម្ម ប្រព្រឹត្តនៅចំណុចអន្លង់ក្រញូង ស្ថិតក្នុងភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខ២៣៣៨ ត.ព ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកោះកុង។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ១៦០ អ.យ/១៧ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

- បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៧២ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តកោះកុង។

**អង្គហេតុមានដូចទៅ**

កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង១៧:៣០នាទីល្ងាច ជនសង្ស័យ ឈ្មោះ:[redacted]បានអង្គុយលេងនៅលើស្ពានចុងថ្នល់ជាមួយមិត្តភក្តិ ស្រាប់តែឃើញឈ្មោះ: [redacted]ភេទប្រុស ជិះម៉ូតូមកពីទិសខាងជើងតែម្នាក់ឯងមកដល់គល់ស្ពានខាងត្បូង ម៉ូតូកង់

របស់ខ្លួនកើតពិភាក្សាគ្នាទៀត បានហៅឲ្យឈប់ បន្ទាប់មកបបួលគ្នាជិះម៉ូតូទៅលេងសាលាម្នាង និងស្រែអំបិល ហើយក៏ត្រឡប់ទៅស្ពានស្រែអំបិលវិញ នៅវេលាម៉ោង២១ និង៣០នាទីយប់ ពេលនោះមិត្តភក្តិរបស់ខ្លួនក៏បានចូលផ្ទះរៀង១ខ្លួន។ ចំណែកឈ្មោ[redacted]ជិះម៉ូតូម្នាក់ឯងសំដៅមកទិសខាងជើង ឃើញដូច្នេះរូបខ្លួនក៏ជិះម៉ូតូម្នាក់ឯង តាមពីក្រោយពេលមកដល់ចំណុចកើតហេតុឈ្មោះ [redacted] បានឈប់ម៉ូតូនៅកៀនថ្នល់ហើយបានស្រែកហៅខ្លួនឱ្យឈប់និយាយគ្នាសិន ពេលខ្លួនដើរទៅដល់ស្រាប់តែឈ្មោះ[redacted]បានយកដំបងឈើជ្រុងវាយមកលើខ្លួនប៉ុន្តែពុំត្រូវ ខ្លួនក៏រើសបានដំបងតាសេកនៅជិតនោះវាយវិញត្រូវបណ្ដាលឱ្យឈ្មោះ [redacted]ដួល ឃើញដូច្នេះខ្លួនក៏យកដំបងឈើជ្រុងរបស់ឈ្មោ[redacted]វាយបន្ថែមទៀតជាច្រើនដំបង ហើយក៏ត្រឡប់ទៅផ្ទះវិញដោយពុំបានដឹងថាឈ្មោះ ល[redacted] ស្លាប់នោះទេ។

-តុលាការប្រកាសបើកសវនាការ

-តុលាការប្រកាសអំពីសមាសភាពជំនុំជម្រះ

-តុលាការសួរអំពីអត្តសញ្ញាណជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់ជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់សាក្សី

-ជនជាប់ចោទមិនជំទាស់ និងសមាសភាពជំនុំជម្រះទេ

**នាពេលសវនាការ**

-តាមចម្លើយរបស់ជនសង្ស័យឈ្មោះ[redacted]បានឆ្លើយសារភាពថា ៖ ពីមុនមកខ្លួននិងជនរងគ្រោះធ្លាប់មានទំនាស់នឹងគ្នាហើយមិនដែលនិយាយជាមួយគ្នានោះទេ។ រហូតមកដល់ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១៧និង៣០ នាទី ខ្លួនកំពុងអង្គុយលេងនៅលើស្ពានចុងថ្នល់ជាមួយមិត្តភក្តិមួយចំនួនទៀត ស្រាប់តែឈ្មោះ[redacted]ជនរងគ្រោះជិះម៉ូតូមកម្នាក់ឯង មិត្តភក្តិខ្លួនម្នាក់ទៀតបានហៅឱ្យឈប់ បន្ទាប់មកបបួលគ្នាជិះម៉ូតូទៅ សាលាម្នាងនិងស្រែអំបិល ហើយក៏ត្រឡប់ទៅស្ពានស្រែអំបិលវិញ នៅវេលាម៉ោង ២១និង ៣០នាទី ។ ពេលនោះមិត្តភក្តិខ្លួនបានចូលផ្ទះរៀង១ខ្លួនចំណែកឈ្មោះ[redacted]បានជិះម៉ូតូម្នាក់ឯងសំដៅមកទិសខាងជើង ឃើញដូច្នេះរូបខ្លួន ក៏ជិះម៉ូតូម្នាក់ឯងតាមពីក្រោយ ពេលមកដល់ចំណុចកើតហេតុ ឈ្មោះ[redacted]នឈប់ម៉ូតូនៅកៀនថ្នល់ ហើយបានស្រែកហៅខ្លួនឱ្យឈប់និយាយគ្នាសិន ពេលខ្លួនដើរទៅដល់ស្រាប់តែ ឈ្មោះ[redacted]បានយកដំបងឈើជ្រុងវាយមកលើ ខ្លួនប៉ុន្តែពុំត្រូវខ្លួនក៏រើសបានដំបងតាសេកនៅជិតនោះវាយវិញត្រូវបណ្ដាលឱ្យឈ្មោះ[redacted]ឃើញដូច្នេះខ្លួនក៏យកដំបងឈើជ្រុងរបស់ឈ្មោះ[redacted]វាយបន្ថែមទៀតជាច្រើន ដំបងហើយក៏ត្រឡប់ទៅផ្ទះវិញ ដោយពុំបានដឹងថាឈ្មោ[redacted]ស្លាប់នោះទេ។

-ដើមបណ្ដឹងរដ្ឋប្បវេណីបានវត្តមាននាពេលសវនាការ ។ ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចឲ្យក្រឡាបញ្ជីអានអំណានកំណត់ហេតុស្តាប់ចម្លើយនៅតំណាក់កាលស៊ើបសួរ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានទាមទារ និងសំណូមពរដល់តុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងទាមទារសំណងជំងឺចិត្តចំនួន៨.០០០.០០០(ប្រាំបីលានរៀល) ។

-<u>តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ :</u>

+ ដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រប់គ្រាន់ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់។ ជាមួយគ្នានេះដែរ ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តនូវសកម្មភាពដូចមានក្នុងអង្គហេតុខាងលើពិតប្រាកដមែន អាស្រ័យហេតុនេះតំណាងអយ្យការសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងជួយបន្ធូរបន្ថយទោសដល់ជននេះផង ព្រោះជននេះជាអនីតិជនដែលមិនមានប្រវត្តិប្រព្រឹត្តបទល្មើស មិនបានរៀនសូត្រចេះដឹង ។

+សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១៦០ អ.យ/១៧ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ទុកជាបានការទាំងស្រុង និងសូមឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់៖

+លោកមេធាវី [redacted] នធ្វើសេចក្តីសន្និដ្ឋានថា តាមរយៈការសួរដេញដោលជនជាប់ចោទបានឆ្លើយថា ជនរងគ្រោះបានវាយមកលើខ្លួនមុនហើយបានប្រតាយប្រតប់គ្នា រហូតបណ្តាលឲ្យជនគ្រោះស្លាប់ ។ ជនជាប់ចោទបានអះអាងទៀតថា ពេលប្រតាយប្រតប់គ្នា ខ្លួនមិនបានដឹងថាជនរងគ្រោះស្លាប់នោះទេ រហូតមានសមត្ថកិច្ចឃាត់ខ្លួនទើបដឹង ។ ខ្លួនគ្នាគំនុំជាមួយជនរងគ្រោះពីមុននោះទេ ។ អាស្រ័យហេតុនេះ ក្នុងនាមមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចប្តូរបទចោទ ពីបទឃាតកម្ម មិនបទហិង្សាមានស្ថានទម្ងន់ទោសបណ្តាលឲ្យជនរងគ្រោះស្លាប់ និងសុំបន្ធូរបន្ថយទោសដល់ជនជាប់ចោទដែលជាអនីតិជន ។

-សំដីចុងក្រោយរបស់ជនជាប់ចោទនៅចំពោះមុខសវនាការបានស្នើសុំដល់ចៅក្រមជំនុំជម្រះមេត្តាជួយបន្ធូរបន្ថយទោសព្រោះ ពួកគេបានយល់ពីទោសកំហុសរបស់ខ្លួន និងសុំប្តេជ្ញាចំពោះមុខអង្គសវនាការថាពួកគេនឹងខិតខំកែប្រែខ្លួនឲ្យល្អ និងឈប់ប្រព្រឹត្តល្មើស នឹងច្បាប់រដ្ឋតទៅទៀតហើយ ។

1) ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
2) ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
3) ក្រោយពីបានពិនិត្យភស្តុតាង
4) ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកោះកុង

## យល់ឃើញថា

១.តាមចម្លើយរបស់ជនសង្ស័យឈ្មោ [redacted] ឆ្លើយសារភាពថា ៖ ពីមុនមកខ្លួន និងជនរងគ្រោះធ្លាប់មានទំនាស់នឹងគ្នាហើយមិនដែលនិយាយជាមួយគ្នានោះទេ។ រហូតមកដល់ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៧ វេលាម៉ោង ១៧និង៣០ នាទី ខ្លួនកំពង់អង្គុយលេងនៅលើស្ពានចុងថ្នល់ជាមួយមិត្តភក្តិមួយចំនួនទៀត ស្រាប់តែឈ្មោ [redacted] ជនរងគ្រោះជិះម៉ូតូមកម្នាក់ឯង មិត្តភក្តិខ្លួនម្នាក់ទៀតបានហៅឱ្យឈប់ បន្ទាប់មកបបួលគ្នាជិះម៉ូតូទៅ សាលាម្នាងនិងស្រែអំបិល ហើយក៏ត្រឡប់ទៅស្ពានស្រែអំបិលវិញ នៅវេលាម៉ោង ២១និង៣០នាទី ។ ពេលនោះមិត្តភក្តិខ្លួនបានចូលផ្ទះរៀងៗខ្លួនចំណែកឈ្មោ [redacted] នជិះម៉ូតូម្នាក់ឯងសំដៅមកទិសខាងជើង ឃើញដូច្នេះរូបខ្លួន ក៏ជិះម៉ូតូម្នាក់ឯងតាមពីក្រោយ ពេលមកដល់ចំណុចកើតហេតុ ឈ្មោ [redacted] នឈប់ម៉ូតូនៅកៀនថ្នល់ ហើយបានស្រែកហៅខ្លួន

ឱ្យឈប់និយាយគ្នាសិន ពេលខ្លួនដើរទៅដល់ស្រាប់តែ ឈ្មោ[redacted]យកដំបងឈើ ជ្រុងវាយមកលើ ខ្លួនប៉ុន្តែពុំត្រូវខ្លួនក៏រើសបានដំបងតាសេកនៅពេលនោះវាយវិញត្រូវបណ្ដាលឱ្យ ឈ្មោះ[redacted] ឃើញដូច្នេះខ្លួនក៏យកដំបងឈើជ្រុងរបស់ឈ្មោះ[redacted]របវ្ថែម ទៀតជាច្រើន ដំបងហើយក៏ត្រឡប់ទៅផ្ទះវិញ ដោយពុំបានដឹងថាឈ្មោះ[redacted]ស្លាប់ នោះទេ។ នៅត្រង់ចំណុចនេះក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ពិតជាមានហេតុការណ៍វាយ តប់គ្នារវាងជនជាប់ចោទឈ្មោ[redacted]ក៏យសកម្មភាពនេះបាន បណ្ដាលឲ្យឈ្មោះ[redacted]ស្លាប់ ។ ជាមួយគ្នានេះដែរតាមចម្លើយសារភាពរបស់ជនជាប់ ចោទក្នុងពេលសវនាការបានបញ្ជាក់ជូនតុលាការថា ខ្លួនគ្មានចេតនាធ្វើឲ្យជនរងគ្រោះស្លាប់នោះ ទេ គឺនៅយប់កើតហេតុនៅពេលប្រតាយប្រតប់គ្នាខ្លួនបានទាញដំបងវាយទៅលើជនរងគ្រោះ ពិតមែន តែវាយក្នុងគោលបំណងកុំជនរងគ្រោះបន្តវាយមកលើខ្លួនទៀត បន្ទាប់មកខ្លួនបានឃើ ញជនរងគ្រោះដួល ខ្លួនក៏បានដើរចេញដោយមិនគិតថាជនរងគ្រោះស្លាប់នោះទេ ។ផ្អែកតាម ចម្លើយសារភាពនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាលើធាតុផ្សំនៃអំពើឃាតកម្ម និង អំពើហិង្សាមានស្ថានទម្ងន់ដែលបណ្ដាលឲ្យជនរងគ្រោះស្លាប់ ។

២ -ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទចាប់តាំងពីតំណាក់កាលនគរបាលយុត្តិធម៌ តំណាក់កាលអយ្យាការ ចៅក្រមស៊ើបសួរ និងក្នុងពេលសវនាការ ជនជាប់ចោទនៅតែរក្សាចម្លើយរបស់ខ្លួនដដែលថា ខ្លួនគ្មានចេតនាវាយជនរងគ្រោះស្លាប់នោះទេ ហេតុការណ៍បានផ្តើមចេញពីការដែលជនរងគ្រោះបានវាយខ្លួនមុន ហើយខ្លួនក៏វាយទៅវិញ ប៉ុន្តែមិនដែលគិតថា ធ្វើឲ្យជនរងគ្រោះស្លាប់ឡើយ ។ គប្បីក្រុមប្រឹក្សាពិចារណាផ្អែកលើធាតុផ្សំនៃបទល្មើស ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាននាពេលសវនាការ ។ ក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចឲ្យក្រឡាបញ្ជីអានអំណានកំណត់ហេតុស្តាប់ចម្លើយនៅតំណាក់កាលស៊ើបសួរ ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រាប់គ្រាន់ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់។ ជាមួយគ្នានេះដែរ ជនជាប់ចោទបានហ៊ានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តនូវសកម្មភាពដូចមានក្នុងអង្គហេតុខាងលើពិតប្រាកដមែន អាស្រ័យហេតុនេះតំណាងអយ្យការសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងជួយបន្ធូរបន្ថយទោសដល់ជននេះផង ព្រោះជននេះជាអនីតិជន ដែលមិនមានប្រវត្តិប្រព្រឹត្តបទល្មើស មិនបានរៀនសូត្រចេះដឹង ។ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា លើអង្គហេតុ និងអង្គច្បាប់ ។

៥ -លោកមេធា[redacted]នធ្វើសេចក្តីសន្និដ្ឋានថា តាមរយៈការសួរដេញដោលជនជាប់ចោទបានឆ្លើយថា ជនរងគ្រោះបានវាយមកលើខ្លួនមុនហើយបានប្រតាយប្រតប់គ្នា រហូតបណ្តាលឲ្យជនគ្រោះស្លាប់ ។ ជនជាប់ចោទបានអះអាងទៀតថា ពេលប្រតាយប្រតប់គ្នា ខ្លួនមិនបានដឹងថាជនរងគ្រោះស្លាប់នោះទេ រហូតមានសមត្ថកិច្ចឃាត់ខ្លួនទើបដឹង ។ ខ្លួនគ្មានគំនុំជាមួយជនរងគ្រោះពីមុននោះទេ ។ អាស្រ័យហេតុនេះ ក្នុងនាមមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចប្តូរបទចោទ ពីបទឃាតកម្ម មកបទហិង្សាមានស្ថានទម្ងន់ទោសបណ្តាលឲ្យជនរងគ្រោះស្លាប់ និងសុំបន្ធូរបន្ថយទោសដល់ជនជាប់ចោទដែលជាអនីតិជន ។ ក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថាការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទក្នុងការសុំប្តូរបទចោទពីបទឃាតកម្ម មកបទហិង្សាមានស្ថានទម្ងន់បណ្តាលឲ្យជនរងគ្រោះស្លាប់ មានភាពសមហេតុសមផល ដោយផ្អែកតាមអង្គហេតុ

ដែលកើតមានឡើង និងភស្តុតាងនានាដែលមានក្នុងសំណុំរឿង ។ អាស្រ័យហេតុនេះ គប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណាប្តូរបទចោទពីបទឃាតកម្ម តាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌមកបទ ហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពរបស់ជនរងគ្រោះ តាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៦-ផ្អែកតាមមាត្រា២០០ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ គប្បីក្រុមប្រឹក្សាជំនុំជម្រះធ្វើការពិចារណាដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿង ។

៧ - ជនជាប់ចោទឈ្មោ[redacted]ាអនិតិជន ដែលពុំធ្លាប់មានប្រវត្តិផ្តន្ទាទោសពីតុលាការឡើយ ។

៨-ផ្អែកតាមមាត្រា១០៦ និង មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា ។

៩-វត្ថុតាងរួមមានដំបងឈើជ្រុងប្រវែង០.៧ម៉ែត្រ (សូន្យក្បៀសប្រាំពីរ) ចំនួន០១ដើម គប្បីរឹបអូសបំផ្លាញចោល ។

១០- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ។

១១ - ទោះបីដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមានក្នុងពេលសវនាការក៏ដោយ ក៏ប៉ុន្តែការខូចខាតដែលបានកើតឡើងដោយសារសកម្មភាពល្មើសរបស់ជនជាប់ចោទ គប្បី ក្រុមប្រឹក្សាជំនុំជម្រះ សម្រេចពិចារណា លើសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

១២. យោងតាមមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ។

<u>**ហេតុដូច្នេះ**</u>

<u>**វិនិច្ឆ័យសេចក្តី**</u>

១/. កែប្រែបទចោទពីបទឃាតកម្ម តាមមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ មកបទហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពរបស់ជនរងគ្រោះ តាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

២/. ផ្តន្ទាទោស ជនជាប់ចោទ ឈ្មោះ តាន់ ធៀន ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៧(ប្រាំ)ឆ្នាំ តែអនុវត្តទោសចំនួន០៥(ប្រាំ)ឆ្នាំ ។

ជាប់ចោទពីបទៈ ហិង្សាមានស្ថានទម្ងន់ដោយសារមរណភាពរបស់ជនរងគ្រោះ ប្រព្រឹត្តនៅចំណុចអន្លង់ក្រញូង ស្ថិតក្នុងភូមិបានទៀត ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

៣/- បង្គាប់ឲ្យឈ្មោះ [redacted]ភេទប្រុស អាយុ១៧ឆ្នាំ សងសំណងជំងឺចិត្ត និងការខូចខាតផ្សេងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន៨.០០០.០០០(ប្រាំបីលាន)រៀល ។

៤/-វត្ថុតាងរួមមានដំបងឈើជ្រុងប្រវែង០.៧ម៉ែត្រ (សូន្យក្បៀសប្រាំពីរ) ចំនួន០១ដើម រឹបអូសបំផ្លាញចោល។

៥/ សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៨ និងប្រកាស ជាសាធារណៈ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើម បណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted] [redacted] [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កោះកុង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
កោះកុង ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥២៤៧
ចុះថ្ងៃទី ៣១-១០-២០១៦
សំណុំរឿងជំនុំជម្រះ
លេខ ២១២
ចុះថ្ងៃទី ១២-០១-២០១៧
លេខក្រមព្រហ្មទណ្ឌ
លេខ ៩៦ ក្រ៣ "ឆ"
ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ដោយមានសមាសភាព៖

**<u>ប្រធានក្រុមប្រឹក្សាជំនុំជំរះ</u>**

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**<u>តំណាងអយ្យការ</u>**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ៥២៤៧ ចុះថ្ងៃទី ៣១-១០-២០១៦ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរជាងធ្វើពិដាន ទីកន្លែងកំណើត ភូមិអូរអង្រៃ ឃុំអូរអង្រៃ ស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ ទីលំនៅបច្ចុប្បន្ន មិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] រស់- ប្រពន្ធឈ្មោះ [redacted] លែងលះ) មានកូន ០២នាក់ ទោសពីមុនគ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៦៧៧ (ធ) ដ.ឃ.ដ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។ (ម១)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ(ចាត់តាំង)។

ជាប់ចោទពីបទ: ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ: [redacted] មានទីលំនៅ ផ្ទះជួល ផ្លូវ២៧១ ក្រុម២ ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៣០នាទី បន្ទាប់ពីខឹងជនរងគ្រោះ: ឈ្មោះ: [redacted] អាយុ២២ឆ្នាំ ដែលជាសង្សារថាមានប្រុសច្រើន រួចមកជនសង្ស័យឈ្មោះ: [redacted] បានទៅជួលបន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

និងបានណាត់ជនរងគ្រោះឲ្យមកដេកជាមួយ ហើយនៅយប់ថ្ងៃដដែលនោះជនរងគ្រោះក៏បានមកដេកជាមួយជនសង្ស័យ និងបានរួមភេទគ្នាចំនួន ០៣លើក។ បន្ទាប់ពីរួមរ័កគ្នារួចមកជនសង្ស័យបានឈ្លោះប្រកែកគ្នាជាមួយជនរងគ្រោះ ហើយជនសង្ស័យក៏បានធ្វើសកម្មភាពសម្លាប់ជនរងគ្រោះតែម្តង។ ក្រោយពេលសម្លាប់ជនរងគ្រោះរួចជនសង្ស័យឈ្មោះ: [redacted]ហៅ ពៅ បានដោះយកខ្សែកប្លាកទីន ០១ខ្សែ កងដៃប្លាកទីនចំនួន ០៣កង និងទូរសព្ទ័ដៃម៉ាក iphon ស៊ិចភ្លើស ចំនួន ០១គ្រឿង របស់ជនរងគ្រោះរួចគេចខ្លួនបាត់។ លុះដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ ជនសង្ស័យត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ក្រោយពេលឃាត់ខ្លួនសមត្ថកិច្ចបានយកទឹកនោមជនសង្ស័យទៅធ្វើតេស្រត៍រកសារធាតុញៀនជាលទ្ធផលបង្ហាញថាមានសារធាតុញៀន ប្រភេទមេតំហ្វេតាមីន។

បានឃើញរបាយការណ៍សំយោគលេខ ១២៣/១៦ រ.ប.ក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣០៧១ អ.យ.ត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាដំណោះស្រាយលេខ ៥៥៨៨ (ធ) ជ.ជ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃ សាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ: [redacted]ានឆ្លើយថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរសព្ទ័ណាត់ជាមួយឈ្មោះ: [redacted] ភេទស្រី អាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៤ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានជួលបន្ទប់ផ្ទះសំណាក់លេខ២០C ដល់ម៉ោង ៥និង៣០នាទី ឈ្មោ[redacted] បានមកដល់ បន្ទាប់មកពួកខ្ញុំបានរួមភេទគ្នា ក្រោយពីរួមភេទគ្នារួច ម៉ោងប្រហែល ៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឲ្យគាត់ឈប់ធ្វើកាជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្ហួតខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរសព្ទ័ឆ្លើយឆ្លងនៅចំពោះមុខខ្លួន ដោយពេលនោះខ្លួនខឹងពេកក៏បានសង្គ្រប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែក ដោះខ្សែដៃ និងយកទូរសព្ទ័របស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង បន្ទាប់មកដើរចេញពីផ្ទះសំណាក់ហើយហៅម៉ូតូឌុបជិះចេញទៅបាត់តែម្តង (នៅពេលខ្លួនដើរចេញពីផ្ទះសំណាក់មិនបានពាក់ម៉ាសទេ)។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១១ថ្ងៃត្រង់ ក៏មានសមត្ថកិច្ចមកធ្វើការឃាត់ខ្លួនសាកសួរ ហើយខ្លួនក៏ឆ្លើយសារភាពតាមសកម្មភាពដែលខ្ញុំបានប្រព្រឹត្តតែម្តង។ មូលហេតុដែលខ្លួនសម្លាប់ហើយយកខ្សែក និងកងដៃរបស់ជនរងគ្រោះ ព្រោះវាជារបស់ដែលខ្លួនបានធ្វើឲ្យនាង ចំណែកឯទូរសព្ទ័គឺជារបស់គាត់។ ខ្លួនមិនមែនណាត់ជួបគាត់ដើម្បីប្លន់យកទ្រព្យសម្បត្តិរបស់គាត់នោះទេ។ ខ្លួននិងជនរងគ្រោះស្គាល់គ្នានិងទាក់ទងគ្នាជាសង្សាប្រហែល១ឆ្នាំ ហើយពួកខ្លួនធ្លាប់ណាត់ជួបគ្នាជារឿយៗ ទើបតែលើកចុងក្រោយនេះគាត់ទើបធ្វើឲ្យខ្លួនដឹងថាគាត់មានសង្សាច្រើន ថែមទាំងទូរសព្ទ័និយាយជាមួយប្រុសផ្សេងមុខខ្លួនទៀត ខ្លួនខឹងពេកដោយទ្រាំនឹងគាត់បញ្ឈឺមិនបានក៏សម្លាប់គាត់តែម្តង។ នៅមុនពេលសម្លាប់ជនរងគ្រោះខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ តែមុនពេលឃាត់ខ្លួន ខ្លួនបានប្រើប្រាស់ថ្នាំញៀន

ពិតមែន។ ខ្លួនសំណូមពរសុំឲ្យតុលាការសម្រេចទៅតាមច្បាប់ ដោយខ្លួនដឹងអំពីកំហុសរបស់ខ្លួន ហើយស្តាយចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តលើជនរងគ្រោះ។

-តាមអំណានចម្លើយដើមបណ្តឹងឈ្មោ[redacted]នឆ្លើយថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៦និង៣០នាទី ប្អូនស្រីខ្លួន[redacted]ភេទស្រី អាយុ២២ឆ្នាំ មុខរបរបុគ្គលិកខារ៉ាអូខេ ហេងហេង(DN) ស្នាក់នៅផ្ទះជួលលេខ១៦C-១៦D ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានស្រុកកំណើតនៅ ភូមិស្វាយពល ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង (ត្រូវជាប្អូនបង្កើតរបស់ខ្លួន) បានចេញពីផ្ទះដោយប្រាប់អ្នកនៅជាមួយថាទៅកក់សក់ រួចក៏ចេញបាត់ទៅ លុះដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៨និង៣០នាទី ខ្លួនបានទទួលដំណឹងតាមរយៈមិត្តភក្រ្តិប្អូនស្រីថា ប្អូនស្រីខ្លួនឈ្មោះ[redacted]ត្រូវបានគេសម្លាប់ ឥឡូវសពតម្កល់នៅវត្តស្ទឹងមានជ័យ។ បានដំណឹងនេះខ្លួនក៏ធ្វើដំណើរទៅកាន់វត្តស្ទឹងមានជ័យកន្លែងតម្កល់សពឃើញថា សពនោះពិតជាប្អូនស្រីបង្កើតខ្លួនឈ្មោះ [redacted] ពិតប្រាកដមែន។ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃរបស់ប្អូនស្រីខ្លួនជាប់នឹងខ្លួនមានកងដៃផ្លាកទីនចំនួន ០៣កង , ខ្សែកផ្លាកទីន ០១ខ្សែ ទម្ងន់ប្រហែល ០២ជី , ទូរសព្ទ័ដៃម៉ាក iphon ស៊ិចភ្លើស ០១គ្រឿង ពណ៌ទឹកមាស ប្រើស៊ីមស្មាតលេខ ០៨៧ ៦៧ ៨៧ ៨៧។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]បានឆ្លើយថា ៖ ខ្លួនបានស្គាល់ឈ្[redacted] រយៈពេលមួយឆ្នាំហើយ ពេលធ្វើការជាមួយគាត់នៅខារ៉ាអូអេ ហេងហេង(២) ម្តុំក្បែរប៉ុស្តិ៍នគរបាលផ្សារដេប៉ូ៣។ នៅឆ្នាំ២០១៥ ប្រហែលក្នុងខែ៧ ឆ្នាំ២០១៦ ខ្លួនក៏ឈប់ធ្វើការនៅហេងហេង(២) ហើយទៅធ្វើការនៅឌីយ៉ាម៉ង់វិញ(ម្តុំអូរបែកក្អម)។ [redacted]ាត់មានសង្សារម្នាក់ឈ្មោ[redacted] ភេទប្រុស អាយុប្រហែល ២០ឆ្នាំជាង មានមុខរបរអ្វីពុំដឹងទេ លេខទូរសព្ទ័មិនស្គាល់ ខ្លួនជួបគាត់នៅផ្ទះជួលរបស់បង [redacted] ជិតខារ៉ាអូខេហេងហេង(២) នាងជួបឈ្មោះ[redacted]ប្រហែល ៣ដងជួបម្តងៗ មួយភ្លែតៗប៉ុណ្ណោះ ឈ្មោះ[redacted]មានកំពស់ប្រហែល ១,៧០ម៉ែត្រ លក់ស្លុត ច្រមុះស្រួចសម្បុរខ្មៅស្រអែម។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៩និង០០នាទី ខ្លួនបានទូរសព្ទ័ទៅបង[redacted]ខ ០៨៧ ៦៧ ៨៧ ៨៧ ដើម្បីខ្ចីលុយគាត់ ២០$ តែគាត់ថាកំពុងនៅផ្ទះសំណាក់ ចាំគាត់គេមកវិញ ពេលនោះគឺខ្លួនកំពុងនៅខារ៉ាអូខេឌីយ៉ាម៉ង់ អូរបែកក្អម ខ្លួនចាំរហូតដល់ម៉ោង ១០យប់ ថ្ងៃដដែលក៏ទូរសព្ទ័ទៅម្តងទៀតតែពុំចូល រហូតដល់ម៉ោង ១១យប់ តេច្រើនលើកនៅតែពុំចូល។ លុះព្រឹកឡើងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៩និង០០នាទីឈ្មោ[redacted]ភេទស្រី នៅខារ៉ាអូខេជាមួយខ្លួនប្រាប់ថាបង[redacted]ប់ហើយ ត្រូវគេសម្លាប់ លុះព្រឹកឡើងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ខ្លួនក៏ទៅធ្វើបុណ្យគាត់នៅខេត្តព្រៃវែងជាមួយមិត្តភក្រ្តិ ០៤នាក់ទៀត។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]នឆ្លើយថា ៖ ខ្លួន និងឈ្មោះ[redacted]បានជួលផ្ទះលេខ១៦C រស់នៅជា[redacted]ក់ រយៈពេលប្រហែល ០៤ខែហើយ ប៉ុន្តែខ្លួនស្គាល់គ្នារយៈពេល ៣ឆ្នាំហើយ។ អ្នកនៅជាមួយគ្នានោះ ១-ខ្លួនឈ្[redacted]ហៅលីហ្សា ទូរសព្ទ័លេខ ០៩៦ ៥៨០ ១២១ ៧ , ២-ឈ្មោះ[redacted]ភេទស្រី អាយុ១៩ឆ្នាំ ទូរសព្ទ័លេខ ០៩៦ ៥០៨ ៨៨៧ ៦ , ៣-[redacted]ភេទស្រី អាយុប្រហែល ២០ឆ្នាំ ទូរសព្ទ័លេខ ០១៦ ៥០ ៥៣ ៣៨ , ៤-ឈ្មោ[redacted]ភេទស្រី អាយុប្រហែល ២៨ឆ្នាំ ទូរសព្ទ័មិនស្គាល់ ទើបមកនៅបានប្រហែល ១អាទិត្យ។ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ២៣រឺ២៤ និង ០០នាទី បានមកលេងក្នុងហាងមួយសន្ទុះហើយចេញទៅវិញ លុះម៉ោង ១និង៣០នាទី ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ពេលខ្លួនចេញពីកន្លែងធ្វើការមកផ្ទះ ស្រាប់តែឃើ[redacted]ក្នុងផ្ទះជាមួយឈ្មោ[redacted]ក្មួយប្រុសម្នាក់អាយុ ៧ឆ្នាំ និងសង្សា(សព)ឈ្មោះ[redacted] ហើយខ្លួនក៏ចូលដេកនឹងនៅជាមួយគ្នារហូតដល់ម៉ោ១៥ និង៩០នាទី ថ្ងៃខែដដែលទើបខ្លួនចេញទៅកន្លែងធ្វើសក់មុនគេ។ ពេលដែលខ្លួនកំពុងនៅក្នុងបន្ទប់ជាមួយ[redacted]ប់ពី ម៉ោង ១២h

ដល់ម៉ោង១៥ៈ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ទូរស[redacted] មានមនុស្សប្រុសគេមកប្រហែល ២-៣ដង លើកទី១ ណាត់[redacted]ជួបគ្នាញ៉ាំអីនៅវត្តតំបូកខ្ពស់ តែខ្លួនប្រាប់ [redacted] ថាកុំទៅអីឆ្ងាយណាស់ លើកទី២ គេមកតែ[redacted]អត់លើកទូរសព្ទ លើកទី៣ គេមកម្តងទៀតប្រាប់ទៅជួបពួកម៉ាក់នៅម្តុំក្តាន់ពីរសិនបន្តចទៀតថាជួបគ្នា ដល់ពេល[redacted]ទៅជួបអ្នកដែលទូរសព្ទមកនោះមិនដឹងម៉ោងប៉ុន្មានទេ ព្រោះខ្លួនចេញទៅកន្លែងកក់សក់បាត់ហើយ។ អ្នកដែលគេមកទូរសព្ទ [redacted]ៈខ្លួនអត់ស្គាល់លេខទេ ឮតែសម្លេងនិយាយឆ្លើយឆ្លងគឺមនុស្សប្រុស។ លុះម៉ោង២៤ និង០០នាទី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ដោយបាត់ [redacted] មិនមកធ្វើការ ខ្លួនបានទូរសព្ទទៅលេខ ០៨៧ ៦៧ ៨៧ ៨៧ តែគេមិនចូល រហូតដល់ម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ក៏គេមិនចូល លុះម៉ោង១៦ និង០០នាទី ថ្ងៃខែដដែលខ្លួនបើកហ្វេសបុកមើលស្រាប់តែឃើញរូបភាព[redacted]ាប់ដែលគេបង្ហោះ ទើបមានការភ្ញាក់ផ្អើលប្រាប់មិត្តភក្ដិគាៗគ្នា។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]នឆ្លើយថា ៖ ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់អូយ៉េស លេខ១៧ ផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល៣២ឆ្នាំ ប្រើលេខទូរសព្ទ ០៩៦ ៨៣ ៧៦ ៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ ៨$ បន្ទប់លេខ២០C ជាន់ទី៣ ពេលបង់ប្រាក់រួចភ្ញៀវបានទិញភេសជ្ជៈចំនួន ៤បដ (គោដល់១ដប ទឹកសណ្តែក១ដប បាកាស១កំប៉ុង ទឹកហ្សេនយ៉ា១ដប) ហើយបានឡើងបន្ទប់លេខ២០C ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឲ្យឡើងទៅបន្ទប់លេខ២០C រហូតមកដល់វេលាម៉ោងប្រហែល ១៧និង៥នាទី ភ្ញៀវស្រីម្នាក់មកដល់ក៏សួររកបន្ទប់លេខ២០C ខ្លួនក៏ប្រាប់ឲ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលាម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោះ[redacted]ភេទស្រី អយុ២៨ឆ្នាំ អាយុ២៨ឆ្នាំ ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០C ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែ។ ពេលភ្ញៀវប្រុសចុះចេញពីបន្ទប់លេខ២០C នោះមិនដឹងចុះតាំងពីពេលណាទេ។ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៦និង៥០នាទី ខ្លួនកំពុងតែប្រចាំការនៅកន្លែងទទួលភ្ញៀវ ក៏មានភ្ញៀវដែលនៅបន្ទប់លេខ២០C ជាន់ទី៣ ក្នុងផ្ទះសំណាក់អូយ៉េស ភេទប្រុស (ជនសង្ស័យ)បានទូរសព្ទលើគុ ហើយខ្លួនបានលើក ហើយប្រាប់ខ្លួនថាទិញកាតទូរសព្ទស្មាត ១$១ ចំនួន២សន្លឹក ពេលនោះខ្លួនក៏បានវាយអាយកូមទៅឈ្មោះ[redacted] ភេទប្រុស អាយុ២០ឆ្នាំ ឲ្យមកយកកាតទៅឲ្យភ្ញៀវខាងលើ។ ចំពោះកាតទូរសព្ទ ស្មាត នៃ គឺខ្លួនត្រូវបានថៅកែទុកឲ្យលក់ ៥០$ មានប្រភេទស្មាត ១ដុល្លា សែលខាត និងមេតហ្វូន គឺគាត់ទុកឲ្យលក់(ចុចពីម៉ាស៊ីនទុកឲ្យលក់) ហើយលក់អស់ទើបចុចឲ្យខ្ញុំទៀត រីឯលុយគឺគិតតាមកាត ហើយទូទាត់ឲ្យថៅកែ។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថា ៖ កាលពីថ្ងៃទី២៥ ខែ១០ ឆ្នាំ២០១៦ វេលាម៉ោង១១និង៣០នាទី ខ្លួនបានឡើងមកឆែកបន្ទប់លេខ២០C ជាន់ទី៣ ពេលឡើងមកដល់មុខបន្ទប់ឃើញបន្ទប់ជាប់សោរ រួចបានគោះបន្ទប់ហៅភ្ញៀវខាងក្នុងចំនួន៣ដង តែមិនឃើញភ្ញៀវឆ្លើយតបក៏បានចុះទៅខាងក្រោមយកកូនសោរមកចាក់បន្ទប់លេខ២០C បើកទ្វារ ខ្លួនក៏សួរថាបង់ថែមម៉ោងឬអត់តែភ្ញៀវដេកដណ្តប់ភួយមិនឆ្លើយ ខ្លួនក៏បានយកដៃទៅអង្រួនជើង ស្រាប់តែឃើញជើងភ្ញៀវត្រជាក់ ពេលនោះនាងខ្ញុំក៏បានហៅអ្នកខាងក្រោមឲ្យជួយពិនិត្យមើល ឃើញភ្ញៀវកំពុងតែដេកស្តូកមិនកំរើក រួចប្រាប់ទៅម្ចាស់ផ្ទះហើយរាយការណ៍ទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលស្រះចកតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]ានឆ្លើយថា ៖ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦និង៤០នាទី ខ្លួនកំពុងឈរមុខផ្ទះសំណាក់ឃើញមនុស្សម្នាក់ ភេទប្រុស អាយុ

ប្រហែល៣២ឆ្នាំ ស្លៀកពាក់ស៊ីវិល ពាក់អាវសោច់ក្រណាត់ដៃវែងពណ៌ក្រហមក្រឡាការ៉ូ ខោពណ៌ខ្មៅជើងវែង ដើរចូលមកក្នុងផ្ទះសំណាក់ម្នាក់ឯងមកជួប[redacted]ប្រុស (អ្នកគ្រប់គ្រង) រកបន្ទប់ដេក រួចមនុស្សប្រុសនោះដើរឡើងមកបន្ទប់ជាន់ទី៣បាត់រហូត ដល់ម៉ោងប្រហែល ១៧និង០០នាទី ខ្លួនឃើញនារីនោះមកពីទិសខាងកើតផ្ទះសំណាក់ ហើយឈប់មុខផ្ទះសំណាក់ រួចរាប់លុយឲ្យអ្នកឌុបចេញទៅបាត់ ចំណែកនារីនោះក៏ដើរឡើងមកជាន់ទី៣បាត់រហូតដល់ម៉ោង ១៩និង០០នាទី ខ្លួនដល់ម៉ោង ត្រូវឈ្មោះ[redacted]ល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្លួនយាមវិញវេលាម៉ោងប្រហែល១១និង០០នាទី ឈ្មោ[redacted]ទស្រី(អ្នកបោសសម្អាតបន្ទប់) បានប្រាប់ខ្លួនថា បន្ទប់លេខ២០ ជាន់ទី៣ ដែលភ្ញៀវ[redacted]ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (មានស្រីម្នាក់ និងប្រុសម្នាក់) បិទទ្វារហៅមិនមានការឆ្លើយតបក៏ឲ្យខ្ញុំជួយមើល ពេលខ្លួនមើលជាមួយស្រីនាង ឃើញមនុស្សស្រីដេកស្លកលើពូក ខ្លួនក៏ទៅប្រាប់ម្ចាស់ផ្ទះតែម្តង។តមការចំណាំរបស់ខ្លួនកន្លងមកខ្លួនមិនដែលឃើញបុរសនោះ និងនារីរងគ្រោះចេញចូលផ្ទះសំណាក់នេះទេ(ជាម៉ូយថ្មី)។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦ជាងជិតម៉ោង១៧ ពេលមនុស្សប្រុសនោះទិញកាតបញ្ចូលទឹកប្រាក់ចំនួន១$ ចំនួនពីរសន្លឹកពី[redacted]ន្តែខ្លួនមិនដឹងថាមនុស្សប្រុសនោះចេញពីផ្ទះសំណាក់ពេលណាទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]បានឆ្លើយថា ៖ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្ញុំកំពុងប្រកបអាជីវកម្ម ទិញ-លក់គ្រឿងអលង្ការ យីហោ ចាបមាស តូបលេខ៥០A ផ្សារសាមគ្គី ស្ថិតក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ោងប្រហែល ៩និង០០នាទីព្រឹក មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ បានយកគ្រឿងអលង្ការផ្លាកទីន មានកងដៃចំនួន៣កង និងខ្សែកតូចមួយខ្សែយកមកលក់ ពេលនោះខ្លួនសួរថារបស់ទាំងហ្នឹងទិញពីកន្លែងណាមក ជននោះក៏យកវិក័យបត្រដែលមានយីហោតូបរបស់ខ្លួនមកបង្ហាញ ដោយឃើញវិក័យបត្រនេះខ្ញុំក៏យល់ព្រមទិញហើយបានយកថ្លឹង ដោយកងដៃ៣កងទម្ងន់បួនជីមួយហ៊ុន ចំណែកខ្សែកមានទម្ងន់មួយជីបួនហ៊ុនបីលី សរុបទាំងអស់ខ្ញុំទិញក្នុងតម្លៃទីផ្សារសរុប ៣៦៥$។ លុះដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ ម៉ោង៩ និង០០នាទីព្រឹក ក្រោយពីខ្លួនដឹងថារបស់ខាងលើពាក់ពន្ធ័ជាវត្ថុតាងនៅអំពើល្មើសច្បាប់ខ្លួនបានសហការណ៍ប្រគល់ឲ្យសមត្ថកិច្ចដើម្បីទុកជាវត្ថុតាង។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា ៖ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១១ថ្ងៃត្រង់ខ្លួនកំពុងនៅហាងលក់ទូរសព្ទ័របស់ឈ្មោះ[redacted]ពលនោះក៏មានមនុស្សចំនួន ០២នាក់ ជិះម៉ូតូម៉ាក់ហុងដា១២៥ មិនដឹងសេរី បានយកទូរសព្ទ[redacted] iphon ស៊ុចភ្លើសពណ៌ទឹកមាសមកលក់ឲ្យខ្លួនក្នុងតម្លៃ ២១០$ ដោយទូរសព្ទ័នោះមានឆ្នាំងសាក និងកាសគ្រប់គ្រាន់ទើបនាងខ្ញុំហ៊ានទិញ ក្រោយពីទិញបានហើយខ្លួនក៏បានដាក់ក្នុងទូរសព្ទ័លក់ធម្មតា។ សូមបញ្ជាក់ថាទូរសព្ទ័នេះខ្ញុំពុំបានដឹងថាពួកគាត់បានមកពីណាទេ។ ទើបមកដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៧និង៣០នាទី ក៏ឃើញមានសមត្ថកិច្ចនាំជនដែលលក់ទូរសព្ទ័ឲ្យខ្លួននោះមកហាងខ្លួន ហើយសមត្ថកិច្ចបានអញ្ជើញខ្លួនមកសួរ ទើបខ្ញុំដឹងថាទូរសព្ទ័នោះពាក់ពន្ធ័នឹងអំពើឃាតកម្ម ហើយខ្លួនសូមប្រគល់ទូរសព្ទ័នេះជូនសមត្ថកិច្ចវិញដោយស្មគ្រ័ចិត្តមិនតវ៉ាអ្វីទេ។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]បានឆ្លើយថា ៖ ចំពោះចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅសមត្ថកិច្ច កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ គឺខ្លួនទទួលស្គាល់ដោយមិនមានការកែប្រែទេ។ ខ្លួន និងជនរងគ្រោះ គឺធ្លាប់ទាក់ទងគ្នាជាសង្សាររយៈពេលប្រហែល ០១ឆ្នាំហើយ រីឯជនល្មើសវិញខ្លួនមិនដែលស្គាល់នោះទេ ហើយជនរងគ្រោះក៏មិនដែលប្រាប់ពីព័ត៌មានទាក់ទងនឹងជនល្មើសឲ្យខ្លួនដឹងដែរ។ ថ្ងៃដែលខ្លួនជួបនឹងជនរងគ្រោះចុងក្រោយបំផុត គឺនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ០៤រសៀល ជិតម៉ោង៥រសៀល គឺខ្លួនទៅយកមួកសុវត្ថិភាពនៅផ្ទះរបស់គាត់ជូលហើយក៏បែកគ្នាទៅ។ ថ្ងៃដែលខ្លួនដឹងថាជនរងគ្រោះស្លាប់គឺនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦

ម៉ោងប្រហែល ៥រសៀល តាមរយៈមិត្តភក្តិស្រីរបស់គាត់ឈ្មោះ [redacted] អ្នកទូរសព្ទ័ប្រាប់ខ្លួន។ ខ្លួនបានដឹងតែប៉ុណ្ណឹង ចំពោះរឿងអ្វីផ្សេងទៀតខ្លួនមិនបានដឹងទេ។

**សេចក្តីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ**

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ឆ្លងតាមការសួរដេញដោលឃើញថា នៅចំណុច ផ្ទះលេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ គឺពិតជាកើតមានអំពើ ឃាតកម្មគិតទុកជាមុន បង្កដោយជនជាប់ចោទឈ្មោះ [redacted] មន ដែលអំពើនេះបានគិតទុកជាមុន អំពើនេះត្រូវបានបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ជនជាប់ចោទក៏បានសារភាពដែរថា ខ្លួនបានប្រើប្រាស់គ្រឿងញៀនផងដែរ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ទុកជាបានការ និងសុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ**

-លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ យោងតាមការពិភាក្សាដេញដោលឃើញថា កូនក្តីខ្លួនពុំមានទោសពីមុន មានកំរិតវប្បធម៌ទាប និងជាជាងពិដាន ដោយកូនក្តីខ្លួនមានការខឹងជនរងគ្រោះដោយកំហឹង ពុំមែនមានគំពេងសម្លាប់ឡើយ គឺកូនក្តីខ្លួនខឹងភ្លាមក៏ស្ទុះសង្កត់ជនរងគ្រោះ និងច្របាច់ក ក៏បណ្តាលឲ្យជនរងគ្រោះស្លាប់ភ្លាមៗ គឺពុំមានគំពេងពីមុនទេ។ ពេលជនរងគ្រោះស្លាប់ហើយ កូនក្តីខ្លួនក៏ដោះយកសម្ភារៈ ព្រោះសម្ភារៈទាំងនោះជារបស់ដែលកូនក្តីខ្លួនទិញឲ្យជនរងគ្រោះ ហើយកូនក្តីខ្លួនយកទៅគឺដោះដូរដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ដូចនេះខ្លួនសំណូមពរសុំឲ្យក្រុមប្រឹក្សាមេត្តាប្តូរបទចោទប្រកាន់ពីមាត្រា ២០០ ទៅជាមាត្រា ២២៥ វិញ គឺហិង្សាដោយមានមរណៈភាពជនរងគ្រោះ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] ៧ ៖ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបាន ពិនិត្យ ពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

-កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ មានករណី ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កើតឡើងនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ជានីតិជន និងជាជនមានសមត្ថភាពអាចទទួលខុសត្រូវពីបទព្រហ្មទណ្ឌបាន។

-តាមការរេះរកងរបស់ជនជាប់ចោទឈ្មោះ [redacted] បានបញ្ជាក់ថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរសព្ទណាត់ជាមួយឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៨ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានចូលបន្ទប់ផ្ទះសំណាក់ លេខ២០C ដល់ម៉ោង ៥និង៣០នាទី [redacted] បានមកដល់ បន្ទាប់មកពួកខ្លួនបានរួមភេទគ្នា ក្រោយពីរួមភេទគ្នារួចម៉ោងប្រហែល ៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឲ្យគាត់ឈប់ធ្វើការជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបញ្ឈឺខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរសព្ទឆ្លើយឆ្លងនៅចំពោះមុខខ្លួន ពេលនោះខ្លួនខឹងពេកក៏បានសង្គ្រប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែកដោះខ្សែដៃ និងយកទូរសព្ទរបស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង ហើយនៅមុនពេលខ្លួនសម្លាប់ជនរងគ្រោះ ខ្លួនបានព្រមានថាឲ្យឈប់ទាក់ទងជាមួយប្រុសទៀត បើនៅតែធ្វើបែបនេះខ្លួននឹងសម្លាប់ចោល ដែលការសារភាពនេះតុលាការអាចជឿបាន ព្រោះវាស៊ីសង្វាក់នឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់ អូយ៉េស ហើយកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣២ឆ្នាំ ប្រើលេខទូរសព្ទ ០៩៦ ៨៣ ៧៦ ៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ ៨$ បន្ទប់លេខ២០C ជាន់ទី៣ ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឲ្យឡើងទៅបន្ទប់លេខ២០C រហូតមកដល់វេលាម៉ោងប្រហែល ១៧និង០៥នាទី ភ្ញៀវស្រីម្នាក់មកដល់ក៏សួររកបន្ទប់លេខ២០C ខ្លួនក៏ប្រាប់ឲ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលា ម៉ោង១១និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោ [redacted] ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០C ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែមែន។

-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ដែលបានប្រើប្រាស់ថ្នាំញៀននៅមុនពេលសម្លាប់ជនរងគ្រោះ និងគិតថានឹងសម្លាប់ជនរងគ្រោះបើសិនជនរងគ្រោះមានប្រុសក្បត់ខ្លួន ហើយនៅថ្ងៃកើតហេតុជនជាប់ចោទក៏បានច្របាច់កជនរងគ្រោះរហូតស្លាប់ និងដោះយកសម្ភារៈជនរងគ្រោះនោះ ត្រូវចាត់ជាអំពើ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-វត្ថុចាប់យករួមមានកៅស៊ូចងសក់ , ពណ៌ខ្មៅចំនួន០៣ , កែវជ័រចំនួន០១និងស្បែកជើងផ្ទាត់ចំនួន០១គូ , ម៉ាសមុខ , កន្សែងពោះគោពណ៌សចំនួន០២ , កន្សែង០១ត្រូវហែកមានប្រឡាក់ឈាម,អាវយឺតមួយពណ៌ស ឆ្នូតពណ៌ខ្មៅ០១ , អាវទ្រនាប់០១ , ខោលីអូ០១ និងកាតទូរស័ព្ទវីងចំនួន០២សន្លឹក,សំបកបាកាស់០១ M150 ១ដប គោដល់០១ដបនិង អាវដៃវែងនិងឆ្នូតក្រហមមួយ គឺជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើស និងជាភស្តុតាងបញ្ជាក់ពីអំពើល្មើសរបស់ជនជាប់ចោទ គប្បីតុលាការរឹបអូសតាមច្បាប់ ។ ចំនែកឯវត្ថុចាប់យក រួមមានកាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌ស ចំនួន០១ , ទូរស័ព្ទដៃ០១គ្រឿងម៉ាកណូគា ពណ៌លឿងនិងឪសចំនួន០១ , កាបូបដៃចំនួន០១អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ [redacted] ងវិក័យប័ត្រទិញលក់មាសចំនួន០៣សន្លឹក

គឺជាសម្ភារៈរបស់ជនរងគ្រោះនិងជាសម្ភារៈរបស់ជនជាប់ចោទ ហើយពុំមានពាក់ព័ន្ធនឹងអំពើល្មើសឡើយ ដូចនេះតុលាការគប្បីប្រគល់ឲ្យម្ចាស់ដើមវិញ។

-មានពិរុទ្ធភាពលើឈ្មោះ: [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ពីបទ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ: [redacted] ពុំបានចូលមកតាំងខ្លួនជាដើមបណ្តឹង និងប្តឹងទាមទារសំណងជម្ងឺចិត្តឡើយ ដូចនេះតុលាការគប្បីទុកសិទ្ធិជូនដើមបណ្តឹងទាមទារសំណងពេលក្រោយតាមច្បាប់។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ: [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់ មួយជីវិត ពីបទ: ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌគឺ:

-កៅស៊ូចងសក់ពណ៌ខ្មៅចំនួន០៣ , កែវជ័រចំនួន០១ និងស្បែកជើងផ្ទាត់ចំនួន០១គូ។

-ម៉ាសមុខ , កន្សែងពោះគោពណ៌សចំនួន០២ , កន្សែង០១ ត្រូវរហែកមានប្រឡាក់ឈាម។

-អាវយឺតមួយពណ៌ស ឆ្នូតពណ៌ខ្មៅ០១ , អាវទ្រនាប់០១ , ខោលីអូ០១ និងកាតទូរស័ព្ទវីងចំនួន០២សន្លឹក។

-សំបកបាកាស់០១ M150 ១ដប និងគោជល់០១ដប , អាវដៃវែងនិងឆ្នូតក្រហមមួយ។

៣-វត្ថុចាប់យកត្រូវប្រគល់ឲ្យម្ចាស់ដើមវិញគឺ:

-កាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌ស ចំនួន០១។

- ទូរស័ព្ទដៃ០១គ្រឿងម៉ាកណូគា ពណ៌លឿងនិងឌីសចំនួន០១។

-កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ: [redacted] និងវិក័យប័ត្រទិញលក់មាសចំនួន០៣សន្លឹក។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៦-០៣-២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ: [redacted] ហៅ ពៅ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប្រកាសជាសាធារណៈនៅថ្ងៃទី ២៨-០៣-២០១៧ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| លេខា និងត្រា [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខានិងត្រា [redacted] |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៧

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៩
សាលក្រមលេខ "គខ៥"
ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១១

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញញ បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១១ វេលាម៉ោង ៨ និង០០ នាទីព្រឹក ដោយមានសមាសភាព :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា
លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌ លេខ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៩ ដែលមានជនជាប់ចោទ :

<u>**សេចក្តីសម្រេច**</u>

ផ្តន្ទាទោស :

១. ឈ្មោះ ភេទប្រុស អាយុ ៥២ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤(បួន) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក ។ ពីបទស៊ីសំណូក ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៨ តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២. ឈ្មោះ ភេទស្រី អាយុ ៤៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ ៦ (ប្រាំមួយ) ខែ ។ ពីបទ សូកប៉ាន់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៨ តាមបញ្ញត្តិមាត្រា ៥៨ នៃចបាប់ពេហទណអនរកាល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១១ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១១ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១១
**ក្រឡាបញ្ជី**

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

សាលាដំបូងខេត្តបន្ទាយមានជ័យ
សាលក្រមព្រហ្មទណ្ឌលេខ: ២៩(ជ)
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៧
សំណុំរឿងព្រហ្មទណ្ឌលេខ: ២៤១
ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦

# ព្រះរាជាណាចក្រកម្ពុជា

## *ជាតិ សាសនា ព្រះមហាក្សត្រ*

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តបន្ទាយមានជ័យ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យ
នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧

***<u>សមាសភាពជំនុំជម្រះ</u>***

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងអយ្យការ</u>**

លោកស្រី [redacted] ជាព្រះរាអាជ្ញារង អមសាលាដំបូងខេត្ត

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted]ក្រឡាបញ្ជី

**<u>មេធាវីការពារជនជាប់ចោទ</u>**

លោក [redacted]ជាមេធាវី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ២៤១ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ: [redacted]ហ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិនិមិត្ត៣ ឃុំនិមិត្ត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ មានទីលំនៅបច្ចុប្បន្ននៅភូមិ៣ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរ កម្មករ។ ឪពុកឈ្មោះ: [redacted]រស់- ម្តាយឈ្មោះ: [redacted]រស់- ប្រពន្ធឈ្មោះ: [redacted] ទោសពីមុន គ្មាន (ក្នុងឃុំ) ។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទ: សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្ត នៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៤ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឈ្មោះ: [redacted] ហៅ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិក្រល់ ឃុំគោកបល័ង្គ ស្រុកបារាយ ខេត្តកំពង់ធំ មានទីលំនៅបច្ចុប្បន្ននៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរ កម្មករ។ ឪពុកឈ្មោះ[redacted]រស់- ម្តាយឈ្មោះ[redacted]រស់- នៅលីវ ទោសពីមុន គ្មាន (ក្នុងឃុំ)។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ[redacted]ភេទប្រុស អាយុ២៦ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិរលា ឃុំក្រគាត ស្រុកពាក់ង ខេត្តព្រៃវែង មានទីលំនៅបច្ចុប្បន្ននៅភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មុខរបរ កម្មករ។ ឪពុកឈ្មោះ[redacted]-រស់- ម្តាយឈ្មោះ[redacted]រស់- នៅលីវ ទោសពីមុន គ្មាន(ក្រៅឃុំ)។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## **<u>អង្គហេតុនៃរឿងក្តី:</u>**

កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១៤ និង០០នាទី កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារកណ្តាល បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននៅចំណុចមណ្ឌល២ ភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានចាប់យកវត្ថុតាងថ្នាំញៀន ប្រភេទមេតំហ្វេតាមីន(ម៉ាទឹកកក) ចំនួន០៤កូនថង់តូច ស្មើនឹងទម្ងន់ ០.២ក្រាម ទូរស័ព្ទដៃចំនួន០៤គ្រឿង ដបថ្លែសម្រាប់ ប្រើប្រាស់ថ្នាំញៀនចំនួន០១ ដែកកេះចំនួន០៤ និងបំពង់ជ័រមួយចំនួន ព្រមទាំងធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់ មានឈ្មោះ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ,ឈ្មោះ[redacted] ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះ[redacted]ភេទប្រុស អាយុ២៦ឆ្នាំ។ ក្រោយមកបានបញ្ជូនជនសង្ស័យចំនួន០៣នាក់ ខាងលើមកស្នងការដ្ឋាននគរបាល ខេត្តបន្ទាយមានជ័យ ដើម្បីកសាងសំណុំរឿងមកអយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:២០៤ ដកសស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ។
-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៥៥៨ អក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ។
-បានឃើញ ដីកាដំណោះស្រាយលេខ: ៤៧៤៨ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ។
-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៥៧០ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ ។

## **<u>នាពេលសវនាការ:</u>**

-បានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted]និងឈ្មោះ[redacted]
-បានស្តាប់អំណានចម្លើយសារភាពរបស់ឈ្មោះ[redacted]
-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ ។
-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។
-ក្រោយពីបានស្តាប់ ជនជាប់ចោទធ្វើសំដីចុងក្រោយ។
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់សាលាដំបូងខេត្តបន្ទាយមានជ័យ

### យល់ឃើញថា:

១-កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ មានករណីជួញដូរ និងសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយឈ្មោះ [redacted] បានយកថ្នាំញៀនពីឈ្មោ[redacted]បកទៅលក់ឲ្យឈ្មោះ [redacted]និងយកទៅប្រើប្រាស់នៅផ្ទះរបស់ឈ្មោះ [redacted]ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

២-តាមការស្តាប់ចម្លើយរបស់ឈ្មោះ [redacted]ហៅ[redacted]នាពេលសវនាការបានបញ្ជាក់ថា: ខ្លួនប្រើប្រាស់ថ្នាំញៀនជិតកន្លះឆ្នាំហើយ ដោយទិញថ្នាំញៀននៅម្តុំផ្សារយប្រាំ ម្តងចំនួនបីម៉ឺនរៀល។ ខ្លួនមិនបានផ្តល់ទីកន្លែងឲ្យគេប្រើប្រាស់ថ្នាំញៀននោះទេ ព្រោះផ្ទះនោះ គឺខ្លួនបានជួលឲ្យឈ្មោះ[redacted]ក្នុងមួយ ខែចំនួនប្រាំរយបាត។ ខ្លួននៅផ្ទះនោះ ដោយខ្លួនទៅចាំយកលុយពីឈ្មោះ[redacted]តប៉ុណ្ណោះ។ ដំបូងខ្លួនមិនដឹងថាឈ្មោះ [redacted] ជាអ្នកលក់ថ្នាំញៀននោះទេ តែក្រោយមកទើបខ្លួនដឹងថាឈ្មោះនេះ ជាអ្នកលក់ថ្នាំញៀន។

៣-តាមការស្តាប់ចម្លើយរបស់ឈ្មោះ[redacted]ហៅ[redacted]នាពេលសវនាការបានបញ្ជាក់ថា:ខ្លួនប្រើប្រាស់ថ្នាំញៀនបានជិតមួយឆ្នាំហើយ ថ្នាំញៀនដែលខ្លួនប្រើប្រាស់នោះ គឺខ្លួនទិញពីឈ្មោះ[redacted] ហើយគេឲ្យកន្លែងប្រើប្រាស់ថ្នាំញៀនតែម្តង។ ខ្លួនមិនបានលក់ថ្នាំញៀននោះទេ ប៉ុន្តែខ្លួនធ្លាប់កាន់ថ្នាំញៀនឲ្យឈ្មោះ[redacted]ផងដែរ។ ការកាន់ថ្នាំញៀនយកទៅឲ្យគេនេះ គឺខ្លួនមិន ដែលបានកម្រៃជាប្រាក់ឈ្នួលនោះទេ គឺបានតែថ្នាំញៀនសម្រាប់ជក់ប៉ុណ្ណោះ។ ខ្លួនមិនដែលលក់ថ្នាំញៀនឲ្យឈ្មោះ [redacted] ,ឈ្មោះ [redacted] នោះទេ។

៤-តាមការស្តាប់អំណានចម្លើយរបស់ឈ្មោះ [redacted]ានបញ្ជាក់ថា: សមត្ថកិច្ចឃាត់ខ្លួនពេល ខ្លួននិងឈ្មោះ [redacted]ពុងរៀបចំឧបករណ៍សម្រាប់ជក់គ្រឿងញៀន នៅផ្ទះរបស់ឈ្មោះ [redacted] ហៅ [redacted] សម្ភារៈដែលសមត្ថកិច្ចដកហូតបានជារបស់ឈ្មោះ[redacted]ដលជាអ្នកលក់ថ្នាំញៀន។ ឈ្មោះ [redacted]គឺលក់ថ្នាំញៀននៅនឹងផ្ទះរបស់ឈ្មោះ[redacted]តម្តង។ ខ្លួនមិនដែលកាន់ថ្នាំញៀនឲ្យអ្នកណានោះទេ។

៥-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៦៧៨៨/១៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ លើសំណាកជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ឈ្មោះមេតំហ្វេតាមីន( Methamphetamine) ដែលមានកម្រិតភាពសុទ្ធ ៧១,៩២% នៃទម្ងន់សរុប ស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

៦-បានឃើញកំណត់ហេតុឆែកឆេរលើខ្លួនបុគ្គលជនសង្ស័យ និងចាប់យកសំភារៈវត្ថុតាងប្រព្រឹត្តបទល្មើស លើឈ្មោះ [redacted] ដែលធ្វើនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ផ្សារកណ្តាល ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦។

៧-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ហៅ [redacted] នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តអំពើសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននោះទេ។ ចម្លើយនេះតុលាការមិនអាចជឿជាក់បានទេ ព្រោះចម្លើយនេះផ្ទុយពីចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់មន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់ចៅក្រមស៊ើបសួរថា ខ្លួនពិតជាបានឲ្យ[illegible] ពេក

រស់នៅក្នុងផ្ទះរបស់ខ្លួនជាមួយគ្នា ហើយឈ្មោះ [redacted] ក៏ចាប់ផ្តើមលក់ថ្នាំញៀននៅនឹងផ្ទះរបស់ខ្លួនតែម្តង។ បន្ទាប់មកក៏ឃើញមានអ្នកមកទិញថ្នាំញៀន ហើយជក់នៅនឹងផ្ទះរបស់ខ្លួនតែម្តង។ ដែលចម្លើយទាំងអស់នេះ ក៏ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា ខ្លួនពិតជាបានប្រើប្រាស់ថ្នាំញៀននៅផ្ទះរបស់ឈ្មោះ [redacted] ពិតប្រាកដមែន។ ហេតុនេះ ការឆ្លើយបដិសេធរបស់ឈ្មោះ [redacted] ក្នុងពេលសវនាការនេះ តុលាការមិនអាចជឿជាក់បាននោះទេ ព្រោះមិនមានសាក្សី ឬភស្តុតាងណាមួយមកដោះបន្ទុកលើរូបគេនោះទេ ហើយគ្រាន់តែជាការឆ្លើយដោះសារដើម្បី រួចផុតពីការទទួលខុសត្រូវលើអំពើល្មើសរបស់ខ្លួនតែប៉ុណ្ណោះ។ ដោយឡែកចំពោះបទល្មើសប្រើប្រាស់ដោយ ខុសច្បាប់នូវសារធាតុញៀន ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា រូបគេពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដែលចម្លើយនេះតុលាការអាចជឿជាក់បាន ហើយចម្លើយនេះដែរក៏ ស៊ីសង្វាក់ទៅនឹងកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន លើឈ្មោះ [redacted] ដែលបញ្ជាក់ថាមាន វត្តមាននូវសារធាតុញៀន។ ដូចនេះ តាមអង្គហេតុ និងភស្តុតាងខាងលើ តុលាការជឿជាក់ថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។ក៏ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] ត្រូវបានចោទប្រកាន់ពីបទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ តែអង្គហេតុនេះដែលបានចោទប្រកាន់កាលនៃការប្រព្រឹត្តបទល្មើស នៅអំឡុង ឆ្នាំ២០១៦ គឺពុំអាចរកឲ្យភស្តុតាង អំពីវត្តមាន និងសកម្មភាពដែលស្តែងចេញឡើយ ដូច្នេះពុំមានពិរុទ្ធភាពគ្រប់គ្រាន់អំឡុងពេលប្រព្រឹត្តដូចកាលបរិច្ឆេទខាងលើឡើយ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] បទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ទៅជា បទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៨៤ កថាខណ្ឌ១ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ។

៨-តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការនេះ តុលាការអាចជឿជាក់បាន ព្រោះជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដោយខ្លួនធ្លាប់បានកាន់ថ្នាំញៀនឲ្យឈ្មោះ [redacted] ដើម្បីយកទៅលក់ឲ្យគេមែន ដោយបានកម្រៃជាថ្នាំញៀនសម្រាប់ជក់ ហើយខ្លួនក៏ចេះប្រើប្រាស់ថ្នាំញៀនផងដែរ។ ចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ រួមនឹងកំណត់ហេតុឆែកឆេរលើខ្លួនបុគ្គលជនសង្ស័យ និងចាប់យកសម្ភារៈវត្ថុតាងដែលប្រព្រឹត្តបទល្មើស បញ្ជាក់ថាបានដកហូតថ្នាំញៀនប្រភេទម្សៅថ្លាស ចំនួន០៤(បួន)កញ្ចប់ ឈ្មោះ [redacted] ពិតមែន ដូចនេះ តាមអង្គហេតុ និងភស្តុតាងខាងលើតុលាការជឿជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស

ដូចការចោទប្រកាន់ប្រាកដមែន។ក៏ប៉ុន្តែជនជាប់ចោទឈ្មោះ: [redacted] ត្រូវបានចោទប្រកាន់ពីបទៈជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ តែអង្គហេតុនេះដែលបានចោទប្រកាន់ កាលនៃការប្រព្រឹត្តបទល្មើស នៅអំឡុង ឆ្នាំ២០១៦ គឺពុំអាចរកឲ្យភស្តុតាង អំពីវត្ថុតាង និងសកម្មភាពដែលស្តែងចេញឡើយ ដូច្នេះពុំមានពិរុទ្ធភាពគ្រប់គ្រាន់អំឡុងពេលប្រព្រឹត្តដូចកាលបរិច្ឆេទខាងលើឡើយ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ: [redacted] ពីបទៈជួញដូយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ <u>ទៅជា</u> បទៈជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត រ និងប្រើប្រាស់ដោ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ។

៩-តាមការស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្ម[redacted]ាពេលសវនាការនេះតុលាការអាចជឿជាក់បាន ព្រោះជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន ដោយខ្លួនប្រើប្រាស់ថ្នាំញៀនបានចំនួនពីរដង។ ចម្លើយទាំងអស់នេះស៊ីសង្វាក់គ្នាតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ រួមនឹងកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន លើឈ្មោះ: [redacted] បញ្ជាក់ថាមានវត្តមានសារធាតុញៀន ដូចនេះ តាមអង្គហេតុ និងភស្តុតាងខាងលើតុលាការជឿជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

១០-អំពើរបស់ជនជាប់ចោទឈ្មោ[redacted]ឈ្មោះ: [redacted] ហៅ [redacted]ងឈ្មោះ: [redacted] ដែលបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ដែលអំពើនេះធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម ជាពិសេសប៉ះពាល់ដល់សុខភាពផ្លូវកាយផ្លូវចិត្ត ចំពោះយុវជនជាសសរទ្រូងប្រទេសជាតិមួយចំនួនដែលកំពុងតែភ្លើតភ្លើននឹងការញៀនថ្នាំញៀនបែបនេះក្នុងសង្គមបច្ចុប្បន្ន ដូច្នេះ អំពើនេះត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ។

១១-ជនជាប់ចោទឈ្មោះ: [redacted] ហ[redacted]ឈ្មោះ: [redacted] ហៅ [redacted]ងឈ្មោ[redacted] ឃាត់ ក្នុងនិងក្រោយពេលប្រព្រឹត្តបទល្មើសជននេះមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើល្មើស ដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន។

១៣-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ: [redacted] ហៅ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ពីបទៈ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៤ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

១៤-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ២៧ឆ្នាំ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

១៥-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្ម[redacted]ភេទប្រុស អាយុ២៦ឆ្នាំ ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៥-ជនជាប់ចោទឈ្មោះ [redacted] ត្រូវបានព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចោទប្រកាន់ពីបទ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២០៤ ដកសស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។ ដោយយោងតាមមាត្រា ១៣៧(ការចោទប្រកាន់តែមួយ) នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការប្រកាសទោសតែមួយចំពោះជនជាប់ចោទ។

១៦-ជនជាប់ចោទឈ្មោះ [redacted] ហៅ ពៅ ត្រូវបានព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ចោទប្រកាន់ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២០៤ ដកសស ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦របស់តំណាង អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។ ដោយយោងតាមមាត្រា ១៣៧(ការចោទប្រកាន់តែមួយ) នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការប្រកាសទោសតែមួយចំពោះជនជាប់ចោទ។

១៦-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានថា សុំតម្កល់បទចោទរបស់តំណាងអយ្យការទុកជាបានការទាំងស្រុង និងសុំឲ្យតុលាការតុលាការផ្តន្ទាទោសជនជាប់ចោទរូបនេះទៅតាមច្បាប់ គប្បីតុលាការលើកយកការសន្និដ្ឋានរបស់តំណាងអយ្យការមកពិចារណាក្នុងការសម្រេចសេចក្តី ។

១៧-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោ[redacted]និងឈ្មោះ [redacted]ានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីរបស់ខ្លួនធ្លាប់បានប្រព្រឹត្តបទល្មើសតែម្តងប៉ុណ្ណោះ ហេតុនេះខ្លួនស្នើសុំឲ្យតុលាការធ្វើការកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះ [redacted]ពីបទសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុរញៀន តាមមាត្រា ៤២ កថាខណ្ឌ១ កថាខណ្ឌ២ និងមាត្រា ៤៥ ទៅបទ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤២ កថាខណ្ឌ១ និងមាត្រា ៤៥ ដោយឡែកឈ្មោ[redacted] ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ ទៅបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ និងសុំឲ្យតុលាការពិចារណាតាមច្បាប់។

១៨-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted]និងឈ្មោ[redacted]ហ [redacted] នាពេលសវនាការបានទទួលស្គាល់កំហុសដែលបានបានប្រព្រឹត្តសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន គប្បីតុលាការលើកយកការស្នើសុំនេះ មកពិចារណាក្នុងការសម្រេចសេចក្តី ។

## ហេតុដូច្នេះសាលាដំបូងខេត្តបន្ទាយមានជ័យ

## ទន្និច្ឆ័យសេចក្ដី

I-សម្រេចកែប្រែបទចោទលើឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ពីបទៈសម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៤ កថាខណ្ឌ១ កថាខណ្ឌ២ ចំណុច២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ទៅជា បទៈ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៤ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ។

II-សម្រេចកែប្រែបទចោទលើឈ្មោះ [redacted] ទប្រុស អាយុ២៧ ឆ្នាំពីបទៈជួញដូរខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ទៅជា បទៈជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ វិញ ។

III-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ ពីបទៈ សម្រួលឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៤ កថាខណ្ឌ១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

IV-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣(បី)ឆ្នាំ និង០៦(ប្រាំមួយ)ខែ ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ។

V-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៣(បី)ខែ ពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិប្រជាធម្មលិច សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ និងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ តែទោសនេះត្រូវព្យួរធម្មតា ។

VI-រឹបអូសវត្ថុតាងមាន:

-ទូរស័ព្ទម៉ាក ណូគា (model 2690) គ្មានអាគ្រៅ ពណ៌ខ្មៅ ចំនួនមួយគ្រឿង ទូរស័ព្ទម៉ាក ណូគា (model 105) ពណ៌ខៀវ ចំនួនមួយគ្រឿង និងកាបូបលុយពណ៌ខ្មៅ(គ្មានលុយ) ចំនួនមួយ

សាលក្រមនេះប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបន្ទាយមានជ័យនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ សម្រេចសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ឈ្មោះ [redacted] ហៅ ពៅ និងកំបាំងមុខឈ្មោះ [redacted] ផ្លូវប្តឹងឧទ្ធរណ៍ និងទាស់ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

30 វិកា 17

[redacted]

# ឧបសម្ព័ន្ធទី៣៖ សាលដីកា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

# <u>តាងនាមប្រជារាស្ត្រខ្មែរ</u>

## <u>សាលាឧទ្ធរណ៍ ភ្នំពេញ</u>

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ៖

ចុះថ្ងៃទី១៣-១១-២០១៩

**<u>សាលដីកា</u>**

លេខ៖ "ក្រ.V.ច"

ចុះថ្ងៃទី៣០-០៣-២០២២

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈនស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ថ្ងៃទី១៨-០៣-២០២២ ដោយមានសមាសភាពដូចតទៅ:

### <u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>

លោកស្រី ជាប្រធានក្រុមប្រឹក្សា

ឯកឧត្តម ជាចៅក្រមប្រឹក្សា

លោក ជាចៅក្រមប្រឹក្សា

### <u>តំណាងមហាអយ្យការ</u>

លោក ជាព្រះរាជអាជ្ញា

### <u>ក្រឡាបញ្ជី</u>

លោក

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ ដោយមាន៖

**១-ជនជាប់ចោទ** ឈ្មោះ ហៅ ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធមុខរបរនៅបាបារាំង ទីកន្លែងកំណើតនៅភូមិក្រពើគម ឃុំពាមព្រឆ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួន ស្នាក់នៅមិនពិតប្រាកដ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ជានីតិជនទោសពីមុន ធ្លាប់ជាប់មណ្ឌលព្រៃកស្តី ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

-ឃុំខ្លួនលេខ (ន) ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ស្នាក់នៅពន្ធនាគារ (ម២) ។

**២-ជនជាប់ចោទ** ឈ្មោះ ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិត្បូងភ្នំ ឃុំតាក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ)

ម្ដាយឈ្មោះ ស្រី (វ) ជានីតិជន ទោសពីមុន ធ្លាប់ជាប់មណ្ឌលព្រៃកស្ដី ពីបទប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន ។

-ឃុំខ្លួនលេខ (ន) ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ស្នាក់នៅពន្ធនាគារ (មដ) ។

-មានមេធាវី ជាមេធាវីការពារសិទ្ធិ ។

<u>-ជាប់ចោទពីបទ</u> លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

## ៦រឿងហេតុមានដូចតទៅ:

កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ០១និង ៣០ នាទី មានជនជាប់ចោទចំនួន ០២ នាក់ឈ្មោះ ហៅ និងឈ្មោះ បាននាំគ្នាធ្វើសកម្មភាពយកដែកលួសសរសៃទៅ ឆ្កឹះមេសារទ្វារបន្ទប់ជួល ស្ថិតក្នុងភូមិត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ចូលលួចយកសម្ភារៈរួមមាន ៖ ទូរស័ព្ទដៃម៉ាកណូគា ១២៨០ ចំនួន ០១គ្រឿង , ឧបករណ៍គៀបសក់ ចំនួន ០១ គ្រឿង ,ទូរស័ព្ទម៉ាក IPHONE 5S ពណ៌ស ចំនួន ០១ គ្រឿង , ទូរស័ព្ទដៃម៉ាកណូគាពណ៌ខ្មៅ ចំនួន ០២ គ្រឿង និងនាឡិកាដៃចំនួន ០១ គ្រឿង ហើយត្រូវសន្តិសុខយាមផ្ទះជួលចាប់បានឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចប៉ុស្តិ៍ចោមចៅទី១ តែម្តង ។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខសាលក្រមព្រហ្មទណ្ឌលេខ "យ" ក្រ១០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចទៅ:

១-ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ ហៅ ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ (បួន) ឆ្នាំ ។

ខ.ឈ្មោះ ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ (បួន) ឆ្នាំ ។

ពីបទ៖ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិ ត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ចំពោះជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ។

**-បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ហៅ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ "យ" ក្រ១០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**-បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ "យ" ក្រ១០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**-បានឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

**-បានឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**<u>នាពេលសវនាការ</u>**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

ជនជាប់ចោទឈ្មោះ ហៅ (អវត្តមាន) បានឆ្លើយនៅសាលាដំបូងថា នៅថ្ងៃកើតហេតុខ្លួនជិះម៉ូតូឌុបគ្នាជាមួយ ឈ្មោះ ដោយគេប្រាប់ថា ទៅលេងផ្ទះបងប្អូនរបស់គេ នៅពេលទៅដល់ កន្លែងកើតហេតុឈ្មោះ បានឡើងទៅលើដោយគេឲ្យខ្លួនចាំនៅក្រោម ហើយខ្លួនមិនដឹងថាឈ្មោះ ឡើងទៅគ្គឹះសោរបន្ទប់យកឥវ៉ាន់របស់គេទេ ហើយខ្លួនក៏ពុំបានរៀបគម្រោងជាមួយគ្នាទេ ។

ជនជាប់ចោទឈ្មោះ (អវត្តមាន) បានឆ្លើយនៅសាលាដំបូងថា នៅថ្ងៃកើតហេតុខ្លួនបបួលឈ្មោះ ទៅទិញថ្នាំឲ្យកូន នៅពេលទៅដល់កន្លែងលក់ថ្នាំគេបិទមិនលក់ ខ្លួនក៏បបួលឈ្មោះ ។ ទៅផ្ទះបងប្អូន លុះពេលទៅដល់ខ្លួនប្រាប់ឈ្មោះ ឲ្យចាំខ្លួននៅខាងក្រោម រីឯខ្លួនឡើង ទៅផ្ទះបង ។ នៅពេលខ្លួនគ្គឹះសោរបន្ទប់ជួលយកឥវ៉ាន់គេ នៅពេលកំពុងរុះរើក៏ត្រូវម្ចាស់គេមកទាន់ ក៏បានឃាត់ ខ្លួនរូបខ្លួនយកទៅប៉ុស្តិ៍សន្តិសុខ ដើម្បីសាកសួរ ខ្លួនបានឆ្លើយថាមកពីខ្លួនអត់លុយទិញថ្នាំឲ្យកូន ។ ពេលខ្លួន ធ្វើសកម្មភាពឈ្មោះ មិនបានដឹងពីសកម្មភាពខ្លួនទេ ហើយនៅពេលសមត្ថកិច្ចឃាត់ខ្លួន គឺមិន បានឃាត់ខ្លួនឈ្មោះ ទេ តែពេលគេនាំខ្លួនទៅសាកសួរឈ្មោះ ចេះតែដើរតាមទៅ មើលខ្លួន ហើយពេលសមត្ថកិច្ចសួរនាំខ្លួនថា ស្គាល់ម្នាក់តែតាមមកទេ ខ្លួនថាមិនស្គាល់ទេ ព្រោះមិនចង់ឲ្យពាក់ ព័ន្ធ ព្រោះគាត់មិនដឹងរឿងទេ តែនៅសមត្ថកិច្ចសួរឈ្មោះ គាត់ប្រាប់ថា ស្គាល់ខ្លួន នៅពេលនោះ សមត្ថកិច្ចក៏ឃាត់ខ្លួនឈ្មោះ ដែរទៅ ។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន**

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជាបទល្មើសជាក់ស្តែង មានភស្តុតាងគ្រប់គ្រាន់ មានការស៊ីចង្វាក់ជាមួយអង្គហេតុទៅនឹងចម្លើយជនជាប់ចោទ សាលក្រមមានលក្ខណៈត្រឹមត្រូវហើយ សុំតម្កល់ទុកជាបានការដដែល ។

**<u>សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ</u>**

កូនក្តីខ្លួនឈ្មោះ បានសារភាពពីការប្រព្រឹត្តបទល្មើស ចំពោះកូនក្តីខ្លួនឈ្មោះ គ្រាន់តែបានទៅជាមួយឈ្មោះ ទេ ការដាក់ទណ្ឌកម្មមកលើកូនក្តីទាំងពីរនាក់រហូតទៅ

សដល់ ០៤ ឆ្នាំ មានភាពធ្ងន់ធ្ងរពេក ព្រោះថា ព្យសនកម្មដែលកូនក្តីខ្លួនបានប្រព្រឹត្តនោះមានលក្ខណៈតិចតួច ណាមួយសម្ភារៈដែលលួចបាន ក៏បានដកហូតប្រគល់ទៅឲ្យដើមបណ្តឹងវិញដែរ សំណូមពរសុំឲ្យក្រុមប្រឹក្សាមានការបន្ធូរបន្ថយទោស ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

ក្រោយពីបានស្តាប់អំណានរបាយការណ៍

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី សាក្សី

ក្រោយពីបានស្តាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន

ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសន្និដ្ឋាន

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា:</u>**

១-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ហៅ និងសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ (យ) ក្រ១០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ ហៅ បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនជិះម៉ូតូឌុបគ្នាជាមួយឈ្មោះ ដោយគេប្រាប់ថា ទៅលេងផ្ទះបងប្អូនរបស់គេ នៅពេលទៅដល់កន្លែងកើតហេតុឈ្មោះ បានឡើងទៅលើដោយគេឲ្យខ្លួនចាំនៅក្រោម ហើយខ្លួនមិនដឹងថាឈ្មោះ ឡើងទៅគ្លីះសោរបន្ទប់យកឥវ៉ាន់របស់គេទេ ហើយខ្លួនក៏ពុំបានរៀបគម្រោងជាមួយគ្នាទេ ។

៣-ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនបបួលឈ្មោះ ទៅទិញថ្នាំឲ្យកូន នៅពេលទៅដល់គេបិទមិនលក់ ខ្លួនក៏បបួលឈ្មោះ ទៅផ្ទះបងប្អូន លុះពេលទៅដល់ខ្លួនប្រាប់ឈ្មោះ ឲ្យចាំខ្លួននៅខាងក្រោម នៅពេលខ្លួនគ្លីះសោរបន្ទប់ចូលយកឥវ៉ាន់គេ នៅពេលកំពុងរុះរើក៏ត្រូវម្ចាស់គេមកទាន់ ក៏បានឃាត់ខ្លួនរូបខ្លួនយកទៅប៉ុស្តិ៍សន្តិសុខដើម្បីសាកសួរ ពេលខ្លួនធ្វើសកម្មភាពឈ្មោះ មិនបានដឹងពីសកម្មភាពខ្លួនទេ ហើយនៅពេលសមត្ថកិច្ចឃាត់ខ្លួន គឺមិនបានឃាត់ខ្លួនឈ្មោះ ទេ ពេលសមត្ថកិច្ចសួរនាំខ្លួនថាមិនស្គាល់ទេ ព្រោះមិនចង់ឲ្យពាក់ព័ន្ធ ព្រោះគាត់មិនដឹងរឿងទេ តែនៅសមត្ថកិច្ចសួរឈ្មោះ គាត់ប្រាប់ថា ស្គាល់ខ្លួននៅពេលនោះ សមត្ថកិច្ចក៏ឃាត់ខ្លួនឈ្មោះ ដែរទៅ ។

៤-តំណាងមហាអយ្យការបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីរ ធ្វើឡើងក្នុង

កំណត់ច្បាប់សាលាឧទ្ធរណ៍អាចទទួលជំរុំជម្រះបាន យោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជាបទល្មើសជាក់ស្តែង មានភស្តុតាងគ្រប់គ្រាន់ មានការស៊ីចង្វាក់ជាមួយអង្គហេតុទៅនឹងចម្លើយជនជាប់ចោទ សាលក្រមមានលក្ខណៈត្រឹមត្រូវហើយ សុំតម្កល់ទុកជាបានការដដែល ។ សាលាឧទ្ធរណ៍យល់ឃើញថា ការសន្និដ្ឋានរបស់តំណាងមហាអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

**៥**-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោះ បានសារភាពពីការប្រព្រឹត្តបទល្មើស ចំពោះកូនក្តីខ្លួនឈ្មោះ គ្រាន់តែបានទៅជាមួយឈ្មោះ ទេ ការដាក់ទណ្ឌកម្មមកលើកូនក្តីទាំងពីរនាក់រហូតទៅសដល់ ០៤ ឆ្នាំ មានភាពធ្ងន់ធ្ងរពេក ព្រោះថា ព្យសនកម្មដែលកូនក្តីខ្លួនបានប្រព្រឹត្តនោះមានលក្ខណៈតិចតួច ណាមួយសម្ភារៈដែលលួចបាន ក៏បានដកហូតប្រគល់ទៅឲ្យដើមបណ្តឹងវិញដែរ សំណូមពរសុំឲ្យក្រុមប្រឹក្សាមានការបន្ធូរបន្ថយទោស ។ សាលាឧទ្ធរណ៍ពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

**៦**-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចភូមិ ត្រពាំងថ្លឹង១ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

**៧**-សាលក្រមព្រហ្មទណ្ឌលេខ (ឃ) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គ្រានតែសាលាឧទ្ធរណ៍ពិចារណាពីការផ្តល់ស្ថានសម្រាលខ្លះដល់ជនជាប់ចោទទាំងពីរ ដោយយល់ឃើញថា ជនជាប់ចោទពុំបង្កព្យសនកម្មធ្ងន់ធ្ងរដល់ជនរងគ្រោះ ។

## <u>ហេតុដូច្នេះ</u>

## <u>វិនិច្ឆ័យសេចក្តី</u>

**១**).**ក**.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ហៅ ទុកជាត្រឹមត្រូវតាមច្បាប់ ។

**ខ**.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ ទុកជាត្រឹមត្រូវតាមច្បាប់ ។

**២**).តម្កល់សាលក្រមព្រហ្មទណ្ឌលេខ (ឃ) ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការលើកលែងចំណុចទី១ (ក)និង(ខ) លើជនជាប់ចោទឈ្មោះ និងឈ្មោះ ត្រូវកែប្រែការផ្តន្ទាទោសដាក់ពន្ធនាគាលើជនជាប់ចោទម្នាក់ៗ កំណត់ ០៤ (បួន) ឆ្នាំ មកអនុវត្តដាក់ពន្ធនាគារលើជនជាប់ចោទម្នាក់ៗ កំណត់ ០៣ ឆ្នាំ ០៨ ខែ (បីឆ្នាំប្រាំបីខែ) វិញ ។

-ចំណុចផ្សេងពីនេះរក្សាទុកជាការដដែល ។

**៣**).បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ និងឈ្មោះ តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទ ឈ្មោះ និងឈ្មោះ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បើកសិទ្ធិប្តឹងទាស់តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ......កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី...៣០...ខែ...មីនា...ឆ្នាំ២០២២

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

# នាមប្រជាជនខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ៖

ចុះថ្ងៃទី១៥-០៣-២០១៩

**សាលដីកា**

លេខ៖ "ក្រ.V.ច"

ចុះថ្ងៃទី៣០-០៣-២០២២

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈនស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ថ្ងៃទី១៨-០៣-២០២២ ដោយមានសមាសភាពដូចតទៅ:

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី ជាប្រធានក្រុមប្រឹក្សា

ឯកឧត្តម ជាចៅក្រុមប្រឹក្សា

លោក ជាចៅក្រុមប្រឹក្សា

### តំណាងមហាអយ្យការ

លោក ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជី

លោក

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដោយមាន៖

**១-ជនជាប់ចោទ** ឈ្មោះ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិត្រៃតាផឹក ឃុំគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលីវ ទោសពីមុនគ្មាន ។

-ឃុំខ្លួនថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ នៅពន្ធនាគារ ខេត្តស្វាយរៀង ។

-មានមេធាវី ជាមេធាវីការពារសិទ្ធិ ។

<u>-ជាប់ចោទពីបទ</u> ឃាតកម្ម ប្រព្រឹត្តនៅភូមិព្រៃតាផឹក ឃុំគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ  ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិព្រៃតាផឹក ឃុំគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ឪពុកឈ្មោះ  (ស) ម្តាយឈ្មោះ  (ស) ប្តីឈ្មោះ  (ស) មានកូន ០៧ នាក់ ទោសពីមុនគ្មាន ។

**៦រឿងហេតុមានដូចតទៅ:**

កាលពីថ្ងៃទី២៤ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង៦និង៣០ នាទីល្ងាច នៅចំណុចភូមិព្រៃតាផឹក ឃុំគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង មានបទល្មើសព្រហ្មទណ្ឌមួយកើតឡើង ដែលបង្កដោយជនសង្ស័យឈ្មោះ  បានធ្វើសកម្មភាពយកកាំបិតកុកកាប់ទៅលើឪពុករបស់ខ្លួនឈ្មោះ  ត្រូវចំនួន ០៦កាំបិតត្រូវចំដើមទ្រូង០១កាំបិត ,ស្មាខាងឆ្វេង០១កាំបិត, ក០១កាំបិត , ក្បាល០១កាំបិត , គុម្ពត្រចៀកខាងឆ្វេង០១កាំបិត និងបោះដៃផុត០១កាំបិត បណ្តាលឲ្យស្លាប់ភ្លាមៗតែម្តងនៅកន្លែងកើតហេតុដោយសារខឹងនិងឪពុកមកពីផឹកស្រាវិញរករឿងជេរប្រមាថប្រពន្ធកូន។ ក្រោយពេលកើតហេតុសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនឈ្មោះ  យកមកធ្វើការសាកសួរ នឹងកសាងសំណុំរឿងបញ្ជូនអយ្យការកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ ។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ  (ង) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារដូចតទៅ ៖

១/.ផ្តន្ទាទោសលើឈ្មោះ  ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ដែលមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារចំនួន ១១ (ដប់មួយ) ឆ្នាំ ពីបទ ឃាតកម្ម ប្រព្រឹត្តនៅភូមិព្រៃតាផឹក ឃុំគគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ។

២/. សាលក្រមនេះជំនុំជំរះ និងប្រកាសសាលក្រមថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ  និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ  ។

-**បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ  ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ឈ្មោះ  ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៖  (ង) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-**បានឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍។

-**បានឃើញ** សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**<u>នាពេលសវនាការ</u>**

**<u>ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង</u>**

-ជនជាប់ចោទឈ្មោះ  ថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន គាត់ផឹកស្រាជារៀងរាល់ថ្ងៃ មកពីផឹកវិញរករឿងជេរស្តីខ្លួន វាយម្តាយខ្លួន និងបានគម្រាមសម្លាប់ ធ្វើឲ្យខ្លួនមិនអាចទប់កំហឹងបាន ទើបខ្លួនកាប់គាត់ ខ្លួនចាប់ដៃគាត់ជាប់ កាប់ចំគាត់ហើយគាត់ក៏ដួល ខ្លួនកាប់ហើយកាប់ទៀតដោយពេលនោះខ្លួនខឹងខ្លាំង ហើយក៏ស្រវឹងដែរ មិនទាន់ស្លាប់ភ្លាមទេ ក្រោយមកប្រហែលមួយម៉ោងទើប

ស្លាប់ ខ្លួនដឹងកំហុសហើយ ប្តឹងឧទ្ធរណ៍សុំបន្ធូរបន្ថយទោស ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ (អវត្តមាន) បានបញ្ជាក់នៅសាលាដំបូងថា ខ្លួនកំពុងងូតទឹក លឺសំលេងកូននិងប្តីរបស់ខ្លួនឈ្លោះគ្នា ជេរកូនខ្លាំងៗ និងលឺកូនថាឲ្យប្តីខ្លួន ថាឪឯងស្រវឹងទៅដេកទៅ ប្តីបានស្រែកជេរខ្លួននិងកូន កូនបានប្រាប់ទៅឪពុកថា កុំជៀលខ្លួននឹងវា បន្ទាប់មកឃើញប្តីស្ទុះទៅរកវាយកូនប្រតាយប្រតប់គ្នាដៃនឹងដៃ ខ្លួនឃើញក៏ចូលទៅឃាត់មិនឈ្នះបានស្រែកហៅអ្នកជិតខាងឲ្យជួយ បានបន្តិចឃើញកូនរត់ទៅរកកាំបិតមកកាប់ទៅលើឪពុកត្រូវស្មា០១កាំបិត នឹងត្រូវជាច្រើនកាំបិតទៀត បណ្តាលឲ្យស្លាប់នៅកន្លែងកើតហេតុ ខ្លួនសុំដកពាក្យឈប់ប្តឹងពីកូនឈ្មោះ នេះតទៀតហើយ និងសំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនរបស់ខ្លួនផង ។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន**

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជាបទល្មើសជាក់ស្តែង រឹបអូសបានវត្ថុតាងពីជនជាប់ចោទ ជនជាប់ចោទសារភាពពីការប្រព្រឹត្ត សាលក្រមមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សុំក្រុមប្រឹក្សាពិចារណាតាមច្បាប់ ។

**<u>សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ</u>**

កូនក្តីខ្លួនបានសារភាពពីការប្រព្រឹត្តបទល្មើសហើយ ដោយខឹងឪពុកគម្រាមសម្លាប់ម្តាយ និងកូនៗ ទើបមានការប្រព្រឹត្តបែបនេះកើតឡើង ឪពុកបានវាយម្តាយ មានសាក្សីបញ្ជាក់ថាជនជាប់ចោទបានគម្រាម ទើបកូនក្តីខ្លួនទប់កំហឹងមិនបាន ដោយរងសំពាធក្នុងគ្រួសារ ដើមបណ្តឹងរដ្ឋប្បវេណីបានដកពាក្យបណ្តឹងហើយ សុំឲ្យក្រុមប្រឹក្សាពិចារណាមានការបន្ធូរបន្ថយទោស តាមមាត្រា ៩៣ , ៩៤ នៃក្រមព្រហ្មទណ្ឌ ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

ក្រោយពីបានស្តាប់អំណានរបាយការណ៍

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី សាក្សី

ក្រោយពីបានស្តាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន

ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសន្និដ្ឋាន

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>យល់ឃើញថា:</u>**

១-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ (ង) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ បានឆ្លើយថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន

គាត់ផឹកស្រាជារៀងរាល់ថ្ងៃ មកពីផឹកវិញរករឿងជេរស្តីខ្លួន វាយម្តាយខ្លួន និងបានគម្រាមសម្លាប់ ធ្វើឲ្យខ្លួនមិនអាចទប់កំហឹងបាន ទើបខ្លួនចាប់ដៃគាត់ជាប់ហើយកាប់គាត់ជាច្រើនកាំបិត គាត់ក៏ដួល ខ្លួនកាប់ហើយកាប់ទៀត ដោយពេលនោះខ្លួនខឹងខ្លាំង ហើយក៏ស្រវឹងដែរ មិនទាន់ស្លាប់ភ្លាមទេ ក្រោយមកប្រហែលមួយម៉ោងទើបស្លាប់ ខ្លួនដឹងកំហុសហើយ ប្តឹងឧទ្ធរណ៍សុំបន្ធូរបន្ថយទោស ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានបញ្ជាក់ថា ខ្លួនកំពុងងូតទឹក លឺសំលេងកូននិងប្តីរបស់ខ្លួនឈ្លោះគ្នា ជេរកូនខ្លាំងៗ និងលឺកូនថាឲ្យប្តីខ្លួន ថាឪឯងស្រវឹងទៅដេកទៅ ប្តីបានស្រែកជេរខ្លួននិងកូន កូនបានប្រាប់ទៅឪពុកថា កុំជៀលខ្លួននឹងវា បន្ទាប់មកឃើញប្តីស្ទុះទៅរកវាយកូនប្រតាយប្រតប់គ្នាដៃនឹងដៃ ខ្លួនឃើញក៏ចូលទៅឃាត់មិនឈ្នះបានស្រែកហៅអ្នកជិតខាងឲ្យជួយ បានបន្តិចឃើញកូនរត់ទៅរកកាំបិតមកកាប់ទៅលើឪពុកត្រូវស្មា០១កាំបិត នឹងត្រូវជាច្រើនកាំបិតទៀត បណ្តាលឲ្យស្លាប់នៅកន្លែងកើតហេតុ ខ្លួនសុំដកពាក្យឈប់ប្តឹងពីកូនឈ្មោះ នេះតទៀតហើយ និងសំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនរបស់ខ្លួនផង ។

៤-តំណាងមហាអយ្យការបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់សាលាឧទ្ធរណ៍អាចទទួលជំរុំជម្រះបាន យោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ បទល្មើសជាក់ស្តែង វត្ថុតាងត្រូវបានរឹបអូសពីជនជាប់ចោទ ជនជាប់ចោទសារភាពពីការប្រព្រឹត្តរបស់ខ្លួន សាលក្រមមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ សុំក្រុមប្រឹក្សាពិចារណាតាមច្បាប់។ សាលាឧទ្ធរណ៍យល់ឃើញថា ការសន្និដ្ឋានរបស់តំណាងមហាអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនបានសារភាពពីការប្រព្រឹត្តបទល្មើសហើយ ដោយខឹងឪពុកគម្រាមសម្លាប់ម្តាយ និងកូនៗ ទើបមានការប្រព្រឹត្តបែបនេះកើតឡើង ឪពុកបានវាយម្តាយ មានសាក្សីបញ្ជាក់ថាជនជាប់ចោទបានគម្រាម ទើបកូនក្តីខ្លួនទប់កំហឹងមិនបាន ដោយរងសំពាធក្នុងគ្រួសារ ដើមបណ្តឹងរដ្ឋប្បវេណីបានដកពាក្យបណ្តឹងហើយ សុំឲ្យក្រុមប្រឹក្សាពិចារណាមានការបន្ធូរបន្ថយទោសតាមមាត្រា ៩៣ , ៩៤ នៃក្រមព្រហ្មទណ្ឌ ។

៦-ការសន្និដ្ឋានរបស់មេធាវី សុំឲ្យក្រុមប្រឹក្សាសាលាឧទ្ធរណ៍ពិចារណាលើ មាត្រា ៩៣ , ៩៤ នៃក្រមព្រហ្មទណ្ឌ ដោយលើកសំអាងហេតុថា កាលដែលកូនក្តីគាត់កាប់ដៃជនរងគ្រោះ ដោយសារជនរងគ្រោះវាយគាត់មុន ។ ការសន្និដ្ឋានរបស់មេធាវី លើកយកមកមាត្រា ៩៣ , ៩៤ នៃក្រមព្រហ្មទណ្ឌ យកមកពិចារណាសុំការបន្ធូរបន្ថយទោសនោះ សាលាឧទ្ធរណ៍យល់ឃើញថា ការសម្រេចរបស់សាលាដំបូងអំពីទណ្ឌកម្មលើជនជាប់ចោទមានលក្ខណៈត្រឹមត្រូវសមរម្យហើយ ។

៧-សាលក្រមព្រហ្មទណ្ឌលេខ (ង) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង បានសម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមនេះទុកជាបានការដដែល ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១).ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ

ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២).តម្កល់សាលក្រមព្រហ្មទណ្ឌលេខ (ង) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការដដែល ។

៣).បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ បើកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា: |

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ.....១១...កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី..៣០...ខែ..មីនា..ឆ្នាំ២០២២

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

11/09/2017

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

**សភាស៊ើបសួរ**
សំណុំរឿងសភាស៊ើបសួរ
លេខ២៦៦/២៥-៨-២០១៧
**សាលដីកា**
លេខ ៣២ក្រVIយ
ចុះថ្ងៃទី០៧-៩-២០១៧

សភាស៊ើបសួរបង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/ រកម/០៧-១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកកិច្ចពិភាក្សាដេញដោលជាអសាធារណៈ នៅបន្ទប់សវនាការសាលាឧទ្ធរណ៍នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានសមាសភាពដូចតទៅ ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**
**ឯកឧត្តម** [redacted] **ប្រធាន**
**លោក** [redacted] **ចៅក្រមប្រឹក្សា**
**លោក** [redacted] **ចៅក្រមប្រឹក្សា**
**តំណាងមហាអយ្យការ**
**កញ្ញា** [redacted]
**ក្រឡាបញ្ជី**
**លោកស្រី** [redacted]

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងសភាស៊ើបសួរលេខ២៦៦ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ រវាង៖

១-ជនត្រូវចោទឈ្មោះ [redacted] ភេទស្រី អាយុ ២៨ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន ភូមិព្រែកព្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៧ ។មានមេធាវី [redacted]

២-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៥៨ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្ន ភូមិព្រែកព្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] ស ប្រពន្ធឈ្មោះ [redacted] ានកូន ៦នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៧។ មានមេធាវី [redacted]

៣-ជនត្រូវចោទឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ។(ក្រៅឃុំ)

៤-ជនត្រូវចោទឈ្មោ [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ។(ក្រៅឃុំ)

ត្រូវបានតុលាការដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស ៣០ឆ្នាំ ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៧៩F ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**អង្គហេតុ**

កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង៩ម៉ោ០០ ព្រឹក អាជ្ញាសាលានៃអយ្យការអមសាលាដំបូងខេត្តកណ្តាល បានដឹកនាំគណកម្មការចំុះចុះអនុវត្តដីកាសម្រេច បង្គាប់ឲ្យប្រគល់អចលនវត្ថុលេខ ៦៤ អ.វ "គ" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តកណ្តាល មានទីតាំងស្ថិតនៅក្នុងភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលបង្គាប់ឲ្យកូនបំណុលឈ្មោ [redacted] និងប្រពន្ធឈ្មោះ [redacted] ប្រគល់ដីនិងផ្ទះ ដែលស្ថិតនៅទីតាំងដីខាងលើទៅឲ្យឈ្មោះ [redacted] ដែលជាអ្នកដេញថ្លៃបាន ។លុះដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ជនត្រូវចោទទាំងបួននាក់ បានកាត់សោរ របងផ្ទះ និងគាស់ទ្វារផ្ទះ ហើយប្រមូលអីវ៉ាន់ចូលទៅរស់នៅលើដីនិងផ្ទះខាងលើវិញតែម្តង។

**បានឃើញ** ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៧៣៥ដក.សយឧ/១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចដូចខាងក្រោម ៖

ឃុំខ្លួនជនត្រូវចោទឈ្មោ [redacted] បណ្តោះអាសន្នរយៈពេលអតិបរិមា..........ខែ។

**បានឃើញ** ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន លេខ ១៩៨១/១៧ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចដូចខាងក្រោម ៖

-មិនអនុញ្ញាតឲ្យឈ្មោះ [redacted] ភេទប្រុស អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ មានទីលំនៅបច្ចុប្បន្ន ភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ដោយសុចរិត និងធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ហើយដែលត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល លេខឃុំខ្លួន ៦៨៩០ ដកបឃខ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៧ នៅក្រៅឃុំបណ្តោះអាសន្នឡើយ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៧ របស់ឈ្មោះ [redacted] មេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៧៣៥ដក.សយឧ/១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ស្នើសុំឲ្យសម្រេចជំនួសលោ [redacted] ជាក្រមស៊ើបសួរសាលាខេត្តកណ្តាល។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧ របស់មេ[redacted] ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោ[redacted]ងនឹងដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ន លេខ១៩៨១ /១៧ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ក្រង់ចំណុចដីកាសម្រេចទាំងមូល។

បានឃើញ របាយការណ៍របស់សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ចៅក្រមអានរបាយការណ៍.

ជនត្រូវចោទឈ្មោះ:[redacted](អវត្តមាន)

ជនត្រូវចោទឈ្មោះ[redacted]អវត្តមាន)

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]អវត្តមាន)

មេធាវី [redacted]និង មេធាវី[redacted]បានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្ញុំបាទជាមេធាវីការពារឲ្យឈ្មោះ[redacted] និង ឈ្មោះ[redacted]បានប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៩៨១/១៧ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ក្រង់ចំណុចដីកាសម្រេចទាំងមូល។កូនក្តីខ្ញុំទាំង២នាក់ ឈ្មោ[redacted]និង ឈ្មោ[redacted]បានសុំនៅក្រៅឃុំ មានមូលហេតុដូចតទៅ៖ កូនក្តីខ្ញុំឈ្មោះ[redacted] មានមុខរបរពិតប្រាកដ មានទីលំនៅពិតប្រាកដ ដែលកំពុងមានជំងឺប្រចាំកាយ ចាំបាច់ត្រូវរស់នៅ និង ហូបចុកគ្រប់គ្រាន់ និង បានព្យាបាលជំងឺជាប់ជាប្រចាំ ។ឯកូនក្តីខ្ញុំឈ្មោះ[redacted]មានមុខរបរពិតប្រាកដ មានទីលំនៅពិតប្រាកដ មានកូនតូចៗក្នុងបន្ទុកចំនួន២នាក់ កំពុងនៅបៅដោះ ។សំណូមពរសុំសម្រេចអនុញ្ញាតឲ្យកូនក្តីខ្លួនឈ្មោះ[redacted]និង ឈ្មោះ[redacted]បាននៅក្រៅឃុំ ដើម្បីបាននៅមើលថែទាំកូនតូចៗទាំង២នាក់ និង ព្យាបាលជំងឺ។

## តំណាងមហាអយ្យការសន្និដ្ឋានថា

យល់ឃើញថា ជនត្រូវចោទទាំងពីរខាងលើ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទល្មើសគឺ ប្រើហិង្សា ទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា ៨១០ នៃក្រមព្រហ្មទណ្ឌ ។ ដូចនេះដើម្បីបញ្ចប់ បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានសារជាថ្មី ពានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីរក្សាជនត្រូវចោទឲ្យនៅក្នុងឃុំ ដូចការសម្រេចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្ត ។សូមសភាស៊ើបសួរពិនិត្យ និង សម្រេចតាមច្បាប់ ។

តាមចំណាររបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារងបញ្ជាក់ថា៖ ជនត្រូវចោទ ប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការ បើឲ្យនៅក្រៅឃុំ មិនបានមកបង្ហាញ ខ្លួនដល់តុលាការ និងរកឲ្យប្រឆាំង

សេចក្តីសម្រេចរបស់តុលាការសាលាដំបូងថ្មី ។

**សភាស៊ើបសួរ យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ របស់លោ[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ[redacted]ប្តឹងឧទ្ធរណ៍សុំឲ្យកូនក្តីខ្លួននៅក្រៅឃុំបណ្តោះអាសន្ន ធ្វើឡើងត្រឹមត្រូវ តាមមាត្រា ២១៧ និង ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧ របស់លោក[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនត្រូវចោទឈ្មោះ[redacted]ប្តឹងឧទ្ធរណ៍ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ ១៩៨១ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាលធ្វើឡើងត្រឹមត្រូវ តាមមាត្រា២៦៧ និង ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-ជនត្រូវចោទឈ្មោះ [redacted]និងឈ្មោះ [redacted]ត្រូវបានតុលាការដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តិនៅ ភូមិព្រែកជ្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

៤-ជនត្រូវចោទទាំង ០២រូបមានមេធាវីធានាត្រឹមត្រូវតាមច្បាប់ ព្យសនកម្មមិនមានលក្ខណៈធ្ងន់ធ្ងរទេ ជនត្រូវចោទទាំង០២រូប ត្រូវបានចៅក្រមធ្វើការកត់ត្រាយកចម្លើយរួចហើយ ដូច្នេះការអនុញ្ញាតឲ្យជនត្រូវចោទនៅក្រៅឃុំ មិនមានការបារម្ភថាប៉ះពាល់ដំណើរការស៊ើបសួរឡើយ ដោយគ្រាន់តែដាក់ជំនួសមកវិញ នូវវិធាននៃការត្រួតពិនិត្យតាមផ្លូវតុលាការមួយចំនួន ដូចមានចែងតាមមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌវិញ។

៥-ដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំលេខ ១៩៨១ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរ ពុំមានលក្ខណៈត្រឹមត្រូវទេ គប្បីបដិសេធចោល ហើយសម្រេចតាមការយល់ឃើញខាងលើ ។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ របស់លោ[redacted]ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ [redacted]ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិអោយជនត្រូវចោទឈ្មោះ [redacted]ទុកជាត្រឹមត្រូវតាមច្បាប់។

៣-បដិសេធដីកាសម្រេចមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ ១៩៨១/១៧ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ចោលជាអសារបង់។

៤-ដោះលែងឈ្មោះ[redacted]និងឈ្មោះ [redacted]មានសាវតាជាតិដូចខាងលើ) ដែលត្រូវតុលាការដាក់ក្រោមការពិនិត្យពីបទ ប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុ ដោយចេ

សុចរិត និងធ្វើអោយខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិព្រែកប្រៅ ឃុំកោះកោង២ ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ បទល្មើសដែលមានចែង ឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា២៥៣ នៃច្បាប់ភូមិបាល និងមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ អោយនៅក្រៅឃុំ។

៥-បង្គាប់ឲ្យលោកប្រធានមន្ទីរឃុំឃាំង ពន្ធនាគារខេត្តកណ្ដាល ដោះលែងឈ្មោះ [redacted] និងឈ្មោះ [redacted] ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួន ពីបទល្មើសអ្វីផ្សេងទៀតទេ។

៦-ដាក់អោយជនត្រូវចោទឈ្មោះ [redacted] ឯឈ្មោះ [redacted] ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ៖

-មិនត្រូវចូលទៅទីកន្លែងប្រព្រឹត្តបទល្មើស។

-បង្គាប់អោយចូលបង្ហាញខ្លួន១ខែម្តង នៅរៀងរាល់ថ្ងៃទី០១ នៃខែនីមួយៗ នៅប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំកោះកោង២។

-មិនត្រូវចាកចេញក្រៅព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា។

-ករណីជនត្រូវចោទមិនអនុវត្តកាតព្វកិច្ច នៃការត្រួតពិនិត្យនេះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបានតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលដីកានេះ ប្រកាសជាអសាធារណៈនៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៧។

ទុកសិទ្ធិអោយប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៧

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

១០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៖ ២៧០/២៦-៤-២០១០

សាលដីកា

លេខ ៖ ០៣ (ឋ) /២២-០៦-២០១០

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាកាជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍នាថ្ងៃទី២២-០៦-២០១០ ដោយមានសមាសភាពដូចខាងក្រោម ៖

<u>ក្រុមប្រឹក្សាជំនុំជំរះ</u>

- ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

- លោក [redacted]

<u>ក្រឡាបញ្ជីសវនាការ</u>

- លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ២៧០ ចុះថ្ងៃទី ២៦-០៤-២០១០ រវាង ៖

-ពិរុទ្ធជនឈ្មោះ [redacted] ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរពេទ្យឈ្នួល កើតនៅភូមិពោធិបាក់ក ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ទីលំនៅភូមិកំពង់រទេះ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោ[redacted] (ស) ម្តាយឈ្មោះ[redacted] (រ) ប្តីឈ្មោ[redacted] ហួន មានកូន ០២នាក់ ទោសពីមុន គ្មាន ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ធំ ។ (ប្តឹងឧទ្ធរណ៍)

ត្រូវចោទពីបទ ៖ **ឆបោក** ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីថ្ងៃទី២០០៥ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] (តំណាង) ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកមន្ទីរពេទ្យសុខភាពខេត្តកំពង់ធំ ទីលំនៅសព្វថ្ងៃភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។

**បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២-៣-២០១០ លើចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល។

## ដំណើររឿងហេតុមានដូចតទៅ ៖

សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

កាលពីអំឡុងឆ្នាំ ២០០០ ជនជាប់ចោទឈ្មោ [redacted] បានធ្វើជាមេតុងទីន ដោយមានសមាជិកតុងទីនជាង ១៨នាក់ គឺក្នុងនោះមានក្បាល ៥០.០០០ រៀល និងក្បាល ១០០.០០០រៀល ហើយសមាជិកតុងទីនដែលឈ្មោះ [redacted] ជំពាក់ប្រាក់នោះ គឺមានឈ្មោះ និងចំនួនប្រាក់ដូចខាងក្រោម ៖

១- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល
២- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល
៣- ឈ្មោះ [redacted] ចំនួន ៧.៤៥០.០០០ រៀល
៤- ឈ្មោះ [redacted] ចំនួន ១.៧០០.០០០ រៀល
៥- ឈ្មោះ [redacted] ចំនួន ១.៣០០.០០០ រៀល
៦- ឈ្មោះ [redacted] ចំនួន ១.៦០០.០០០ រៀល
៧- ឈ្មោ [redacted] ចំនួន ២.០០០.០០០ រៀល
៨- ឈ្មោ [redacted] ចំនួន ១.០០០.០០០ រៀល
៩- ឈ្មោះ [redacted] ចំនួន ២.៣០០.០០០ រៀល
១០- ឈ្មោះ [redacted] ចំនួន ៣.០០០.០០០ រៀល
១១- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល
១២- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល
១៣- ឈ្មោះ [redacted] ចំនួន ៦.១០០.០០០ រៀល
១៤- ឈ្មោះ [redacted] ចំនួន ៧.០០០.០០០ រៀល
១៥- ឈ្មោះ [redacted] ចំនួន ៦.៤៥០.០០០ រៀល
១៦- ឈ្មោះ [redacted] ចំនួន ១.០០០.០០០ រៀល
១៧- ឈ្មោ [redacted] ចំនួន ៣.០០០.០០០ រៀល
១៨- ឈ្មោ [redacted] ចំនួន ៧.១០០.០០០ រៀល ។

នៅពេលប្រមូលប្រាក់តុងទីនបានហើយ ជនជាប់ចោទឈ្មោះ [redacted] បានប្រើល្បិចកលភូតកុហកដល់សមាជិកតុងទីនថា សមាជិកនេះ ឬសមាជិកនោះដេញបានបន្តបន្ទាប់ជារៀងរាល់ខែ ហើយលុះដល់ថ្ងៃខែមិនចាំ ឆ្នាំ២០០៤ ជនជាប់ចោទរត់គេចខ្លួនបាត់ ដោយពុំបានធ្វើការទូទាត់ប្រាក់ឲ្យសមាជិកតុងទីនដែលនៅសល់ឡើយ ។

បានឃើញសេចក្តីសំរេចរបស់សាលាដំបូងខេត្តកំពង់ធំ សម្រេចតាមអំណាចសាលក្រមលេខ ២៧-គ- ចុះថ្ងៃទី០២-០៣-២០១០ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរ កំណត់ដាក់ពន្ធនាគាររយៈពេល ០២ ឆ្នាំ (ពីរឆ្នាំ) ពីបទ៖ **ឆបោក** ប្រព្រឹត្តនៅភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កាលពីឆ្នាំ២០០៥ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាតិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២ ។

២-បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ក្នុងពេលនេះតែម្តង ។

៣-បង្គាប់ឲ្យសងសំណង និងជំងឺចិត្តចំនួន ៦០.៤០០.០០០ រៀល និងជំងឺចិត្តសរុបជាប្រាក់ចំនួន ១៦.៩០០.០០០ រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះ [redacted] សំណូមពរលើសពីនេះត្រូវបដិសេធចោល ដែលក្នុងនោះត្រូវសងទៅ ៖

១- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល និងជំងឺចិត្តចំនួន ៥០០.០០០ រៀល
២- ឈ្មោះ [redacted] ចំនួន ២.៥០០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
៣- ឈ្មោះ [redacted] ចំនួន ៧.៨៥០.០០០ រៀល និងជំងឺចិត្តចំនួន ៣.០០០.០០០រៀល
៤- ឈ្មោះ [redacted] ចំនួន ១.៧០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៥- ឈ្មោះ [redacted] ចំនួន ១.៣០០.០០០ រៀល និងជំងឺចិត្តចំនួន ៥០០.០០០រៀល
៦- ឈ្មោះ [redacted] ចំនួន ១.៦០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៧- ឈ្មោះ [redacted] ចំនួន ២.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៨- ឈ្មោះ [redacted] ចំនួន ១.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
៩- ឈ្មោះ [redacted] ចំនួន ២.៣០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
១០- ឈ្មោះ [redacted] ចំនួន ៣.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
១១- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
១២- ឈ្មោះ [redacted] ចំនួន ១.៩៥០.០០០ រៀល និងជំងឺចិត្តចំនួន ១.០០០.០០០រៀល
១៣- ឈ្មោះ [redacted] ចំនួន ៦.១០០.០០០ រៀល និងជំងឺចិត្តចំនួន ៣.០០០.០០០រៀល
១៤- ឈ្មោះ [redacted] ចំនួន ៧.០០០.០០០ រៀល និងជំងឺចិត្តចំនួន ២.០០០.០០០រៀល
១៥- ឈ្មោះ [redacted] ចំនួន ៦.៥៥០.០០០ រៀល និងជំងឺចិត្តចំនួន ៣.០០០.០០០រៀល
១៦- ឈ្មោះ [redacted] ចំនួន ១.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
១៧- ឈ្មោះ [redacted] ចំនួន ៣.០០០.០០០ រៀល និងជំងឺចិត្តចំនួន ១០០.០០០រៀល
១៨- ឈ្មោះ [redacted] ចំនួន ៧ ១០០.០០០ រៀល និងជំងឺចិត្តចំនួន ២០០.០០០រៀល ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខគូភាគី ។

បើកសិទ្ធិឲ្យប្តឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃផុតកំណត់បណ្តឹងទាស់ ។

**បានឃើញ** បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៤-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី០២-៣-២០១០ លើចំណុចសេចក្ដីសម្រេចនៃសាលក្រមទាំងមូល។

**បានឃើញ** របាយការណ៍រឿងចុះថ្ងៃទី ០៥-០៥-២០១០ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

**បានឃើញ** សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី ៧-០៥-២០១០ របស់មហាអយ្យការអមតុលាការសាលាឧទ្ធរណ៍ភ្នំពេញ។

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបអង្គហេតុ

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា ៖ ឈ្មោះ [redacted] ធ្វើជាមេតុងទីន ខ្ញុំសុំសំណងប្រាក់ដើម និងជំងឺចិត្តវិញតាមការសម្រេចរបស់សាលាដំបូង ។

<u>**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា ៖**</u>

-ជនល្មើសឈ្មោះ [redacted] ពិតជាប្រើល្បិចកិច្ចកលយកប្រាក់ជនរងគ្រោះជាច្រើននាក់ ការសម្រេចរបស់តុលាការខេត្តកំពង់ធំ មានលក្ខណៈសមស្របគប្បីតម្កល់សាលក្រម ។

-មេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា ៖ កូនក្ដីខ្ញុំត្រូវបានកូនតុងទីនចំនួន ០៨ នាក់ឆបោក រត់គេចវេសបាត់ កូនក្ដីខ្ញុំក៏រងគ្រោះដែរ ចំនួនប្រាក់ដើមសុំទទួលស្គាល់ រីឯសំណងជំងឺចិត្តសុំបន្ថយ និងបន្ថយទណ្ឌកម្មជាក់ពន្ធនាគារ ។ កូនក្ដីខ្ញុំទទួលស្គាល់ការជំពាក់ប្រាក់កូនតុងទីន ហើយបានតម្កល់ប្រាក់ជានាចំនួន ៨.០០០.០០០រៀល និងមានដី នឹងផ្ទះមានតំលៃជាង ៣០.០០០ដុល្លាអាមេរិក កូនក្ដីខ្ញុំមានទីលំនៅពិតប្រាកដ សុំឲ្យសម្រេចទណ្ឌកម្ម កូនក្ដីខ្ញុំជាទោសព្យួរ។

## **សាលាឧទ្ធរណ៍**

**យល់ឃើញថា ៖**

១. បណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី១៩-៤-២០១០ របស់ពិរុទ្ធជនឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២.មានភស្តុតាងជាចម្លើយសារភាពរបស់ពិរុទ្ធជន ចម្លើយរបស់ដើមបណ្ដឹង សាក្សី អាចកំណត់បានថា ពិរុទ្ធជនឈ្មោះ [redacted] នប្រព្រឹត្តអំពើឆបោកយកប្រាក់ចំនួន ៦០.៨០០.០០០រៀល ពីជនរងគ្រោះចំនួន ១៨នាក់ ដូចមានសំអាងហេតុក្នុងសាលក្រមព្រហ្មទណ្ឌលេខ ២៧ "គ" ចុះថ្ងៃទី ០២-០៣-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ប្រាកដមែន សាលាឧទ្ធរណ៍ឯកភាពទាំងស្រុងលើការលើកសំអាងហេតុនៅក្នុងសាលក្រមដោយពុំចាំបាច់សរសេរបញ្ជាក់សារជាថ្មីឡើងវិញទេ។

៣-ជនជាប់ចោទមិនដែលត្រូវបានផ្ដន្ទាទោសពីមុនមកទេ ហើយមេធាវីការពារបានសុំឲ្យ សម្រេចទោសព្យួរ ដើម្បីមានឱកាសបានរកស៊ីចិញ្ចឹមជីវិត និងខិតខំប្រឹងប្រែងរកស៊ីយកប្រាក់ សងបំណុលទៅដើមបណ្ដឹងវិញ ម្យ៉ាងទៀតពិរុទ្ធជនមានដីផ្ទះ ដែលរស់នៅសព្វថ្ងៃ និងបានបង់ប្រាក់ចំនួន ៨.០០០.០០០ រៀលតម្កល់ទុកនៅនាយកក្រឡាបញ្ជីតាមពាក្យស្នើសុំចុះថ្ងៃទី ១៧-៦-២០១០ និងតាមបង្កាន់ដៃបង់ប្រាក់ ចុះថ្ងៃ

# ឧបសម្ព័ន្ធទី៤៖ សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃ ការព្យួរទោសសាកល្បង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ : [illegible]

## សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

### ក-ចៅក្រមជំនុំជម្រះ

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្តារពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

### ខ-ព្រះរាជអាជ្ញា

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្តារនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ដាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។/

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែមករា.. ឆ្នាំ២០១៨..

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនា

**ចម្លងជូន៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៥៖ សារាចរស្តីពី ការអនុវត្តបទប្បញ្ញត្តិ នៃ ការអនុវត្តទោសការងារ សហគមន៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងយុត្តិធម៌

លេខ : [illegible]/១៦

## សារាចរ

## ស្ដីពី

## ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្ដីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៨៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្ដីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្ដល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្ដល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែ..[illegible].. ឆ្នាំ..២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

**ចម្លងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-តុលាការ និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ